International Labour Organization

BetterFactories Cambodia

ការអប់រំផ្នែកហិរញ្ញវត្ថុ

សម្រាប់កម្មករកាត់ដេរនៅកម្ពុជា



គ្រប់គ្រងប្រាក់ចំណូលរបស់អ្នកដោយឆ្លាតវៃ!

រក្សាសិទ្ធិ © អង្គការអន្តរជាតិខាងការងារ ២០២៣
បោះពុម្ពលើកទីមួយ ២០២៣

ឯកសារបើកចំហនេះ ចែកចាយក្រោមអាជ្ញាប័ណ្ណអន្តរជាតិ Creative Commons Attribution 4.0 (https://creativecommons.org/licenses/by/4.0/)។ អ្នកប្រើប្រាស់អាចប្រើឡើងវិញ ចែករំលែក កែសម្រួល និងយោងលើឯកសារដើមនេះ ដូចបានរៀបរាប់លម្អិតក្នុងអាជ្ញាប័ណ្ណ។ អង្គការ ILO ត្រូវទទួលស្គាល់យ៉ាងច្បាស់ថាជាម្ចាស់ឯកសារដើម។ ការប្រើប្រាស់និមិត្តសញ្ញារបស់ ILO ពាក់ព័ន្ធនឹងការងាររបស់អ្នកប្រើប្រាស់ មិនត្រូវបានអនុញ្ញាតឡើយ។

ការទទួលស្គាល់៖ សម្រាប់ការដកស្រង់ ឯកសារនេះ ត្រូវយោងដូចខាងក្រោម៖ ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក សៀវភៅសម្រាប់សិក្ខាកាម៖ ការសិក្សាអំពីការចាត់ចែងថវិការបស់អង្គការ ILO សម្រាប់កម្មករកាត់ដេរនៅកម្ពុជា។

ការបកប្រែ៖ ក្នុងករណីធ្វើការបកប្រែឯកសារនេះ ត្រូវដាក់បន្ថែមសេចក្តីបញ្ជាក់ដូចខាងក្រោម ដោយទទួលស្គាល់ថា៖ ការបកប្រែនេះមិនបានធ្វើឡើងដោយអង្គការអន្តរជាតិខាងការងារ (ILO) ហើយមិនគួរ ចាត់ទុកថាជាការបកប្រែផ្លូវការរបស់ ILO នោះទេ។ ILO មិនទទួលខុសត្រូវចំពោះខ្លឹមសារ ឬភាពត្រឹមត្រូវនៃការបកប្រែនេះឡើយ។

ការកែសម្រួល៖ ក្នុងករណីមានការកែសម្រួលក្នុងឯកសារនេះ ត្រូវដាក់បន្ថែមសេចក្តីបញ្ជាក់ដូចខាងក្រោម ដោយទទួលស្គាល់ថា៖ ឯកសារនេះ ត្រូវបានកែសម្រួលពីឯកសារដើមរបស់អង្គការអន្តរជាតិខាងការងារ (ILO)។ ទំនួលខុសត្រូវចំពោះទស្សនៈ និងមតិដែលបានបង្ហាញនៅក្នុងការកែសម្រួលនេះ គឺជារបស់អ្នកនិពន្ធដែលធ្វើការកែសម្រួលតែប៉ុណ្ណោះ ហើយមិនត្រូវបានគាំទ្រដោយ ILO ទេ។

សូមផ្ញើរាល់សំណួរអំពីសិទ្ធិ និងអាជ្ញាបណ្ណ ផ្ញើទៅកាន់ ILO Publishing (សិទ្ធិ និងអាជ្ញាប័ណ្ណ) CH-1211 Geneva 22, Switzerland ឬតាមរយៈអ៊ីមែលទៅកាន់ right@ilo.org។
ភាសាអង់គ្លេស

ISBN: 9789220388105 (ឯកសារបោះពុម្ព)
ISBN: 9789220388112 (គេហទំព័រ PDF)

ការពិពណ៌នាដែលប្រើប្រាស់នៅក្នុងការបោះពុម្ពនានារបស់អង្គការ ILO ដែលអនុលោមតាមការអនុវត្តរបស់អង្គការសហប្រជាជាតិ និងការលើកយកបង្ហាញនានាដែលមាននៅក្នុងការបោះពុម្ពផ្សាយទាំងនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ការិយាល័យអង្គការអន្តរជាតិខាងការងារទាក់ទងនឹងស្ថានភាពគតិយុត្តិរបស់ប្រទេសណាមួយ វិស័យ ឬព្រំដែនសិទ្ធិអំណាចរបស់ប្រទេសនោះ ឬទាក់ទងនឹងការកំណត់ព្រំដែនរបស់ណានោះឡើយ។

ការទទួលខុសត្រូវចំពោះទស្សនៈដែលបានបង្ហាញនៅក្នុងការសិក្សា អត្ថបទដែលមានចុះហត្ថលេខា និងអត្ថបទចែកចាយផ្សេងៗទៀតគឺជារបស់អ្នកនិពន្ធទាំងស្រុង ហើយការបោះពុម្ពផ្សាយមិនមែនសំដៅទៅលើការគាំទ្ររបស់ការិយាល័យអង្គការអន្តរជាតិខាងការងារ លើទស្សនៈយោបល់ដែលបញ្ចេញនៅក្នុងការបោះពុម្ពផ្សាយនោះទេ។

ការយោងលើឈ្មោះក្រុមហ៊ុន និងជម្រើសពាណិជ្ជកម្ម និងដំណើរការផ្សេងៗទៀត មិនបញ្ជាក់ពីការគាំទ្ររបស់ការិយាល័យអង្គការអន្តរជាតិខាងការងារនោះទេ ហើយការខកខានមិនបានលើកឡើងពី ក្រុមហ៊ុន ជម្រើសពាណិជ្ជកម្ម ឬដំណើរការណាមួយ ក៏មិនមែនជាសញ្ញាបដិសេធមិនគាំទ្រដែរ។

ព័ត៌មានស្តីពីការបោះពុម្ពផ្សាយ និងជម្រើសឌីជីថលរបស់អង្គការ ILO អាចរកបាននៅ៖ www.ilo.org/publns ។

បោះពុម្ពនៅកម្ពុជា

សេចក្តីថ្លែងអំណរគុណ

ការបង្កើតសៀវភៅសម្រាប់សិក្ខាកាម៖ ការអប់រំផ្នែកហិរញ្ញវត្ថុរបស់អង្គការ ILO សម្រាប់កម្មករកាត់ដេរនៅកម្ពុជា ដឹកនាំដោយលោក Gustavo Prepelitchi ដោយមានការគាំទ្រពីលោក នួន វីរៈ ក្រោមការណែនាំ និងការត្រួតពិនិត្យ ជារួមរបស់លោកស្រី Valérie Breda នៃកម្មវិធីហិរញ្ញវត្ថុសង្គមរបស់ ILO ។ កិច្ចខិតខំប្រឹងប្រែងនេះ ទទួលបានការគាំទ្រយ៉ាងខ្លាំងក្លាពីគម្រោងរោងចក្រកាត់ដេរកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia) ជាពិសេសពីលោកស្រី Sara Park លោកស្រី Jenny Anne Hickey និងលោក កែវ ជារាមង្គល។ ក្រៅពីនេះ ក៏ទទួលបានការគាំទ្រប្រកបដោយអត្ថន័យ និង ជាតុចូលសំខាន់ៗពីភាគីពាក់ព័ន្ធសំខាន់ៗនៃឧស្សាហកម្មកាត់ដេរ និងអ្នកធ្វើការងារពាក់ព័ន្ធនៃប្រព័ន្ធអេកូហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។

គំនូរដោយ Samba Cissé និងរចនាដោយ Jimena Bello

តារាងមាតិកា

សេចក្តីផ្តើម ៧

១. សាវតា ៧
២. ការបង្ហាញអំពីសៀវភៅសម្រាប់សិក្ខាកាម ៨
៣. ការណែនាំអំពីតួអង្គ ៨
អត្តសញ្ញាណរបស់សុភាព ៩
អត្តសញ្ញាណរបស់ប៊ូវ៉ាន ១០
អត្តសញ្ញាណរបស់ណារី ១១
អត្តសញ្ញាណរបស់រក្សា ១២

ក) កំណត់គោលដៅ និងទំនាក់ទំនងក្នុងគ្រួសាររបស់អ្នក ១៣

១. កំណត់គោលដៅរបស់អ្នក ១៤
២. វាយតម្លៃការចំណាយលើគោលដៅនិងអាទិភាពរបស់អ្នក ១៦
៣. បង្កើតផែនការសន្សំដើម្បីសម្រេចបាននូវគោលដៅរបស់អ្នក ១៧
៤. និយាយទៅកាន់គ្រួសាររបស់អ្នកអំពីគោលដៅរបស់អ្នក ២០
៥. សម្រេចចិត្តថាតើការធ្វើចំណាកស្រុកគឺជាជម្រើសត្រឹមត្រូវសម្រាប់អ្នកដែរឬទេ ២៣
៦. គណនាការចំណាយហិរញ្ញវត្ថុលើការចំណាកស្រុក ២៤

ខ) គ្រប់គ្រងប្រាក់ចំណូលរបស់អ្នកដោយឆ្លាតវៃ ២៧

១. ធ្វើជាអ្នកចំណាយដ៏ឆ្លាតវៃ! ២៨
២. ស្វែងយល់ពីកិច្ចសន្យាការងារនិងលិខិតបញ្ជាក់ប្រាក់ខែរបស់អ្នក! ៣៣
៣. បង្កើតថវិការបស់អ្នក! ៣៩
៤. តាមដានថវិការ និងធ្វើការចំណាយមិនឲ្យលើសពីថវិការបស់អ្នក ៤៨
៥. រក្សាកំណត់ត្រាហិរញ្ញវត្ថុរបស់អ្នក ៥៦
៦. ទទួលបាន លទ្ធភាពប្រើប្រាស់ និងប្រើប្រាស់ប្រាក់ឈ្នួលរបស់អ្នកដោយសុវត្ថិភាពតាមរយៈ
មធ្យោបាយឌីជីថល ៥៧
ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ ៦១

គ) ស្វែងយល់អំពីវិធីសន្សំប្រាក់ និងជម្រើសនៃការសន្សំប្រាក់ ៦៣

១. ជ្រើសរើសវិធីសន្សំប្រាក់! ៦៤
២. ជ្រើសរើសជម្រើសនៃការសន្សំប្រាក់របស់អ្នកដោយឆ្លាតវៃ ៦៨
ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ ៧៥
ចម្លើយរបស់លំហាត់ខាងលើ ៧៦

ឃ) ប្រើប្រាស់ជម្រើសឥណទានដោយឆ្លាតវៃ ៧៩

១. ជ្រើសរើសវិធីមួយដើម្បីទទួលបានប្រាក់សម្រាប់គម្រោងរបស់អ្នក ៨០
២. ជ្រើសរើសឥណទានរបស់អ្នកដោយឆ្លាតវៃ ៨៤
៣. គណនាការចំណាយសម្រាប់ឥណទានរបស់អ្នក ៨៧
៤. សូមប្រុងប្រយ័ត្ន! កុំជំពាក់បំណុលច្រើនពេក! ៩៦
ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ ១០០
ចម្លើយចំពោះលំហាត់ ១០១

ជ) ជ្រើសរើសមធ្យោបាយទូទាត់ និងជម្រើសនៃការផ្ទេរប្រាក់ ១០៥

១. ប្រើមធ្យោបាយទូទាត់ដោយសុវត្ថិភាព ១០៦
២ ស្វែងយល់អំពីប្រតិបត្តិការផ្ទេរប្រាក់ ១១១
៣. របៀបផ្ញើ និងទទួលប្រាក់ ១១៧
ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ ១២១
ចម្លើយចំពោះលំហាត់ ១២២

ឈ) ស្វែងយល់អំពីគ្រឹះស្ថានហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រកបដោយទំនុកចិត្ត ១២៥

១. ស្វែងយល់អំពីស្ថាប័នហិរញ្ញវត្ថុ ១២៦
២. ការប្រើប្រាស់គ្រឹះស្ថានហិរញ្ញវត្ថុប្រកបដោយទំនុកចិត្ត! ១៣២
ចម្លើយចំពោះលំហាត់ ១៤១

ញ) ការគ្រប់គ្រងហានិភ័យ និងការធានារ៉ាប់រង ១៤៥

១. គ្រប់គ្រងហានិភ័យ ១៤៦
២. គន្លឹះក្នុងការបង្កើតមូលនិធិគ្រាអាសន្នរបស់លោកអ្នក ១៥០
៣. ស្វែងយល់ពីគោលការណ៍ធានារ៉ាប់រងរបស់អ្នក ១៥១
៤. ប្រើប្រាស់គោលនយោបាយធានារ៉ាប់រងរបស់អ្នក ១៥៥
៥. ជ្រើសរើសជម្រើសធានារ៉ាប់រងត្រឹមត្រូវ ១៥៨
ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ ១៦០
ចម្លើយចំពោះលំហាត់ ១៦១

ដ) បន្ថែម: ប្រាក់សោធននិវត្តន៍ និងការធ្វើផែនការរយៈពេលវែង ១៦២

១. រៀបចំផែនការចូលនិវត្តន៍របស់អ្នក ១៦៣
និយមន័យឧបសម្ព័ន្ធ ១៦៦

សេចក្តីផ្តើម

១. សាខតា

ឯកសារនៅក្នុងដៃរបស់អ្នកគឺជាសៀវភៅសម្រាប់ការអប់រំផ្នែកហិរញ្ញវត្ថុ។ សៀវភៅនេះផ្តោតជាចម្បងទៅលើកម្មករកាត់ដេរដែលមានបំណងចង់កែលម្អការគ្រប់គ្រងប្រាក់របស់ពួកគាត់។

សៀវភៅនេះ ផ្តល់ចំណេះដឹង ជំនាញ និងឧបករណ៍ជាមូលដ្ឋានទាក់ទងនឹងការរកប្រាក់ចំណូល ការចំណាយ ថវិកា និងការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុដូចជា ការសន្សំ ឥណទាន ការផ្ទេរប្រាក់ និងការធានារ៉ាប់រង។

សម្ភារៈបណ្តុះបណ្តាល៖ ការអប់រំផ្នែកហិរញ្ញវត្ថុ មានគោលបំណងបង្រៀនកម្មករអំពីមូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុផ្ទាល់ខ្លួន និងសម្រាប់គ្រួសារ។ សម្ភារៈបណ្តុះបណ្តាលនេះ គ្របដណ្តប់លើប្រធានបទនានា រួមមាន៖ ការកំណត់គោលដៅហិរញ្ញវត្ថុ ទំនាក់ទំនងប្រកបដោយទំនុកចិត្ត ការគណនាការចំណាយហិរញ្ញវត្ថុនៃការធ្វើចំណាកស្រុក ការស្វែងយល់ពីជម្រើសហិរញ្ញវត្ថុសំខាន់ៗ (ការសន្សំ ប្រាក់កម្ចី ការទូទាត់ កាបូបឌីជីថល ការធានារ៉ាប់រង) ការយល់ដឹងអំពីប្រាក់ឈ្នួលឌីជីថល ការយល់ដឹង និងការចរចាជាមួយស្ថាប័នហិរញ្ញវត្ថុ ការផ្ទេរប្រាក់ និងការគ្រប់គ្រងហានិភ័យ។ ការបណ្តុះបណ្តាល ក៏មានគោលបំណងឆ្លើយតបនឹងការអប់រំកម្រិតទាប និងទំនាក់ទំនងអំណាចមិនស្មើគ្នា - រវាងបុរស និងស្ត្រី និងរវាងមនុស្សចាស់ និងក្មេងជំនាន់ក្រោយ ដែលជារឿយៗ មានឥទ្ធិពលលើការសម្រេចចិត្តទាក់ទងនឹងប្រាក់។ សៀវភៅបណ្តុះបណ្តាលនេះ ដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបទៅនឹងឱកាសក្នុងវិស័យកាត់ដេរ នៅចំពោះមុខកម្មករនាពេលបច្ចុប្បន្ន និងកម្មករនាពេលអនាគត។

សៀវភៅបណ្តុះបណ្តាលនេះ ត្រូវបានបង្កើតឡើងដោយអង្គការអន្តរជាតិខាងការងារ (ILO) ដោយផ្អែកលើឧបករណ៍អប់រំហិរញ្ញវត្ថុរបស់ ILO ជាច្រើនដែលត្រូវបានបង្កើតឡើងសម្រាប់ក្រុមគោលដៅផ្សេងៗគ្នា។ សៀវភៅនេះត្រូវបានកែសម្រួលសម្រាប់ការប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា។

សៀវភៅសម្រាប់ការបណ្តុះបណ្តាលនេះ ត្រូវប្រើរួមគ្នាជាមួយសៀវភៅណែនាំរបស់គ្រូឧទ្ទេស។ សៀវភៅនេះ ត្រូវបានបង្កើតឡើងសម្រាប់ក្រុមគោលដៅជាក់លាក់។ ជាការបំពេញបន្ថែមទៅលើសៀវភៅណែនាំរបស់គ្រូឧទ្ទេស សៀវភៅនេះ ផ្តល់នូវព័ត៌មានទាំងអស់ទាក់ទងនឹងតួអង្គប្រឌិត ករណីសិក្សា លំហាត់ និងឯកសារយោងជាក់លាក់ចំពោះក្រុមគោលដៅ។ សៀវភៅនេះ ក៏ជាក់បញ្ជូលផងដែរនូវចំណុចសំខាន់ៗនៃការបណ្តុះបណ្តាល និងឧបករណ៍ដែលត្រូវការសម្រាប់ការប្រើប្រាស់ និងគ្រប់គ្រងលុយដោយឆ្លាតវៃ។ សៀវភៅនេះ ត្រូវបានរចនាឡើងសម្រាប់បុរស និងស្ត្រីដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាល ហើយគួរតែត្រូវប្រើជាសៀវភៅលំហាត់ក្នុងអំឡុងវគ្គសិក្សា និងជាឯកសារយោង។

សៀវភៅសម្រាប់ការបណ្តុះបណ្តាលនេះ ត្រូវបានបង្កើតឡើងក្រោមក្របខ័ណ្ឌនៃកិច្ចសហការរវាង រោងចក្រកាន់តែប្រសើរនៅកម្ពុជា និងមជ្ឈមណ្ឌលសកលរបស់ ILO ស្តីពីប្រាក់ឈ្នួលឌីជីថលសម្រាប់ការងារសមរម្យ។

២. ការបង្ហាញអំពីសៀវភៅសម្រាប់សិក្ខាកាម

តើការសិក្សាអំពីការចាត់ចែងថវិកា បង្ហាញអំពីអ្វី?



ការសិក្សាអំពីការចាត់ចែងថវិកា ផ្តល់ចំណេះដឹង ជំនាញ និងឧបករណ៍ដែលអាចឲ្យអ្នកអាចគ្រប់គ្រងប្រាក់របស់អ្នកបានកាន់តែប្រសើរឡើង។ វគ្គបណ្តុះបណ្តាលដែលអ្នកនឹងត្រូវចូលរួមនឹងអាចឲ្យអ្នករៀបចំផែនការ និងរៀបចំសម្រាប់គម្រោងរបស់អ្នកនាពេលអនាគត។ វគ្គនេះផ្តល់ឱកាសដើម្បីរៀនជំនាញដែលទាក់ទងនឹងការរកប្រាក់ចំណូល ការចំណាយ ថវិកា ការសន្សំ ការខ្ចីប្រាក់ និងវិធីដើម្បីទទួលបានធនធានច្រើនបំផុត។

ការសិក្សានេះ ក៏នឹងផ្តល់ឲ្យអ្នកនូវឱកាសក្នុងការស្វែងយល់អំពីការប្រាស្រ័យទាក់ទងគ្នាកាន់តែប្រសើរ លើបញ្ហាប្រាក់ជាមួយគ្រួសារ សាច់ញាតិរបស់អ្នក និយោជក ឬអ្នកដែលអ្នកធ្វើការជាមួយ និងដោះស្រាយបញ្ហាប្រឈមមួយចំនួននៅពេលកើតឡើង។

អ្នកនឹងរៀន ឬពិនិត្យមើលឧបករណ៍មួយចំនួន ដើម្បីគ្រប់គ្រងលុយរបស់អ្នកឲ្យបានល្អ។

សេវាកម្មហិរញ្ញវត្ថុដូចជា ឥណទាន ការសន្សំ ការផ្ទេរប្រាក់ ឬការធានារ៉ាប់រង នឹងមិនមានអាថ៌កំបាំង ណាមួយសម្រាប់អ្នកឡើយ។

តើត្រូវប្រើសៀវភៅនេះដោយរបៀបណា?


អ្នកគួរតែប្រើសៀវភៅនេះក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលស្តីពីការសិក្សាអំពីការចាត់ចែងថវិកា។ ជំពូកនីមួយៗ ត្រូវបានរៀបចំតាមលំដាប់លំដោយ ដោយដាក់បញ្ចូលមេរៀន និងវគ្គផ្សេងៗ។ ទោះយ៉ាងណានេះក្តី អ្នកអាចអានជំពូកណាមួយក៏បាន តាមចិត្តរបស់អ្នក!

ករណីសិក្សាដែលដាក់បញ្ចូលក្នុងសៀវភៅនេះ បង្ហាញពីបទពិសោធន៍នៃតួអង្គប្រឌិតរបស់យើង។ អ្នកនឹងជួបពួកគេក្នុងវគ្គនីមួយៗ ហើយស្គាល់ពួកគេកាន់តែច្បាស់។

សៀវភៅនេះ ដាក់បញ្ចូលលំហាត់ និងសន្លឹកកិច្ចការជាច្រើនដែលអ្នកអាចបំពេញសម្រាប់ខ្លួនអ្នក។

៣. ការណែនាំអំពីតួអង្គ

កម្មវិធីបណ្តុះបណ្តាលប្រើប្រាស់រឿងរ៉ាវ និងបទពិសោធន៍របស់តួអង្គសំខាន់ៗចំនួនបួន។



តួអង្គទី ១
សុភាព

ឈ្មោះ៖ សុភាព

ក្រុមគោលដៅ៖ *កម្មករកាត់ដេរ, ជនចំណាកស្រុកក្នុងស្រុក*

ទីកន្លែងស្នាក់នៅ៖ *ជួលបន្ទប់តូចមួយជាមួយកម្មកររផ្សេងទៀតនៅជិតរោងចក្រ*

ភេទ៖ *ស្រី*

អាយុ៖ *៣៧*

ស្ថានភាពអាពាហ៍ពិពាហ៍៖ *រៀបការហើយមានកូន ៣នាក់*

សកម្មភាពសេដ្ឋកិច្ច៖ *នាងធ្វើការនៅរោងចក្រកាត់ដេរ ជាអ្នកកាត់ដេរ*


គ្រួសារ៖ *នាងផ្ញើប្រាក់ទៅដៃគូ និងឪពុកម្តាយត្រឡប់ទៅភូមិវិញជាប្រចាំ*
កម្រិតនៃការទទួលបានការអប់រំ៖ *បានបញ្ចប់ថ្នាក់បឋមសិក្សា*

អាកប្បកិរិយាចំពោះលុយ៖ *រៀនពីរបៀបប្រើប្រាស់លុយពីឪពុកម្តាយរបស់នាង ហើយនាងប្រយ័ត្នប្រយែងនឹងលុយរបស់នាង*

ស្ថានភាពហិរញ្ញវត្ថុ៖
- *អ្នករកចំណូលចម្បងដើម្បីផ្គត់ផ្គង់គ្រួសារនាង*
- *ទុកប្រាក់សន្សំខ្លះសម្រាប់នាង ប៉ុន្តែផ្តល់ប្រាក់ភាគច្រើនរបស់នាងទៅគ្រួសារនៅខេត្ត*
- *នាងចាប់អារម្មណ៍លើស្ថាប័នផ្លូវការ ប៉ុន្តែខ្លាចមិនហ៊ានប្រើប្រាស់*

គោលបំណង៖
- *បញ្ចប់ការសាងសង់ផ្ទះរបស់នាងនៅស្រុកកំណើត*
- *សន្សំបានច្រើនតាមតែអាចធ្វើទៅបានពីពេលដែលនាងត្រឡប់ទៅផ្ទះវិញ*

តួអង្គបន្ទាប់បន្សំ៖
- *ប្តីនាង ឈ្មោះសុជា*
- *ឪពុកម្តាយនាង ឈ្មោះ សាម៉ែត (ម្តាយ) និងសុខ (ឪពុក)*
- *មិត្តរបស់នាងឈ្មោះ ចាន់ណា*
- *មិត្តរួមការងាររបស់នាងគឺបុប្ផា*



តួអង្គទី២
ប៊ុន

ឈ្មោះ៖ ប៊ុន

ក្រុមគោលដៅ៖ *កម្មករកាត់ដេរ*

ទីកន្លែងស្នាក់នៅ៖ *ជួលបន្ទប់តូចមួយ, ធ្វើដំណើរតាមម៉ូតូជារៀងរាល់ថ្ងៃ*

ភេទ៖ *ប្រុស*

អាយុ៖ *៣៥*

ស្ថានភាពអាពាហ៍ពិពាហ៍៖ *រៀបការរួច មានកូន២នាក់នៅភូមិជាមួយប្រពន្ធ និងម្តាយ (ខេត្តព្រៃវែង)*

សកម្មភាពសេដ្ឋកិច្ច៖ *គាត់ធ្វើការនៅរោងចក្រកាត់ដេរ, គាត់ធ្វើការនៅឃ្លាំង*

គ្រួសារ៖ *ប្រពន្ធធ្វើការជាគ្រូបង្រៀននៅខេត្តព្រៃវែង, កូនរបស់ពួកគេនៅជាមួយនាង*


កម្រិតនៃការទទួលបានការអប់រំ៖ *បានបញ្ចប់ថ្នាក់បឋមសិក្សា*

អាកប្បកិរិយាចំពោះលុយ៖
- *មិនដែលទទួលបានព័ត៌មានអំពីរបៀបគ្រប់គ្រងលុយរបស់គាត់ទេ*
- *ចំណូលចិត្តខ្លាំងលើប្រាក់ ព្រោះវាជាករណីទូទៅនៅក្នុងភូមិរបស់គាត់*

ស្ថានភាពហិរញ្ញវត្ថុ៖
- *ព្យាយាមសន្សំឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន*
- *មិនហ៊ានប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុថ្មីៗ*
- *នៅតែសងប្រាក់កម្ចី*

គោលបំណង៖
- *គាត់ចង់បញ្ចប់ការសងប្រាក់កម្ចីដែលគាត់បានយកទៅទិញម៉ូតូដើម្បីសម្រេចគោលដៅផ្សេងទៀត*
- *គាត់និងប្រពន្ធរបស់គាត់ចង់មានផ្ទះផ្ទាល់ខ្លួន*

តួអង្គបន្ថែម៖
- *ភរិយា ឈ្មោះ ចិន្តា*
- *កូនរបស់គាត់ ប្រុស២នាក់៖ ឆាយ (អាយុ១០ឆ្នាំ) និងសុផាត (៨ឆ្នាំ)*
- *សហការី ឈ្មោះ សាយ និង វិបុល*



តួអង្គទី ៣
ណារី

ឈ្មោះ៖ ណារី

ក្រុមគោលដៅ៖ *រោងចក្រទំនិញធ្វើដំណើរ ដែលមានទីតាំងនៅតំបន់សេដ្ឋកិច្ចពិសេស*

ទីកន្លែងស្នាក់នៅ៖ *រស់នៅផ្ទះតូចមួយជិតរោងចក្រជាមួយគ្រួសារ*

ភេទ៖ *ស្រី*

អាយុ៖ *២៤*

ស្ថានភាពអាពាហ៍ពិពាហ៍៖ *នៅលីវ គ្មានកូន*

សកម្មភាពសេដ្ឋកិច្ច៖ *នាងធ្វើជាអ្នកវេចខ្ចប់នៅក្នុងផ្នែកមួយ*

គ្រួសារ៖ *រស់នៅជាមួយឪពុកម្តាយ បងប្រុស និងបងស្រីរបស់នាង នៅក្នុងផ្ទះតែមួយ*


កម្រិតនៃការទទួលបានការអប់រំ៖ *បានបញ្ចប់ថ្នាក់បឋមសិក្សា*

អាកប្បកិរិយាចំពោះលុយ៖
- *បានរៀនជំនាញជាមូលដ្ឋានមួយចំនួនអំពីការគ្រប់គ្រងលុយពីម្តាយរបស់នាង*
- *នាងមានការផ្ទេរប្រហែសបន្តិចនៅពេលនិយាយអំពីការគ្រប់គ្រងលុយ ហើយធ្វើការសម្រេចចិត្តជាច្រើន ដែលបន្ទាប់មកនាងសោកស្តាយ*

ស្ថានភាពហិរញ្ញវត្ថុ៖
- *នាងឲ្យលុយទៅមិត្តភ័ក្តិ/សាច់ញាតិ ខ្ចីច្រើនពេក ដោយមិនរំពឹងពីការសងប្រាក់វិញ*
- *នាងចែករំលែកព័ត៌មានលម្អិតអំពីប័ណ្ណរបស់នាងជាមួយសមាជិកដទៃទៀតនៃគ្រួសារ*
- *ប្រើប្រាស់ជម្រើសផ្លូវការពីស្ថាប័នហិរញ្ញវត្ថុ*

គោលបំណង៖
- *នាងចង់សាងសង់បន្ទប់បន្ថែមសម្រាប់នាងនៅផ្ទះឪពុកម្តាយរបស់នាង*
- *កែលម្អការគ្រប់គ្រងហិរញ្ញវត្ថុរបស់នាង*

តួអង្គបន្ថែមទៀត៖
- *អ្នកជិតខាងឈ្មោះនាង បុប្ផា និងឧត្តម*
- *បងប្អូនជីដូនមួយរបស់នាងឈ្មោះ រដ្ឋា*
- *ឪពុកម្តាយរបស់នាង*
- *ប្អូនប្រុសរបស់នាងឈ្មោះ ជា*



តួអង្គទី ៤
រក្សា

ឈ្មោះ៖ រក្សា

ក្រុមគោលដៅ៖ *កម្មករកាត់ដេរ។*

ទីកន្លែងស្នាក់នៅ៖
- *រស់នៅក្បែរឪពុកម្តាយរបស់នាងនៅក្នុងផ្ទះទើបសាងសង់ថ្មី*
- *ធ្វើដំណើរជារៀងរាល់ថ្ងៃតាមរថយន្តទៅកាន់រោងចក្រដែលមានទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស*
- *នាងចំណាយពេល ២ ម៉ោងក្នុងការធ្វើដំណើរជារៀងរាល់ថ្ងៃ*

ភេទ៖ *ស្រី*

អាយុ៖ *២៤*

ស្ថានភាពអាពាហ៍ពិពាហ៍៖ *រៀបការហើយមានកូនម្នាក់*

សកម្មភាពសេដ្ឋកិច្ច៖ *នាងធ្វើការនៅរោងចក្រនាំចេញ ជាអ្នកត្រួតពិនិត្យគុណភាព*

ក្រួសារ៖
- *ឪពុកម្តាយរបស់នាង*
- *ប្តី និងកូនរបស់នាង*


កម្រិតនៃការទទួលបានការអប់រំ៖ *បានបញ្ចប់វិទ្យាល័យ*

អាកប្បកិរិយាចំពោះលុយ៖ *មានការប្រុងប្រយ័ត្នខ្ពស់ក្នុងការចំណាយលុយ ដោយសារគ្រួសាររបស់នាងមានតម្រូវការច្រើន*

ស្ថានភាពហិរញ្ញវត្ថុ៖
- *ចំណង់ចំណូលចិត្តខ្លាំងចំពោះសាច់ប្រាក់ ប៉ុន្តែចាប់អារម្មណ៍លើប្រាក់ឈ្នួលឌីជីថល ដើម្បីគ្រប់គ្រងប្រាក់របស់នាងឲ្យកាន់តែប្រសើរ*
- *កែលម្អការគ្រប់គ្រងហិរញ្ញវត្ថុរបស់នាង*

គោលបំណង៖
- *សន្សំបានច្រើនតាមតែអាចធ្វើទៅបាន*
- *ផ្តល់ការអប់រំល្អដល់កូន*

តួអង្គបន្ថែមបន្ថែម៖
- *សហការីរបស់នាងឈ្មោះ ប៉ានី*
- *វិសាល ជាអ្នកផ្តល់ប្រាក់កម្ចីក្រៅផ្លូវការ*
- *មិត្តភក្តិរបស់នាង ផានី និង ធីណា*
- *បងប្អូនជីដូនមួយរបស់គាត់នៅក្នុងភូមិ*



ក

FINANCIAL EDUCATION QUIZ

កំណត់គោលដៅ និងចំណាត់ចំនួនក្នុងក្រួសាររបស់អ្នក

ក១. តើសុភាសិតខាងក្រោមនេះមានន័យយ៉ាងណា? "ប្រសិនបើមនុស្សម្នាក់មិនដឹងថាគាត់ត្រូវកាប់ចង្កូតទៅកំពង់ផែណាទេនោះ គាត់នឹងមិនទទួលបានខ្យល់ដែលអំណោយផលចំពោះគាត់ឡើយ"។

- ☐ **ក.** អ្នកត្រូវមានខ្យល់ ទើបអាចបើកទូកបាន។
- ☐ **ខ.** វាកាន់តែងាយស្រួលក្នុងការដឹងពីគម្រោងជីវិតរបស់អ្នក ប្រសិនបើអ្នកដឹងពីកន្លែងដែលអ្នកទៅ ហើយប្រសិនបើអ្នកកំណត់គោលដៅច្បាស់លាស់។
- ☐ **គ.** វាងាយស្រួលក្នុងការកាប់ចង្កូតទូកនៅពេលមានខ្យល់។

ក២. តើអ្វីជាវិធីដ៏ល្អបំផុតដើម្បីសម្រេចបានគោលដៅរបស់អ្នកសម្រាប់អនាគត?

- ☐ **ក.** ត្រូវមានគោលដៅរយៈពេលខ្លី និងរយៈពេលវែង ហើយសន្សំឲ្យបានទៀងទាត់ ទើបអាចសម្រេចបាន។
- ☐ **ខ.** ត្រូវមានគោលដៅ និងសង្ឃឹមថានឹងសម្រេចបាន។ សំខាន់មានជំនឿលើខ្លួនឯង។
- ☐ **គ.** ខ្ញុំនៅក្មេងពេកក្នុងការរៀបចំគោលដៅសម្រាប់អនាគត ខ្ញុំអាចគិតអំពីរឿងនេះនៅថ្ងៃអនាគត។

ក៣. ឪពុកម្តាយទូរស័ព្ទសុំលុយពីខ្ញុំម្តងទៀតដើម្បីធ្វើបុណ្យនៅភូមិ

- ☐ **ក.** ខ្ញុំផ្ញើលុយឲ្យពួកគាត់ភ្លាម ព្រោះខ្ញុំតែងតែធ្វើតាមអ្វីដែលឪពុកម្តាយស្នើសុំ។
- ☐ **ខ.** ខ្ញុំមិនយល់ព្រមទាល់តែសោះ ហើយបដិសេធមិនផ្ញើប្រាក់ឡើយ។
- ☐ **គ.** ខ្ញុំពិភាក្សាជាមួយពួកគាត់ ដើម្បីយល់កាន់តែច្បាស់ពីតម្រូវការរបស់ពួកគាត់ និងគិតមើលពីរបៀបដែលខ្ញុំអាចជួយពួកគាត់ឲ្យចង់ចាំគោលដៅរបស់ខ្ញុំ និងផែនការសន្សំរបស់ខ្ញុំ។

ក៤. តើផែនការសន្សំគឺជាអ្វី?

- ☐ **ក.** ជម្រើសហិរញ្ញវត្ថុ។
- ☐ **ខ.** ផែនការដែលអ្នកអាចមើលឃើញគោលដៅរបស់អ្នក ការចំណាយសម្រាប់គោលដៅទាំងនោះ កាលបរិច្ឆេទដែលអ្នកចង់សម្រេចគោលដៅរបស់អ្នក និងចំនួនទឹកប្រាក់ដែលអ្នកត្រូវតែសន្សំដើម្បីសម្រេចគោលដៅ។
- ☐ **គ.** ប្រអប់លុយ។

ក៥. តើអ្នកគួរធ្វើអ្វីខ្លះមុននឹងសម្រេចចិត្តធ្វើចំណាកស្រុក?

- ☐ **ក.** ខ្ញុំគួរតែទៅធនាគារ ហើយពិនិត្យមើលថាតើខ្ញុំអាចខ្ចីលុយដើម្បីធ្វើចំណាកស្រុកបានដែរឬទេ។
- ☐ **ខ.** ខ្ញុំគួរតែគិតគូរអំពីគុណសម្បត្តិ និងគុណវិបត្តិទាំងអស់ គណនាថាតើវានឹងត្រូវចំណាយអស់ប៉ុន្មាន ហើយធ្វើការសម្រេចចិត្តដោយទទួលបានព័ត៌មានគ្រប់គ្រាន់ ។
- ☐ **គ.**ខ្ញុំគួរតែស្តាប់ និងទុកចិត្តលើអ្នកដែលបានធ្វើចំណាកស្រុកប៉ុណ្ណោះ។

ចម្លើយ៖ ក:ខ, ខ:ខ, គ:ក, ឃ:ក, ង:ខ, ច:ខ, ឆ:ខ, ជ:ខ

១. កំណត់គោលដៅរបស់អ្នក

និយមន័យ

គោលដៅគឺជាអ្វីដែលអ្នកចង់ធ្វើ។ ការកំណត់គោលដៅជួយឲ្យអ្នកកំណត់នូវអ្វីដែលអ្នកចង់ធ្វើក្នុងជីវិត ហេតុដូច្នេះហើយទើបដឹងពីអ្វីដែលអ្នកត្រូវធ្វើដើម្បីធ្វើឲ្យវាក្លាយជាការពិត។



តោះមកស្គាល់ សុភាព ដែលជាតួអង្គមួយរបស់យើង។

ករណីសិក្សាទី១

រឿងរ៉ាវរបស់សុភាព


សុភាព អាយុ៣៧ឆ្នាំ។ នាងបានចំណាកស្រុកមកពីខេត្តក្រចេះកាលពីប៉ុន្មានឆ្នាំមុន ហើយបានធ្វើការនៅក្នុងរោងចក្រនាំចេញតែមួយនោះ តាំងពីពេលនោះមក។ នាងបានរៀបការជាមួយសុផា នៅភូមិរបស់នាងកាលនាងមានអាយុ១៦ឆ្នាំ។ ពួកគាត់មានកូនបីនាក់នៅផ្ទះ មានអាយុ ១៨ ឆ្នាំ ១៦ និង ១២ ឆ្នាំ។

សុភាព ធ្វើការជាអ្នកកាត់ដេរនៅក្នុងរោងចក្រ។ នាងបានឮអំពីឱកាសធ្វើការនៅក្នុងរោងចក្រពីស្ត្រីផ្សេងទៀតនៅក្នុងស្រុករបស់នាង ហើយបានសម្រេចចិត្តថាវាជាឱកាសល្អក្នុងការរកប្រាក់សន្សំសម្រាប់សាងសង់ផ្ទះ និងផ្គត់ផ្គង់គ្រួសាររបស់នាង។ វាមានការពិបាកសម្រេចចិត្តដោយសារត្រូវនៅឆ្ងាយពីកូនៗ ប៉ុន្តែនាងបានពិភាក្សាជាមួយសុផា ហើយសម្រេចថានេះជាពេលដ៏ល្អដោយសារកូនៗរាងធំបន្តិចហើយ។ នាងចូលចិត្តការងាររបស់នាង ប៉ុន្តែពេលខ្លះនាងនឿយហត់ដោយសារត្រូវធ្វើការច្រើនម៉ោង។ សុផា រស់នៅក្នុងផ្ទះជាមួយឪពុកម្តាយរបស់សុភាពនៅភូមិ។ គាត់ធ្វើការជាកម្មករប្រចាំថ្ងៃក្នុងកសិដ្ឋានកសិកម្មក្បែរនោះ ដូចឪពុករបស់សុភាពដែរ។ ម្តាយរបស់សុភាពមើលថែផ្ទះ។ បងស្រីរបស់សុភាពមានអាយុ២២ឆ្នាំ ជួយម្តាយនៅផ្ទះ និងធ្វើការម្តងម្កាលលក់ជម្រើសនៅផ្សារ។

សុភាពផ្ញើរៀងរាល់ខែស្ទើរតែ ៥០% នៃប្រាក់ចំណូលរបស់នាងទៅគ្រួសាររបស់នាងតាមរយៈប្រតិបត្តិករទូរស័ព្ទចល័តប្រាក់។ នាងរក្សាប្រាក់ដែលនៅសល់ ហើយនាងចំណាយវាក្នុងការជួលបន្ទប់ អាហារ សម្ភារៈបន្ទប់ទឹក និងកញ្ចប់ទិន្នន័យអ៊ីនធឺណិត។ នាងក៏រក្សាទុកបន្តិចសម្រាប់ការចំណាយពេលទំនេររបស់នាង។ ពេលខ្លះនាងអាចរក្សាទុកបន្តិចក្នុងគណនីផ្ទាល់ខ្លួនរបស់នាង។ លុយដែលផ្ញើមកផ្ទះ តាមអ្វីដែលប្តីនាងប្រាប់ មួយភាគធំគឺយកទៅទុកសម្រាប់សង់ផ្ទះធំជាងនេះ សម្រាប់ពេលដែលសុភាពត្រឡប់មកផ្ទះវិញ ហើយសល់ទុកសម្រាប់ចំណាយធម្មតារបស់ពួកគាត់នៅទីនោះ។


សុភាព មានគំនិតច្រើនសម្រាប់អនាគតនាងត្រឡប់មកផ្ទះវិញ។ ក្តីស្រមៃរបស់នាងគឺចង់មានហាង សាឡនផ្ទាល់ខ្លួន។ សុភាព សុផា និងគ្រួសារ ស្រមៃចង់ទិញដីមួយកន្លែងដើម្បីជាំបន្លែផ្ទាល់ខ្លួន។ សុភាពក៏ចង់រៀនចប់ដែរ។


តើអ្វីទៅជាសុបិនរបស់សុភាព?
សូមសរសេរនៅទីនេះ!




ជំនួយការបណ្តុះបណ្តាល ក.១.១
គោលដៅរបស់ខ្ញុំ

តើអ្នកធ្លាប់គិតពីគោលដៅរបស់អ្នកទេ?
បើដូច្នេះ សូមសរសេរ ឬគូររៀនៅទីនេះ!







ត្រូវចងចាំថា៖

គោលបំណងរបស់អ្នកទាំងអស់គឺសំខាន់!គោលដៅខ្លះអាចសម្រេចបានលឿនជាងគោលដៅផ្សេងទៀត។

⚠ **ចំណុចសំខាន់៖** ការគ្រប់គ្រងលុយរបស់អ្នកឲ្យបានល្អ អាចកាត់បន្ថយកម្រិតភាពតានតឹងរបស់អ្នក។

២. ទាយតម្លៃការចំណាយលើគោលដៅ និងអាទិភាពរបស់អ្នក

តើអ្នកដឹងពីការចំណាយនៃគោលដៅរបស់អ្នកទេ?

តើអ្នកដឹងពីការចំណាយសម្រាប់គោលដៅរបស់អ្នកដែរឬទេ? ប្រសិនបើអ្នកធ្វើបាន សូមសរសេរ ការចំណាយនៅក្បែរគោលដៅដែលអ្នកបានសរសេរ ឬគូរខាងលើ។ ប្រសិនបើអ្នកមិនធ្វើទេ វាពិតជាសំខាន់ណាស់ដែលអ្នកត្រូវស្វែងយល់។ វាគឺជាមធ្យោបាយតែមួយគត់ដើម្បីដឹងថាអ្នកត្រូវការប្រាក់ប៉ុន្មានដើម្បីសម្រេចបាននូវគោលដៅរបស់អ្នក។ ទន្ទឹមនឹងនេះ អ្នកអាចបង្ហាញពីការចំណាយប្រហាក់ប្រហែលដែលអ្នកអាចកែតម្រូវនៅពេលក្រោយ។

បន្ទាប់មក កំណត់អាទិភាពគោលដៅរបស់អ្នកដោយដាក់លេខ ១ សម្រាប់សំខាន់បំផុត លេខ២ សម្រាប់សំខាន់បំផុតទីពីរ និងបន្តបន្ទាប់ទៀត។

លេខ	គោលដៅផ្ទាល់ខ្លួន ឬ សម្រាប់ត្រួសារ	គោលដៅ	ការចំណាយប៉ាន់ស្មាន

ត្រូវចងចាំថា

គោលដៅជាទូទៅគឺងាយស្រួលជាងក្នុងការសម្រេចបាន ប្រសិនបើអ្នកគិតជាមុន ហើយប្រមូលព័ត៌មានទាំងអស់ដែលអ្នកត្រូវការដើម្បីធ្វើការសំរេចចិត្តដោយទទួលបានព័ត៌មានច្បាស់លាស់។ វាសំខាន់ណាស់ដែលយើងវាយតម្លៃថាតើវានឹងត្រូវចំណាយប៉ុន្មានដើម្បីសម្រេចបាននូវគោលដៅរបស់យើង។ ជួនកាលការស្រាវជ្រាវដោយប្រុងប្រយ័ត្នគឺចាំបាច់ (ស្វែងរកព័ត៌មានពីអ្នកផ្គត់ផ្គង់ ការស្វែងយលអំពីទំនោរទីផ្សារ។ល។)។

កុំភ្លេចថាតម្លៃឡើងតាមពេលវេលា! ដូច្នេះ ជារឿយៗត្រូវបង្កើនសន្សំប្រាក់បន្ថែមបន្តិច ក្នុងករណីដែលការចំណាយសម្រាប់គោលដៅរបស់អ្នក កើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

៣. រៀបចំផែនការសន្សំដើម្បីសម្រេចបានឆាប់គោលដៅរបស់អ្នក



ករណីសិក្សាទី២

ផែនការសន្សំប្រាក់របស់ណារី

ណារី ធ្វើការជាអ្នករៀបខ្ចប់ក្នុងរោងចក្រផលិតផលធ្វើដំណើរ និងកាបូប។ នាងនៅលីវ និងគ្មានកូន។ នាងរស់នៅជាមួយឪពុកម្តាយ បងប្រុស និងបងស្រីរបស់នាង។ ពួកគេទាំងអស់ចែករំលែកចំណូល និងចំណាយសម្រាប់គ្រួសារ។ នាងមានគោលបំណងជាច្រើនសម្រាប់អនាគតរបស់នាង ប៉ុន្តែនាងដឹងថាវាមិនងាយស្រួលទេក្នុងការសម្រេចបានគោលដៅទាំងអស់នោះ។ ណារីបានពិនិត្យមើលគម្រោងរបស់នាង។

នាងចង់ផ្លាស់ប្តូរទូរស័ព្ទដៃរបស់នាងក្នុងរយៈពេលខ្លី ព្រោះវាពិតជាចាស់ ហើយកម្មវិធីភាគច្រើនក្នុងទូរស័ព្ទដៃលនាងប្រើជារៀងរាល់ថ្ងៃ មិនដំណើរការល្អ។ នាងក៏ចង់មានម៉ូតូ ដើម្បីចៀសវាងការធ្វើដំណើរយូរទៅរោងចក្រ ប៉ុន្តែនាងដឹងថាវាថ្លៃណាស់ ហើយក៏សម្រេចចិត្តផ្អាកគោលដៅនេះទៅពេលនេះ។ អ្វីដែលនាងចង់សម្រេចបានក្នុងរយៈពេលមួយឆ្នាំគឺទិញម៉ាស៊ីនដេរថ្មី។ នាងអាចចែករំលែកការចំណាយជាមួយបងស្រីរបស់នាងដែលរស់នៅជាមួយនាងផងដែរ។
នៅពេលខាងមុខ នាងចង់ទិញសម្ភារៈដែលត្រូវការសម្រាប់សាងសង់បន្ទប់បន្ថែមនៅក្នុងផ្ទះ។ ឪពុករបស់នាងអាចជួយការងារដែលត្រូវការបាន ដោយសារគាត់មានជំនាញសម្រាប់ការងារនេះ។
ណារីបានវាយតម្លៃការចំណាយគម្រោងនីមួយៗ និងកំណត់កាលបរិច្ឆេទថាតើនាងចង់សម្រេច គោលដៅនៅពេលណា។ នាងបានគណនាចំនួនទឹកប្រាក់ដែលនាងត្រូវការសន្សំជារៀងរាល់ខែសម្រាប់គោលបំណងនេះ។ ណារីបានគូសវាសនូវអ្វីដែលយើងហៅថាផែនការសន្សំ។ តាមរយៈផែនការសន្សំនេះ វាបានផ្តល់ឲ្យនាងនូវរូបភាពកាន់តែច្បាស់អំពីអ្វីដែលនាងត្រូវការសន្សំជារៀងរាល់ខែដើម្បីសម្រេចបាននូវគោលដៅរបស់នាង។

ដូច្នេះសូមមើលគម្រោងសន្សំប្រាក់របស់ ណារី !

ផែនការសន្សំប្រាក់

គោលដៅ	កាលបរិច្ឆេទពេលចង់សម្រេចគោលដៅ	ការចំណាយដើម្បីសម្រេចគោលដៅ	ចំនួនខែមុនកាលបរិច្ឆេទក្នុងការសម្រេចគោលដៅ	ប្រភពហិរញ្ញវត្ថុផ្សេងទៀត (ប្រសិនបើមានភាពទាក់ទង)	ក្នុងមួយខែៗ តើត្រូវសន្សំប្រាក់ចំនួនប៉ុន្មានដើម្បីសម្រេចគោលដៅ
គោលដៅរយៈពេលខ្លី (តិចជាង១២ខែ)៖					
ទិញទូរស័ព្ទដៃថ្មី	ខែមីនា ឆ្នាំនេះ	១៨០$	៦ខែ		៣០$
គោលដៅរយៈពេលមធ្យម (១ឆ្នាំ ទៅ៣ឆ្នាំ)៖					
ទិញម៉ាស៊ីនដេរថ្មី	ខែមករា ឆ្នាំក្រោយ	២៤០$	១២ខែ	បងថ្លៃជួយចេញថ្លៃចំណាយពាក់កណ្តាល	១០$
គោលដៅរយៈពេលវែង (ច្រើនជាង៣ឆ្នាំ)៖					
ទិញសម្ភារៈដើម្បីសាងសង់បន្ទប់បន្ថែមក្នុងផ្ទះ	ខែមករា រយៈពេល៥ឆ្នាំក្រោយ រយៈពេល៥ឆ្នាំក្រោយ	៣០០០$	៦០ខែ		៥០$
ចំនួនទឹកប្រាក់សរុបដែលខ្ញុំត្រូវសន្សំដើម្បីសម្រេចគោលដៅទាំងអស់របស់ខ្ញុំ (ចំនួនទឹកប្រាក់សរុបនៅផ្នែកខាងស្តាំនៃតារាង)					៩០$



⚠ **ចំណុចសំខាន់៖** នៅពេលដែល ណារី សម្រេចបាននូវគោលដៅរយៈពេលខ្លីរបស់នាង នាងនឹងត្រូវកែសម្រួលផែនការសន្សំនិងប្រាក់ដែលនាងត្រូវការទុកជារៀងរាល់ខែ ដើម្បីសម្រេចបាននូវគោលដៅផ្សេងទៀតរបស់នាង។

ជំនួយការបណ្តុះបណ្តាល ក.១.២

ផែនការសន្សំប្រាក់របស់ខ្ញុំ



ឥឡូវជាវេនអ្នកម្តង!

ឥឡូវនេះ ចូរសង្ខេប និងបំពេញតារាងខាងក្រោមជាមួយនឹងព័ត៌មានទាំងអស់ដែលអ្នកបានគិត រួមមាន គោលដៅ អាទិភាព ការចំណាយ កាលបរិច្ឆេទដែលអ្នកចង់សម្រេចបាននូវគោលដៅរបស់អ្នក និងប្រភពហិរញ្ញវត្ថុផ្សេងទៀត។

▶ ជំនួយការបណ្តុះបណ្តាល

ក.១.២

ផែនការសន្សំប្រាក់					
គោលដៅ	កាលបរិច្ឆេទពេលចង់សម្រេចគោលដៅ	ការចំណាយដើម្បីសម្រេចគោលដៅ	ចំនួនខែមុនកាលបរិច្ឆេទក្នុងការសម្រេចគោលដៅ	ប្រភពហិរញ្ញវត្ថុផ្សេងទៀត (ប្រសិនបើមានភាពទាក់ទង)	ក្នុងមួយខែៗ តើត្រូវសន្សំប្រាក់ចំនួនប៉ុន្មានដើម្បីសម្រេចគោលដៅ
គោលដៅរយៈពេលខ្លី មានរយៈពេល					
គោលដៅរយៈពេលវែង មានរយៈពេល					
គោលដៅរយៈពេលវែងជាមួយគ្រួសារ					
គោលដៅរយៈពេលខ្លីជាមួយគ្រួសាររួមមាន					
ចំនួនទឹកប្រាក់សរុបដែលខ្ញុំត្រូវសន្សំដើម្បីសម្រេចគោលដៅទាំងអស់របស់ខ្ញុំ (ចំនួនទឹកប្រាក់សរុបនៅផ្នែកខាងស្តាំនៃតារាង)					

ភេនរបស់អ្នក

ខ្ញុំត្រូវសន្សំ
.....
ក្នុងមួយខែ ដើម្បីសម្រេចបានគ្រប់គោលដៅរបស់ខ្ញុំ។

ត្រូវប្រុងប្រយ័ត្ន! ប្រសិនបើអ្នកមិនអាចសន្សំបានច្រើនជារៀងរាល់ខែ អ្នកត្រូវពិនិត្យមើលគោលដៅរបស់អ្នកឡើងវិញ៖
ដោយកាត់បន្ថយការចំណាយរបស់ពួកគេ ឬដោយការលុបចោលគោលដៅមួយចំនួននៅពេលនេះ ឬដោយការពន្យារពេលកាលបរិច្ឆេទដែលអ្នកចង់សម្រេចបាននូវគោលដៅមួយចំនួនរបស់អ្នក។
អ្នកអាចធ្វើបាន ដោយពិនិត្យមើលពីរបៀបដែលអ្នកកំណត់អាទិភាព

គោលដៅ៖ ខុទាហរណ៍ អ្នកនឹងមិនផ្លាស់ប្តូរគោលដៅទី១ និងទី២ របស់អ្នកទេ ប៉ុន្តែអ្នកប្រហែលជាត្រូវផ្លាស់ប្តូរគោលដៅទី៣ និងទី៤ របស់អ្នក។

⚠ ចំណុចសំខាន់
ការបង្កើតផែនការសន្សំអាចបណ្តាលឲ្យមានទុក្ខព្រួយមួយចំនួន ជាពិសេសប្រសិនបើអ្នកមិនអាចសន្សំបានច្រើនតាមដែលអ្នកចង់បាន។ កុំរុញច្រានខ្លួនឯង! ចងចាំជានិច្ចថា អ្នកតែងតែអាចកែសម្រួលផែនការសន្សំរបស់អ្នក។

សារសំខាន់

- វាកាន់តែងាយស្រួលក្នុងការសម្រេចបាននូវផែនការជីវិតរបស់អ្នក ប្រសិនបើអ្នកដឹងពីអ្វីដែលអ្នកចង់បាន ហើយកំណត់ខ្លួនអ្នកនូវគោលដៅច្បាស់លាស់ដើម្បីសម្រេចបាន។
- គោលដៅមួយចំនួនអាចសម្រេចបានយ៉ាងឆាប់រហ័ស។ គោលដៅផ្សេងទៀតចំណាយពេលរាប់ឆ្នាំ ឬរាប់ទសវត្សរ៍។ គោលដៅត្រូវចាត់ថ្នាក់ជារយៈពេលខ្លី មធ្យម ឬវែង។
- គោលដៅរបស់យើង ផ្លាស់ប្តូរក្នុងដំណើរជីវិតរបស់យើង ហើយសមាជិកគ្រួសារផ្សេងគ្នានឹងមាន គោលដៅខុសៗគ្នា។ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យគោលដៅផ្សេងៗគ្នារបស់សមាជិកគ្រួសារ ត្រូវគ្នានឹងគ្នាទៅវិញទៅមក។
- ការប្រាស្រ័យទាក់ទងល្អគឺជាការចង់បាននៅក្នុងគ្រួសារទាំងអស់ ជាពិសេសនៅក្នុងគ្រួសារដែលមានសាច់ញាតិរស់នៅក្នុងទីក្រុងធំៗ តំបន់ ឬប្រទេស។
- ការកំណត់គោលដៅរបស់មនុស្សម្នាក់ និងធ្វើឲ្យមានភាពខុសគ្នា រវាងជំនឿមិនពិត និងការពិតក្នុងការកំណត់គោលដៅ ធ្វើឲ្យវាកាន់តែងាយស្រួលក្នុងការសម្រេចបាននូវគោលដៅ។
- វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកព័ត៌មានដែលអាចទុកចិត្តបានក្នុងការវាយតម្លៃលើគុណតម្លៃ និងការចំណាយដើម្បីសម្រេចបាននូវគោលដៅរបស់អ្នក។
- អ្នកក៏ត្រូវមានលទ្ធភាពកែតម្រូវគោលដៅរបស់អ្នកផងដែរ ប្រសិនបើត្រូវចំណាយខ្ពស់ពេក និងមានភាពបត់បែនក្នុងការកែតម្រូវគោលដៅរបស់អ្នក (ក្នុងករណីមានការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុ ឬសង្គមរបស់អ្នក)
- រក្សាគោលដៅរបស់អ្នកក្នុងចិត្តគឺជាវិធីប្រាកដក្នុងការសម្រេចដោយជោគជ័យ។
- បង្កើតផែនការសន្សំជួយអ្នកឲ្យសម្រេចគោលដៅបានកាន់តែងាយស្រួល។

៤. និយាយទៅកាន់គ្រួសាររបស់អ្នកអំពីគោលដៅរបស់អ្នក!

ការណែនាំអំពីពិភាក្សាអំពីគោលដៅរបស់អ្នកជាមួយគ្រួសាររបស់អ្នក

- គិតឲ្យបានល្អអំពីអ្វីដែលអ្នកចង់បាន (និងហេតុផលដែលអ្នកចង់បាន) មុនពេលអ្នកនិយាយជាមួយគ្រួសាររបស់អ្នក។
- កុំខ្លាចក្នុងការនិយាយអំពីគោលដៅរបស់អ្នក។ បុរស និងស្ត្រីទាំងអស់ មិនថាក្មេង ឬចាស់ មានសិទ្ធិកំណត់គោលដៅផ្ទាល់ខ្លួនរបស់ពួកគេ។
- ស្វែងរកសម្ព័ន្ធមិត្តនៅក្នុងគ្រួសាររបស់អ្នក៖ មនុស្សដែលអ្នកធ្លាប់និយាយពីមុនមក និងអ្នកដែលអាចជួយអ្នកបាន មនុស្សដែលគេគោរពក្នុងគ្រួសារ។
- ដើម្បីនិយាយអំពីគោលដៅរបស់អ្នកទៅកាន់ប្តីឬប្រពន្ធរបស់អ្នក និង/ឬសមាជិកគ្រួសារផ្សេងទៀត សូមជ្រើសរើសពេលវេលាត្រឹមត្រូវ កំណត់ពេលវេលាយកពួកគេទំនេរ។
- ត្រូវមានទំនុកចិត្តនៅពេលអ្នកនិយាយអំពីគោលដៅរបស់អ្នកនិងស្តាប់យោបល់របស់មនុស្សផ្សេងទៀតដោយមិនរំខាន។
- ត្រូវគោរពសមាជិកគ្រួសាររបស់អ្នក និងមានភាពបត់បែនលើជំហររបស់អ្នក។
- ប្រសិនបើមានការមិនចុះសម្រុងគ្នា សូមពិនិត្យមើលបញ្ហា ហើយរកមើលជំណោះស្រាយសម្របសម្រួលដែលនឹងផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នាក្នុងគ្រួសារ។

ចំណុចគួរធ្វើ	ចំណុចមិនគួរធ្វើ
• មានទំនុកចិត្តលើខ្លួនឯង • បញ្ជាក់ឲ្យច្បាស់នូវអ្វីដែលអ្នកចង់បាន • ស្តាប់ដៃគូរបស់អ្នក • ទទួលស្គាល់ទស្សនៈរបស់អ្នកដទៃ • បង្ហាញការគោរព • មានភាពបត់បែន និងសុប់ស្ងាត់ • បញ្ចេញមតិរបស់អ្នក ទោះបីជាអ្នកមានការ គោរពដល់អ្នកនោះក៏ដោយ។	• បង្ហាញភាពអត់ធ្មត់ • មិនយកចិត្តទុកដាក់ស្តាប់ ឬក្រអឺតក្រទម • ស្រែក • រំខាន • ខឹង • ជេរប្រមាថ ឬជេរប្រមាថ • លើកឡើងចំណុចដដែលជាច្រើនដង • បដិសេធភ្លាមៗនូវគំនិតរបស់អ្នកដទៃ • ប្រកាន់យកឥរិយាបថការពារទស្សនៈ របស់ខ្លួនពេក



⚠ **ចំណុចសំខាន់៖** ការនិយាយអំពីលុយអាចបង្កឲ្យមានប្រតិកម្មអារម្មណ៍ច្រើន។ ព្យាយាមស្វែងរកនរណាម្នាក់ដែលអ្នកទុកចិត្តដើម្បីនិយាយអំពីរឿងនេះ។ ការមិននិយាយអំពីអារម្មណ៍របស់អ្នកមានឥទ្ធិពលអវិជ្ជមានលើសុខភាពផ្លូវចិត្តរបស់អ្នក។

ជំនួយការបណ្តុះបណ្តាល ក.២.១
សកម្មភាពដើរតួ៖ ការមិនយល់ស្របគ្នា និងការចរចា



ការមិនយល់ស្របគ្នា ទី១

សុភាពបានចាត់ចែងការសន្សំប្រាក់ផ្ទាល់ខ្លួនមួយចំនួន។ នាងកំពុងនិយាយតាមទូរស័ព្ទជាមួយឪពុកដែលសួរនាងថាតើនាងអាចឲ្យមីងរបស់ខ្លួនខ្ចីលុយខ្លះដើម្បីទិញឪសថដែរឬទេ។ សុភាពមិនឲ្យមីងខ្ចីលុយនាងទេ ព្រោះនាងគិតថានាងត្រូវការលុយទាំងអស់ដែលនាងសន្សំសម្រាប់ថ្ងៃដែលនាងត្រឡប់ទៅផ្ទះវិញ។ នាងមិនចង់និយាយថាទេចំពោះប្អូនស្រីរបស់ឪពុកនាង ហើយមិនដឹងថាត្រូវធ្វើយ៉ាងណា។ តើនាងគួរធ្វើយ៉ាងណា?



ចូរធ្វើការសំដែងដែលបង្ហាញពីការសន្ទនារវាងតួអង្គដែលបានពិពណ៌ន និងដំណោះស្រាយរបស់អ្នក។ យ៉ាងហោចណាស់ តួអង្គម្នាក់ ត្រូវព្យាយាមអនុវត្តវិធីសម្រាប់ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។

ការមិនយល់ស្របគ្នា ទី២

បូរ៉ាន កំពុងញ៉ាំអាហារថ្ងៃត្រង់នៅអាហារដ្ឋានជាមួយសាយ ដែលជាអ្នកធ្វើការជាមួយគាត់។ បូរ៉ាន ប្រាប់គាត់ថាកាលពីម្សិលមិញគាត់បានពិភាក្សាជាមួយប្រពន្ធរបស់គាត់ឈ្មោះចិន្តាអំពីការរៀបចំធ្វើឧបកំណើតកូនប្រុសច្បងរបស់ពួកគេ។ ចិន្តាចង់រៀបចំពិធីឧបកំណើតធំមួយ ហើយសុំបូរ៉ានធ្វើលុយបន្ថែម ដោយសារឆាយឈានចូលអាយុ១០ឆ្នាំហើយ។ បូរ៉ានចង់ឲ្យឆាយរៀបចំពិធីជប់លៀងធំ ប៉ុន្តែគាត់គិតថាចំនួនទឹកប្រាក់ដែលសាយ ឲ្យយោបល់នោះគឺមានចំនួនច្រើនពេក។ គាត់ខ្លាចថាបើគាត់មិនព្រម ប្រពន្ធនិងគ្រួសារគាត់នឹងគិតថាគាត់កំណាញ់ពេក ជាពិសេសដោយសារគាត់ជាអ្នករកលុយបានច្រើនជាងគេក្នុងគ្រួសារ។ តើគាត់គួរធ្វើយ៉ាងណា?


ចូរធ្វើការសំដែងដែលបង្ហាញពីការសន្ទនារវាងតួអង្គដែលបានពិពណ៌នា និងដំណោះស្រាយរបស់អ្នក។ យ៉ាងហោចណាស់ តួអង្គម្នាក់ ត្រូវព្យាយាមអនុវត្តវិធីសម្រាប់ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។

ការមិនយល់ស្របគ្នា ទី៣

ណារី តែងតែសន្សំទុកលុយ ដើម្បីសម្រេចគោលបំណងរបស់នាង។ បងប្រុសរបស់នាងបានស្នើសុំលុយពីនាងដោយទទូច ដើម្បីទិញខោអាវថ្មី ព្រោះថាគាត់ខានទិញខោថ្មីជាយូរណាស់មកហើយ។ ណារីចង់ជួយបងប្រុស ប៉ុន្តែក៏គិតថានាងគួរសន្សំប្រាក់ឲ្យបានច្រើនតាមអាចធ្វើបាន។ តើនាងគួរធ្វើយ៉ាងណា?



ចូរធ្វើការសំដែងដែលបង្ហាញពីការសន្ទនារវាងតួអង្គដែលបានពិពណ៌នា និងដំណោះស្រាយរបស់អ្នក។ យ៉ាងហោចណាស់ តួអង្គម្នាក់ ត្រូវព្យាយាមអនុវត្តវិធីសម្រាប់ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។




ការមិនយល់ស្របគ្នា ទី៤

រក្សាធ្វើការយ៉ាងលំបាកក្នុងនាមជាអ្នកត្រួតពិនិត្យគុណភាពនៅក្នុងរោងចក្រកាត់ដេរ។ ជារៀងរាល់ខែ នាងបានផ្តល់ប្រាក់ខ្លះដល់ឪពុកម្តាយរបស់នាង ដោយប្រាប់ពួកគាត់ឲ្យរក្សាទុកប្រាក់ខ្លះសម្រាប់គ្រាអាសន្ន។ ពេលម្តាយធ្លាក់ខ្លួនឈឺ ឪពុកសារភាពថា គាត់មិនបានទុកប្រាក់ខ្លះ ហើយគ្មានសល់អ្វីឡើយ។ នាងមានការខកចិត្ត និងខឹងយ៉ាងខ្លាំង។ តើនាងគួរយ៉ាងណា?

ចូរធ្វើការសំដែងដែលបង្ហាញពីការសន្ទនារវាងតួអង្គដែលបានពិពណ៌នា និងដំណោះស្រាយរបស់អ្នក។ យ៉ាងហោចណាស់ តួអង្គម្នាក់ ត្រូវព្យាយាមអនុវត្តវិធីសម្រាប់ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។

ករណីសិក្សាទី៣

ប៉ូវ៉ាន ហូបតែជាមួយ សាយ ដែលជាមិត្តរួមការងារ



ពេលកំពុងផឹកតែជាមួយមិត្តភ័ក្តិ និងមិត្តរួមការងារ ឈ្មោះ សាយ នៅក្នុងអាហារដ្ឋាន នោះ ប៉ូវ៉ាន និយាយថា គាត់សម្រេចចិត្តពន្យល់អ្នកគ្រប់គ្រងរោងចក្ររបស់គាត់ថា គាត់មិនសប្បាយចិត្តនឹងម៉ោងបន្ថែមប៉ុន្មានម៉ោងដែលគាត់ផ្តល់ឱ្យគាត់ទេ។ គាត់មិនអាចផ្ញើប្រាក់ទៅផ្ទះបានច្រើនតាមដែលគាត់ចង់បាន ហើយកំពុងស្វែងរកជម្រើសផ្សេងទៀត។ វាជាការលំបាកក្នុងការប្រាប់ប្រពន្ធរបស់គាត់អំពីស្ថានភាពនេះ ព្រោះពួកគេពិតជារំពឹងថានឹងមានប្រាក់ច្រើនជាងនេះផ្ញើមកផ្ទះ ប៉ុន្តែប្រពន្ធរបស់គាត់ បានយល់អំពីបញ្ហានេះ។

ចំពោះសាយ គាត់បានប្រាប់ប៉ូវ៉ានគាត់ថាគ្រួសាររបស់គាត់ក៏កំពុងប្រឈមមុខនឹងបញ្ហាធំនៅផ្ទះផងដែរព្រោះពួកគេប្រឈមនឹងការចំណាយដែលមិននឹកស្មានដល់។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនបានប្រាប់ពួកគេអំពីអំពីការងារម៉ោងបន្ថែម ហើយគាត់បានសម្រេចចិត្តខ្ចីប្រាក់ពីមនុស្សម្នាក់នៅរោងចក្រ ដើម្បីអាចផ្ញើប្រាក់បន្ថែមទៀតដល់ផ្ទះ។ គាត់បានពន្យល់ថាគាត់ត្រូវតែកាត់បន្ថយការចំណាយផ្ទាល់ខ្លួនរបស់គាត់ឱ្យតិចបំផុតដើម្បីអាចសងបំណុលថ្មីនេះ។

សូម្បីតែបន្ទាប់ពីកាត់បន្ថយការចំណាយផ្ទាល់ខ្លួនទាំងអស់របស់គាត់ក៏ដោយ ជួនកាលគាត់ប្រឈមនឹងបញ្ហាដើម្បីសងប្រាក់កម្ចីតូចមួយនេះ។ ស្ថានភាពនេះធ្វើឲ្យគាត់រងសម្ពាធធ្ងន់ ហើយគាត់កំពុងរកដំណោះស្រាយ។

កន្លែងកត់ត្រា



៥. សម្រេចចិត្តថាតើការធ្វើចំណាកស្រុកគឺជាជម្រើសដ៏ត្រឹមត្រូវសម្រាប់អ្នកដែរឬទេ

ករណីសិក្សាទី៤

ទស្សនៈរបស់ម្តាយ សុភាពអំពីការចំណាកស្រុករបស់កូនស្រីគាត់

ខ្ញុំជាម្តាយរបស់សុភាព។ នាងជាកូនស្រីច្បងរបស់ខ្ញុំ។ ពេលនាងចំណាកស្រុកទៅធ្វើការនៅរោងចក្រប្រហែល ២ ឆ្នាំមុន ខ្ញុំសប្បាយចិត្តណាស់ដែលនាងទទួលបានឱកាសដូចស្ត្រីផ្សេងទៀតក្នុងភូមិ។ ទោះជាយ៉ាងណា ខ្ញុំសោកស្តាយដែលកូនស្រីរបស់ខ្ញុំទៅរស់នៅឆ្ងាយពីផ្ទះ និងកូន។ ទោះបីជានាងផ្ញើប្រាក់មកយើងរាល់ខែសម្រាប់ការចំណាយ និងការថែទាំសុខភាពរបស់យើងក៏ដោយ ហើយនេះមានប្រយោជន៍ខ្លាំងណាស់ក្នុងការធានាថាយើងតែងតែមានអាហារបរិភោគនៅលើតុរបស់យើង។ ប្រាក់ដែលកូនផ្ញើមក ក៏បានជួយយើងក្នុងការទិញសម្ភារៈដើម្បីបញ្ចប់ការសាងសង់ផ្ទះរបស់យើងនៅទីនេះ។ ទាក់ទងនឹងហិរញ្ញវត្ថុរបស់យើង ការសម្រេចចិត្តរបស់ សុភាព ក្នុងការធ្វើចំណាកស្រុក គឺជាការសម្រេចចិត្តដ៏ល្អ។

តាំងពីកូនស្រីខ្ញុំចាកចេញទៅ ខ្ញុំមិនសូវមានអ្នកជួយនៅផ្ទះធ្វើកិច្ចការទាំងអស់ បូករួមទាំងការងារច្រើនជាមួយកូនៗរបស់នាងដោយសារ សុធា ដែលជាកូនប្រសាររបស់ខ្ញុំ ពេលខ្លះត្រូវធ្វើការច្រើនម៉ោង។ វត្តមានរបស់នាងក៏បានផ្តល់ការសម្រាលទុក្ខដល់យើងទាំងអស់គ្នាផងដែរ នៅពេលដែលយើងត្រូវការធ្វើការសម្រេចចិត្តខ្លះៗក្នុងគ្រួសារ។ ខ្ញុំនឹកនាងខ្លាំងណាស់។

ខ្ញុំសប្បាយចិត្តដែលនាងកំពុងធ្វើការនៅទីនោះ ហើយថានាងអាចមានបទពិសោធន៍នេះ ដែលស្ត្រីជាច្រើននៅទីនេះបន្ត។ យ៉ាងណាមិញ ខ្ញុំពិតជាចង់ឲ្យនាងនៅទីនេះជាមួយស្វាមី និងកូនរបស់នាង និងមានចៅ។

⚠ **ចំណុចត្រូវយកចិត្តទុកដាក់ ៖** មនុស្សច្រើនតែគិតអំពីអត្ថប្រយោជន៍នៃការធ្វើចំណាកស្រុកតែប៉ុណ្ណោះ។ ប៉ុន្តែការធ្វើចំណាកស្រុកក៏មានគុណវិបត្តិមួយចំនួនផងដែរ។

គុណសម្បត្តិ និងគុណវិបត្តិនៃការចំណាកស្រុក

(ទស្សនៈរបស់អ្នកចំណាកស្រុក)

គុណសម្បត្តិ	គុណវិបត្តិ
• រកលុយបានច្រើន។ • អាចផ្តល់ផ្តង់គ្រួសារសម្រាប់ចំណាយទូទៅ៖ អាហារ ការថែទាំសុខភាព ការអប់រំ ភ្លើង... • រៀនជំនាញថ្មីៗ • ធ្វើការងារថ្មី និងទទួលបានបទពិសោធន៍ ជីវិត • មានអារម្មណ៍សេរីភាព និងឯករាជ្យ • សន្សំប្រាក់សម្រាប់អនាគត។	• ការធ្វើចំណាកស្រុក អាចឲ្យជាប់កិច្ចសន្យាបំណុលដែលនឹងពិបាកក្នុងការសងវិញ។ • ការស្វែងរកការងារនៅក្នុងទីក្រុងមួយផ្សេងទៀតអាចត្រូវការពេលវេលា • ការចំនាយខ្ពស់ក្នុងការរស់នៅតាមទីកន្លែងគោលដៅផ្សេងៗ • ភាពឯកា និងភាពឯកោ។ • ការមាក់ងាយសង្គមនៅពេលអ្នកត្រលប់មក វិញ

សារសំខាន់

- យើងសម្រេចចិត្តធ្វើចំណាកស្រុកដោយហេតុផលជាច្រើន៖ រកលុយបានច្រើន បទពិសោធន៍ផ្សេងៗ សិក្សា ទទួលបានជំនាញថ្មី ចាកចេញពីជម្លោះនៅក្នុងតំបន់របស់យើង។
- អ្នកត្រូវយល់ពីអត្ថប្រយោជន៍នៃការធ្វើចំណាកស្រុក នោះគឺជាអ្វីដែលអ្នកអាចសម្រេចបាន។ អ្នកក៏ត្រូវវិភាគគុណវិបត្តិ ឬការចំណាយផងដែរ នោះគឺអ្វីដែលអ្នក និងគ្រួសាររបស់អ្នកអាចបាត់បង់ដោយសារតែការចំណាកស្រុក។
- គុណសម្បត្តិ និងគុណវិបត្តិទាំងនេះនៃការធ្វើចំណាកស្រុក អាចត្រូវបានផ្សារភ្ជាប់ទៅនឹងប្រាក់ ប៉ុន្តែក៏ទាក់ទងទៅនឹងទំនាក់ទំនងសង្គម និងគ្រួសារផងដែរ។
- ព័ត៌មានមិនពិតជាច្រើនកំពុងផ្សព្វផ្សាយទាក់ទងនឹងការចំណាកស្រុក៖ មិនដូចអ្វីដែលគេនិយាយជាទូទៅឡើយ លុយមិនតែងតែអាចរកបាននៅគ្រប់ទីកន្លែងឡើយ ទោះជានៅក្នុងភូមិ ឬនៅទីក្រុងធំឡើយ!

៦. គណនាការចំណាយហិរញ្ញវត្ថុលើការចំណាកស្រុក

ការចំណាកស្រុក ត្រូវចំណាយច្រើន ប៉ុន្តែតើអ្នកដឹងទេថា ការចំណាកស្រុក ត្រូវចំណាយប៉ុន្មាន? តើអ្នកអាចបែងចែករវាងការចំណាយផ្សេងៗបានទេ?



ជំនួយការបណ្តុះបណ្តាល ក.៣.១

ការវិភាគលម្អិតនៃការចំណាយហិរញ្ញវត្ថុលើការចំណាកស្រុក



ខ្ញុំកំពុងគិតអំពីការធ្វើការចំណាកស្រុក៖ .....

.....

.....

ទីកន្លែងគោលដៅ៖ .....

	តើត្រូវចំណាយអ្វីខ្លះ?	តើខ្ញុំទូទាត់ក្នុងការចំណាយដោយវិធីណា?
ការចំណាយសម្រាប់ការរៀបចំ		
ការចំណាយសម្រាប់ការធ្វើដំណើរ		
ការចំណាយក្នុងទីក្រុង ឬប្រទេសដែលត្រូវទៅ		
ការចំណាយសម្រាប់ការត្រលប់មកវិញ		
ការចំណាយលើគ្រួសារនៅផ្ទះ		
ការចំណាយសរុបសម្រាប់ការចំណាកស្រុក		

ការចំណាយទាក់ទងនឹងផ្លូវចិត្ត

ការចំណាយខ្លះ មិនជាប់ទាក់ទងជាមួយនឹងលុយទេ ប៉ុន្តែជាប់ទាក់ទងច្រើនទៅនឹងផ្លូវចិត្តនិងអារម្មណ៍របស់យើង។ ការចំណាយផ្លូវចិត្តមួយចំនួនដែលជាប់ទាក់ទងទៅនឹងការធ្វើចំណាកស្រុកដែលត្រូវយកមកពិចារណាគឺ៖

- ចំណងគ្រួសារ អាចនឹងត្រូវខូចខាត
- គ្រួសារអាចមានការភ័យខ្លាច ឬខ្មាស់អៀនដែលសាច់ញាតិរស់នៅក្រៅស្រុក ដែលមិនស្របតាមគុណតម្លៃប្រពៃណី
- ជនចំណាកស្រុកអាចជួបប្រទះភាពឯកោ និងឯកោ

⚠ **ចំណុចសំខាន់ៗ** វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការថ្លឹងថ្លែងការចំណាយ និងអត្ថប្រយោជន៍សម្រាប់ខ្លួនអ្នក និងក្រុមគ្រួសាររបស់អ្នក មុនពេលសម្រេចចិត្តធ្វើចំណាកស្រុក។

សារសំខាន់

• តារាងនេះគឺជាឧបករណ៍សំខាន់មួយ ដែលអ្នក និងគ្រួសាររបស់អ្នកអាចប្រើដើម្បីស្វែងយល់ថាតើវានឹងត្រូវចំណាយប៉ុន្មានក្នុងការធ្វើចំណាកស្រុក។

• ប្រសិនបើអ្នកដឹងពីការចំណាយនោះ អ្នកមានស្ថានភាពល្អប្រសើរ ដើម្បីវាយតម្លៃថាតើគុណសម្បត្តិនៃការធ្វើចំណាកស្រុកមានលើសពីគុណវិបត្តិដែរឬទេ ហើយថាតើវាមានប្រយោជន៍សម្រាប់សមាជិកគ្រួសារក្នុងការទៅធ្វើការនៅកន្លែងផ្សេងទៀតដែរឬទេ (ឬសម្រាប់ជនចំណាកស្រុកនៅក្នុងប្រទេស ដើម្បីត្រលប់មកផ្ទះវិញ)

• សូមចងចាំថាវាពិបាកក្នុងការដឹងច្បាស់ថាតើវានឹងត្រូវចំណាយអស់ប៉ុន្មានសម្រាប់ពលករដើម្បីធ្វើចំណាកស្រុក។ ដើម្បីធ្វើឲ្យការវាយតម្លៃត្រឹមត្រូវតាមដែលអាចធ្វើបាន និងសម្រាប់ថតភាពពិតនៃលទ្ធភាព និងគុណវិបត្តិនៃការទៅរស់នៅ និងធ្វើការនៅកន្លែងផ្សេង ក្រុមគ្រួសារអាចស្វែងរកព័ត៌មានពីប្រភពផ្សេងៗដូចជា៖ ទីភ្នាក់ងារសាធារណៈ សហជីព អង្គការក្រៅរដ្ឋាភិបាល និងជនចំណាកស្រុកដែលត្រឡប់មកវិញ។

• ចូរកុំស្តាប់អ្វីគ្រប់យ៉ាងដែលគេនិយាយអំពីការធ្វើចំណាកស្រុក។ មានរឿងរ៉ាវជាច្រើន ហើយពេលខ្លះ គេមិនប្រាប់ការពិតទាំងស្រុងទេ ដោយសារពួកគេចង់ការពារខ្លួនគេ។ ខុសពីពាក្យចចាមអារ៉ាម ផ្លូវមិនក្រាលដោយមាសទេ មិនថានៅស្រុក ឬនៅក្នុងទីក្រុងធំ!



២

គ្រប់គ្រងប្រាក់ចំណូលរបស់អ្នកដោយឆ្លាតវៃ

២១. ដល់ចុងខែហើយ ខ្ញុំនៅតែទទួលបានប្រាក់ខែ៖
- ☐ **ក.** ខ្ញុំប្រញាប់ទៅផ្សារដើម្បីទិញអាវដ៏ស្អាតនេះដែលខ្ញុំបានឃើញកាលពីថ្ងៃមុន។
- ☐ **ខ.** ខ្ញុំបានទុកមួយចំណែកនៃប្រាក់ខែរបស់ខ្ញុំ ដើម្បីសម្រេចគោលដៅរបស់ខ្ញុំ។
- ☐ **គ.** ខ្ញុំទិញកាដូធំមួយសម្រាប់ថ្ងៃខួបកំណើតមិត្តល្អរបស់ខ្ញុំ។

២២. ថវិកាគឺជា៖
- ☐ **ក.** ឧបករណ៍ដើម្បីធ្វើការសម្រេចចិត្ត រៀបចំផែនការ និងប្រើប្រាស់លុយរបស់អ្នកដើម្បីសម្រេចបាននូវគោលដៅរបស់អ្នក។
- ☐ **ខ.** សន្លឹកសម្រាប់កត់ត្រាការចំណាយ។
- ☐ **គ.** តារាងមួយ។

២៣. តើកិច្ចសន្យាការងារជាអ្វី?
- ☐ **ក.** កំណត់ត្រាដែលផ្តល់ឲ្យនិយោជិតដែលរៀបរាប់លម្អិតអំពីចំនួនទឹកប្រាក់ដែលពួកគាត់នឹងទទួលបាន និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត។
- ☐ **ខ.** កិច្ចព្រមព្រៀងផ្លូវច្បាប់រវាងនិយោជក និងការងារដែលបញ្ជាក់ពីភារកិច្ច ទំនួលខុសត្រូវ និងអត្ថប្រយោជន៍សម្រាប់ភាគីទាំងពីរ។
- ☐ **គ.** លិខិតក្រៅផ្លូវការដែលនិយោជិតទទួលបានមុនពេលចាប់ផ្តើមការងារឬបញ្ជាក់ពីលក្ខខណ្ឌនៃការងារ របស់គាត់។

២៤. តើផ្នែកសំខាន់បីនៃថវិកាមានអ្វីខ្លះ?
- ☐ **ក.** កាលបរិច្ឆេទ ចំណូល និងចំណាយ។
- ☐ **ខ.** ប្រាក់ចំណូល ការចំណាយ និងការសន្សំ។
- ☐ **គ.** ការចំណាយ ចំណូល និងហត្ថលេខា។

២៥. តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីតាមដានថវិការបស់ខ្ញុំ?
- ☐ **ក.** ខ្ញុំមានកាតព្វកិច្ចច្រើនណាស់ ដូច្នេះមិនអាចតាមដានថវិការបស់ខ្ញុំបានទេ។
- ☐ **ខ.** ខ្ញុំមិនរៀបចំធ្វើថវិការទេ ព្រោះខ្ញុំជឿជាក់លើព្រេងវាសនា។
- ☐ **គ.** ខ្ញុំប្រើតារាងតាមដាន ដើម្បីកត់ត្រាការចំណាយ និងចំណូលរបស់ខ្ញុំ។

២៦. តើមួយណាក្នុងចំណោមចំណុចខាងក្រោមនេះ ដែលមិនមែនជាអត្ថប្រយោជន៍នៃការទទួលបានប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល?
- ☐ **ក.** វាមានសុវត្ថិភាពជាង ព្រោះវាកាត់បន្ថយហានិភ័យនៃការបាត់បង់លុយ។
- ☐ **ខ.** វាលឿនជាងព្រោះអ្នកមិនចាំបាច់តម្រង់ជួរដើម្បីទទួលបានប្រាក់ឈ្នួលរបស់អ្នក។
- ☐ **គ.** ដោយសារមិនសូវមានម៉ាស៊ីនដកប្រាក់ ATM វាកាន់តែងាយស្រួលក្នុងការសន្សំប្រាក់។

១. ធ្វើជាអ្នកចំណាយដ៏ឆ្លាតវៃ!

សំណួរ


- តើអ្នកជាមនុស្សដែលចូលចិត្តចំណាយ ឬជាមនុស្សចូលចិត្តការសន្សំ?
- ជាឧទាហរណ៍ តើអ្នកងាយនឹងបោះបង់ការទិញនូវទំនិញដែលគ្រាន់តែជាការចង់បាន?

និយមន័យ

យោងទៅតាមស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក ជ្រើសរើសរវាងការចំណាយចាំបាច់ (យើងហៅថាតម្រូវការ) និងការចំណាយមិនចាំបាច់ (យើងហៅពួកគេថាការចង់បាន)! គូសរង្វង់រូបភាពដែលជាតម្រូវការរបស់អ្នក ហើយកត់សម្គាល់របស់ដែលអ្នកចង់បាន។


លំហាត់

ការសន្សំមានន័យថាមិនចំណាយប្រាក់របស់អ្នកទាំងអស់ ហើយទុកផ្នែកមួយសម្រាប់គោលដៅជាក់លាក់មួយនាពេលអនាគត។ វាមានន័យថាការទុកប្រាក់តិចឬច្រើនជាប្រចាំ ឬពីពេលមួយទៅពេលមួយ។




ជំនួយការបណ្តុះបណ្តាល ខ.ម.ប.១

រូបភាពៈ របស់ដែលចង់បាន និងរបស់ដែលត្រូវការ






ឆ្នោត



ម៉ូតូ




ចានបាយ




សងបំណុល



ការដកប្រាក់



អាចាតមិន



សាលារៀន



ទូរស័ព្ទ ស្មាតហ្វូន



ទឹក



ស៊ីមភាត



ជួបពេទ្យ



អគ្គិសនី




តេសដ្ឋ:



សំបុត្រកុន



ការ៉ែម




ស្បែកជើងថ្លៃ



ចារី



ទូរទស្សន៍ កញ្ចក់ស្តើង



ម៉ាស៊ីន ថតរូប



ប្រព័ន្ធ សំឡេង



ការគុប តែងមុខ

ខ្ញុំចង់ទិញ...

អ្វីដែលខ្ញុំត្រូវការ	តើវាមានតម្លៃប៉ុន្មាន?
ចំណាយសរុបសម្រាប់តម្រូវការ	
អ្វីដែលខ្ញុំចង់បាន	**តើវាមានតម្លៃប៉ុន្មាន?**
ចំណាយសរុបសម្រាប់ការចង់បាន	

សូមយកចិត្តទុកដាក់!

ត្រូវប្រុងប្រយ័ត្ន! ពេលខ្លះ អ្វីមួយអាចជាតម្រូវការសម្រាប់នរណាម្នាក់ និងការចង់បានសម្រាប់នរណាម្នាក់ផ្សេងទៀត។ ឧទាហរណ៍ ទូរសព្ទដៃ មនុស្សម្នាក់អាចត្រូវការវាសម្រាប់អាជីវកម្ម ខណៈពេលដែលអ្នកផ្សេងទៀតអាចប្រើវាដើម្បីហៅទៅកាន់មិត្តភក្តិ និងក្រុមគ្រួសាររបស់គាត់ប៉ុណ្ណោះ។

តើខ្ញុំមានលុយគ្រប់គ្រាន់ដើម្បីទិញរបស់ទាំងអស់ដែលខ្ញុំរាយបញ្ជីដែរឬទេ?

☐ បាទ/ចាស ☐ អត់ទេ

បើខ្ញុំមិនមានលុយគ្រប់គ្រាន់ ខ្ញុំសម្រេចចិត្តបោះបង់ការចង់បានដូចខាងក្រោម៖

កន្លែងកត់ត្រា


ចំណុចសំខាន់ៈ អ្នកអាចចំណាយដើម្បីធ្វើឲ្យខ្លួនអ្នកមានអារម្មណ៍ល្អប្រសើរជាងមុន។ មនុស្សមួយចំនួនពណ៌នាថា អារម្មណ៍ល្អនេះហាក់ដូចជាមានលក្ខណៈបណ្តោះអាសន្ន និងមានរយៈពេលខ្លីប៉ុណ្ណោះ។ ត្រូវប្រុងប្រយ័ត្ន! ប្រសិនបើថវិការបស់អ្នកមានភាពតឹងតែង សូមចំណាយពេលបន្តិច ដើម្បីបែងចែករវាង តម្រូវការ និងការចង់បាន។ បើមិនដូច្នោះទេ ការមិនមានប្រាក់គ្រប់គ្រាន់សម្រាប់តម្រូវការរបស់អ្នកនៅពេលក្រោយ អាចបង្កើតជាភាពតានតឹងសម្រាប់អ្នក។

អានសាច់រឿងរបស់តួអង្គទាំងនេះ ហើយឆ្លុះបញ្ចាំងអំពីអ្វីដែលកំពុងកើតឡើងចំពោះពួកគេ។ តើពួកគេអាចធ្វើអ្វីប្រសើរជាងនេះ?

ករណីសិក្សាទី១

គ្រួសាររបស់ប៉ូរ៉ាន ប្រឈមមុខនឹងគ្រោះអាសន្នផ្ទះ

ប៉ូរ៉ាន ធ្វើការយ៉ាងលំបាកជាកម្មករផ្នែកឃ្លាំងក្នុងរោងចក្រ។ ភរិយារបស់លោក ឈ្មោះចិន្តា ធ្វើការជាគ្រូបង្រៀននៅភូមិមួយក្នុងខេត្តព្រៃវែង។ ពួកគេមានកូន ២ នាក់ ហើយ ប៉ូរ៉ាន កំពុងព្យាយាមទៅលេងពួកគេនៅរដូវក្តៅ។ ពួកគេសន្សំសំចៃខ្លាំងណាស់ ប៉ុន្តែមានប្រាក់ចំណូលតិចតួច ខណៈដែលពួកគេនៅតែសងបំណុលចាស់មួយចំនួន។ កាលពីសប្តាហ៍មុន ចិន្តាចាប់ផ្តើមមិនស្រួលខ្លួន ហើយកូនៗ ក៏មិនស្រួលខ្លួនដែរ។ ពួកគេអាចទទួលបានឱសថពីមន្ទីរពេទ្យនៅស្រុក ប៉ុន្តែដោយសារតែពួកគេព្រួយបារម្ភ និងត្រូវការជាបន្ទាន់ នាងបាននិយាយជាមួយប៉ូរ៉ានតាមទូរស័ព្ទ ហើយពួកគេក៏សម្រេចចិត្តទៅឱសថស្ថានក្បែរនោះ ហើយបង់ប្រាក់ដើម្បីឆាប់បានឱសថ។ ដោយសារដល់ចុងខែហើយពួកគាត់ខ្វះលុយ ទើបត្រូវខ្ចីលុយអ្នកជិតខាង។



ប៉ូរ៉ាននឹងផ្ញើប្រាក់នៅសប្តាហ៍ក្រោយ។ អ្នកជិតខាងបានឲ្យចិន្តាខ្ចី៥ដុល្លារ ហើយនាងក៏ព្រមសងគាត់វិញ ៦ដុល្លារ ពេលទទួលប្រាក់ផ្ញើពីប៉ូរ៉ាន។ នាងបានប្រើលុយទិញឱសថពីឱសថស្ថាន។ ពួកគេទាំងអស់បានជាសះស្បើយយ៉ាងឆាប់រហ័ស បន្ទាប់ពីបានប្រើប្រាស់ឱសថនោះ។

ករណីសិក្សាទី២

បុប្ផា ដែលជាមិត្តរបស់ណារី មានបញ្ហា

ណារីមានទំនាក់ទំនងជិតស្និទ្ធជាមួយបុប្ផាដែលជាអ្នកជិតខាង។ នាងមានហាងកែសម្ផស្សតូចមួយនៅតាមផ្លូវដែលមានភាពមមាញឹកនៅជិតផ្ទះរបស់នាង។ ហាងបុប្ផាទទួលបានជោគជ័យគួរឲ្យកត់សម្គាល់។ នាងបានរៀនអំពីការមានវិន័យលើការចាយវាយ ហើយនៅពេលនេះ បានចំណេញខ្លះហើយ។ ដោយសារនាងមិនយល់ដឹងអំពីស្ថាប័នហិរញ្ញវត្ថុ នាងបានផ្តល់ប្រាក់ចំនួលមួយផ្នែកទៅឲ្យប្តីឈ្មោះ ឧត្តម ជាប្រចាំ ដើម្បីឲ្យគាត់ដាក់ប្រាក់នៅក្នុងគណនីធនាគារ។ ថ្ងៃមួយនាងត្រឡប់មកផ្ទះវិញ គិតចង់សុំលុយពី ឧត្តម ពីគណនីជំនួញ ព្រោះនាងចង់ទិញឧបករណ៍ថ្មីសម្រាប់ហាងរបស់នាង។ ពេលទៅដល់ទើបដឹងថា ប្តីបានទិញម៉ូតូថ្មី ។

ពេលនាងសុំលុយសម្រាប់ហាង ឧត្តមនិយាយថាឥឡូវមិនអាចយកលុយទៅហាងកែសម្ផស្សបានទេ។ បុប្ផាខឹងក៏ទៅធនាគារពិនិត្យគណនី ដើម្បីដកប្រាក់សន្សំ។ ប៉ុន្តែពេលនាងទៅដល់ នាងបានដឹងថាគណនីនោះគឺជាឈ្មោះប្តីនាង ហើយនាងមិនអាចប្រាក់ចំនួនតិចតួចដែលនៅសល់ក្នុងគណនីនោះបានទេ។ នាងកើតទុក្ខយ៉ាងខ្លាំង។



គន្លឹះនៃការសន្សំប្រាក់

- ទុកលុយបន្តិចបន្តួចជារៀងរាល់ថ្ងៃ ឬរៀងរាល់សប្តាហ៍។
- កុំទិញរបស់ថ្មី ប្រសិនបើរបស់របស់អ្នកនៅតែប្រើបាន ឬអាចជួសជុលបាន។
- ទិញអំណោយតិចតួចសម្រាប់គ្រួសាររបស់អ្នក។ និយាយជាមួយពួកគេជាមុនសិន មុននឹងយល់ព្រមជួយដល់ពួកគេ។
- បើអាចធ្វើបាន ចំណាយតិចលើពិធីបុណ្យវប្បធម៌ ឬសង្គម។
- រក្សាសាច់ប្រាក់តិចនៅក្នុងកាបូបរបស់អ្នក (ហើយទុកវានៅកន្លែងដែលមានសុវត្ថិភាព៖ នៅផ្ទះ នៅក្នុងគណនីធនាគារ...)
- ប្រសិនបើអ្នកផ្ញើប្រាក់ទៅឪពុកម្តាយរបស់អ្នក ឬសមាជិកគ្រួសារផ្សេងទៀត សូមកុំផ្ញើប្រាក់ទាំងអស់របស់អ្នកទៅឲ្យពួកគេ ហើយរក្សាទុកមួយផ្នែកសម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់អ្នក និងសម្រាប់ពេល មានគ្រាអាសន្ន។
- ចងចាំជានិច្ចនូវគោលដៅរយៈពេលវែងរបស់អ្នក ដើម្បីរំលឹកអ្នកពីមូលហេតុដែលអ្នកត្រូវសន្សំប្រាក់!

សារសំខាន់

- អ្នកត្រូវចេះបែងចែករវាងការចំណាយចាំបាច់ និងការចំណាយមិនចាំបាច់។
- សន្សំសម្រាប់ពេលមានអាសន្ន៖ ការសន្សំគឺមានភាពចាំបាច់ ជាតម្រូវការដាច់ខាត។
- "គ្រប់គ្រងឲ្យបានល្អនូវអ្វីដែលអ្នកដទៃរកបាន"
- ការសន្សំមានន័យថាបោះបង់អ្វីដែលអ្នកចង់បានភ្លាមៗ ដើម្បីវិនិយោគ និងសម្រេចបាននូវគោលដៅនាពេលអនាគត។
- ការសន្សំធ្វើឲ្យមានសុវត្ថិភាព។


កន្លែងកត់ត្រា

២. ស្វែងយល់អំពីកិច្ចសន្យាការងាររបស់អ្នក និងលិខិតបញ្ជាក់ប្រាក់ខែរបស់អ្នក

ការយល់ដឹងអំពីកិច្ចសន្យាការងាររបស់អ្នកមានសារៈសំខាន់ណាស់។ ប្រសិនបើអ្នកយល់វា វាអាចការពារអ្នកបាន។ ប៉ុន្តែប្រសិនបើអ្នកចុះហត្ថលេខាលើកិច្ចសន្យាដោយមិនអានវា ឬដឹងថាវាមានន័យយ៉ាងណា អ្នកអាចបញ្ចប់ក្នុងស្ថានភាពមិនល្អ។

និយមន័យ

កិច្ចសន្យាការងារ៖ កិច្ចព្រមព្រៀង (ផ្លូវច្បាប់) រវាងនិយោជក និងកម្មការនិយោជិត ដែលបញ្ជាក់ពីភារកិច្ច និងការទទួលខុសត្រូវ និងអត្ថប្រយោជន៍សម្រាប់ភាគីទាំងពីរ។




ករណីសិក្សាទី ៣

រឿង ចាន់ណា ដែលជាមិត្តរបស់សុភាព

ចាន់ណា ជាមិត្តភ័ក្តិរបស់សុភាព រស់នៅក្នុងភូមិ ហើយទើបតែទទួលបានការបញ្ជាក់ថា នាងទទួលបានការងារពីរោងចក្រកាត់ដេរដូចគ្នា ដែលជាកន្លែងធ្វើការរបស់សុភាព។ នាង សប្បាយចិត្តព្រោះមាន មនុស្សជាច្រើនបានដាក់ពាក្យ រកការងារ។ ចាន់ណា ពិតជាមិនបានអានកិច្ចសន្យាទេ ព្រោះអក្សរតូចណាស់ ហើយនាងក៏មិនមានវ៉ែនតាដែរ។ យ៉ាងណាក៏ដោយ នាងក៏ពេញចិត្តដែរ ដោយនាងត្រូវបានគេប្រាប់ថា នាងនឹងទទួលបានប្រាក់ខែដូចស្ត្រីឯទៀតមកពីភូមិរបស់នាងដែលធ្វើការនៅរោងចក្រ។

ប៉ុន្មានខែក្រោយមក នាងបានធ្វើដំណើរទៅទីក្រុងរោងចក្រ។ នាងចាប់ផ្តើមធ្វើការ ប៉ុន្តែនាងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលបានទទួលត្រឹមតែពាក់កណ្តាលនៃប្រាក់ខែគោលរបស់នាងបន្ទាប់ពី ១៥ ថ្ងៃតាមប្រតិទិន។ នាងគិតថានាងនឹងទទួលបានប្រាក់ខែពាក់កណ្តាលនៃប្រាក់ឈ្នួលទាំងអស់របស់នាង រួមទាំងប្រាក់បន្ថែមម៉ោងដែលនាងបានធ្វើក្នុងអំឡុងពេលថ្ងៃដំបូង និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត។ នាងសួរសុភាព ដែលពន្យល់នាងថានាងកំពុងទទួលនោះគឺជាប្រាក់បំណាច់មុន និងចំណាយតែពាក់កណ្តាលនៃប្រាក់ខែគោលប៉ុណ្ណោះ។ នាងពន្យល់នាងថា ជាផ្លូវការ ប្រាក់បៀវត្សរ៍របស់នាងក្នុងខែដំបូងគឺត្រូវបង់នៅថ្ងៃដំបូងនៃខែបន្ទាប់ ប៉ុន្តែរោងចក្រផ្តល់ឲ្យនាងជាមុននូវពាក់កណ្តាលនៃប្រាក់ខែគោលរបស់នាង។

ចាន់ណាភ្ញាក់ផ្អើលយ៉ាងខ្លាំង។ នាងមិនដឹងរឿងនេះទេ។ នាងព្រួយបារម្ភព្រោះគ្រួសាររបស់នាងត្រូវការប្រាក់ជាបន្ទាន់ត្រឡប់ទៅផ្ទះវិញ ប៉ុន្តែពួកគេនឹងត្រូវរង់ចាំមួយថ្ងៃទៀត រហូតដល់នាងទទួលបានប្រាក់ខែពាក់កណ្តាលទៀត បូករួមទាំងប្រាក់បន្ថែមម៉ោង និងប្រាក់ឧបត្ថម្ភ។



Case Study

ករណីសិក្សាទី៤

រឿងវ៉ាតរបស់ប៊ូវ៉ាន

ប៊ូវ៉ាន ហៀបនឹងចាប់ផ្តើមការងារនៅឃ្លាំងនៃរោងចក្រមួយ។ គាត់ដឹងថាមុខតំណែងនេះ អាចមាន ហានិភ័យមួយចំនួន នៅពេលនិយាយអំពីគ្រោះថ្នាក់ ដោយសារពួកគេតែងតែធ្វើការជាមួយឧបករណ៍កាត់ និងកញ្ចប់ធ្ងន់។ ក្នុងវគ្គបណ្តុះបណ្តាលដើម្បីចូលធ្វើការ ប៊ូវ៉ាន បានសួរសំណួរជាច្រើនដល់តំណាង រោងចក្រ ជាពិសេសទាក់ទងនឹងកន្លែងថែទាំសុខភាពក្នុងរោងចក្រ ពេលវេលាបើកដំណើរការ ហើយប្រសិនបើមានគ្រោះថ្នាក់ធ្ងន់ធ្ងរ កម្មករមានសិទ្ធិទៅពិនិត្យនៅគ្លីនិកឯកទេសដែរឬទេ។

តំណាងរោងចក្របានផ្តល់ការធានាដល់គាត់ថា ការងារទាំងអស់នេះ ត្រូវរ៉ាប់រងដោយនិយោជក ដូចមានចែងក្នុងច្បាប់ការងារ។ ពួកគេបានពន្យល់គាត់យ៉ាងខ្លីថា រាល់ការរ៉ាប់រងទាំងអស់បានផ្តល់នូវការធានារ៉ាប់រងរបស់រដ្ឋ។ ពួកគេក៏បានពន្យល់គាត់ថា ក្នុងករណីមានរបួស ឬគ្រោះថ្នាក់ដែលត្រូវការពេលសម្រាក កម្មករមានសិទ្ធិឈប់សម្រាកឈឺ។ ប៊ូវ៉ាន រីករាយដែលឃើញអ្វីៗទាំងអស់នេះ ត្រូវបានសរសេរនៅលើកិច្ចសន្យាការងាររបស់គាត់ផងដែរ។

ជំនួយការបណ្តុះបណ្តាល ខ.២.១
ឧទាហរណ៍នៃកិច្ចសន្យាការងារល្អ

តំបន់ពាណិជ្ជកម្មពិសេសភ្នំពេញ

រូបថត ៤ គុណ ៦
Photo 4x6

កិច្ចសន្យាអំពីរយៈពេលការងារ

គាតីទី១

និយោជក៖ .....

តំណាងដោយលោក/លោកស្រី៖ .....

អាសយដ្ឋាន៖ .....

លេខទូរស័ព្ទ៖ .....

គាតីទី២

គោត្តនាម៖ .....

កេទ៖ .....

ថ្ងៃខែកំណើត ៖ .....

លេខអត្តសញ្ញាណប័ណ្ណ៖ .....

អាសយដ្ឋាន៖ .....

លេខទូរស័ព្ទ៖ .....

ចាត់យល់ព្រមដូចខាងក្រោម៖

មាត្រា ១៖

ក្រុមហ៊ុនមិនបង់ប្រាក់សម្រាប់ពាក្យសុំធ្វើការងារនេះទេ។

មាត្រា ២៖

ក្រុមហ៊ុនទទួលយកបុគ្គលិករយៈពេល៣ខែ ចាប់ពីថ្ងៃ .....,

ក្នុងផ្នែក៖....., មុខតំណែង៖.....

មុខតំណែងអាចផ្លាស់ប្តូរបានតាមតម្រូវការរបស់ក្រុមហ៊ុន

មាត្រា ៣៖

ប្រាក់បៀវត្សមូលដ្ឋាន ត្រូវបានយល់ព្រមចំនួន ..... ដុល្លាអាមេរិក ក្នុងមួយខែ។ រាល់ការគណនាប្រាក់បៀវត្សត្រូវផ្អែកលើច្បាប់ការងារ ដែលភ្ជាប់មកជាមួយកិច្ចសន្យានេះ។

មាត្រា ៤៖

កាតព្វកិច្ចពន្ធលើប្រាក់បៀវត្ស និងវិភាគទានផ្សេងទៀត គឺជាការទទួលខុសត្រូវរបស់ និយោជិត។ ការរួមចំណែកដល់បេឡាជាតិរបបសន្តិសុខសង្គមនឹងត្រូវធ្វើឡើងតាមច្បាប់ការងារ។

មាត្រា ៥៖

និយោជិត ត្រូវអនុវត្តការកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនស្របតាមលក្ខណៈនៃការងាររបស់ខ្លួន និងស្ថិតក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់និយោជក ឬតំណាងរបស់និយោជក។

មាត្រា ៦៖

ម៉ោងធ្វើការរបស់និយោជិតមានដូចខាងក្រោម៖
ពេលព្រឹកចាប់ពីម៉ោង ៧.០០ ដល់ ១២.០០ ថ្ងៃត្រង់
សម្រាកអាហារថ្ងៃត្រង់ចាប់ពីម៉ោង ១២.០១ ដល់ ០១.០០ ថ្ងៃ
ពេលរសៀលចាប់ពីម៉ោង ០១.០១ ដល់ ០៤.០០ រសៀល
ការងារបន្ថែមម៉ោងគឺនៅលើមូលដ្ឋានស្ម័គ្រចិត្តចាប់ពីម៉ោង ០៤.០០ ល្ងាចដល់ ០៦.០០ ល្ងាច ក្នុងករណីដែលក្រុមហ៊ុនតម្រូវ។
ការឈប់សម្រាកមួយថ្ងៃក្នុងមួយសប្តាហ៍មានសិទ្ធិក្រោមកិច្ចព្រមព្រៀងនេះ។

មាត្រា ៧៖

និយោជកត្រូវផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់និយោជិត ដូចតទៅ៖

- ប្រាក់រង្វាន់ចូលរួម _____ ដុល្លាអាមេរិក សម្រាប់បុគ្គលិកដែលចូលធ្វើការទាន់ពេល
- ប្រាក់បំណាច់អតីតភាពស្របតាមច្បាប់ការងារ
- ការជឹកជញ្ជូនដោយឥតគិតថ្លៃទៅកាន់អាសយដ្ឋានឯកជន ប្រសិនបើម៉ោងបន្ថែមម៉ោងបញ្ចប់បន្ទាប់ពីម៉ោង ៩.00 យប់
- ប្រាក់ឧបត្ថម្ភអាហារសម្រាប់ការងារបន្ថែមម៉ោងក្នុងអត្រា _____ ប្រាក់រៀលក្នុងមួយវេនការងារបន្ថែមម៉ោង
- ឈប់សម្រាកឈឺពេលមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតត្រឹមត្រូវ ត្រូវបានបង្ហាញជាភស្តុតាង
- ការឈប់សំរាកលំហែមាតុភាព __ ថ្ងៃជាមួយនឹងប្រាក់ឈ្នួលពាក់កណ្តាលរួមទាំងប្រាក់ឧបត្ថម្ភទាំងអស់ប្រសិនបើកម្មករនិយោជិតបានធ្វើការលើសពី ១ ឆ្នាំ។
- ការបំបៅកូនដោយទឹកដោះម្តាយយ៉ាងហោចណាស់ ១ ម៉ោងក្នុងអំឡុងពេលធ្វើការរហូតដល់ទារកមានអាយុ ១ ឆ្នាំ។
- សរុបចំនួន ___ ថ្ងៃឈប់សម្រាកដែលបានបង់ប្រចាំឆ្នាំ
- សេវាព្យាបាល និងព្យាបាលដោយមិនគិតថ្លៃសម្រាប់កម្មកររនិយោជិតក្នុងអំឡុងពេលធ្វើការ ក្នុងករណីមានតម្រូវការផ្នែកវេជ្ជសាស្ត្រ
- ថ្ងៃឈប់សម្រាកក្នុងថ្ងៃបុណ្យជាតិ

មាត្រា ៨៖
បទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និងវិសោធនកម្ម ព្រមទាំងបទប្បញ្ញត្តិ និងសេចក្តីណែនាំដែលចេញដោយយោងតាមច្បាប់នេះ ត្រូវអនុវត្តស្របតាមច្បាប់ការងារ។

មាត្រា ៩៖
និយោជិតត្រូវប្រគល់វត្ថុទាំងអស់ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនវិញនៅពេលលាលែង ឬបណ្តេញចេញ

មាត្រា ១០៖
នៅពេលដែលកិច្ចសន្យានេះផុតកំណត់ និយោជកត្រូវបង់ប្រាក់អត្ថប្រយោជន៍ដែលកំណត់ដោយច្បាប់ ការងារ។

មាត្រា ១១៖
និយោជកត្រូវបង់ប្រាក់ឈ្នួល ប្រាក់ឆ្នាន់ ប្រាក់លើកទឹកចិត្ត ប្រាក់បន្ថែមម៉ោង និងសិទ្ធិផ្សេងទៀតដែលជាផ្នែកមួយនៃគោលគំនិតនៃប្រាក់ឈ្នួល (ក្នុងរយៈពេលមិនលើសពីប្រាំពីរថ្ងៃនៃថ្ងៃទទួលសិទ្ធិ) ជាសាច់ប្រាក់ ឬតាមរយៈការផ្ទេរប្រាក់តាមធនាគារ ឬការផ្ទេរតាមអេឡិចត្រូនិក ដូចដែលបានព្រមព្រៀងលើ រវាងភាគីទាំងពីរ។

មាត្រា ១២៖
កម្មករបញ្ជាក់ថារាល់ព័ត៌មានដែលមានក្នុងប្រវត្តិរូបសង្ខេប និងពាក្យសុំគឺត្រឹមត្រូវ។ និយោជករក្សាសិទ្ធិក្នុងការបញ្ចប់កិច្ចសន្យាភ្លាមៗ ប្រសិនបើមានការបំពានលើមាត្រាទាំងនេះ ឬការរំលោភបំពានលើវិធានផ្ទៃក្នុងរបស់ក្រុមហ៊ុនកើតឡើង។

កិច្ចសន្យានេះចូលជាធរមាននៅថ្ងៃទី _____ និងផុតកំណត់នៅថ្ងៃទី _____

ហត្ថលេខាដោយតំណាងរោងចក្រ

ថ្ងៃទី ខែ ឆ្នាំ ...../...../.....

ហត្ថលេខាដោយនិយោជិក

ថ្ងៃទី ខែ ឆ្នាំ ...../...../.....

ចូរចងចាំថាអ្នកតែងតែអាច៖

- អានកិច្ចសន្យា ហើយសុំឲ្យមិត្តម្នាក់ជួយអ្នកឲ្យយល់ពីលក្ខខណ្ឌដ៏ស្មុគស្មាញ។
- សួរសំណួរប្រសិនបើអ្នកមិនយល់ផ្នែកណាមួយនៃកិច្ចសន្យារបស់អ្នក។
- កុំចុះហត្ថលេខាលើកិច្ចសន្យា ឬឯកសារណាមួយផ្សេងទៀត ប្រសិនបើអ្នកមិនដឹងថាវាចែងពីអ្វី។
- រក្សាច្បាប់ចម្លងកិច្ចសន្យារបស់អ្នកនៅកន្លែងដែលមានសុវត្ថិភាព។

ជំនួយការបណ្តុះបណ្តាល ខ.២.២

សំណួរដើម្បីយល់ពីកិច្ចសន្យាការងាររបស់អ្នក។

• តើនិយោជកខ្ញុំឈ្មោះអ្វី?
• តើនិយោជករបស់ខ្ញុំមានអាសយដ្ឋាននៅទីណា?
• លេខទូរស័ព្ទរបស់និយោជក?
• តើការកិច្ចប្រចាំថ្ងៃរបស់ខ្ញុំមានអ្វីខ្លះ?
• តើអ្នកណាជាចៅហ្វាយរបស់ខ្ញុំ?
• តើខ្ញុំនឹងធ្វើការនៅទីនេះរយៈពេលប៉ុន្មាន?
• តើខ្ញុំនឹងទទួលបានប្រាក់ឈ្នួលនៅពេលណា? ប្រចាំសប្តាហ៍? ប្រចាំខែ?
• តើខ្ញុំនឹងទទួលបានប្រាក់ឈ្នួលនៅថ្ងៃតែមួយរាល់ពេលដែរឬទេ?
• តើខ្ញុំនឹងទទួលបានកំណត់ត្រាជាលាយលក្ខណ៍អក្សរនៃប្រាក់ឈ្នួលរាល់លើកដែរឬទេ?
• តើខ្ញុំនឹងទទួលបានប្រាក់ឈ្នួលជាសាច់ប្រាក់ ឬប្រាក់នឹងត្រូវដាក់ក្នុងគណនីធនាគារ?
• ប្រសិនបើខ្ញុំធ្វើការថែមម៉ោង តើខ្ញុំនឹងទទួលបានប្រាក់បន្ថែមដែរឬទេ? ចំនួនប៉ុន្មាន?
• តើអាចនឹងមានការកាត់ប្រាក់ឈ្នួលពីសំណាក់និយោជករបស់ខ្ញុំដែរឬទេ? ចំនួនប៉ុន្មាន?
• តើខ្ញុំនឹងធ្វើការប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?
• តើខ្ញុំចាប់ផ្តើម និងបញ្ចប់ម៉ោងប៉ុន្មានក្នុងមួយថ្ងៃ?
• តើថ្ងៃណាឈប់សម្រាករបស់ខ្ញុំ?
• តើខ្ញុំនឹងទទួលបានថ្ងៃឈប់សម្រាកប៉ុន្មានថ្ងៃក្នុងមួយឆ្នាំ?
• តើខ្ញុំនឹងទទួលបានការបណ្តុះបណ្តាលអំពីសុវត្ថិភាពដែរឬទេ?
• តើនិយោជករបស់ខ្ញុំនឹងផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ដែរឬទេ?
• ប្រសិនបើខ្ញុំមានផ្ទៃពោះ តើនិយោជករបស់ខ្ញុំនឹងអនុញ្ញាតឲ្យខ្ញុំបន្តធ្វើការ និងផ្តល់អត្ថប្រយោជន៍ការពារមាតុភាពដែរឬទេ?

⚠ **ចំណុចត្រូវយកចិត្តទុកដាក់៖** សូមចងចាំថា អ្នកតែងតែអាចសួរសំណួរទៅកាន់និយោជករបស់អ្នក និងស្វែងរកជំបូន្មានពីសហជីព និងកម្មការផ្សេងទៀត មុនពេលចូលធ្វើការងារ។ មុនពេលចុះហត្ថលេខាលើកិច្ចសន្យា ពួកគេប្រហែលជាអាចជួយអ្នកឲ្យយល់អំពីលក្ខខណ្ឌនៃកិច្ចសន្យា។ ក្រោយមក ប្រសិនបើអ្នកប្រឈមមុខនឹងបញ្ហាជាមួយនិយោជករបស់អ្នក តំណាងសហជីពរបស់អ្នកអាចជួយអ្នកក្នុងការដោះស្រាយឲ្យបាន។

និយមន័យ

បើកប្រាក់បៀវត្សរ៍គឺជាកំណត់ត្រាដែលផ្តល់ឲ្យនិយោជិតនៅពេលពួកគេបានទទួលប្រាក់ដោយរៀបរាប់លម្អិតអំពីចំនួនប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភផ្សេងទៀតដែលបានផ្តល់ឲ្យ និងចំនួននៃការកាត់កង (ពន្ធ ការធានារ៉ាប់រង ប្រាក់បៀវត្សរ៍ជាមុនៗលៗ)

ព័ត៌មានសំខាន់ៗនៅក្នុងប័ណ្ណបើកប្រាក់បៀវត្សរ៍

ព័ត៌មានទូទៅ	ការទូទាត់	ការកាត់ប្រាក់
• ឈ្មោះ និងអាសយដ្ឋាន របស់ក្រុមហ៊ុន • ឈ្មោះ និងអាសយដ្ឋានរបស់និយោជិត • លេខសម្គាល់បុគ្គលិក • ខែ និងឆ្នាំ • លេខគណនីធនាគាររបស់និយោជិត (សម្រាប់ការផ្ទេរប្រាក់តាមធនាគារ) • លេខធានារ៉ាប់រងជាតិ • វិធីសាស្ត្រទូទាត់ (សាច់ប្រាក់ ឬផ្ទេរប្រាក់តាមធនាគារ)	• ឈ្មោះ និងអាសយដ្ឋាន របស់ក្រុមហ៊ុន • ឈ្មោះ និងអាសយដ្ឋានរបស់និយោជិត • លេខសម្គាល់បុគ្គលិក • ខែ និងឆ្នាំ • លេខគណនីធនាគាររបស់និយោជិត (សម្រាប់ការផ្ទេរប្រាក់តាមធនាគារ) • លេខធានារ៉ាប់រងជាតិ • វិធីសាស្ត្រទូទាត់ (សាច់ប្រាក់ ឬផ្ទេរប្រាក់តាមធនាគារ)	• ប្រាក់ខែគោល ចំនួនម៉ោងនិងបរិមាណ • ចំនួនម៉ោង • បន្ថែមម៉ោង (OT) • ប្រាក់ឧបត្ថម្ភ • អាហារ • ប្រាក់រង្វាន់ • ការលើកទឹកចិត្ត • ការធ្វើដំណើរ • អតីតភាព • ប្រាក់បៀវត្សរ៍សរុប

ជំនួយការបណ្តុះបណ្តាល ខ.២.៣

ឧទាហរណ៍នៃបណ្ណបើកប្រាក់បៀវត្សរ៍



ឈ្មោះក្រុមហ៊ុន

លេខរបស់និយោជិត		ឈ្មោះនិយោជក		កាលបរិច្ឆេទ រយៈពេល	លេខសម្គាល់ ប.ស.ស
នាយកដ្ឋាន		ផ្នែក		មុខតំណែង	ចូលធ្វើការចាប់តាំងពី៖
ការទូទាត់	ឯកតា	អត្រា	ចំនួន (ដុល្លាអាមេរិក)	ការកាត់ប្រាក់	ចំនួន (ដុល្លាអាមេរិក)
ប្រាក់ខែគោល				ការធានារ៉ាប់រងសង្គម	
ប្រាក់លើសម៉ោង				ការធានារ៉ាប់រង សុខភាព	
ប្រាក់រង្វាន់				ពន្ធចំណូល	
ប្រាក់ឧបត្ថម្ភ				ការសងប្រាក់កម្ចី	
កូន				ប្រាក់ខែបើកជាមុន	
អាហារ				វិភាគទានសហជីព	
កន្លែងស្នាក់នៅ					
ការធ្វើដំណើរ					
អតីតភាព					
ផ្សេងៗ					
ប្រាក់ឈ្នួលសរុប (ដុល្លារអាមេរិក)				**ការកាត់ប្រាក់សរុប**	
អាសយដ្ឋាននិយោជិត				**ប្រាក់ឈ្នួល (ដុល្លារអាមេរិក)**	
វិធីទូទាត់					


ចំណុចត្រូវយកចិត្តទុកដាក់៖ បណ្ណបើកប្រាក់បៀវត្សរ៍គឺជាឯកសារសំខាន់ដែលត្រូវរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព។ បណ្ណបើកប្រាក់បៀវត្សរ៍ បង្ហាញថាអ្នកមានចំណូលទៀងទាត់។ អ្នកអាចត្រូវបានស្នើសុំឲ្យបង្ហាញបណ្ណបើកប្រាក់បៀវត្សរ៍នៅពេលអ្នកស្នើសុំប្រាក់កម្ចី ឬនៅពេលអ្នកចង់ជួលអាផាតមិន ឬផ្ទះ។

៣. បង្កើតផែនការរបស់អ្នក!

ជំនួយការបណ្តុះបណ្តាល ខ.៣.១


រូបភាពសម្រាប់ការរៀបចំផែនការ
(សម្រាប់ក្រុមដែលមានការលំបាកក្នុងការអាន)












































ជំនួយការបណ្តុះបណ្តាល ខ.៣.២

តារាងថវិការគ្រួសាររបស់ភួរអ



តោះមកស្គាល់ សុភាព និងដឹងអំពីរបៀបបង្កើតថវិការបស់នាង

ថវិការបស់គ្រួសារសុភាព

ប្រភពចំណូល	ចំនួន
ចំណូលថេរ	
ការផ្តល់ប្រាក់ចំណូលពីសុភាពទៅដល់គ្រួសារ	
ចំណូលថេរសរុប	
ចំណូលអថេរ	
ចំណូលរបស់ឪពុកសុភាព	
ចំណូលរបស់សុធា	
ចំណូលរបស់បងស្រីសុភាព	
ចំណូលអថេរសរុប	
ប្រាក់ចំណូលសរុប	

ការចំណាយ	
ការចំណាយសំខាន់ៗ (ចាំបាច់)	
អាហារ និងគ្រឿងអនាម័យ	
ការធ្វើដំណើរ	
ការចំណាយលើការថែទាំសុខភាព	
ទូរស័ព្ទបង់ប្រាក់ជាមុន	
ការសងប្រាក់កម្ចី	
ការចំណាយសរុបសម្រាប់តាពចាំបាច់	
ការចំណាយមិនចាំបាច់ (ការចង់បាន)	
ប្រាក់សម្រាប់ទិញសម្ភារៈសាងសង់ផ្ទះ	
សម្លៀកបំពាក់	
ការចំណាយសរុបសម្រាប់ការចង់បាន	
ការចំណាយសរុប	

ការចំណាយសរុប	
ចំណូល-ការចំណាយ	





ករណីសិក្សាទី៥

ថវិកាគ្រួសាររបស់ សុភាព – ភគ្គ ១

ម្សិលមិញជាថ្ងៃដាច់ខែ ហើយសុភាពបានសម្រេចចិត្តពិនិត្យមើលថាតើនាងនឹងប្រើប្រាស់ចំណូលរបស់នាងក្នុងខែនេះដោយរបៀបណា។ ដូចរាល់ខែដែរ ប្រាក់ខែសុទ្ធរបស់នាងគឺ ២៥០ ដុល្លារ។ ដូចខែមុនដែរ សុភាពបានសម្រេចចិត្តផ្តល់ប្រាក់ ១៣០ ដុល្លារ សម្រាប់ការចំណាយរបស់គ្រួសារនៅភូមិ ហើយទុក១២០ ដុល្លារសម្រាប់ខ្លួននាង ជាថវិកាផ្ទាល់ខ្លួនរបស់នាង។

យោងតាមគ្រួសាររបស់នាងនៅក្នុងភូមិបានឲ្យដឹងថា ក្នុងខែនេះ ពួកគេក៏នឹងមានចំនួនប្រាក់ចំណូលដូចខាងក្រោមផងដែរ៖ ៨០ ដុល្លារម្នាក់សម្រាប់ឪពុកនាង និងសុធា ដែលជាកម្មករកសិកម្មប្រចាំថ្ងៃ និង ៤០ ដុល្លារជារបស់បងស្រីរបស់នាងដែលរកបានពីការលក់ជម្រើសនៅលើទីផ្សារ។

ករណីសិក្សាទី៦

ថវិកាគ្រួសាររបស់សុភាព - ភគ្គ ២

នៅពេលដែល សុភាព និងក្រុមគ្រួសារត្រឡប់មកផ្ទះវិញបានពិនិត្យមើលប្រាក់ចំណូលរបស់ពួកគេសម្រាប់ខែបន្ទាប់ ពួកគេចាប់ផ្តើមរៀបចំផែនការថាតើពួកគេនឹងចំណាយប្រាក់យ៉ាងដូចម្តេច។ ពួកគេមិនចាំបាច់បង់ថ្លៃជួលទេ ដោយសារពួកគេជាម្ចាស់ផ្ទះតូចដែលពួកគេរស់នៅឥឡូវនេះ។ សម្រាប់ថាមពល និងទឹក ពួកគេគ្រោងចំណាយ ១៥ ដុល្លារ។

សម្រាប់អាហារ និងគ្រឿងអនាម័យ គេប៉ាន់ប្រមាណ ១២០ ដុល្លារ សម្រាប់ការដឹកជញ្ជូន ២០ ដុល្លារ និងសម្រាប់ចំណាយពាក់ព័ន្ធនឹងសុខភាព គឺ២០ ដុល្លារ។ ថ្លៃទូរស័ព្ទដៃលបង់មុនរបស់ពួកគេ នឹងចំណាយប្រហែល ៥ ដុល្លារសម្រាប់មួយគ្រឿង។ ដោយសារពួកគេមានទូរស័ព្ទ សរុបចំនួន ៣គ្រឿងនៅក្នុងផ្ទះ ការចំណាយ សរុប គឺអស់ ១៥ ដុល្លារ។ ពួកគេនឹងចំណាយ ៣០ ដុល្លារសម្រាប់ការសងប្រាក់កម្ចីដែលពួកគេបានយកដើម្បីទិញកង់។ ជារៀងរាល់ខែ ពួកគេបានទុកលុយ ៥០ ដុល្លារ ដើម្បីបន្តពង្រីកផ្ទះរបស់ពួកគេ។ ពួកគេប្រើលុយនេះដើម្បីទិញសម្ភារៈ។ ពួកគេក៏មានគម្រោងចំណាយប្រហែល ២០ ដុល្លារផងដែរ ដើម្បីទិញអាវយឺតថ្មីៗសម្រាប់សមាជិកគ្រួសារទាំងអស់។

បន្ទាប់ពីផ្ញើប្រាក់ ១៣០ ដុល្លារដល់គ្រួសារ សុភាព រក្សាប្រាក់ចំណូលរបស់នាងចំនួន ១២០ ដុល្លារសម្រាប់ការចំណាយរបស់នាងនៅកន្លែងដែលនាងរស់នៅ។ ក្នុងខែនេះនាងគណនាការចំណាយផ្ទាល់ខ្លួនរបស់នាងសម្រាប់ខែបន្ទាប់គឺ៖ ៤៥ ដុល្លារសម្រាប់អាហារ ២០ ដុល្លារសម្រាប់ថ្លៃជួលបន្ទប់ និងទឹកភ្លើង ៥ ដុល្លារសម្រាប់សម្រាប់ទូរស័ព្ទរបស់នាង ១០ ដុល្លារសម្រាប់ការចំណាយបន្ថែម រួមទាំងថ្លៃផ្ទេរប្រាក់។ នាងក៏រក្សាទុក ២០ ដុល្លារសម្រាប់ការចំណាយដែលនាងប្រហែលជាចង់ធ្វើនៅថ្ងៃទំនេររបស់នាង។ នាងព្យាយាមសន្សំ ២០ ដុល្លារជារៀងរាល់ខែ ហើយនាងទុកលុយនេះក្នុងប្រអប់តូចមួយនៅក្នុងបន្ទប់របស់ នាង។





ជំនួយការ បណ្តុះបណ្តាល ខ.៣.៣

ថវិការគ្រួសាររបស់តួអង្គ

ថវិការបស់គ្រួសារសុភាព

ប្រភពចំណូល	ចំនួន
ចំណូលថេរ	
ការផ្តល់ប្រាក់ចំណូលពីសុភាពទៅដល់គ្រួសារ	១៣០ USD
ចំណូលថេរសរុប	**១៣០** USD
ចំណូលអថេរ	
ចំណូលរបស់ឪពុកសុភាព	៨០ USD
ចំណូលរបស់សុធា	៨០ USD
ចំណូលរបស់បងស្រីសុភាព	៤០ USD
ចំណូលអថេរសរុប	២០០ USD
ប្រាក់ចំណូលសរុប	**៣៣០** USD

ការចំណាយ	
ការចំណាយសំខាន់ៗ (ចាំបាច់)	
អាហារ និងគ្រឿងសម្ភារៈអនាម័យ	១២០ USD
ថាមពល និងទឹក	១៥ USD
ការធ្វើដំណើរ	២០ USD
ការចំណាយលើការថែទាំសុខភាព	២០ USD
ទូរស័ព្ទបង់ប្រាក់ជាមុន	១៥ USD
ការសងប្រាក់កម្ចី	៣០ USD
ការចំណាយសរុបសម្រាប់ភាពចាំបាច់	**២២០** USD
ការចំណាយមិនចាំបាច់ (ការចង់បាន)	
ប្រាក់សម្រាប់ទិញសម្ភារៈសាងសង់ផ្ទះ	៥០ USD
សម្លៀកបំពាក់	២០ USD
ការចំណាយសរុបសម្រាប់ការចង់បាន	**៧០** USD
ការចំណាយសរុប	**២៩០** USD

ចំណូល-ការចំណាយ	**៤០** USD

ជំនួយការ បណ្តុះបណ្តាល ខ.៣.៤

ថវិកាផ្ទាល់ខ្លួនរបស់តួអង្គ



ថវិការបស់សុភាព

ប្រភពចំណូល	ចំនួន
ចំណូលថេរ	
ការផ្តល់ប្រាក់ចំណូលពីសុភាពទៅដល់គ្រួសារ	២៥០ USD
ចំណូលថេរសរុប	**២៥០** USD
ចំណូលអថេរ	
ចំណូលអថេរសរុប	0 USD
ប្រាក់ចំណូលសរុប	**២៥០** USD

ការចំណាយ	
ការចំណាយសំខាន់ៗ (ចាំបាច់)	
ការផ្តល់ប្រាក់សម្រាប់ថវិកាគ្រួសារ	១៣០ USD
ការជួលកន្លែងស្នាក់ ទឹក និងអគ្គិសនី	២០ USD
ការចំណាយលើអាហារ និងគ្រឿងសម្ភារៈអនាម័យ	៤៥ USD
ទូរស័ព្ទ	៥ USD
ការចំណាយបន្ថែម	១0 USD
ការចំណាយសរុបសម្រាប់ភាពចាំបាច់	**២១0** USD
ការចំណាយមិនចាំបាច់ (ការចង់បាន)	
ការចំណាយសម្រាប់ពេលទំនេរ	២0 USD
ការចំណាយសរុបសម្រាប់ការចង់បាន	**២0** USD
ការចំណាយសរុប	**២៣0** USD

ចំណូល-ការចំណាយ	**២0** USD

សំណួរ

- តើអ្នកបានបង្កើតថវិការួចហើយឬនៅ?

☐ បាទ/ចាស ☐ មិនទាន់ទេ

- បើបាទ/ចាស តើអ្នកបានកត់ត្រា ឬគ្រាន់តែគិតទុកក្នុងចិត្ត?

☐ បានកត់ត្រា ☐ គិតក្នុងចិត្ត

និយមន័យ

ថវិកាគឺជាឧបករណ៍សម្រាប់សម្រេចចិត្ត រៀបចំផែនការ និងប្រើប្រាស់ប្រាក់របស់អ្នក ដើម្បីសម្រេច គោលដៅរបស់អ្នក។

⚠ **ចំណុចសំខាន់ៈ** ប្រសិនបើអ្នកមិនសូវស្រួលខ្លួន ឬអ្នកមានអារម្មណ៍សោកសៅបន្តិចនៅពេលនេះ ការរៀបចំថវិកាអាចត្រូវធ្វើកិច្ចការដ៏ច្រើនលើសលុប។ និយាយអំពីអារម្មណ៍របស់អ្នកជាមួយមនុស្សជា ទីស្រលាញ់របស់អ្នក ឬនរណាម្នាក់ដែលអ្នកទុកចិត្ត ហើយព្យាយាមស្វែងរកជំនួយ ដើម្បីចាប់ផ្តើមរៀបចំថវិការបស់អ្នកបន្តិចម្តងៗ។ កុំដាក់សម្ពាធលើខ្លួនអ្នកខ្លាំងពេក!

លំហាត់

អ្នកបានឃើញក្នុងអំឡុងពេលបណ្តុះបណ្តាលអំពីរបៀបដែល សុភាព និងក្រុមគ្រួសារបង្កើតថវិការបស់ពួកគេ។ ឥឡូវនេះវាជាវេនរបស់អ្នក! បង្កើតថវិកាផ្ទាល់ខ្លួនរបស់អ្នក!

ត្រូវប្រុងប្រយ័ត្ន! ខ្ជង់ « ចំណូល - ចំណាយ » នៅខាងក្រោមតារាងត្រូវតែវិជ្ជមាន។ ប្រសិនបើវាមិនវិជ្ជមាន មានន័យថាអ្នកមិនមានប្រាក់ចំណូលគ្រប់គ្រាន់ និងមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ការចំណាយទាំងអស់របស់អ្នកឡើយ។ វាក៏មានន័យផងដែរថា អ្នកមិនមានលុយសន្សំដើម្បីសម្រេចគោលដៅរបស់អ្នកទេ។

ប្រសិនបើអ្នកកំពុងរំពឹងថានឹងត្រូវចំណាយច្រើនក្នុងរយៈពេលពីរបីខែខាងមុខ ត្រូវចាប់ផ្តើមសន្សំប្រាក់បានគ្រប់ពេលដែលអ្នកអាចធ្វើបាន ដើម្បីឲ្យអ្នកអាចទូទាត់លើការចំណាយធំៗទាំងនេះ និងស្ថិតនៅក្នុងថវិការបស់អ្នក។



ជំនួយការ បណ្តុះបណ្តាល ខ.៣.៥
ថវិការបស់ខ្ញុំ

ថវិការបស់ខ្ញុំ

ប្រភពចំណូល	ចំនួន
ចំណូលថេរ	
សរុបចំណូលថេរ	
ចំណូលអថេរ	
សរុបចំណូលអថេរ	
ចំណូលសរុប	

ការចំណាយ	
ការចំណាយចាំបាច់ (តម្រូវការ)	
ថាមពល និងទឹក	
អាហារ និងគ្រឿងសម្ភារៈអនាម័យ	
ការធ្វើដំណើរ	
ការថែទាំសុខភាព / ឱសថ	
ទំនាក់ទំនង (ទូរស័ព្ទ)	
ការសងប្រាក់កម្ចី	
ជួលកន្លែងស្នាក់នៅ	
សរុប (តម្រូវការ)	
ការចំណាយមិនចាំបាច់ (ការចង់បាន)	
សរុប (ការចង់បាន)	
ការចំណាយសរុប	

ចំណូល ដកចំណាយ (ប្រាក់សន្សំ)	

យើងបន្តជាមួយនឹងករណីសិក្សាអំពីសុភាព



ករណីសិក្សាទី៧

ថវិកាគ្រួសាររបស់សុភាព (ភាគ៣)

វាហាក់ដូចជាគ្រួសាររបស់សុភាពកំពុងជួបបញ្ហាមួយចំនួន។ ទោះបីជាពួកគេបានរៀបចំគម្រោងថវិការបស់ខ្លួនយ៉ាងប្រុងប្រយ័ត្នក៏ដោយ អ្វីៗក្នុងខែនេះហាក់ដូចជាមិនល្អទេ។ ការផ្តល់ប្រាក់ពីសុភាពសម្រាប់ថវិកាគ្រួសារនៅមានចំនួនដដែល ប៉ុន្តែប្រភពចំណូលប្រែប្រួលបានផ្លាស់ប្តូរ។ ឪពុករបស់សុភាព និងសុធា មិនត្រូវបានគេជួលឲ្យធ្វើការបានច្រើនថ្ងៃដូចការសន្យាទេ ដោយសារបញ្ហានៅកសិដ្ឋាន។ អ្នកទាំងពីរមានប្រាក់ចំណូលម្នាក់ៗ ៦០ ដុល្លារ។ ចំណូលបងស្រីរបស់សុភាពបានរងគ្រោះដោយសារកូវីដ១៩ ដូច្នេះនាងអាចរកបានត្រឹមតែ ២០ ដុល្លារប៉ុណ្ណោះ ខណៈដែលទីផ្សារត្រូវបានបិទពាក់កណ្តាលខែ ដោយសារមានករណីវិជ្ជមាន។

ដូចគ្នានេះផងដែរដោយសារតែអតិផរណានៅក្នុងខែនេះ ការចំណាយរបស់ពួកគេបានកើនឡើង។ ការចំណាយលើអគ្គិសនី និងទឹករបស់ពួកគេ បានកើនឡើងដល់ ២០ ដុល្លារ។ លើសពីនោះ ការចំណាយលើអាហារ និងគ្រឿងសម្ភារៈអនាម័យរបស់ពួកគេក៏បានកើនឡើងដល់ ១៥០ ដុល្លារផងដែរ ដោយសារតែ កង្វះទំនិញនៅទីផ្សារ និងការកើនឡើងតម្លៃ ហើយក៏ដោយសារតែពួកគេស្នាក់នៅផ្ទះច្រើនម៉ោងផងដែរ។

កន្លែងកត់ត្រា



ជំនួយការបណ្តុះបណ្តាល ខ.៣.៦

ថវិការដែលបានកែតម្រូវរបស់សុភាព

ថវិការបស់គ្រួសារសុភាពដែលបានកែតម្រូវ


ប្រភពចំណូល	ចំនួន
ចំណូលថេរ	
ការផ្តល់ប្រាក់ចំណូលពីសុភាពទៅដល់គ្រួសារ	១៣០ USD
ចំណូលថេរសរុប	**១៣០** USD
ចំណូលអថេរ	
ចំណូលរបស់ឪពុកសុភាព	៦០ USD
ចំណូលរបស់សុជា	៦០ USD
ចំណូលរបស់បងស្រីសុភាព	២០ USD
ចំណូលអថេរសរុប	**១៤០** USD
ប្រាក់ចំណូលសរុប	**២៧០** USD

ការចំណាយ	
ការចំណាយសំខាន់ៗ (ចាំបាច់)	
អាហារ និងគ្រឿងសម្ភារៈអនាម័យ	១៥០ USD
ថាមពល និងទឹក	២០ USD
ការធ្វើដំណើរ	២០ USD
ការចំណាយលើការថែទាំសុខភាព	២០ USD
ទូរស័ព្ទបង់ប្រាក់ជាមុន	១៥ USD
ការសងប្រាក់កម្ចី	៣០ USD
ការចំណាយសរុបសម្រាប់ភាពចាំបាច់	**២៥៥** USD
ការចំណាយមិនចាំបាច់ (ការចង់បាន)	
ប្រាក់សម្រាប់ទិញសម្ភារៈសាងសង់ផ្ទះ	៥០ USD
សម្លៀកបំពាក់	២០ USD
ការចំណាយសរុបសម្រាប់ការចង់បាន	**៧០** USD
ការចំណាយសរុប	**៣២៥** USD

ចំណូល-ការចំណាយ	- **៥៥** USD

សារសំខាន់

- មានឧបករណ៍ដែលប្រើដើម្បីគ្រប់គ្រងចំណូលរបស់អ្នក – ថវិកា។
- ដើម្បីបង្កើតថវិការបស់អ្នក អ្នកត្រូវគណនាចំណូល និងចំណាយរបស់អ្នក។ ជាមួយនឹងការគណនានេះ អ្នកអាចកំណត់សមត្ថភាពសន្សំរបស់អ្នក មានន័យថាអ្នកអាចកំណត់ទឹកប្រាក់ចំនួនប៉ុន្មានក្នុងមួយខែ។
- ក្នុងករណីមានភាពអាសន្ន ឬការផ្លាស់ប្តូរក្នុងស្ថានភាពហិរញ្ញវត្ថុរបស់អ្នក អ្នកនឹងត្រូវកែសម្រួលថវិការបស់អ្នក ដើម្បីអាចទូទាត់លើរាល់ការចំណាយរបស់អ្នក និងសន្សំប្រាក់សម្រាប់គោលដៅរបស់អ្នក។
- ថវិកាអាចជួយអ្នកក្នុងការសម្រេចចិត្តអំពីរបៀបចំណាយប្រាក់របស់អ្នក និងសន្សំប្រាក់ដើម្បីសម្រេចគោលដៅរបស់អ្នក។



ករណីសិក្សាទី៨

ការគ្រប់គ្រងថវិការបស់ សុភាព

៤. តាមដានថវិកា និងធ្វើការចំណាយមិនឲ្យលើសពីថវិការបស់អ្នក

កាលពីខែមុន សុភាពបានពន្យល់ម្តងទៀតដល់ប្តី និងឪពុកម្តាយអំពីប្រាក់ដែលនាងនឹងផ្ញើឲ្យពួកគេ។ ម្សិលមិញ សុភាព បានទទួលទូរស័ព្ទពីប្តី៖ គាត់បានសុំឲ្យនាងផ្ញើប្រាក់បន្ថែមទៀត ព្រោះពួកគេត្រូវបង់ថ្លៃសាលា។ លោកបន្តថា ប៉ុន្មានខែចុងក្រោយនេះពួកគេមានការចំណាយច្រើនជាងនេះ ព្រោះត្រូវបានខ្យល់ព្យុះបោកបក់ខ្លាំង ហើយដំបូលផ្ទះរបស់ពួកគេត្រូវការជួសជុល។ សុភាព ស្ទាក់ស្ទើរ៖ នាងចាំបានថា នាងបានផ្ញើប្រាក់ទៅកាន់គ្រួសាររបស់នាងរួចហើយ តាមចំនួនប្រាក់ដែលបានអនុញ្ញាតក្នុងថវិការបស់ពួកគេ ហើយប្រាក់ដែលបានផ្ញើគួរតែគ្រប់គ្រាន់សម្រាប់ថ្លៃសាលា និងការចំណាយដែលមិនបានរំពឹងទុក ដូចជាការជួសជុលដំបូលជាដើម។ នាងមិនប្រាកដថាត្រូវផ្ញើប្រាក់បន្ថែមដល់ពួកគេឬអត់ទេ ព្រោះវាមានន័យថាត្រូវប្រើប្រាក់សន្សំផ្ទាល់ខ្លួនភាគច្រើនរបស់នាង។

នាងបាននិយាយជាមួយគ្រួសាររបស់នាង ហើយប្រាប់ពួកគេឲ្យប្រើប្រាស់ប្រាក់សន្សំដែលពួកគេបានសន្សំនៅទីនោះ ព្រោះនាងមិនអាចផ្ញើប្រាក់បន្ថែមទៀតបានទេនៅពេលនេះ។





ករណីសិក្សាទី៩

ការគ្រប់គ្រងថវិការបស់ណារី

កាលពីខែមុន ណារី បានដឹងថាថវិការបស់នាងមានស្ថានភាពតឹងតែង ហើយនាងគួរតែតាមដានការចំណាយរបស់នាងជានិច្ច។ កាលពីម្សិលមិញ ណារី បានទទួលទូរសព្ទពីបងប្អូនជីដូនមួយរបស់នាងឈ្មោះរដ្ឋា។ រដ្ឋា បានសុំខ្ចីលុយខ្លះ ពីព្រោះនាងជំពាក់បំណុលគេច្រើន ដោយសារនាងបានទិញឧបករណ៍ប្រើប្រាស់ ក្រោមគម្រោងបង់រំលោះ។ ណារី ស្ទាក់ស្ទើរ៖ នាងចាំបានថា នាងមិនមានលុយនៅសសល់ក្នុងថវិកាទេ ព្រោះនាងក៏មានបំណុលខ្លះដែលត្រូវសង និងការចំណាយច្រើន។ ពេលគិតដល់រឿងនេះ នាងនឹកឃើញថាបងប្អូនជីដូនមួយរបស់នាងបានជួយនាងជាច្រើនដងហើយដែលនាងមិនអាចបដិសេធបានទេ។ នៅចុងសប្តាហ៍នោះ ទូរស័ព្ទរបស់ណារី ចាប់ផ្តើមមានបញ្ហា។ ណារីមិនមានលុយគ្រប់គ្រាន់ដើម្បី ជួសជុលទេ ហើយរដ្ឋានៅតែមិនមានលុយសងនាង។ ណារីត្រូវខ្ចីលុយពីមិត្តភ័ក្រឈ្មោះបុប្ផា។

សំណួរ

- តើសុភាពធ្វើដូចម្តេច ដើម្បីកុំឲ្យចំណាយលើសពីថវិការបស់នាង?

មានវិធីជាច្រើន ដើម្បីធ្វើឲ្យប្រាកដថាអ្នកមិនចំណាយលើសពីថវិការបស់អ្នក។ អ្នកអាចប្រើសៀវភៅបញ្ជី (spreadsheet) ដូចជា សុភាព ឬកម្មវិធី (app) ដែលមានមនុស្សជាច្រើនកំពុងប្រើប្រាស់!

ចូរយើងដឹងពីវិធីមួយដើម្បីកុំឲ្យចំណាយលើសពីថវិការបស់អ្នក។

ចំណុចសំខាន់៖ ការអនុវត្តជាទម្លាប់ អាចមានផលល្អសម្រាប់សុខភាពផ្លូវចិត្ត នៅពេលដែលអ្វីៗមិនដំណើរការបានល្អ។ ការតាមដានថវិការបស់អ្នក អាចជាលំហាត់ដ៏ល្អដើម្បីផ្តោតអារម្មណ៍ និងពិនិត្យមើលថាតើអ្នកកំពុងធ្វើដូចម្តេច ដើម្បីកុំឲ្យចំណាយលើសពីថវិការបស់អ្នក។

កន្លែងកត់ត្រា

ជំនួយការបណ្តុះបណ្តាល ខ.៤.១

តារាងតាមដានប្រាក់ចំណូល

តារាងតាមដានប្រាក់ចំណូល

ឈ្មោះ៖ _____
ខែ៖ _____
ឆ្នាំ៖

កាលបរិច្ឆេទ	ការពិពណ៌នាអំពីប្រភពចំណូល	ចំណូល

ជំនួយការបណ្តុះបណ្តាល ខ.៤.២


តារាងតាមដានការចំណាយ

តារាងតាមដានការចំណាយ

ឈ្មោះ៖ _____
ខែ៖ _____
ឆ្នាំ៖

កាលបរិច្ឆេទ	ការពិពណ៌នាអំពីការចំណាយ	ចំនួនប្រាក់ដែលបានចំណាយ	បានគ្រោងទុក ឬ មិនបានគ្រោងទុក	
			បានគ្រោងទុក	មិនបានគ្រោងទុក
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐

ការចំណាយសរុប	
ចំណូលសរុប	
ប្រាក់សន្សំ (=ចំណូល – ចំណាយ)	



គន្លឹះកុំឲ្យចំណាយលើសពីថវិការបស់អ្នក

- រំលឹកខ្លួនឯងឲ្យបានញឹកញាប់អំពីអ្វីដែលអ្នកគ្រោងនឹងចំណាយ។
- ដាក់ក្នុងថវិកានូវអ្វីមួយសម្រាប់តម្រូវការចំណាយដែលមិនរំពឹងទុក។
- កុំចាយវាយប្រាក់សន្សំរបស់អ្នក។
- តាមដាននូវអ្វីដែលអ្នកចំណាយ។
- ត្រូវប្រាកដថាអ្នកមិនចំណាយលើសពីថវិកា។
- ប្រសិនបើអ្នកចំណាយកាន់តែច្រើនលើវត្ថុមួយ ចូរចំណាយតិចលើអ្វីផ្សេងទៀត។
- ធ្វើបញ្ជីនៃវិធីកាត់បន្ថយការចំណាយដែលបានគ្រោងទុក។
- ឲ្យក្រុមគ្រួសារចូលរួមក្នុងការរៀបចំថវិកា និងអនុវត្តខ្ជាប់ខ្ជួនតាមថវិកា។



ជំនួយការបណ្តុះបណ្តាល ខ.៤.៣

ប័ណ្ណប្រតិបត្តិការ ក្រួសាររបស់តួអង្គ

ក្រួសាររបស់សុភាព

កាលពីថ្ងៃទី១ ខែកុម្ភៈ សុភាពទទួលបានប្រាក់ខែ។ គាត់ផ្ញើប្រាក់១៣០ដុល្លាទៅផ្ទះ។

ក្រួសាររបស់សុភាព

កាលពីថ្ងៃទី១ ខែកុម្ភៈ ឪពុករបស់សុភាពទទួលបានប្រាក់ឈ្នួលតាមចំនួនថ្ងៃធ្វើការសម្រាប់ការងារគាត់បានធ្វើកាលពីខែមុន ។ គាត់ទទួលបាន៨០ដុល្លា។



ត្រួសារបស់សុភាព

កាលពីថ្ងៃទី១ ខែកុម្ភៈ សុធា ទទួលបានប្រាក់ឈ្នួលតាមចំនួនថ្ងៃធ្វើការ សម្រាប់ការងារគាត់បានធ្វើ កាលពីខែមុន ។ គាត់ទទួលបាន៨០ដុល្លា។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១ ខែកុម្ភៈ បងស្រីរបស់សុភាពពិនិត្យមើលចំនួនប្រាក់ដែលគាត់រកបានកាលពីខែមុន។ វាមាន៤០ដុល្លា។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១ ខែកុម្ភៈ ពួកគេបង់ប្រាក់១៥ដុល្លាសម្រាប់ថាមពល និងទឹក។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១ ខែកុម្ភៈ ពួកគេបែងចែកប្រាក់ចំនួន១២០ដុល្លាដាក់ក្នុងស្រោមសំបុត្រសម្រាប់ការចំណាយលើអាហារ និងគ្រឿងសម្ភារៈអនាម័យសម្រាប់ពេលមួយខែ។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី២ ខែកុម្ភៈ ពួកគេបែងចែកប្រាក់ចំនួន២០ដុល្លាដាក់ក្នុងស្រោមសំបុត្រសម្រាប់ការចំណាយលើការធ្វើដំណើរ។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១០ ខែកុម្ភៈ ពួកគេត្រូវចំណាយប្រាក់ចំនួន២០ដុល្លាលើឪសថ។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១២ ខែកុម្ភៈ ពួកគេបញ្ចូលប្រាក់សម្រាប់ទូរស័ព្ទដៃទាំងអស់ ១៥ដុល្លា។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ពួកគេសងប្រាក់៣០ដុល្លា សម្រាប់ប្រាក់កម្ចីទិញកង់។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១ ខែកុម្ភៈ ពួកគេចំណាយ៥០ដុល្លាដើម្បីទិញសម្ភារៈសាងសង់ផ្ទះដែលគម្រោងរបស់ពួកគេ។

ត្រួសារបស់សុភាព

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ពួកគេត្រូវជួសជុលម៉ាស៊ីនទឹកក្តៅចំណាយអស់២០ដុល្លា។

លំហាត់

អ្នកអាចប្រើតារាងទាំងពីរខាងលើដែលត្រូវបានហៅថា "តារាងតាមដានចំណូល និងចំណាយ" ដើម្បីតាមដានចំណូល និងចំណាយ។ ចូរយើងពិនិត្យមើលថាមានអ្វីកើតឡើងជាមួយ សុភាព និងក្រុមគ្រួសាររបស់នាង។

តារាងតាមដានប្រាក់ចំណូល


ឈ្មោះ៖ គ្រួសាររបស់សុភាព
ខែ៖ កុម្ភៈ
ឆ្នាំ៖ ២០២៣

កាលបរិច្ឆេទ	ការពិពណ៌នាអំពីប្រភពចំណូល	ចំណូល
១/២/២៣	ចំណូលគ្រួសាររបស់សុភាព	៨០
១/២/២៣	ការផ្តល់ប្រាក់ររបស់សុភាពដល់គ្រួសារ	១៣០
១/២/២៣	ចំណូលរបស់សុខភាព	៨០
១/២/២៣	ចំណូលបងស្រីរបស់សុភាព	៤០
ចំណូលសរុប		៣៣០

តារាងតាមដានការចំណាយ

ឈ្មោះ៖ គ្រួសាររបស់សុភាព
ខែ៖ កុម្ភៈ
ឆ្នាំ៖ ២០២៣

កាលបរិច្ឆេទ	ការពិពណ៌នាអំពីការចំណាយ	ចំនួនប្រាក់ដែលបានចំណាយ	បានគ្រោងទុក ឬមិនបានគ្រោងទុក	
			បានគ្រោងទុក	មិនបានគ្រោងទុក
១/២/២៣	ថ្លៃមាសនិងទឹក	១៥	☒	☐
១/២/២៣	ការចំណាយលើអាហារ	១២០	☒	☐
២/២/២៣	ការធ្វើដំណើរ	២០	☒	☐
១០/២/២៣	ឱសថ	២០	☒	☐
១២/២/២៣	ទូរស័ព្ទដៃ	១៥	☒	☐
១៥/២/២៣	ប្រាក់កម្ចី	៣០	☒	☐
១៥/២/២៣	សម្ភារៈសាងសង់ផ្ទះ	៥០	☒	☐
១៥/២/២៣	ជួសជុលម៉ាស៊ីនកម្តៅទឹក	២០	☐	☒
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
ការចំណាយសរុប		២៤០		
ចំណូលសរុប		៣៣០		
ប្រាក់សន្សំ (=ចំណូល – ចំណាយ)		៩០		



ឥឡូវនេះ ជាវេនរបស់អ្នក។

នៅក្នុងឧបសម្ព័ន្ធ និងឯកសារសំខាន់ៗនៅចុងបញ្ចប់នៃមេរៀននេះ អ្នកនឹងរកឃើញតារាងតាមដានចំណូល និងចំណាយ ដែលអ្នកអាចប្រើដើម្បីតាមដានចំណូល និងចំណាយផ្ទាល់ខ្លួនរបស់អ្នក។

តាមវិធីនេះ អ្នកនឹងស្ថិតនៅក្នុងថវិការបស់អ្នក ហើយទីបំផុតអ្នកនឹងសម្រេចបានគោលដៅរបស់អ្នក។



សារសំខាន់

- រំលឹកខ្លួនឯងឲ្យបានញឹកញាប់នូវអ្វីដែលអ្នកគ្រោងនឹងចំណាយ។

- ដាក់ក្នុងថវិកានូវអ្វីមួយសម្រាប់តម្រូវការចំណាយដែលមិនរំពឹងទុក។

- ឲ្យក្រុមគ្រួសារចូលរួមក្នុងការរៀបចំថវិកា និងអនុវត្តខ្ជាប់ខ្ជួនតាមថវិកា។

- អ្នកត្រូវដឹងពីចំណូលសរុបរបស់អ្នក។ ការដឹងពីចំនួនទឹកប្រាក់ដែលអ្នករកបាន គឺជាជំហានដ៏សំខាន់មួយដើម្បីគ្រប់គ្រងទឹកប្រាក់របស់អ្នក និងអនុញ្ញាតឲ្យអ្នករៀបចំផែនការទុកជាមុនសម្រាប់ការចំណាយ។ អ្នកក៏ត្រូវដឹងពីចំនួននៃការចំណាយសរុបរបស់អ្នកផងដែរ។ វាមានសារៈសំខាន់ណាស់ក្នុងការគ្រប់គ្រងថវិការបស់អ្នក។ អ្នកអាចកែតម្រូវការចំណាយរបស់អ្នកនៅពេលអ្នកឃើញថាអ្នកចំណាយលើសពីការរំពឹងទុក។

⚠ **ត្រូវប្រុងប្រយ័ត្ន!** ប្រសិនបើអ្នកមានប្រាក់ចំណូលមិនទៀងទាត់ មានន័យថាជារៀងរាល់ខែដែលអ្នករកបានចំនួនផ្សេងៗគ្នា អ្នកអាចបង្កើតថវិការបស់អ្នកដោយប្រើប្រាក់ចំណូលជាមធ្យម ហើយបន្ទាប់មកសន្សំនៅពេលដែលអ្នករកបានកាន់តែច្រើន ដើម្បីធ្វើឲ្យមានតុល្យភាព នៅពេលដែលអ្នករកបានតិច។

៥. រក្សាកំណត់ត្រាហិរញ្ញវត្ថុរបស់អ្នក



ករណីសិក្សាទី១០

វ៉ានី ចោះចោលវិក័យប័ត្រមួយចំនួន

សហការីរបស់ រស្មី គឺ វ៉ានី តែងតែខ្វីពីអ្នកឲ្យខ្វីប្រាក់ក្រៅផ្លូវការ។ ទោះបីជាមានការណែនាំពី រក្សា ក៏ដោយ ក៏វ៉ានីមានបំណុលជាមួយមនុស្សជាច្រើន។ រស្មីតែងប្រាប់នាងឲ្យតាមដានបំណុលរបស់នាង ហើយកត់ត្រាអ្វីៗទាំងអស់។ វ៉ានី និយាយថា នាងមើលមិនឃើញសារៈសំខាន់នៃការរក្សាទុកឯកសារ ឡើយ ព្រោះនាងមានការចងចាំល្អ ហើយចាំថានាងជំពាក់លុយអ្នកណាខ្លះ។ ថ្ងៃនេះ វ៉ានី ប្រាប់ រស្មី ថា នាងខឹងអ្នកឲ្យខ្វីម្នាក់ណាស់ ព្រោះគាត់ប្រាប់នាងថា បំណុលសរុបរបស់នាងគឺពីរដងនៃចំនួនពិតប្រាកដ។ នៅពេល វ៉ានី សួរនាងថាតើនាងមានឯកសារចុះហត្ថលេខាបង្ហាញពីចំនួនប្រាក់ដែលនាងបានខ្វីនោះ វ៉ានីប្រាប់នាងថានាងបានបោះចោលឯកសារទាំងអស់។ នាងសោកស្តាយដោយមិនបានរក្សាទុកឯកសារទាំងនេះ។



ករណីសិក្សាទី១១

ណារី រកមិនឃើញវិក័យប័ត្រទឹកភ្លើង

ណារី និងគ្រួសាររបស់នាង បង់ថ្លៃទឹកភ្លើងដោយផ្ទាល់ទៅឲ្យម្ចាស់ផ្ទះជាសាច់ប្រាក់។ ជាធម្មតា ម្ចាស់ផ្ទះ ឬមនុស្សម្នាក់ដែលធ្វើការជាមួយគាត់ មកប្រមូលលុយនេះនៅដើមខែ។

យប់នេះ ខណៈពេលដែលពួកគេកំពុងញ៉ាំអាហារពេលល្ងាច ពួកគេបានទទួលទូរស័ព្ទពីម្ចាស់ផ្ទះថាគាត់នឹងមកថ្ងៃស្អែកដើម្បីប្រមូលលុយសម្រាប់វិក័យប័ត្រទឹកភ្លើង។ ឪពុករបស់ណារីប្រាប់គាត់ថា បុគ្គលិករបស់គាត់បានមកប្រមូលរួចហើយកាលពីសប្តាហ៍មុន។ ម្ចាស់ផ្ទះនិយាយថា មិនអាចទៅរួចទេ ព្រោះបុគ្គលិកនោះលែងធ្វើការឲ្យគាត់តាំងពីខែមុនម្ល៉េះ។ គាត់ទទូចថាគាត់នឹងមកយកលុយនៅថ្ងៃបន្ទាប់។

ណារី និងក្រុមគ្រួសារខឹងសម្បារយ៉ាងខ្លាំងចំពោះស្ថានភាពនេះ។ ទោះបីជាពួកគេប្រាកដថាពួកគេបានបង់ប្រាក់ក៏ដោយ ក៏ពួកគេមិនមានបង្កាន់ដៃ ឬកស្តុតាងនៃការបង់ប្រាក់ដែរ។ ឥឡូវនេះពួកគេនឹងត្រូវបង់ប្រាក់ម្តងទៀត។ ពួកគេមិនបានរៀបចំសម្រាប់ការចំណាយពិសេសណាមួយនៅក្នុងថវិការបស់ពួកគេសម្រាប់ស្ថានភាពនេះទេ។ ណារី ប្រាប់គ្រួសារនាងថា ថ្ងៃស្អែកនាងនឹងនិយាយជាមួយម្ចាស់ផ្ទះ ហើយប្រាប់គាត់ថាពួកគេចង់ចាប់ផ្តើមបង់ប្រាក់នេះដោយការផ្ទេរដោយផ្ទាល់ពីគណនីធនាគាររបស់នាង។ វិធីនោះ ពួកគេនឹងមានកស្តុតាងនៃការបង់ប្រាក់ជានិច្ច។

⚠ **ចំណុចសំខាន់ៈ** ប្រសិនបើអ្នកមានការព្រួយបារម្ភច្រើន អ្នកអាចមានអារម្មណ៍ថាការពិនិត្យមើលគណនីធនាគាររបស់អ្នក គណនីកាបូបឌីជីថល ឬសូម្បីតែពិនិត្យមើលការចំណាយរបស់អ្នកអាចត្រូវបានមើលឃើញថាជាសកម្មភាពដែលនឹងធ្វើឲ្យអ្នកកាន់តែតានតឹង និងមិនស្រួលចិត្ត។ ប៉ុន្តែត្រូវចាំថា ការមិនអើពើ ឬមិនគិតពីលុយ អាចនឹងធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ទៅនៅថ្ងៃអនាគត។

៦. ទទួលបាន លទ្ធភាពប្រើប្រាស់ និងប្រើប្រាស់ប្រាក់ឈ្នួលរបស់អ្នកដោយសុវត្ថិភាព តាមរយៈ មធ្យោបាយឌីជីថល

⚠ ចំណុចសំខាន់

• ក្នុងនាមជាកម្មករ អ្នកគួរតែមានសិទ្ធិសម្រេចអំពីវិធីនៃការទូទាត់ប្រាក់ឈ្នួលរបស់អ្នក ទាំងជាសាច់ប្រាក់ ឬតាមប្រព័ន្ធឌីជីថល ដូចបណ្តាៈ

- មិនមានច្បាប់នៅក្នុងប្រទេសដែលកំណត់វិធីទូទាត់ប្រាក់ឈ្នួល ឬមិនមានកិច្ចព្រមព្រៀងចរចារួមគ្នា នោះទេ ពោលគឺកិច្ចព្រមព្រៀងរវាងនិយោជករបស់អ្នក និងសហជីពរបស់អ្នកលើបញ្ហានោះ។

• ប្រសិនបើអ្នកមិនប្រាកដថាស្ថានភាពបែបណាទេ ត្រូវប្រាកដថានិយាយជាមួយនិយោជក សហជីព ឬតំណាងកម្មកររបស់អ្នកអំពីបញ្ហានេះ។

• ប្រសិនបើរោងចក្ររបស់អ្នកកំពុងបើកប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលរួចហើយ ឬកំពុងពិចារណាធ្វើវា អ្នកក៏គួរមានសិទ្ធិសម្រេចថាតើអ្នកចង់បង់ឲ្យមានការបើកប្រាក់ឈ្នួលតាមរយៈគណនីធនាគារ គណនីប្រាក់ចល័ត ឬប័ណ្ណបង់ប្រាក់ជាមុន។

• ប្រសិនបើអ្នកមានគណនីរួចហើយ ឬមានអ្នកផ្តល់សេវាផ្សេងៗគ្នា សូមប្រាកដថាត្រូវយល់យ៉ាងលម្អិតអំពីលក្ខខណ្ឌ និងថ្លៃសេវាផ្សេងៗដែលពួកគេផ្តល់ជូន ដើម្បីអាចជ្រើសរើសភាពងាយស្រួលបំផុត។ រោងចក្ររបស់អ្នកអាចរ៉ាប់រងការចំណាយមួយចំនួនក្នុងវិសាលភាព



ករណីសិក្សាទី១២

ការទទួលបានប្រាក់ឈ្នួលដែលទូទាត់តាមរយៈគណនីប្រាក់ចល័ត
(MOBILE MONEY ACCOUNT)

ចូវ៉ាន:	ជម្រាបសួរ សំបូរ! ខ្ញុំដឹងថាអ្នកធ្វើការជាគណនេយ្យករនៅក្នុងរោងចក្រ។ តើអ្នកអាចប្រាប់ខ្ញុំបានទេ តើពេលណាខ្ញុំនឹងទទួលបានប្រាក់ឈ្នួលដែលខ្ញុំបានស្នើសុំបើកជាមុន ក្នុងខែនេះ?
សំបូរ:	ជម្រាបសួរ ចូវ៉ាន! ប្រាក់ឈ្នួលដែលបានស្នើសុំបើកជាមុនទាំងអស់ ត្រូវបានទូទាត់នៅព្រឹកនេះ។ ប៉ុន្តែត្រូវចាំថា អ្នកមិនទទួលបានប្រាក់ឈ្នួលរបស់អ្នកជាសាច់ប្រាក់ទៀតទេ។ វាត្រូវបានបង់ទៅគណនីប្រាក់ចល័តរបស់អ្នក។
ចូវ៉ាន:	អូ! ខ្ញុំភ្លេច! ខ្ញុំពិតជាល្ងង់មែន។
សំបូរ:	មិនអីទេ នេះជាលើកទីមួយរបស់អ្នកដែលបានទទួលប្រាក់តាមវិធីនេះ។
ចូវ៉ាន:	តើលោកអាចរំលឹកខ្ញុំបានទេថាតើធ្វើដូចម្តេច ដើម្បីដកប្រាក់ខ្លះបាន?
សំបូរ:	បាទ មិនអីទេ។ អ្វីដំបូងដែលអ្នកត្រូវការនោះ គឺទូរស័ព្ទរបស់អ្នក។
ចូវ៉ាន:	អូខេ នេះជាទូរស័ព្ទរបស់ខ្ញុំ។ តើខ្ញុំគួរធ្វើដូចម្តេច?
សំបូរ:	ជាដំបូង សូមពិនិត្យមើលសាររបស់អ្នកនៅលើកម្មវិធីប្រាក់ចល័ត។ ខ្ញុំគិតថាអ្នកបានទាញយកវារួចហើយ ហើយអ្នកគួរតែបានទទួលសារមួយថាអ្នកទទួលបានប្រាក់។
ចូវ៉ាន:	អូ បាទ ខ្ញុំបានទាញយកកម្មវិធីនេះ កាលពីសប្តាហ៍មុន បន្ទាប់ពីកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានជាមួយក្រុមហ៊ុននៅរោងចក្រ។ បាទ អ្នកនិយាយត្រូវ ខ្ញុំឃើញហើយថា ខ្ញុំមានសារមួយពីកម្មវិធីប្រាក់ចល័តដែលនិយាយថាខ្ញុំបានទទួលបានប្រាក់។ តើខ្ញុំត្រូវធ្វើអ្វីនៅពេលនេះ?
សំបូរ:	អ្នកត្រូវចូលកម្មវិធីទូទាត់ប្រាក់ចល័តរបស់អ្នក។
ចូវ៉ាន:	មិនអីទេ ខ្ញុំបានវាយលេខសម្ងាត់របស់ខ្ញុំទៅក្នុងកម្មវិធីនេះ។
សំបូរ:	ល្អណាស់ ឥឡូវអ្នកគ្រាន់តែចុចដកប្រាក់ ហើយវាយបញ្ចូលចំនួនទឹកប្រាក់ដែលអ្នកចង់ដកពីគណនីប្រាក់ចល័តរបស់អ្នក។ សូមចងចាំថាអ្នកមិនចាំបាច់ដកប្រាក់របស់អ្នកទាំងអស់នោះទេ។ វាពិតជាល្អណាស់ ប្រសិនបើអ្នកដកប្រាក់ដែលអ្នកត្រូវការនៅពេលនេះ ហើយរក្សាទុកប្រាក់នៅសេសសល់ដោយសុវត្ថិភាពក្នុងគណនីឌីជីថលរបស់អ្នក។
ចូវ៉ាន:	អ្នកនិយាយត្រូវ។ ខ្ញុំនឹងដកប្រាក់ដែលខ្ញុំត្រូវការសម្រាប់តែការទិញអាហារ និងគ្រឿងសម្ភារៈ អនាម័យមួយចំនួនប៉ុណ្ណោះ។ ខ្ញុំបានបញ្ជាក់ពីការដកប្រាក់របស់ខ្ញុំ ហើយខ្ញុំឃើញថាខ្ញុំទើបតែទទួលបានសារមួយផ្សេងទៀតពីកម្មវិធី។
សំបូរ:	ល្អណាស់។ ឥឡូវនេះបន្ទាប់ពីចេញពីធ្វើការ អ្នកអាចយកសារនោះទៅភ្នាក់ងារដកប្រាក់ចល័ត។ ហើយអ្នកបង្ហាញសារនោះ គេនឹងដកឲ្យលុយអ្នក។
ចូវ៉ាន:	តើងាយស្រួលទេ? តើនៅក្បែររោងចក្រនេះមានភ្នាក់ងារដកប្រាក់ចល័តដែរឬទេ?
សំបូរ:	មាន។ ដោយសារតែកម្មករជាច្រើន ឥឡូវនេះទទួលបានប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល ហាងលក់គ្រឿងទេសនៅក្បែររោងចក្រក៏ឥឡូវធ្វើជាភ្នាក់ងារដកប្រាក់ចល័ត។ អ្នកអាចដកប្រាក់របស់អ្នកបានយ៉ាងងាយស្រួលនៅទីនោះ។
ចូវ៉ាន:	ល្អណាស់ សំបូរ។ អរគុណច្រើន។

ករណីសិក្សាទី១៣

ការទទួលបានប្រាក់ខែក្នុងគណនីធនាគារតាមរយៈម៉ាស៊ីនអេធីអឹម

សុភាពៈ សួស្តី វ៉ានី ខ្ញុំដឹងថាអ្នកជាគណនេយ្យករនៅក្នុងរោងចក្រ។ តើអ្នកអាចប្រាប់ខ្ញុំបានទេ ពេលណា ខ្ញុំទទួលបានប្រាក់ខែ?

វ៉ានីៈ ជំរាបសួរ សុភាព ប្រាក់ខែទាំងអស់ ត្រូវបានបើកនៅព្រឹកនេះ។ ប៉ុន្តែត្រូវចាំថា អ្នកមិនទទួលបានប្រាក់ខែរបស់អ្នកជាសាច់ប្រាក់ទៀតទេ។ វាត្រូវបានបង់ទៅគណនីធនាគាររបស់អ្នក។

សុភាពៈ បាទ ខ្ញុំដឹងរឿងហ្នឹង។ ប៉ុន្តែខ្ញុំយល់ច្រឡំបន្តិចអំពីរបៀបដកលុយពីគណនីធនាគារ។

វ៉ានីៈ មិនអីទេ នេះជារឿងធម្មតាទេ នៅពេលអ្នកចាប់ផ្តើមទទួលបានប្រាក់ដែលរកដោយលំបាក តាមវិធីថ្មីផ្សេងទៀត។

សុភាពៈ តើអ្នកអាចប្រាប់ខ្ញុំជាមុនបានទេ អំពីរបៀបឆែកមើលថាខ្ញុំមានលុយក្នុងគណនីធនាគាររបស់ខ្ញុំ ហើយឬនៅ?

វ៉ានីៈ បាទ បាន។ មិនចាំបាច់បង្ហាញខ្ញុំទេ សូមបើកកម្មវិធីធនាគាររបស់អ្នកនៅលើទូរស័ព្ទរបស់អ្នក។ សូម ឡុកអ៊ីនចូល។

សុភាពៈ បាទ ខ្ញុំចូលរួចហើយ។ តើខ្ញុំគួរចុចលើរូបតំណាងគណនីរបស់ខ្ញុំដែរទេ?

វ៉ានីៈ ត្រឹមត្រូវហើយ ប្រសិនបើអ្នកធ្វើដូច្នេះ អ្នកគួរតែអាចមើលឃើញសមតុល្យដែលបានធ្វើបច្ចុប្បន្នភាពរបស់អ្នក ជាមួយនឹងប្រាក់ដែលយើងបានផ្ទេរអ្នករួចហើយ។

សុភាពៈ បាទ អ្នកនិយាយត្រូវ។ ខ្ញុំឃើញលុយនៅលើគណនីរបស់ខ្ញុំ។ ឥឡូវនេះខ្ញុំចង់ដកវាចេញ។

វ៉ានីៈ ដើម្បីធ្វើដូច្នេះ អ្នកនឹងត្រូវការកាតធនាគារ និងលេខកូដ កីន របស់អ្នក។ អ្នកបានទទួលកាលពី សប្តាហ៍មុន តើអ្នកចាំទេ?

សុភាពៈ បាទ ខ្ញុំបានទុកដាក់នៅក្នុងបន្ទប់របស់ខ្ញុំដោយសុវត្ថិភាព។ តើខ្ញុំគួរសុំឲ្យមិត្តរួមផ្ទះរបស់ខ្ញុំម្នាក់ជួយខ្ញុំក្នុងការដកប្រាក់ដែរឬទេ?

វ៉ានីៈ អ្នកអាចស្នើសុំឲ្យអ្នកណាម្នាក់រស់នៅជាមួយអ្នកដែលមានបទពិសោធន៍ជាមួយម៉ាស៊ីនអេធីអឹម ឲ្យទៅជាមួយអ្នក។ សូមចងចាំថា កុំចែករំលែកកូដ កីន ជាមួយនរណាម្នាក់។ ព្យាយាមទន្ទេញវា ហើយយកកាតរបស់អ្នកទៅជាមួយ។

សុភាពៈ ហើយអេធីអឹម នៅឯណា? នៅទីនេះក្នុងរោងចក្រ?

វ៉ានីៈ គ្មានម៉ាស៊ីនអេធីអឹមនៅខាងក្នុងរោងចក្រទេ។ ប៉ុន្តែធនាគារដៃគូរបស់យើងបានបើកមួយនៅជិតហាងលក់គ្រឿងទេសនៅកាច់ជ្រុង។ ខ្ញុំជឿជាក់ថាថាអ្នកអាចដកប្រាក់របស់អ្នកនៅទីនោះ។ សូមចងចាំថា ព្យាយាមកុំដកសមតុល្យរបស់អ្នកទាំងអស់ដកប្រាក់ក្នុងចំនួនដែលអ្នកត្រូវការប៉ុណ្ណោះ។

សុភាពៈ អរគុណច្រើន។ បាទ ខ្ញុំនឹងដកប្រាក់សម្រាប់តែការចំណាយខ្លះប៉ុណ្ណោះ។ ខ្ញុំនឹងទៅដកភ្លាម នៅពេលដែលមិត្តខ្ញុំយកកាតពីផ្ទះឲ្យខ្ញុំ។

វ៉ានីៈ មិនអីទេ។ ខ្ញុំសង្ឃឹមថាអ្នកអាចដកប្រាក់បាន!

គុណសម្បត្តិ និងគុណវិបត្តិនៃលទ្ធភាពប្រើប្រាស់ និងការប្រើប្រាស់ប្រព័ន្ធប្រាក់ឈ្នួលឌីជីថល

គុណសម្បត្តិ	គុណវិបត្តិ
• លឿនជាងមុន (មិនចាំបាច់តម្រង់ជួរដើម្បីទទួលបានប្រាក់ឈ្នួល) • មានសុវត្ថិភាពជាងមុន (កាត់បន្ថយ ហានិភ័យនៃការបាត់បង់ ចោរកម្ម។ល។) • កាត់បន្ថយសម្ពាធក្នុងការផ្តល់លុយដល់គ្រួសារ/មិត្តភ័ក្តិ/សហការី • កាត់បន្ថយការឈ្លួងឲ្យចំណាយលើរបស់ដែលមិនចាំបាច់ (ដកតែចំនួនដែលត្រូវការ) • ងាយស្រួលរក្សាទុក • អាចជួយក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្សេងទៀត (ការសន្សំ ឥណទាន ការផ្ទេរប្រាក់ ការទូទាត់) • ផ្តល់កស្តុតាងនៃការទូទាត់ប្រាក់ឈ្នួល • ជួយសម្រួលដល់ការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន (ងាយស្រួលក្នុងការប្រើប្រាស់កំណត់ត្រាហិរញ្ញវត្ថុ) • ការទូទាត់កាន់តែត្រឹមត្រូវ និងទាន់ពេលវេលា	• ដើម្បីបើក និងរក្សាទុកគណនី ដកប្រាក់ ផ្ទេរប្រាក់) • មិនមានម៉ាស៊ីនអេធីអឹមច្រើន • ម៉ាស៊ីនអេធីអឹម មិនដំណើរការ (ដាច់ចរន្តអគ្គិសនី អស់សាច់ប្រាក់) តម្រង់ជួរនៅម៉ាស៊ីនអេធីអឹម ទីភ្នាក់ងារ ឬសាខាធនាគារ • មិនអាចធ្វើការទូទាត់តាមឌីជីថលនៅជិតផ្ទះ ឬកន្លែងធ្វើការរបស់ខ្ញុំបានទេ។ • ប្រព័ន្ធប្រតិបត្តិការ និងសេវាកម្មអតិថិជន មិនមានជាភាសារបស់ខ្ញុំទេ។

សារសំខាន់

• នៅពេលអ្នកទទួលបានប្រាក់ឈ្នួលសម្រាប់ការងាររបស់អ្នកតាមប្រព័ន្ធឌីជីថល អ្នកមិនទទួលបានប្រាក់ឈ្នួលជាសាច់ប្រាក់ទេ។ ប្រាក់ទាំងអស់ចូលទៅក្នុងគណនីដែលអ្នកគ្រប់គ្រង។ វាជាមធ្យោបាយសុវត្ថិភាពក្នុងការទទួលបានប្រាក់ឈ្នួលរបស់អ្នកទាន់ពេល។

• ត្រូវប្រាកដថានិយោជករបស់អ្នក សហជីព ឬតំណាងកម្មកររបស់អ្នក ដើម្បីយល់ពី ស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកទាក់ទងនឹងការទូទាត់ប្រាក់ឈ្នួលឌីជីថល។ មានអារម្មណ៍ជឿជាក់ក្នុងការត្រួតពិនិត្យជាមួយនិយោជករបស់អ្នក!

• ប្រសិនបើរោងចក្ររបស់អ្នកកំពុងបើកប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលរួចហើយ អ្នកក៏គួរមានសិទ្ធិសម្រេចថា តើអ្នកចង់ឲ្យបញ្ជូនប្រាក់ទៅគណនីធនាគារ ឬគណនីប្រាក់ចល័ត។

• ការទូទាត់តាមឌីជីថល អាចមានអត្ថប្រយោជន៍ជាច្រើន៖ វាលឿន សុវត្ថិភាព វាអាចធ្វើឲ្យការសន្សំកាន់តែងាយស្រួល និងអាចជួយឲ្យអ្នកទទួលបានសេវាហិរញ្ញវត្ថុផ្សេងទៀត។ វាក៏អាចមានគុណវិបត្តិមួយចំនួនផងដែរ៖ ថ្លៃសេវា វត្តមានម៉ាស៊ីនអេធីអឹម/ភ្នាក់ងារដកប្រាក់ និងសេវាកម្មអតិថិជនជាភាសាផ្ទាល់ខ្លួនរបស់អ្នក។

• ការទាក់ទងជាមួយស្ថាប័នហិរញ្ញវត្ថុផ្លូវការដែលផ្តល់គណនីហិរញ្ញវត្ថុឌីជីថល មានន័យថាអ្នកត្រូវបានការពារដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងស្ថាប័នទាំងនេះ។

• ត្រូវប្រាកដថាអ្នកដកប្រាក់ដែលអ្នកត្រូវការតាមចរិការបស់អ្នកតែប៉ុណ្ណោះពីគណនីរបស់អ្នក។ តាម វិធីនោះ អ្នកទំនងជាមិនសូវចំណាយប្រាក់លើអ្វីមួយដែលមិនមាននៅក្នុងចរិការបស់អ្នកឡើយ ហើយអ្នកសន្សំបានកាន់តែច្រើន ដើម្បីខិតទៅជិតគោលដៅរបស់អ្នក។

ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ
ជំនួយការបណ្តុះបណ្តាល ខ.៤.១
តារាងតាមដានប្រាក់ចំណូល

តារាងតាមដានប្រាក់ចំណូល

ឈ្មោះ៖ _____
ខែ៖ _____
ឆ្នាំ៖

កាលបរិច្ឆេទ	ការពិពណ៌នាអំពីប្រភពចំណូល	ចំណូល
ចំណូលសរុប		

ជំនួយការបណ្តុះបណ្តាល ខ.៤.២


តារាងតាមដានការចំណាយ

តារាងតាមដានការចំណាយ

ឈ្មោះ៖ _____
ខែ៖ _____
ឆ្នាំ៖ _____

កាលបរិច្ឆេទ	ការពិពណ៌នាអំពីការចំណាយ	ចំនួនប្រាក់ដែលបានចំណាយ	បានគ្រោងទុក ឬ មិនបានគ្រោងទុក	
			បានគ្រោងទុក	មិនបានគ្រោងទុក
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐
			☐	☐

ការចំណាយសរុប	
ចំណូលសរុប	
ប្រាក់សន្សំ (=**ចំណូល** – **ចំណាយ**)	



ល្បង

ស្វែងយល់ពីវិធីសន្សំប្រាក់ និងប្រភេទនៃការសន្សំប្រាក់

ក១. តាមទស្សនៈរបស់អ្នក តើអ្វីទៅជាវិធីដ៏ល្អបំផុតក្នុងការសន្សំប្រាក់?

- ☐ **ក.** ខ្ញុំទុកលុយនៅបន្ទប់ស្នាក់នៅ ឬផ្ទះខ្ញុំ ព្រោះវាស្រួលជាង។
- ☐ **ខ.** ខ្ញុំដាក់ប្រាក់នៅធនាគារ ព្រោះវាមានសុវត្ថិភាពជាង។
- ☐ **គ.** ខ្ញុំបង្វិលលុយក្នុងចំណោមមិត្តភក្តិ ព្រោះខ្ញុំមានមិត្តភក្តិជាច្រើននៅទីនោះ។
- ☐ **ឃ.** វិធីសាស្ត្រនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិ។ ខ្ញុំពិនិត្យមើលពួកវាដោយប្រុងប្រយ័ត្នមុននឹងជ្រើសរើសវិធីសាស្ត្រដែលសមស្របបំផុតសម្រាប់តម្រូវការរបស់ខ្ញុំ។

ក២. អ្នកមានប្រាក់សន្សំខ្លះ ហើយអ្នកមានគម្រោងប្រើវា នៅឆ្នាំក្រោយប៉ុណ្ណោះ។ តើគណនីសន្សំមួយណាដែលសមស្របបំផុតសម្រាប់អ្នក?

- ☐ **ក.** គណនីសន្សំធម្មតា។
- ☐ **ខ.** គណនីសន្សំតាមកិច្ចសន្យា។
- ☐ **គ.** គណនីប្រាក់បញ្ញើមានពេលវេលាកំណត់។

ក៣. លក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យដែលត្រូវពិចារណានៅពេលជ្រើសរើសវិធីសាស្ត្រសន្សំគឺសុវត្ថិភាព។?

- ☐ **ក.** ពិត
- ☐ **ខ.** មិនពិត


ឆ្លើយ៖ ក១៖ ខ ក២៖ គ ក៣៖ ក ប្រភព៖



១. ជ្រើសរើសវិធីសន្សំប្រាក់!

ឥឡូវនេះអ្នកបានបង្កើតថវិកាផ្ទាល់ខ្លួនរបស់អ្នក (ឬថវិកាគ្រួសាររបស់អ្នក) អ្នកដឹងថាអ្នកអាចសន្សំបានប៉ុន្មានជារៀងរាល់ខែ និងចំនួនប៉ុន្មានដែលអ្នកត្រូវសន្សំសម្រាប់គោលដៅនីមួយៗរបស់អ្នក។

ជំនួយការបណ្តុះបណ្តាល ត.១.១
វិធីសាស្ត្រសន្សំ



សុភាព សន្សំប្រាក់មួយផ្នែកក្នុងប្រអប់តូចមួយនៅក្នុងបន្ទប់ដែលនាងរស់នៅរួមគ្នាជាមួយកម្មករផ្សេងទៀត។



ចិន្តា ប្រពន្ធរបស់បូវ៉ាន សន្សំប្រាក់នៅក្នុងក្រុមសន្សំប្រាក់ស្ត្រីភូមិជាមួយគ្រូៗផ្សេងទៀតនៅសាលារបស់នាង។ នាងចូលចិត្តសន្សំប្រាក់នៅទីនោះ ហើយជួបស្ត្រីផ្សេងទៀតនៅក្នុងក្រុមរបស់នាងជាទៀងទាត់។



ឈារី ណារីចូលចិត្តរក្សាទុកប្រាក់សន្សំផ្ទាល់ខ្លួននៅគណនីធនាគារដែលនាងទទួលបានប្រាក់ខែ។ ធ្វើបែបនេះនាងមិនត្រូវបានល្បួងឲ្យចំណាយប្រាក់ដែលនាងបានសន្សំទុកឡើយ។



រក្សា រស្មី បានបង្កើតក្រុមជាមួយកម្មកររផ្សេងទៀតនៅក្នុងរោងចក្រដូចគ្នា ហើយពួកគេជំរុញការកម្មវិធីសន្សំ និងឥណទានបង្វិលជុំក្នុងចំណោមពួកគេ (តុងទីន)

សំណួរ

- តើវិធីសន្សំប្រាក់បែបណាខ្លះដែលត្រូវប្រើដោយតួអង្គខាងលើ?

- តើវិធីទាំងនេះ មានលក្ខណៈផ្លូវការ ពាក់កណ្តាលផ្លូវការ ឬក្រៅផ្លូវការ?

- វិធីសាស្ត្រនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិរបស់វា។ នៅចុងបញ្ចប់នៃមេរៀននេះ នៅក្នុងផ្នែក ចម្លើយសម្រាប់លំហាត់ អ្នកនឹងឃើញតារាងដែលសង្ខេបពីគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្រសន្សំ នីមួយៗ។

ចូរចងចាំថា ដើម្បីជាក់បញ្ជូលលក្ខណៈបន្ថែមទៀតនៅក្នុងតារាង អ្នកអាចគិតអំពីៈ

- សុវត្ថិភាពនៃប្រាក់របស់អ្នកនៅទីនោះ
- លទ្ធភាពដកប្រាក់របស់អ្នកនៅពេលអ្នកចង់
- ការពន្យារពេលដែលអាចកើតមានក្នុងការដកប្រាក់របស់អ្នក
- លទ្ធភាពក្នុងការសន្សំបានច្រើន ឬច្រើនជាងមុនបន្តិច។
- លទ្ធភាពទទួលបានឥណទានធៀបនឹងប្រាក់សន្សំរបស់អ្នក
- លទ្ធភាពដែលប្រាក់សន្សំរបស់អ្នកបង្កើតប្រាក់មួយចំនួន (ការប្រាក់)។



⚠ **ចំណុចសំខាន់ៈ** ការជ្រើសរើសវិធីសាស្ត្រសន្សំដែលមានសុវត្ថិភាព អាចជួយអ្នកឲ្យមានអារម្មណ៍ ធូរស្រាល។ ប្រសិនបើជានិច្ចជាកាល អ្នកព្រួយបារម្ភអំពីសុវត្ថិភាពលុយរបស់អ្នក សូមគិតមើលថាតើ ជំណោះស្រាយណាមួយដែលអ្នកអាចជ្រើសរើស ដើម្បីឈប់ឲ្យមានការព្រួយបារម្ភ។



ចុះអ្នកវិញម្តង!

ខ្ញុំដឹងពីគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសន្សំប្រាក់មួយចំនួន។ ពិនិត្យមើលគោលដៅ និងថវិការបស់ខ្ញុំម្តងទៀត ខ្ញុំគិតថាវិធីសន្សំប្រាក់ដ៏ល្អបំផុតសម្រាប់គម្រោងរបស់ខ្ញុំគឺ៖

គោលដៅរបស់ខ្ញុំ	វិធីសន្សំប្រាក់

សារសំខាន់

- ការសន្សំផ្តល់សុវត្ថិភាពក្នុងករណីមានអាសន្ន។
- តម្រូវការ/ភាពអាសន្នខ្លះ អាចត្រូវបានរំពឹងទុកជាមុន ខ្លះទៀតមិនអាច។ ការសន្សំប្រាក់អាចឲ្យអ្នករៀបចំផែនការសម្រាប់តម្រូវការ ឬគម្រោងនាពេលអនាគត។
- នៅពេលអ្វីៗដំណើរការល្អ ការសន្សំក៏អាចឲ្យអ្នករៀបចំផែនការសម្រាប់អ្វីដែលអ្នកចង់ធ្វើ ឬចង់បាន។
- អ្នកត្រូវដឹងពីវិធីសន្សំផ្សេងៗគ្នា ដើម្បីជ្រើសរើសវិធីមួយដែលសមស្របបំផុតទៅនឹងតម្រូវការរបស់អ្នក។



២. ជ្រើសរើសជម្រើសសម្រាប់ការសន្សំប្រាក់របស់អ្នកដោយឆ្លាតខៃ

ឧទាហរណ៍ ជម្រើសសម្រាប់ការសន្សំប្រាក់ គឺជាគណនីសន្សំធម្មតាដែលផ្តល់ការប្រាក់ ៤% ឬគណនីសន្សំប្រាក់ (មានពេលកំណត់) រយៈពេលប្រាំឆ្នាំ។

និយមន័យ

ជម្រើសសម្រាប់សន្សំប្រាក់ គឺជាវិធីសន្សំប្រាក់ដែលយើងដឹងពីលក្ខណៈនានាដូចជា៖

- អត្រាការប្រាក់ និងអត្ថប្រយោជន៍ពន្ធ
- ចូលពិនិត្យមើលសន្សំប្រាក់ / ភាពបត់បែននៃការដកប្រាក់
- ភាពងាយស្រួល និងភាពងាយស្រួលនៃការប្រើប្រាស់
- តម្រូវការសម្រាប់ការបើកគណនីសន្សំ
- សុវត្ថិភាព
- ការចំណាយសម្រាប់ការសន្សំប្រាក់ (ថ្លៃបើក គ្រប់គ្រង ឬបិទគណនី ប្រតិបត្តិការដកជាក់)
- សាច់ប្រាក់
- គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រសន្សំរបស់អ្នក។
- លទ្ធភាពប្រើអ៊ីនធឺណិត

នេះគឺជាជម្រើសនៃការសន្សំប្រាក់សំខាន់ៗចំនួនបីដែលផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុ៖

គណនីសន្សំធម្មតា ត្រូវបានកែសម្រួលសម្រាប់នៅពេលអ្នកចង់ដាក់ប្រាក់ ឬចូលពិនិត្យមើលប្រាក់របស់អ្នកគ្រប់ពេល។

គណនីសន្សំគោលដៅ/តាមកិច្ចកិច្ចសន្យា ត្រូវបានកែសម្រួលនៅពេលដែលអ្នកចង់សន្សំប្រាក់ក្នុងចំនួនដែលបានកំណត់ជារៀងរាល់ខែ សម្រាប់រយៈពេលដាក់លាក់មួយ ដើម្បីសម្រេចគោលដៅដាក់លាក់មួយ (ផ្ទះ ការអប់រំ អាពាហ៍ពិពាហ៍ អាជីវកម្ម...)។ សូមចងចាំថាការដកប្រាក់មុនពេល ត្រូវហាមឃាត់ ឬពិន័យ។ ធនាគារជាច្រើនហៅជម្រើសនេះថា គណនីប្រាក់បញ្ញើតាមដំណាក់កាល ហើយអ្នកមិនចាំបាច់បញ្ជាក់គោលដៅរបស់អ្នកជាមុនទេ។

ពេលវេលា (មានកំណត់) គណនីប្រាក់បញ្ញើ ត្រូវបានកែសម្រួល ប្រសិនបើអ្នកចង់ធ្វើឲ្យប្រាក់របស់អ្នកកើនឡើង សម្រាប់គោលដៅរយៈពេលវែង (អ្នកដាក់ប្រាក់មួយដុំដែលអ្នកសន្យាថានឹងមិនប៉ះពាល់ក្នុង រយៈពេលដាក់លាក់ណាមួយ)។



ជម្រើសនីមួយៗ មានគុណសម្បត្តិ និងគុណវិបត្តិ (ឧទាហរណ៍ អត្រាការប្រាក់ខុសគ្នា)។

នៅទំព័របន្ទាប់ អ្នកនឹងឃើញខិត្តប័ណ្ណចំនួនបី សម្រាប់ជម្រើសនីមួយៗ ។ នៅចុងបញ្ចប់នៃមេរៀននេះ នៅក្នុងផ្នែក ចម្លើយសម្រាប់លំហាត់ អ្នកនឹងឃើញតារាងប្រៀបធៀបដែលសង្ខេបព័ត៌មានពីខិត្តប័ណ្ណនីមួយៗ។

ជំនួយការបណ្តុះបណ្តាល គ.២.១

ខិត្តប័ណ្ណសម្រាប់គណនីសន្សំធម្មតា

គណនីសន្សំធម្មតា



អាចពិនិត្យមើលប្រាក់របស់អ្នកគ្រប់ពេល

មធ្យោបាយងាយស្រួល សាមញ្ញ និងងាយស្រួលក្នុងការរក្សាទុក និងដកប្រាក់របស់អ្នកនៅពេលណាក៏បាននៅពេលដែលអ្នកត្រូវការ។ វិធីដែលមានប្រសិទ្ធភាព និងសុវត្ថិភាពបំផុតរបស់អ្នកដើម្បីចាប់ផ្តើមសន្សំ ប្រាក់។ គណនីសន្សំធម្មតារបស់យើងផ្តល់នូវភាពបត់បែនក្នុងការគ្រប់គ្រងប្រាក់របស់អ្នក។ វាអនុញ្ញាតឲ្យអ្នកបង្កើនដើមទុនរបស់អ្នកតាមពេលវេលា តាមល្បឿនផ្ទាល់ខ្លួនរបស់អ្នក។

គុណសម្បត្តិ

- ជម្រើសគ្មានហានិភ័យ
- ប្រាក់សន្សំរបស់អ្នកមានសុវត្ថិភាព
- អត្រាការប្រាក់៖ រហូតដល់ ១% ជាដុល្លារ និង ១.៥% ជាប្រាក់រៀល
- អ្នកអាចដាក់ប្រាក់បានគ្រប់ពេលវេលា តាមចំនួនដងដែលអ្នកចង់ដាក់
- អ្នកអាចដកប្រាក់របស់អ្នកបានគ្រប់ពេល និងដោយគ្មានការជូនដំណឹងជាមុន
- មិនគិតថ្លៃសេវា នៅក្នុងប្រតិបត្តិការរបស់អ្នកទាំងអស់ នៅពេលប្រើប្រាស់បណ្តាញធនាគាររបស់យើង។
- ដោយមិនគិតថ្លៃសម្រាប់ការបើក និងបិទគណនីរបស់អ្នក (ប្រសិនបើអ្នកបិទមុនពេលបើក ៣ ខែ អ្នកនឹងត្រូវបង់ថ្លៃ ២០ ដុល្លារសម្រាប់ការបិទជាមុន)
- ការដាក់ប្រាក់អប្បបរមា៖ ១០ដុល្លារ
- សន្សំសម្រាប់គ្រាអាសន្ន
- ប័ណ្ណឥតគិតថ្លៃសម្រាប់ដាក់ប្រាក់ ឬដកប្រាក់ពីម៉ាស៊ីនអេធីអឹម ប្រើម៉ាស៊ីនអេធីអឹមណាមួយក្នុងប្រទេស
- ចូលប្រើគណនីរបស់អ្នកដោយឥតគិតថ្លៃតាមរយៈកម្មវិធីទូរស័ព្ទរបស់យើង។

រយៈពេល៖ បើកចំហ

លក្ខខណ្ឌ:

- ត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសុពលភាព
- បំពេញទម្រង់ពាក្យសុំ

ជំនួយការបណ្តុះបណ្តាល គ.២.២

ខិត្តប័ណ្ណសម្រាប់គណនីសន្សំគោលដៅ/តាមកិច្ចសន្យា



ប្រសិនបើអ្នកពិតជាចង់សន្សំប្រាក់សម្រាប់អនាគតរបស់អ្នក

គណនីដាក់ប្រាក់តាមដំណាក់កាលគឺជាការសន្សំប្រាក់រយៈពេលវែង។ វាគឺជាកន្លែងដែលអ្នកដាក់ចំនួនទឹកប្រាក់ដែលបានកំណត់ឬតាមដំណាក់កាលទៅក្នុងគណនីប្រចាំថ្ងៃ ឬប្រចាំខែសម្រាប់រយៈពេលកំណត់មួយ ហើយប្រាក់របស់អ្នកនឹងកើនឡើង។ ពេលផុតរយៈពេលកំណត់ហើយ អ្នកដកប្រាក់ដើមនិងការប្រាក់ចេញនៅពេលតែមួយ។

គណនីនេះ ធ្វើឲ្យគោលដៅនៃការសន្សំប្រាក់របស់អ្នកកាន់តែងាយស្រួល។ តាមជម្រើសនេះ អ្នកអាចដាក់ប្រាក់ជាមុននៅពេលណាក៏បាន ដើម្បីបំពេញកាតព្វកិច្ចដាក់ប្រាក់ប្រចាំខែរបស់អ្នក។ អ្នកអាចជ្រើសរើសពី ៦ ទៅ ៣៦ ខែជាមួយនឹងអត្រាការប្រាក់ខុសៗគ្នា។

លក្ខណៈសំខាន់ៗ

- អត្រាការប្រាក់រហូតដល់ ៥% ក្នុងមួយឆ្នាំគិតជាដុល្លារសម្រាប់រយៈពេល ៣៦ ខែ
- អត្រាការប្រាក់រហូតដល់ ៧% ក្នុងមួយឆ្នាំជាប្រាក់រៀលសម្រាប់រយៈពេល ៣៦ ខែ
- ដាក់ប្រាក់យ៉ាងតិច ២០ ដុល្លារ ដើម្បីបើកគណនី
- ឥតគិតថ្លៃសម្រាប់ការបើក ធ្វើប្រតិបត្តិការ និងបិទគណនីរបស់អ្នក។
- ប្រាក់សន្សំរបស់អ្នក មិនអាចដកបាន រហូតដល់ចុងបញ្ចប់នៃរយៈពេលដែលអ្នកបានជ្រើសរើស
- ប្រសិនបើអ្នករំពឹងថាធ្វើការដកប្រាក់នៅពេលណាមួយ អ្នកមិនបង់ថ្លៃសេវាទេ ប៉ុន្តែអ្នកបាត់បង់ ការប្រាក់មួយផ្នែក

លក្ខខណ្ឌ

- អត្តសញ្ញាណប័ណ្ណដែលមានសុពលភាព (អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន ឬឯកសារកំណត់អត្តសញ្ញាណស្របច្បាប់ និងត្រឹមត្រូវផ្សេងទៀត)
- លិខិតបញ្ជាក់ទីលំនៅ



រយៈពេល៖
ជ្រើសរើសពី ៦ ខែ ដល់ ៣៦ ខែ។

ជំនួយការបណ្តុះបណ្តាល គ.២.៣

ខិតប័ណ្ណគណនីបញ្ញើរ (មានកាលកំណត់)

គណនីមានកាលកំណត់



ធ្វើឲ្យប្រាក់របស់អ្នករកប្រាក់បន្ថែមឲ្យអ្នក

ជាមួយនឹងប្រាក់បញ្ញើមានកាលកំណត់របស់យើង អ្នកធ្វើឲ្យប្រាក់របស់អ្នកប្រឹងធ្វើការឲ្យអ្នក និងដឹងច្បាស់អំពីអ្វីដែលអ្នកនឹងទទួលបាន។ គណនីប្រាក់បញ្ញើមានកាលកំណត់ អាចបើកជាប្រាក់ដុល្លារ និងប្រាក់រៀលនៅគ្រប់សាខា ឬគ្រាន់តែចុចពីរបីដងនៅលើកម្មវិធីទូរស័ព្ទរបស់យើង!

គណនីនេះជួយអ្នកឲ្យទទួលបានអត្រាការប្រាក់ខ្ពស់។ ប្រាក់ដែលអ្នកវិនិយោគក្នុងគណនីនេះ មិនអាចដកបានមុនពេលផុតកាលកំណត់ ហើយវាល្អឥតខ្ចោះសម្រាប់ការវិនិយោគនាពេលអនាគតរបស់អ្នក និងការចំណាយសំខាន់ៗដែលអ្នកកំពុងរៀបចំផែនការ។ គណនីដ៏ល្អឥតខ្ចោះដើម្បីកុំឲ្យមានការល្បួងឲ្យប្រើការសន្សំរបស់អ្នក ខណៈពេលដែលទទួលបានផលចំណេញមកវិញលើដើមទុនរបស់អ្នក។



រយៈពេល៖ ពី ១ ខែ ដល់ ៥ ឆ្នាំ

លក្ខណៈសំខាន់ៗ

- អត្រាការប្រាក់ខ្ពស់បំផុតនៅលើទីផ្សារ - រហូតដល់ ៩% ជាប្រាក់រៀល ឬ ៦% ជាដុល្លារ។
- អត្រាត្រូវបានកំណត់ និងដឹងជាមុន។
- ការដាក់ប្រាក់អប្បបរមា៖ ៤00,000 រៀល ឬ ១00 ដុល្លារ
- ឥតគិតថ្លៃសម្រាប់ការបើក ប្រតិបត្តិការ និងបិទគណនី
- ប្រាក់បញ្ញើដែលអាចបត់បែនបាន៖ អ្នកអាចបន្ថែមប្រាក់នៅពេលណាដែលអ្នកអាចធ្វើបាន
- ការដកប្រាក់មុនពេលកំណត់ មិនត្រូវបានអនុញ្ញាតទេ។
- ជូនវិញ្ញាបនបត្រដាក់ប្រាក់ដោយឥតគិតថ្លៃ
- បង្កើតប្រវត្តិសន្សំប្រាក់របស់អ្នកជាមួយយើង និងចូលប្រើឥណទានសម្រាប់គម្រោងរបស់អ្នក។
- បំណុលឥណទានឥតគិតថ្លៃសម្រាប់ការដាក់ប្រាក់លើសពី ៣,000 ដុល្លារ

លក្ខខណ្ឌ

- ភស្តុតាងនៃប្រភពដើមនៃមូលនិធិ
- អត្តសញ្ញាណប័ណ្ណដែលមានសុពលភាព (អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន ឬឯកសារបញ្ជាក់អត្តសញ្ញាណស្របច្បាប់ និងត្រឹមត្រូវផ្សេងទៀត)

ឥឡូវនេះអ្នកដឹងបន្ថែមអំពីជម្រើសនៃការសន្សំប្រាក់ផ្សេងៗ ជួយតួអង្គរបស់យើងក្នុងការសម្រេចចិត្តថាតើគណនីសន្សំមួយណាដែលពួកគេគួរតែបើក ដើម្បីជួយពួកគេសម្រេចបាននូវគោលដៅរបស់ពួកគេ។

ជំនួយការបណ្តុះបណ្តាល គ.២.៤

ការផ្គូរផ្គងគោលដៅទៅនឹងស្ថានភាពសម្រាប់ជម្រើសនៃការសន្សំប្រាក់



MATCHING GOALS TO SAVINGS PRODUCTS SITUATION CARDS

ស្ថានភាពទី ១

សុភាពអាចសន្សំបានប្រហែល២០ដុល្លារជារៀងរាល់ខែក្នុងប្រអប់តូចមួយនៅក្នុងបន្ទប់របស់នាង។ ពេលខ្លះនាងមានអារម្មណ៍ថាមិនមានសុវត្ថិភាពក្នុងការមានលុយនេះជាសាច់ប្រាក់នៅក្នុងបន្ទប់របស់នាង។ នាងដឹងតាមរយៈអ្នកគ្រប់គ្រងរោងចក្រថា ឥឡូវនេះនាងអាចទទួលបានប្រាក់ឈ្នួលតាមរយៈគណនី ធនាគារ។ នាងឆ្ងល់ថាតើវាប្រសើរជាងសម្រាប់នាងក្នុងការសន្សំប្រាក់នេះនៅក្នុងធនាគារដែរឬទេ? នាងមិនចង់ឲ្យមានការល្បួងឲ្យចំណាយប្រាក់នេះ។ នាងមិនប្រាកដថាស្តាប់ន៍ផ្លូវការ នឹងយកនាងជាអតិថិជនទេ ប៉ុន្តែនាងចង់សាកល្បង។

តើនាងអាចជ្រើសរើសគណនីសន្សំប្រភេទណា?

ការអប់រំផ្នែកហិរញ្ញវត្ថុ



MATCHING GOALS TO SAVINGS PRODUCTS SITUATION CARDS

ស្ថានភាពទី ២

ការផ្ទេរប្រាក់របស់បូរ៉ានជារៀងរាល់ខែទៅកាន់ចិន្តា គឺធ្វើឡើងតាមរយៈប្រតិបត្តិការផ្ទេរប្រាក់។ ខណៈពេលដែលប្រាក់ភាគច្រើនត្រូវបានប្រើប្រាស់ដើម្បីសងបំណុលសម្រាប់ការទិញម៉ូតូ និងតម្រូវការចាំបាច់ ពួកគេរក្សាមួយចំណែកតូចជាប្រាក់សន្សំនៅផ្ទះ និងមួយផ្នែកទៀត ចិន្តាដាក់សន្សំនៅក្នុងក្រុមសន្សំស្ត្រីភូមិឃុំរបស់នាងជារៀងរាល់ខែ។ ពួកគេមានគោលបំណងជាច្រើន ដែលសំខាន់បំផុតគឺត្រូវសន្សំឲ្យបានគ្រប់គ្រាន់សម្រាប់ការមានផ្ទះផ្ទាល់ខ្លួន។ ចិន្តាបានឮថាមិត្តរួមការងារនៅសាលាកាន់តែច្រើនឡើង កំពុងបើកគណនីធនាគារ។ នាងចង់បើកគណនីមួយ ពីព្រោះនាងក៏បានឮថាពួកគេផ្តល់គណនីប្រភេទផ្សេងគ្នាសម្រាប់គោលដៅផ្សេងគ្នា។ ក្នុងករណីរបស់ពួកគេ នាងចង់បានគណនីដែលជួយនាងមិនឲ្យមានការល្បួងឲ្យប្រើលុយរបស់ពួកគេសម្រាប់គោលបំណងផ្សេងទៀត។ ប្រសិនបើអាចធ្វើបាន ពួកគេចង់ទទួលបាន អត្រាការប្រាក់ខ្ពស់បំផុត។

តើពួកគេអាចជ្រើសរើសគណនីសន្សំប្រភេទណា?

ការអប់រំផ្នែកហិរញ្ញវត្ថុ

MATCHING CARDS TO SAVINGS PRODUCTS SITUATION CARDS



ស្ថានភាពទី ៣

ណារីបានធ្វើការច្រើនម៉ោងបន្ថែមនាពេលថ្មីៗនេះ ហើយសន្សំប្រាក់បានជាប់លាប់ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ដើម្បីទិញសម្ភារៈដែលត្រូវការសម្រាប់សាងសង់បន្ទប់បន្ថែមនៅក្នុងផ្ទះរបស់នាង។ នាងដឹងថានាងមិនប្រើលុយនេះសម្រាប់គោលបំណងផ្សេងទេ ហើយនាងក៏ដឹងថានាងនឹងមិនអាចមានលុយទាំងអស់ដែលនាងត្រូវការរហូតដល់ឆ្នាំក្រោយ។

តើនាងអាចជ្រើសរើសគណនីសន្សំប្រភេទណា?

ការអប់រំផ្នែកហិរញ្ញវត្ថុ

MATCHING CARDS TO SAVINGS PRODUCTS SITUATION CARDS



ស្ថានភាពទី ៤

រក្សាសន្សំរាល់ខែ។ ប្រាក់ភាគច្រើនរបស់នាងត្រូវបានចំណាយលើតម្រូវការរបស់នាង ប៉ុន្តែនាងរក្សាមួយផ្នែកតូចនៅក្នុងក្រុមសន្សំបង្វិលជាមួយសហការីរបស់នាង។ ឥឡូវនេះ នាងដឹងតាមរយៈអ្នកតំណាង រោងចក្រថា នាងអាចទទួលបានប្រាក់តាមគណនីធនាគារ។ នាងមិនច្បាស់ថាតើវាប្រសើរជាងសម្រាប់នាងក្នុងការសន្សំប្រាក់នេះនៅក្នុងធនាគារជាជាងបន្តសន្សំប្រាក់ជាមួយក្រុមរបស់នាងដែរឬទេ។ នាងមិនចង់ឲ្យមានការល្បួងក្នុងការចំណាយប្រាក់នេះទេ ហើយចង់រក្សាទុកវាឲ្យមានសុវត្ថិភាព។ នាងមិនប្រាកដថាស្ថាប័នផ្លូវការនឹងយកនាងធ្វើជាអតិថិជនដែរឬទេ ហើយនាងក៏មិនច្បាស់ថា នាងនឹងយល់ពីលក្ខខណ្ឌទាំងអស់របស់ពួកគេដែរ ប៉ុន្តែនាងចង់សាកល្បង។

តើនាងអាចជ្រើសរើសគណនីសន្សំប្រភេទណា?

ការអប់រំផ្នែកហិរញ្ញវត្ថុ

គន្លឹះសំខាន់

ជម្រើសនីមួយៗ មានគុណសម្បត្តិ និងគុណវិបត្តិរបស់វា (ឧទាហរណ៍ អត្រាការប្រាក់ខុសគ្នា)។ ដើម្បីជ្រើសរើសជម្រើសនៃការសន្សំប្រាក់ អ្នកមិនត្រឹមតែត្រូវដឹងពីលក្ខណៈនានានៃជម្រើសផ្សេងៗគ្នាប៉ុណ្ណោះទេ។ អ្នកក៏គួរស្គាល់ខ្លួនឯងឲ្យបានច្បាស់ ដោយសួរដូចខាងក្រោម៖

- ស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក៖ តើអ្នកមានចំណូលប៉ុន្មាន? ការចំណាយរបស់អ្នក (រួមទាំងការសងបំណុល)? តើអ្នកសន្សំបានប៉ុន្មាន? តើអ្នកសន្សំទុកប៉ុន្មាននៅពេលមិនមានបញ្ហាអ្វី? តើអ្នកអាចសន្សំទុកបានប៉ុន្មាន នៅពេលគ្រប់គ្រងលុយរបស់អ្នកបានល្អ?
- គោលដៅរបស់អ្នក៖ តើអ្នកចង់សន្សំក្នុងគោលបំណងអ្វី? សម្រាប់គ្រាអាសន្ន? សិក្សា? ដើម្បីវិនិយោគបង្កើតអាជីវកម្ម? ដើម្បីត្រឡប់ទៅផ្ទះរបស់អ្នក? សម្រាប់កន្លែងស្នាក់នៅ? សម្រាប់ការចូលនិវត្តន៍?
- ការរំពឹងទុក៖ តើអ្នកចង់សន្សំប្រាក់/រក្សាទុកប្រាក់របស់អ្នករយៈពេលប៉ុន្មាន?
- អាកប្បកិរិយារបស់អ្នក៖ តើអ្នកចង់ប្រថុយឬអត់? កុំធ្វើការវិនិយោគដែលមានហានិភ័យ ប្រសិនបើអ្នកមិនដឹងច្បាស់អំពីទីផ្សារហិរញ្ញវត្ថុនោះទេ!

⚠ ចូរប្រយ័ត្នចំពោះការផ្សាយពាណិជ្ជកម្មមិនពិត! សូមចងចាំថា គ្មានជម្រើសនៃការសន្សំប្រាក់ណាអាចធានាអ្នកនូវប្រាក់ចំណូលខ្ពស់ ជាពិសេសក្នុងរយៈពេលដ៏ខ្លី ដោយគ្មានហានិភ័យនោះទេ ។

តើសំណួរអ្វីខ្លះដែលត្រូវសួរស្ថាប័នហិរញ្ញវត្ថុមុនពេលជ្រើសរើសជម្រើសនៃការសន្សំប្រាក់របស់អ្នក?

- *តើខ្ញុំអាចដកប្រាក់នៅពេលណាដែលខ្ញុំចង់ដកបានដែរឬទេ?*
- *តើទទួលបានអត្រាការប្រាក់ប៉ុន្មាន?*
- *តើខ្ញុំត្រូវបង់ពន្ធលើអត្រាការប្រាក់ដែរឬទេ? បើបង់ពន្ធ តើប៉ុន្មាន?*
- *តើខ្ញុំអាចដកប្រាក់កម្ចីធៀបនឹងនឹងប្រាក់សន្សំរបស់ខ្ញុំបានទេ?*
- *តើកាលកំណត់ដាក់ប្រាក់សន្សំ អាចបត់បែនបានទេ? (និយាយម្យ៉ាងទៀត តើអ្នកត្រូវដាក់ប្រាក់មួយចំនួនទៅតាមកាលបរិច្ឆេទកំណត់ទេ?)*
- *តើត្រូវដាក់ប្រាក់បញ្ចើជាអប្បបរមានៅពេលខ្ញុំបើកគណនីសន្សំ ឬចំនួនអប្បបរមាដែលគួរតែមានក្នុងគណនីជានិច្ចដែរឬទេ?*
- *តើត្រូវគិតថ្លៃពីការធ្វើការដកប្រាក់ដែលបានរំពឹងទុកឬ? បើគិតថ្លៃ តើគិតតម្លៃប៉ុន្មាន?*
- *តើជាធម្មតា គណនីប្រភេទនេះត្រូវបានប្រើប្រាស់ដោយរបៀបណា?*

សារសំខាន់ៗ

- មានជម្រើសនៃការសន្សំប្រាក់សមស្រប សម្រាប់គោលដៅសន្សំប្រាក់នីមួយៗ ។

⚠ ចំណុចសំខាន់ ៖ ការចូលទៅក្នុងស្ថាប័នហិរញ្ញវត្ថុដើម្បីសួរសំណួរទាំងនេះ អាចធ្វើឲ្យអ្នកភ័យខ្លាច ឬ ថប់បារម្ភ។ ត្រូវចាំថា អ្នកតែងតែអាចសុំមិត្តភក្តិ ឬមិត្តរួមការងារមកជំនួសអ្នកហូតទាល់តែអ្នកមានអារម្មណ៍ជឿជាក់ក្នុងការទៅម្នាក់ឯង។

ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ

លក្ខណៈដែលត្រូវពិចារណានៅពេលជ្រើសរើសវិធីសន្សំប្រាក់

<u>ភាពងាយស្រួលប្រើប្រាស់ / ការដកប្រាក់ដែលអាចបត់បែនបាន</u>
នេះសំដៅលើរបៀបដែលងាយស្រួល ឬពិបាកសម្រាប់មនុស្សម្នាក់ក្នុងការដកប្រាក់សន្សំរបស់ពួកគេ។ ឧទាហរណ៍ តើការដកប្រាក់ប៉ុន្មានដែលម្ចាស់គណនីត្រូវបានអនុញ្ញាតឲ្យដកចេញពីគណនីបស់គាត់ក្នុងមួយខែ ឬថាតើធនាគារ ឬស្ថាប័នហិរញ្ញវត្ថុមានម៉ាស៊ីនអេធីអឹម ឬសាខានៅគ្រប់តំបន់នៃប្រទេសដែរឬទេ (ធ្វើឲ្យវាកាន់តែងាយស្រួលសម្រាប់ម្ចាស់គណនីដើម្បីប្រើប្រាស់គណនីរបស់គាត់)។

<u>ភាពទាន់ចិត្ត និងភាពងាយស្រួលនៃការប្រើប្រាស់</u>
អតិថិជនចូលចិត្តភាពងាយស្រួលទាន់ចិត្ត និងចង់ដកប្រាក់ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍ មនុស្សមួយចំនួនចង់ឲ្យធនាគារបស់ពួកគេបើក នៅពេលដែលពួកគេខ្លួនឯងមិនធ្វើការ។

<u>តម្រូវការក្នុងការបើកគណនីសន្សំ</u>
មនុស្សជាច្រើនគិតថាអ្នកត្រូវមានជីវភាពធូរធារដើម្បីបើកគណនីធនាគារ។ នេះមិនតែងតែជាការពិតទេ។ ធនាគារខ្លះត្រូវការប្រាក់បញ្ញើតិចតួចបំផុត (ឬគ្មានទាំងអស់) ប្រសិនបើអ្នកចង់បើកគណនីសន្សំ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេអាចត្រូវការអត្តសញ្ញាណប័ណ្ណ ភស្តុតាងនៃលំនៅដ្ឋាន និង/ឬថ្លៃសេវា ដែលប្រហែលជាមិនមានភាពងាយស្រួលសម្រាប់មនុស្សជាច្រើនជាពិសេសជនភៀសខ្លួនដោយបង្ខំ។

<u>សុវត្ថិភាព</u>
នៅពេលដែលយើងជ្រើសរើសទុកលុយនៅផ្ទះ វាអាចមានហានិភ័យនៃការលួច ឬបាត់បង់។ ស្ថាប័ន ហិរញ្ញវត្ថុដែលគ្រប់គ្រងដោយរដ្ឋមួយចំនួនផ្តល់ការធានាដល់អ្នកសន្សំខ្នាតតូច។ ម្យ៉ាងវិញទៀត ប្រសិនបើធនគារទាំងនោះក្សីយធន អ្នកនឹងមិនបាត់បង់ប្រាក់សន្សំរបស់អ្នកឡើយ។

<u>អត្រាការប្រាក់ និងអត្ថប្រយោជន៍ពន្ធ</u>
នៅពេលអ្នកសន្សំប្រាក់ជាមួយស្ថាប័នផ្លូវការ (ឬពាក់កណ្តាលផ្លូវការ) អ្នកនឹងទទួលបានរង្វាន់សម្រាប់ការដាក់ប្រាក់របស់អ្នកជាមួយស្ថាប័នពាក់ព័ន្ធ។ រង្វាន់ ឬការប្រាក់ ដាទូទៅគឺជាភាគរយនៃចំនួនទឹកប្រាក់ដែលអ្នកបានដាក់។ វាក៏អាចមានអត្ថប្រយោជន៍ពន្ធក្នុងការសន្សំជាមួយស្ថាប័នផ្លូវការផងដែរ។

<u>សាច់ប្រាក់</u>
តើអ្នកអាចដកប្រាក់សន្សំចេញពីគណនីរបស់អ្នកបានទេ? តើដោយរបៀបណា និងក្នុងលក្ខខណ្ឌអ្វី? ប្រសិនបើអ្នកត្រូវការប្រាក់ជាបន្ទាន់ វិធីសាស្ត្រនៃការសន្សំដែលអ្នកបានជ្រើសរើសត្រូវតែអនុញ្ញាតឲ្យអ្នកដកប្រាក់របស់អ្នកទាំងអស់ក្នុងរយៈពេលជិតសមរម្យមួយ។ នៅក្នុងករណីនៃការសន្សំទ្រព្យផ្សេងៗ (ឧទាហរណ៍ ទ្រព្យសម្បត្តិ ឬសត្វពាហនៈ) អ្នកប្រហែលជាត្រូវរង់ចាំច្រើនថ្ងៃ ឬច្រើនខែ មុនពេលអ្នកអាចលក់ទ្រព្យសកម្មរបស់អ្នក និងទទួលបានសាច់ប្រាក់។


<u>ការចំណាយសម្រាប់ការសន្សំប្រាក់ (ថ្លៃសេវា)</u>
ស្ថាប័នផ្លូវការអាចគិតថ្លៃសេវាពីអ្នកសម្រាប់ការផ្ទេរប្រាក់ ដកប្រាក់ពីម៉ាស៊ីនអេធីអឹមជាដើម។ ក្នុងករណីអ្នកត្រូវការប្រើប្រាស់ប្រាក់ភ្លាម។ វាជាការប្រសើរក្នុងការជ្រើសរើសវិធីសន្សំប្រាក់ដែលអនុញ្ញាតឲ្យអ្នកដក ប្រាក់របស់អ្នក ដោយរង់ចាំរយៈពេលសមស្រប។

<u>គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រសន្សំរបស់អ្នក</u>
អាស្រ័យលើហេតុផលនៃការសន្សំប្រាក់របស់អ្នក វិធីចំនួននឹងសមស្របជាមួយអ្នកជាងអ្នកផ្សេងទៀត (ឧ. ដើម្បីសន្សំសម្រាប់ផ្ទះ ឬអាជីវកម្ម ដែលត្រូវការប្រាក់ច្រើន។ វិធីសន្សំប្រាក់ផ្លូវការនឹងសមស្របជាងការលេងតុនទីន ឬទុកលុយរបស់អ្នកនៅក្រោមពូក)។

<u>ការប្រើប្រាស់អ៊ីនធឺណិត</u>
តើអ្នកអាចប្រើសេវាកម្មទាំងនេះដោយប្រើឧបករណ៍អេឡិចត្រូនិក ដូចជាកុំព្យូទ័រ ថេប្លេត ឬទូរស័ព្ទ បានក្នុងកម្រិតណា? ចំពោះមនុស្សមួយចំនួន ការគ្រប់គ្រងការសន្សំប្រាក់របស់ពួកគេទាំងស្រុង តាមប្រព័ន្ធអនឡាញ គឺមានសារៈសំខាន់ខ្លាំងណាស់ ដោយសារមិនចាំបាច់អាស្រ័យលើពេលធនាគារបើក ឬបំពេញឯកសារដើម្បីធ្វើប្រតិបត្តិការឡើយ។

ចម្លើយរបស់លំហាត់ខាងលើ

វិធីសន្សំប្រាក់	គុណសម្បត្តិ	គុណវិបត្តិ
ផ្លូវការ • ធនាគារ • បុស្តិ៍ប្រៃសណីយ៍ • គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី • ការសន្សំដែលបានចុះបញ្ជី និង សហករណ៍ឥណទាន • ក្រុមហ៊ុនធានារ៉ាប់រង (សម្រាប់ជម្រើសនៃសន្សំប្រាក់រយៈពេលវែង ដូចជាការធានារ៉ាប់រងអាយុជីវិត) • Fintech/កម្មវិធី apps • កាបូបចល័ត	• ជម្រើសដែលមានសុវត្ថិភាពបំផុត • ភាពឯកជន (គ្មាននរណាម្នាក់លើកលែងតែអ្នកទទួលបន្ទុកមើលលើប្រាក់សន្សំ ដឹងថាអ្នកមានចំនួនប៉ុន្មាននៅក្នុង គណនី)។ • ការល្បួងតិចជាងមុនដើម្បីដកប្រាក់ (ងាយស្រួលជាងក្នុងការ បដិសេធសំណើ)។ • អ្នកអាចទទួលបានការប្រាក់។ • អ្នកអាចចូលប្រើជម្រើសហិរញ្ញវត្ថុផ្សេងទៀត (គណនីបច្ចុប្បន្ន ការសន្សំប្រាក់ចូលនិវត្តន៍ គណនី កម្ចី ជាដើម)។ • វិធីប្រសើរជាងក្នុងការគ្រប់គ្រងប្រាក់របស់អ្នក (របាយការណ៍គណនីសន្សំ)។ • ទូទាត់វិក័យបត្របានលឿន។ • នៅពេលដែលធនាគារ ដាក់ឲ្យដំណើរការសេវាអ៊ីនធឺណិត ឬ សេវាធនាគារចល័ត អ្នកអាចពិនិត្យមើលសមតុល្យ និងគ្រប់គ្រងប្រាក់សន្សំរបស់អ្នក ២៤ ម៉ោងក្នុងមួយថ្ងៃ។ • អ្នកផ្តល់សេវាឌីជីថលក៏អនុញ្ញាតឲ្យអ្នកពិនិត្យមើល សមតុល្យរបស់អ្នក និងគ្រប់គ្រងប្រាក់សន្សំរបស់អ្នក ២៤ ម៉ោងក្នុងមួយថ្ងៃ។ • ធនាគារជាច្រើនដំណើរការតាមរយៈភ្នាក់ងារធនាគារ ដែលធ្វើឲ្យសេវាកម្មរបស់ពួកគេកាន់តែងាយស្រួលប្រើប្រាស់។	• ប្រហែលជាត្រូវការអត្តសញ្ញាណប័ណ្ណ ឬ កស្តុតាងនៃការស្នាក់នៅ ដែលអាចមានភាពមិនងាយស្រួល។ • បុគ្គលិកធនាគារជារឿយៗជាបុគ្គលិកផ្នែកលក់ដែលមានបំណងលក់ផលិតផលធនាគារ ដូច្នេះពួកគេអាចផ្តោតលើផលប្រយោជន៍របស់ធនាគារជាជាងអតិថិជន។ • អត្រាការប្រាក់ មានការប្រែប្រួលខុសគ្នាពីជម្រើសមួយទៅជម្រើសមួយទៀត។ វាអាចមានកម្រិតទាបណាស់។ • ជម្រើសសម្រាប់ការសន្សំប្រាក់មួយចំនួន អាចតម្រូវឲ្យតម្កល់ប្រាក់បញ្ញើអប្បបរមាដែលត្រូវការសម្រាប់ការបើកគណនី។ • អ្នកប្រហែលជាត្រូវបង់ថ្លៃសេវាសម្រាប់គណនី។ • ចំណាយពេលវេលាច្រើនក្នុងការតម្រង់ជួរនៅធនាគារ។ • ផលិតផល និងថ្លៃសេវាផ្សេងៗ មានលក្ខណៈពិបាកយល់។ ត័យខ្លាចធ្វើអ្វីមួយខុស។ • ម៉ោងបើកមានកម្រិត (បិទពេលល្ងាច និងអំឡុងពេលចុងសប្តាហ៍)។ • ផលប៉ះពាល់នៃអស្ថិរភាព សេដ្ឋកិច្ច ឬនយោបាយ៖ វិបត្តិហិរញ្ញវត្ថុ ការធ្លាក់តម្លៃរូបិយប័ណ្ណ ការទប់ស្កាត់មិនឲ្យដកប្រាក់ ការមិនអាចយកបានប្រាក់ចេញពីប្រទេស (ការគ្រប់គ្រងលើ ការប្តូរប្រាក់)។ • ភ្នាក់ងារធនាគារប្រហែលជាមិនមានមូលនិធិគ្រប់គ្រាន់ដើម្បីបើកឲ្យអ្នក។



ចំណុចល្អ និងចំណុចមិនល្អសម្រាប់ការសន្សំប្រាក់

វិធីសន្សំប្រាក់	គុណសម្បត្តិ	គុណវិបត្តិ
ពាក់កណ្តាលផ្លូវការ • ក្រុមសន្សំប្រាក់ • ក្រុមជួយគ្នា • តុង-ទីន • ធនាគារភូមិ • សមាគមសន្សំប្រាក់ និងខ្ចីប្រាក់ភូមិ (VSLAs) • គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមិនបានចុះបញ្ជី • សហករណ៍សន្សំ និងឥណទានដែលមិនបានចុះបញ្ជី • គ្រឹះស្ថានកម្ចីដែលមិនបានចុះបញ្ជី	• ងាយស្រួលចូលប្រើ • ការសន្សំប្រាក់ មានន័យថាអ្នកក៏អាចទទួលបានប្រាក់កម្ចីផង ដែរ។ • អ្នកអាចទទួលបានការប្រាក់ពីប្រាក់កម្ចីដែលបានពីប្រាក់សន្សំ។ • ច្បាប់របស់ក្រុមសន្សំអំពី ភាពទៀងទាត់ និងចំនួនប្រាក់បញ្ចើ លើកទឹកចិត្តឲ្យមាន ការសន្សំប្រាក់។ • វិន័យ។ • បង្កើតឲ្យមានសាមគ្គីភាព និងពង្រឹងទំនាក់ទំនងសង្គមក្នុងចំណោមសមាជិក។	• ការធានាតិចតួច។ • អ្នកមិនអាចប្រាកដថាអាចទទួលបានការប្រាក់លើការសន្សំរបស់អ្នកបានទេ។ • លទ្ធភាពទទួលបានប្រាក់កម្ចីមានកំណត់ ឬគ្មាន។ • ការអាចសន្សំ ឬដកប្រាក់បាន គឺអាស្រ័យទៅលើការយល់ព្រមពីសមាជិក។ • មានហានិភ័យក្នុងករណីដែលសមាជិកនឹងមិនគោរពតាមច្បាប់ (ឧ. នរណាម្នាក់អាចបាត់ខ្លួនបន្ទាប់ពីទទួលបានប្រាក់ ពីក្រុម)។ • អាស្រ័យលើកម្រិតនៃការធ្វើឲ្យទៅជាផ្លូវការ ប្រហែលជាមិនអាច ប្តឹងប៉ូលីសបានទេ ប្រសិនបើមានបញ្ហាណាមួយ។ • មានហានិភ័យក្នុងករណី សមាជិកនៃក្រុមសន្សំស្លាប់។ • អ្នកត្រូវជាផ្នែកមួយនៃបណ្តាញ ដើម្បីចូលរួមក្រុមសន្សំ។ • ក្រុមសន្សំមានហានិភ័យខ្ពស់ឈានទៅបរាជ័យ (មិនមានការគ្រប់គ្រងដោយអាជ្ញាធរទេ)។
ក្រៅផ្លូវការ • នៅផ្ទះ (ជាសាច់ប្រាក់នៅក្នុងប្រអប់សុវត្ថិភាព ឬប្រអប់ដាក់ប្រាក់)។ • ទ្រព្យសម្បត្តិ (មាស គ្រឿងអលង្ការ សត្វពាហនៈ ដីទ្រព្យសម្បត្តិ ។ល។) • ទុកជាមួយមិត្តភ័ក្តិ សាច់ញាតិ ឬពាណិជ្ជករដែលខ្លួនទុកចិត្ត។	• ងាយស្រួលប្រើប្រាស់ • តម្លៃទ្រព្យរបស់អ្នក អាចកើនឡើង។ • អ្នកត្រូវតែលក់ទ្រព្យរបស់អ្នកដើម្បីបានប្រាក់របស់អ្នកមកវិញ (ផ្អែកលើច្បាប់ផ្សារ)។ • មិត្តភ័ក្តិ សាច់ញាតិ ឬ ពាណិជ្ជករ តែងតែអាចរកបាន។ • មានអត្ថប្រយោជន៍ផ្សេងទៀតក្នុងការសន្សំក្នុងប្រភេទ៖ ការផ្តល់ឥត ឬលក់ទឹកដោះគោ (ក្នុងករណីគោក្របី) គ្រឿងអលង្ការ អាចពាក់សម្រាប់ព្រឹត្តិការណ៍សំខាន់ៗបាន។ • ប្រសិនបើអ្នកសន្សំទ្រព្យ (ចិញ្ចឹមសត្វ ទ្រព្យសម្បត្តិ) អ្នកប្រហែលជាអាចរកប្រាក់បាន (លក់សាច់/ទឹកដោះគោ ជួល។ល។)	• មិនមានសុវត្ថិភាព៖ តម្លៃអាចធ្លាក់ចុះក្នុងរយៈពេលជាច្រើនឆ្នាំ ហានិភ័យនៃការលួច ឈឺ ឬស្លាប់ (ក្នុងករណីសត្វចញ្ចឹម)។ • ប្រហែលជាមានការល្បួងខ្លាំងក្នុងការចំណាយ (ប្រសិនបើអ្នកទុកលុយនៅក្នុងផ្ទះ)។ • ពិបាកក្នុងការលក់ជាសាច់ប្រាក់ ក្នុងករណីមានអាសន្ន (ការលក់ទ្រព្យត្រូវចំណាយពេល)។ • ការចំណាយទាក់ទងនឹងការសន្សំទ្រព្យ៖ ថ្លៃអាហារ និងថ្លៃពេទ្យសត្វ ការជួសជុលទ្រព្យសម្បត្តិ។



តារាងប្រៀបធៀបជម្រើសសម្រាប់ការសន្សំប្រាក់ផ្អែកលើខិតប័ណ្ណប្រឌិត

	គណនីសន្សំធម្មតា	គណនីសន្សំតាមកិច្ចសន្យា	គណនីប្រាក់ការដាក់ប្រាក់បញ្ញើមានកាលកំណត់
តើយើងគ្រប់គ្នាអាចបើកគណនីនេះ បានដែរទេ?	ទំនងជាអាច	ទំនងជាអាច	ទំនងជាអាច
តើមានការកំណត់ឲ្យដាក់ប្រាក់អប្បបរមានៅពេលអ្នកបើកគណនី ឬនៅពេលណាដែលអ្នកចង់ដាក់ប្រាក់ចូលគណនីដែរឬទេ?	10 ដុល្លា	20 ដុល្លា	100 ដុល្លា 400,000 រៀល
តើអ្នកអាចដកប្រាក់នៅពេលណាក៏បានដែរឬទេ? តើត្រូវបង់ថ្លៃសេវា ឬត្រូវពិន័យ ដែរឬទេ?	អាចដកបាន មិនបង់ថ្លៃសេវា ឬពិន័យទេ	អាចដកបាន ប៉ុន្តែបាត់បង់ការប្រាក់	មិនអាចដកបាន
តើទទួលបានអត្រាការប្រាក់ប៉ុន្មាន?	1% ដុល្លា 1.5% រៀល	5% ដុល្លា 7% រៀល	6% ដុល្លា 9% រៀល
តើអ្នកអាចខ្ចីលុយបានទេ ប្រសិនបើអ្នកបើកគណនីសន្សំ?	មិនមានព័ត៌មាន	មិនមានព័ត៌មាន	អាចាន បន្ទាប់ពី រយៈពេលមួយ
តើតារាងពេលវេលាសម្រាប់ដាក់ប្រាក់បញ្ញើអាចបត់បែនបានដែរឬទេ? (មានន័យថា តើអ្នកមានកាតព្វកិច្ចដាក់ប្រាក់ ឬមិនចាំបាច់ដាក់ប្រាក់មួយចំនួន នៅថ្ងៃកំណត់ណាមួយ ឬអ្នកអាចធ្វើការដាក់ប្រាក់នៅពេលណាក៏បាន?)	អាចបត់បែន	ត្រូវដាក់ប្រាក់ រាល់ខែ ឲ្យបានទៀងទាត់	អ្នកត្រូវដាក់ប្រាក់ក្នុងចំនួនអប្បបរមា។ បន្ទាប់មក អាចបត់បែន
តើខ្ញុំអាចដាក់ប្រាក់ ឬដកប្រាក់សន្សំក្នុងម៉ាស៊ីនអេធីអឹម បានទេ?	បាន	មិនបាន	មិនបាន

ជំនួយការបណ្តុះបណ្តាល គ.២.៤

ផ្គូរផ្គងគោលដៅទៅនឹងស្ថានភាពជម្រើសសម្រាប់ការសន្សំប្រាក់



ចម្លើយចំពោះស្ថានភាពទី ១

សុភាព គួរព្យាយាមបើកគណនីធនាគារធម្មតា ព្រោះនាងមិនដែលមានគណនីធនាគារទេ។ ក្នុងគណនីធនាគារនោះ នាងនឹងអាចទុកប្រាក់មួយចំនួនជារៀងរាល់ខែ ដែលនាងអាចផ្ទេរ ឬយកទៅជាមួយពេលនាងត្រឡប់ទៅភូមិវិញ។



ចម្លើយចំពោះស្ថានភាពទី ២

ទីមួយ ចិន្តា អាចព្យាយាមបើកគណនីសន្សំធម្មតា ហើយក្លាយជាអតិថិជនរបស់ធនាគារ។ បន្ទាប់មក នាងអាចពិនិត្យមើលថាតើនាងអាចមានលទ្ធភាពបើកគណនីសន្សំតាមកិច្ចសន្យាដែរឬទេ។



ចម្លើយចំពោះស្ថានភាពទី ៣

ដោយសារ ណារី មិនមានផែនការចំណាយប្រាក់នេះយ៉ាងហោចណាស់រយៈពេលមួយឆ្នាំ គណនីប្រាក់បញ្ញើមានកាលកំណត់ អាចឲ្យនាងទទួលបានអត្រាការប្រាក់ខ្ពស់បំផុត និងដើម្បីការពារប្រាក់របស់នាងពីការល្បួងឲ្យចំណាយលើរបស់ផ្សេងទៀត (ដោយសារមានការពិន័យសម្រាប់ការដកប្រាក់មុនកាលកំណត់)។



ចម្លើយចំពោះស្ថានភាពទី ៤

រក្សា គួរតែព្យាយាមបើកគណនីធនាគារធម្មតា ព្រោះថានាងមិនដែលមានគណនីធនាគារទេ។ ក្នុងគណនីធនាគារនោះ នាងនឹងអាចទុកប្រាក់មួយចំនួនជារៀងរាល់ខែ ដើម្បីប្រើប្រាស់តាមគោលដៅរបស់នាង។

១៥



ប្រើប្រាស់ដម្រើសឥណទានដោយឆ្លាតវៃ



ឃ១. តើអ្នកគិតថាវិធីណាដែលល្អបំផុតក្នុងការទទួលបានប្រាក់សម្រាប់គម្រោងមួយ?

- ☐ **ក.** ខ្ចីប្រាក់។
- ☐ **ខ.** ប្រើប្រាស់ប្រាក់សន្សំរបស់អ្នក។
- ☐ **គ.** ខ្ចីប្រាក់ និងប្រើប្រាស់ប្រាក់សន្សំរបស់អ្នក។
- ☐ **ឃ.** វិភាគតម្រូវការ និងធនធានរបស់អ្នក ហើយជ្រើសរើសដម្រើសដ៏ល្អបំផុត តាមការដាក់ស្នើង។

ឃ២. តើអ្វីដែលសំខាន់បំផុតនៅពេលជ្រើសរើសប្រាក់កម្ចី?

- ☐ **ក.** អត្រាការប្រាក់។
- ☐ **ខ.** លក្ខខណ្ឌសងប្រាក់វិញ។
- ☐ **គ.** លក្ខខណ្ឌទាំងអស់សុទ្ធតែសំខាន់ យើងត្រូវសិក្សាលក្ខខណ្ឌទាំងអស់ ហើយជ្រើសរើសប្រាក់កម្ចី និងអ្នកឲ្យប្រាក់ខ្ចីដែលត្រូវនឹងតម្រូវការ និងស្ថានភាពផ្ទាល់ខ្លួនរបស់យើង។
- ☐ **ឃ.** អ្នកឲ្យខ្ចីប្រាក់ស្ថិតនៅជិតអ្នក។

ឃ៣. តើពាក្យណាដែលមិនមែនជាលក្ខខណ្ឌឥណទាន?

- ☐ **ក.** អត្រាការប្រាក់។
- ☐ **ខ.** ប្រាក់ធានា។
- ☐ **គ.** ថវិកា។
- ☐ **ឃ.** ពិន័យ។

ប:ឃ៣ ម:ឲ៣ ៣:ឲ៣ ៖ភាន្តីរេ

១. ជ្រើសរើសវិធីមួយដើម្បីទទួលបានប្រាក់សម្រាប់គម្រោងរបស់អ្នក

បន្ទាប់ពីបានសិក្សាជម្រើសផ្សេងៗសម្រាប់ការសន្សំប្រាក់នៅក្នុងមេរៀនមុន ឥឡូវនេះ យើងនឹងធ្វើការ ប្រៀបធៀបវិធីផ្សេងៗ ក្នុងការទទួលបានប្រាក់ ដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុ និងទទួលបានប្រាក់សម្រាប់គម្រោងរបស់យើង។

ដំណួយការបណ្តុះបណ្តាល ឃ.១.១

រឿងរ៉ាវអំពីការទទួលបានប្រាក់ពីប្រភពផ្សេងៗ

STORY OF FINANCING





សុភាព

ឪពុកម្តាយរបស់ សុភាព សម្រេចចិត្តដកប្រាក់សន្សំដើម្បីទិញពូកថ្មី ដោយសារពូកចាស់របស់ពួកគេសើម បន្ទាប់ពីទឹកជំនន់នាពេលកន្លងមក។ ដូច្នេះ ពួកគេត្រូវប្រើប្រាស់ប្រាក់សន្សំរបស់ពួកគេមួយចំនួន។ ទោះយ៉ាងណា ពួកគេមិនត្រូវសងប្រាក់ ឬបង់ការប្រាក់ឡើយ។

ការអប់រំផ្នែកហិរញ្ញវត្ថុ

STORY OF FINANCING





ប៊ូរ៉ាន

ប៊ូរ៉ាន ចង់ទិញកង់ថ្មីជាកាដូថ្ងៃខួបកំណើតដល់កូនច្បងរបស់គាត់។ ពួកគេកំពុងសន្សំប្រាក់សម្រាប់ផ្ទៃផ្ទះ។ ដូច្នេះហើយ ប៊ូរ៉ាន និងចិន្តា សម្រេចលក់កង់ចាស់របស់ប៊ូរ៉ាន ទៅឲ្យអ្នកជិតខាង។ ពួកគេយកប្រាក់នោះ ទៅទិញកង់ថ្មីតូចមួយបាន។

ការអប់រំផ្នែកហិរញ្ញវត្ថុ

STORY OF FINANCING






ណារី

ណារីខ្ចីលុយពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការដើម្បីទិញសម្ភារៈសំណង់សម្រាប់សាងសង់បន្ទប់បន្ថែមនៅក្នុងផ្ទះរបស់នាង។ ផលវិបាកៈ នាងនឹងត្រូវសងប្រាក់កម្ចី និងការប្រាក់ ផ្អែកលើគម្រោងសងបំណុលមួយ ។

ការអប់រំផ្នែកហិរញ្ញវត្ថុ

STORY OF FINANCING





រក្សា

រក្សា ត្រូវដៀវទូរស័ព្ទរបស់នាង ពីព្រោះទូរស័ព្ទរបស់នាងធ្លាក់ និងខូចទាំងស្រុង។ នាងមិនមានប្រាក់សន្សំគ្រប់គ្រាន់ដើម្បីទិញវានៅពេលនេះទេ។ នាងសម្រេចចិត្តខ្ចីលុយពីអ្នកឲ្យខ្ចីប្រាក់ក្រៅផ្លូវការ ដែលមនុស្សគ្រប់គ្នាខ្ចីប្រាក់នៅរោងចក្រ។ ផលវិបាកៈ នាងនឹងត្រូវសងប្រាក់កម្ចីវិញជាមួយនឹងការប្រាក់ខ្ពស់ ហើយត្រូវប្រាកដថានាងសងទាន់ពេល ពីព្រោះនាងបានលឺថាអ្នកឲ្យខ្ចីប្រាក់ក្រៅផ្លូវការនេះ តឹងតែងណាស់ជាមួយនឹងការពន្យារពេល។

ការអប់រំផ្នែកហិរញ្ញវត្ថុ

ជាទូទៅ មានវិធីបួនយ៉ាងដែលយើងអាចទទួលបានប្រាក់ ដើម្បីដោះស្រាយបញ្ហា ឬយកធ្វើអ្វីមួយៈ

១. លក់ទ្រព្យ ដូចអ្វីដែលបូរ៉ាន បានធ្វើ។

២. ប្រើប្រាក់សន្សំផ្ទាល់ខ្លួន ដូចសុភាព។

៣. ខ្ចីប្រាក់ពីគ្រួសារ/មិត្តភក្តិ និងប្រភពឥណទានក្រៅផ្លូវការផ្សេងទៀត ដូចរក្សា។

៤. ខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុ ដូចជាធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬសហករណ៍សន្សំប្រាក់ និង ឥណទានដែលបានចុះបញ្ជី ដូចជា ណារី។

នៅចុងបញ្ចប់នៃមេរៀននេះ ក្នុងផ្នែកចម្លើយសម្រាប់លំហាត់ អ្នកនឹងរកឃើញជំនួយការបណ្តុះបណ្តាល យ.១.៣ ដែលជាតារាងពិពណ៌នាអំពីគុណសម្បត្តិ និងគុណវិបត្តិនៃវិធីនីមួយៗ ក្នុងការទទួលបានប្រាក់។

ជំនួយការបណ្តុះបណ្តាល យ.១.២

រឿង"ជានីអំពីអាជីវកម្មចំនួនពីរ



ជានី

អ្នកគឺជាជានី ជាមិត្តដ៏ល្អរបស់ស្មើ ហើយអ្នកបើកអាជីវកម្មលក់អាហារតូចមួយ ។ ថ្ងៃនេះ អ្នកទៅសួរសុខទុក្ខមិត្តរបស់អ្នកឈ្មោះ ទីណា ដែលលក់ម្ហូបឆ្អិនស្រាប់ផងដែរ។

អ្នកសួរមិត្តរបស់អ្នកនូវសំណួរជាច្រើនអំពីវិធីដែលគាត់ទទួលបានដើមទុនសម្រាប់ដល់អាជីវកម្មរបស់ គាត់។ មិត្តរបស់អ្នកក៏ចង់ដឹងវិធីដែលចាប់ផ្តើមបង្កើត និងពង្រីកអាជីវកម្មរបស់អ្នកផងដែរ។ អ្នកបានចាប់ ផ្តើមជាមួយដើមទុន៥០០ ដុល្លា ដែលអ្នកបានសន្សំបន្ទាប់ពីធ្វើការជាច្រើនឆ្នាំនៅក្នុងរោងចក្រ។ ហើយមុននោះ អ្នកក៏សន្សំបាន១៥០ដុល្លាផងដែរ។ ទោះបីជាអាជីវកម្មរបស់អ្នកមានទំហំតូចក៏ដោយ អ្នកមានគម្រោងពង្រីកវាបន្តិចម្តងៗ។

អ្នកព្យាយាមសន្សំទុក ៣០ ដុល្លារក្នុងមួយសប្តាហ៍នៅក្នុងគណនីសន្សំដែលអ្នកទើបបើកនៅធនាគារជាតិ សម្រាប់អាជីវកម្មរបស់អ្នក ។ តាមវិធីនេះ រៀងរាល់ ៣ ឬ ៤ ខែម្តង អ្នកសន្សំប្រាក់គ្រប់គ្រាន់ ដើម្បីកែលម្អអាជីវកម្មរបស់អ្នកគ្រាន់បើបន្តិច (ឧបករណ៍ សម្ភារៈផ្ទះបាយប្រសើរសម្ភារៈវេចខ្ចប់ល្អជាងមុន) និង ពង្រីកអាជីវកម្ម។ ឥឡូវនេះ អ្នកអាចទិញសម្ភារៈច្រើន ហើយធ្វើឲ្យអាជីវកម្មរបស់អ្នកមានភាពសម្បូរ បែប។ អ្នកក៏បានគិតអំពីការបើកហាងផ្ទាល់ខ្លួនផងដែរ។

អ្នកទទួលបានប្រាក់ចំណេញកាន់តែច្រើន និងអាចសន្សំប្រាក់បានកាន់តែច្រើន។ ហើយអ្នកក៏អាច វិនិយោគកាន់តែធំនៅក្នុងអាជីវកម្មរបស់អ្នក។

ទីណា

អ្នកគឺជាទីណា ហើយអ្នកបើកអាជីវកម្មតូចមួយលក់អាហារចម្អិនស្រាប់។ មិត្តរបស់អ្នក ផានី ក៏មានហាង ស្រដៀងគ្នាដែរ។ ថ្ងៃនេះនាងនឹងមកលេងអ្នក។

អ្នកចង់ដឹងអំពីវិធីដែលមិត្តរបស់អ្នកទទួលបានដើមទុន និងពង្រីកអាជីវកម្មរបស់គាត់។ គាត់ក៏ចង់ដឹងវិធីដែល អ្នកចាប់ផ្តើមបង្កើត និងពង្រីកអាជីវកម្មរបស់អ្នកផងដែរ។
អ្នកចាប់ផ្តើមជាមួយដើមទុន ១.០០០ ដុល្លា ដែលអ្នកបានសន្សំ និងប្រាក់កម្ចី ១៥០០ ដុល្លា ពីធនាគាររបស់អ្នក។

ប្រាក់កម្ចីនេះ បានជួយឲ្យអ្នកធ្វើការកែលម្អហាងជួលរបស់។ បន្ទាប់ពីកែលម្អហាងហើយ អ្នកទទួលបាន អតិថិជនកាន់តែច្រើននៅក្នុងហាងដ៏ស្អាតរបស់អ្នក នៅទីតាំងមិនសូវមមាញឹកមួយ។ អ្នកបានទូទាត់ប្រាក់សម្រាប់ ការចំណាយប្រចាំសប្តាហ៍របស់អ្នកទាន់ពេលវេលា រាល់សប្តាហ៍ រួមទាំងការសងប្រាក់កម្ចីផងដែរ។ ប៉ុន្តែអ្នកអាច សន្សំបានត្រឹមតែ ១៥ ដុល្លារប៉ុណ្ណោះក្នុងមួយសប្តាហ៍។
ថ្ងៃមួយ ហាងតូចមួយនៅក្នុងផ្សារនៅតំបន់នោះ សម្រាប់ជួល។

វាទំនងជាឱកាសអាជីវកម្មដ៏ល្អមួយ។ អ្នកបានគណនាថាចំណូលរបស់អ្នកនឹងកើនឡើងទ្វេដង ប្រសិនបើអ្នកជួល ហាងនោះ។ ដូច្នេះ អ្នកបានធ្វើការសម្រេចចិត្តយ៉ាងឆាប់រហ័ស ដើម្បីជួលឲ្យបានមុនអ្នក ផ្សេងទៀតជួល។ ដូច្នេះហើយ អ្នកបានខ្ចីប្រាក់ ២៥០០ ដុល្លារពីបងប្រុសថ្លៃរបស់អ្នក។

សំណួរ

- តើ ផានី និង ទីណា បានពង្រីកអាជីវកម្មដោយរបៀបណា?
- ក្នុងចំណោមពួកគាត់ទាំងពីរ តើស្ត្រីរូបណា ទំនងជាជោគជ័យជាង? ហេតុអ្វី?
- តើអ្នកណាដែលប្រថុយប្រថានជាង?
- តើអ្នកនឹងផ្តល់ដំបូន្មានអ្វីខ្លះដល់ផានី និងទីណា?

⚠ **ចំណុចសំខាន់ៈ** ការធ្វើការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុច្រើន អាចបង្កើតភាពតានតឹង និងប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់អ្នក។ ប្រសិនបើអ្នកមានអារម្មណ៍ធុញថប់ កុំស្ទាក់ស្ទើរក្នុងការសុំជំនួយ។

កន្លែងកត់ត្រា

វេនអ្នកម្តង!

ក្រឡេកមើលគោលដៅ និងចរិការបស់ខ្ញុំ ខ្ញុំគិតថាជម្រើសដ៏ល្អបំផុតក្នុងការទទួលបានដើមទុនដើម្បីសម្រេចបានគោលដៅរបស់ខ្ញុំគឺ៖


គោលដៅរបស់ខ្ញុំ	ជម្រើសហិរញ្ញវត្ថុដ៏ល្អបំផុត

សារសំខាន់

- មានជម្រើសជាច្រើន ដើម្បីឲ្យអ្នកទទួលបានដើមទុនសម្រាប់គោលដៅរបស់អ្នក។
- ជម្រើសនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិ។ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹង និង ពិនិត្យមើលជម្រើសនីមួយៗដោយប្រុងប្រយ័ត្ន ដើម្បីជ្រើសរើសយកជម្រើសដែលត្រូវនឹងតម្រូវការរបស់អ្នក និងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក។
- អ្នកក៏អាចរួមបញ្ចូលគ្នាជម្រើសហិរញ្ញវត្ថុនានា (កម្ចី និងការសន្សំ)។
- ពិភាក្សាអំពីជម្រើសហិរញ្ញវត្ថុសម្រាប់គ្រួសាររបស់អ្នក ជាពិសេសសមាជិកគ្រួសាររបស់អ្នក ដែលចូលរួមក្នុងគោលដៅរបស់អ្នក (ប្តីប្រពន្ធ ឪពុកម្តាយ កូនៗ បងប្អូន...)។



២. ជ្រើសរើសឥណទានរបស់អ្នកដោយឆ្លាតវៃ!



មានប្រភពឥណទានជាច្រើន។ ប្រភពឥណទានមួយចំនួន ដូចជាធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីឯកទេស គឺជាផ្នែកនៃសេដ្ឋកិច្ចផ្លូវការ ហើយដាក់លក្ខខណ្ឌជាក់លាក់សម្រាប់បុគ្គល ឬស្ថាប័នណាមួយដែលចង់ធ្វើកិច្ចសន្យាខ្ចីប្រាក់។ ប្រភពឥណទានខ្លះ ព្យាយាមធ្វើឲ្យកាន់តែងាយស្រួលក្នុងការផ្តល់ប្រាក់កម្ចី ដល់មនុស្សគ្រប់គ្នាព្រមទាំងប្រជាជនក្រីក្រ។

ប្រភពឥណទានផ្សេងទៀត តម្រូវឲ្យអ្នកជាផ្នែកមួយនៃក្រុម ដូចជាតុងទីន ឬតម្រូវឲ្យអ្នកមានប្រាក់សន្សំខ្លះរួចហើយ។

និយមន័យ

ប្រាក់កម្ចី៖ ការផ្តល់ប្រាក់ ទ្រព្យសម្បត្តិ ឬទំនិញសម្ភារៈផ្សេងទៀតទៅឲ្យភាគីម្ខាងទៀត ជាថ្នូរនឹងការសងប្រាក់ដើមនាពេលអនាគតរួមជាមួយនឹងការប្រាក់ ឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀត។

ឥណទាន៖ កិច្ចសន្យាដែលអ្នកខ្ចីទទួលបានចំនួនទឹកប្រាក់នាពេលបច្ចុប្បន្ន ហើយយល់ព្រមសងអ្នកឲ្យប្រាក់ខ្ចី តាមកាលបរិច្ឆេទណាមួយនាពេលអនាគត ជាមួយនឹងការប្រាក់។

ការប្រាក់៖ គឺជាតម្លៃសម្រាប់ការប្រើប្រាស់លុយរបស់អ្នកឲ្យខ្ចីក្នុងរយៈពេលជាក់លាក់ណាមួយ។



ជំនួយការបណ្តុះបណ្តាល ឃ.២.១

លក្ខខណ្ឌ និងនិយមន័យដែលពាក់ព័ន្ធជាមួយឥណទាន/ប្រាក់កម្ចី

ចូរផ្គូផ្គងពាក្យទាក់ទងនឹងឥណទាននីមួយៗជាមួយនឹងនិយមន័យរបស់វា។ សូមកុំបារម្ភប្រសិនបើអ្នកមិនយល់ច្បាស់។

នៅចុងបញ្ចប់នៃមេរៀនក្នុងផ្នែក អ្នកនឹងឃើញចម្លើយត្រឹមត្រូវនៅក្នុងចម្លើយសម្រាប់លំហាត់នេះ ។

ការប្រាក់	អ្នកជំនាញដែលជួយអតិថិជនរបស់គាត់ក្នុងការទទួលបានប្រាក់កម្ចីសមស្របបំផុត និង/ឬមានការប្រាក់ទាបបំផុត (ជាទូទៅ ប្រាក់កម្ចីបញ្ចាំ) ពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត
ឈ្មួញកណ្តាលឥណទាន	ចំនួនប្រាក់ដែលអ្នកខ្ចីប្រាក់បង់ទៅអ្នកឲ្យប្រាក់ខ្ចី បន្ថែមពីលើការសងប្រាក់កម្ចី ដើម្បីអាចប្រើប្រាស់ប្រាក់របស់អ្នកឲ្យប្រាក់ខ្ចី។
ការពិន័យ	ចំនួនប្រាក់កម្ចីដែលផ្តល់ឲ្យដោយអ្នកផ្តល់ប្រាក់កម្ចី មិនគិតបញ្ចូលការប្រាក់
ប្រាក់ដើម	បុគ្គលដែលនឹងសងប្រាក់កម្ចីរបស់អ្នកក្នុងករណីដែលអ្នកខកខានមិនបានសង។ បុគ្គលនេះអាចត្រូវបានស្នើសុំឲ្យចុះហត្ថលេខារបស់គាត់បញ្ជាក់ពីការព្រមព្រៀងជាមួយអ្នកផ្តល់ប្រាក់កម្ចី។ ការធានាក៏អាចធ្វើឡើងក្នុងទម្រង់ជាទ្រព្យសម្បត្តិផងដែរ។
អ្នកធានា	ចំនួនប្រាក់ដែលអ្នកខ្ចីនឹងត្រូវបង់ទៅឲ្យអ្នកខ្ចី ប្រសិនបើគាត់ខកខានក្នុងការសងប្រាក់កម្ចី (ឧ. ការរឹបអូសទ្រព្យសម្បត្តិ យានយន្ត ការសន្សំ...)
រយៈពេលអនុគ្រោះ	ការសងប្រាក់វិញទាំងអស់ ឬមួយផ្នែកនៃប្រាក់កម្ចីរបស់អ្នកមុនរយៈពេលសងប្រាក់ដែលបានព្រមព្រៀង។
ការគិតសារ ជាថ្មី	សមាមាត្រនៃចំនួនប្រាក់ដែលអ្នកត្រូវផ្តល់សម្រាប់គម្រោងខ្ចីប្រាក់របស់អ្នក មុនពេលខ្ចីប្រាក់បន្ថែមពីស្ថាប័នឥណទាន ដែលផ្តល់ឲ្យតាមរយៈទ្រព្យសកម្ម និងប្រាក់សន្សំរបស់អ្នក។
ការសងប្រាក់មុនពេលកំណត់	រយៈពេលអនុញ្ញាតចាប់ពីការទទួលប្រាក់កម្ចី និងការសងដំបូង (ទិញឥឡូវនេះ បង់ពេលក្រោយ)
ការដាក់ទ្រព្យបញ្ចាំ	ការលុបចោលកិច្ចព្រមព្រៀងឥណទានដោយគ្មានការពិន័យ។ "រយៈពេលសម្រាប់ធ្វើការពិចារណា" សម្រាប់ការទិញដោយគ្មានគ្រោងទុក។
ការចូលរួមចំណែកផ្ទាល់ខ្លួន	ការដាក់ទ្រព្យសម្បត្តិរបស់អ្នកជាសន្តិសុខដើម្បីទទួលបានឥណទានពីស្ថាប័នហិរញ្ញវត្ថុ។ ក្នុងករណីដែលមិនបានសងវិញ ម្ចាស់បំណុលអាចរឹបអូសយកទ្រព្យសម្បត្តិដែលពាក់ព័ន្ធ ទៅលក់ដើម្បីទទួលបានមកវិញនូវចំនួនប្រាក់ដែលអ្នកបានខ្ចី បូកនឹងការចំណាយផ្សេងៗ។ កម្មសិទ្ធិករមិនបាត់បង់កម្មសិទ្ធិលើអចលនទ្រព្យដែលជាប់បញ្ចាំទេ ដរាបណាគាត់គោរពតាមកាតព្វកិច្ចសងបំណុលរបស់គាត់។

សំណួរ

• តាមគំនិតរបស់អ្នក តើអ្នកត្រូវពិភាគអ្វីនៅពេលជ្រើសរើសអ្នកឲ្យខ្ចី?

លក្ខណៈសំខាន់ៗដែលត្រូវពិចារណានៅពេលជ្រើសរើសអ្នកឲ្យខ្ចីប្រាក់

• អត្រាភាគរយប្រចាំឆ្នាំ (APR) ការចំណាយពិតប្រាកដនៃការទទួលយកប្រាក់កម្ចី (រួមទាំងការគិតថ្លៃ រដ្ឋបាល ការធានារ៉ាប់រងជាកំហិត)

• ចំនួនទឹកប្រាក់ដែលអ្នកអាចខ្ចីបាន។

• តើវាងាយស្រួលប៉ុណ្ណាក្នុងការទទួលបានប្រាក់កម្ចី (ឧ. តើអ្នកត្រូវតែសន្សំចំនួនប៉ុន្មាន មុនពេលផ្តល់ប្រាក់កម្ចី ចំនួនទឹកប្រាក់នៃការធានា...)

• តម្រូវការ (ឯកសារដែលខ្ញុំត្រូវបង្ហាញ លទ្ធភាពដែលពួកគេនឹងផ្តល់ឥណទានដល់ខ្ញុំ)

• តើអ្នកទទួលបានប្រាក់លឿនប៉ុណ្ណា

• ការផាកពិន័យក្នុងករណីយឺតតាវក្នុងការសង

• ចម្ងាយពីផ្ទះរបស់ខ្ញុំ

• វិធីសាស្ត្រប្រមូលបំណុលក្នុងករណីទូទាត់យឺត (ផ្លូវច្បាប់ ការបំភិតបំភ័យ ការគំរាមកំហែង...)

• រយៈពេលអនុគ្រោះ

• កាតព្វកិច្ចប្រើប្រាស់ប្រាក់កម្ចីសម្រាប់គោលបំណងជាក់លាក់មួយ (លំនៅដ្ឋាន ការវិនិយោគដែលមានលទ្ធភាពចំណេញ..)

• លទ្ធភាពនៃការបន្តរយៈពេល ឬការផ្តល់រយៈពេលអនុគ្រោះ

• លទ្ធភាពនៃការចូលប្រើសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត៖ គណនីចរន្ត ផ្ទេរប្រាក់ ប័ណ្ណឥណពន្ធ ទូរស័ព្ទចល័ត ឬសេវាអ៊ីនធឺណិត...)

• ការរៀបចំផ្សេងៗនៅក្នុងករណីនៃមានការស្លាប់ ជំងឺ ឬការផ្លាស់ប្តូរនៅស្ថានភាពរបស់អ្នកខ្ចី

សារសំខាន់

• ដើម្បីប្រើប្រាស់ជម្រើសឥណទានដោយជោគជ័យ អ្នកត្រូវយល់ឲ្យបានច្បាស់អំពីវាក្យស័ព្ទទាក់ទងនឹងឥណទាន។

• អ្នកខ្ចីត្រូវទទួលខុសត្រូវក្នុងការទូទាត់សងប្រាក់កម្ចីវិញ តាមកាលវិភាគសងប្រាក់ ។

• ការទទួលយកប្រាក់កម្ចីគឺជាបញ្ហាធ្ងន់ធ្ងរ។ កុំគិតងាយពេក។

• អ្នកមានជាអ្នកអាចសងបំណុល (សុភាសិត)!

• ដើម្បីជ្រើសរើសប្រាក់កម្ចី និងអ្នកឲ្យខ្ចីដោយឈ្លាសវៃ ដំបូងអ្នកត្រូវដឹងថាតើមានជម្រើសណាខ្លះ ហើយអ្នកឲ្យខ្ចីជានរណា ដោយប្រមូលព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ជាមួយនឹងព័ត៌មាននោះ អ្នកនឹងអាចជ្រើសរើសជម្រើសដែលសមស្របបំផុតតាមតម្រូវការរបស់អ្នក។

• អ្នកឲ្យខ្ចីមួយណាដែលអ្នកជ្រើសរើសនឹងអាស្រ័យលើលក្ខណៈនៃគម្រោងរបស់អ្នក ពោលគឺគោលដៅដែលអ្នកចង់សម្រេចបាន តាមរយៈការខ្ចីប្រាក់

៣. គណនាការចំណាយសម្រាប់ឥណទានរបស់អ្នក

សមត្ថភាពទូទាត់

ឧបមាថាបន្ទាប់ពីគិតបានច្បាស់លាស់ អ្នកបានសម្រេចចិត្តខ្ចីប្រាក់ជាដើមទុនសម្រាប់គម្រោងរបស់អ្នក។ សូមអបអរសាទរ! អ្នកដឹងថាអ្នកត្រូវការប៉ុន្មាន ហើយអ្នកមានអារម្មណ៍ថាត្រៀមខ្លួនរួចជាស្រេចដើម្បីទៅមើលស្ថាប័នហិរញ្ញវត្ថុ ដើម្បីស្វែងរកជម្រើសដែលត្រឹមត្រូវសម្រាប់អ្នកហើយឬនៅ។ មុនពេលអ្នកទៅមើលពួកគេ អ្នកនឹងត្រូវចំណាយពេលដើម្បីគណនាលទ្ធភាពរបស់អ្នកក្នុងការសងឥណទាន។

យោងតាមច្បាប់ជាធរមាននៅក្នុងប្រទេសជាច្រើន មនុស្សម្នាក់មិនអាចសងលើសពីភាគរយនៃប្រាក់ចំណូលប្រចាំខែរបស់គាត់បានទេ។ វាប្រែប្រួលតាមប្រទេសនីមួយៗ ពី ៣០% ទៅ ៤០% នៃប្រាក់ចំណូលប្រចាំខែ។ ប្រសិនបើយើងលើសពីភាគរយនេះ វាមានហានិភ័យខ្ពស់នៃការជំពាក់បំណុលគេ។ ជាងនេះទៅទៀត ស្ថាប័នហិរញ្ញវត្ថុដែលផ្តល់ឥណទានដល់បុគ្គលដែលនឹងត្រូវសងប្រាក់លើសពីភាគរយនៃប្រាក់ចំណូលដែលបានអនុញ្ញាតរបស់គាត់ អាចទទួលរងនូវបណ្តឹង។

⚠ **ប៉ុន្តែសូមប្រយ័ត្ន**! ៤០% គឺជាចំនួនភាគរយអតិបរមាដែលអនុញ្ញាត ប៉ុន្តែមិនមែនជាចំនួនភាគរយដែលគួរណែនាំឡើយ ៣០% ឬទាបជាងនេះ គួរជាភាគរយខ្ពស់បំផុត។ សូមប្រុងប្រយ័ត្នថាភាគរយនៃ អត្រានៃលទ្ធភាពសងប្រាក់ អាចត្រូវបានវិភាគដោយពិចារណាលើថវិការបស់អ្នកប៉ុណ្ណោះ។ ពេលខ្លះថវិការបស់យើងតឹងពេកដែលមិនអនុញ្ញាតឲ្យយើងធ្វើការខ្ចីប្រាក់បាន។

យើងនឹងគណនាសមត្ថភាពសងប្រាក់របស់ណារី ជាឧទាហរណ៍។

ករណីសិក្សាទី១

សមត្ថភាពទូទាត់សងរបស់ណារី

បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ ណារីក៏ចាប់ផ្តើមរៀបចំថវិការបស់នាងបានល្អ។ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់នាងគឺ ៣០០ ដុល្លា (កំណត់សម្គាល់! ប្រាក់ចំណូលអថេរ ដូចជាប្រាក់បន្ថែមម៉ោង ដែលប្រែប្រួលពីមួយខែទៅមួយខែ មិនត្រូវបានគិតក្នុងគោលបំណងនៃការគណនានេះទេ)។

ប្រាក់ចំណូលប្រចាំខែ៖ ៣១០ ដុល្លារ។
សមត្ថភាពទូទាត់ប្រចាំខែ៖ ៣០% នៃប្រាក់ចំណូលប្រចាំខែ ៖ ៩៣ ដុល្លារ។

ផ្អែកលើការគណនានេះ ណារី អាចនឹងមិនមានលទ្ធភាពសងប្រាក់លើសពី ៩៣ ដុល្លារក្នុងមួយខែឡើយ (សម្រាប់ប្រាក់កម្ចីទាំងអស់ដែលគាត់បានចុះកិច្ចសន្យា)។



សមត្ថភាពផ្ទាល់ខ្លួន

ឥឡូវដល់វេនរបស់អ្នក! ចូរគណនាសមត្ថភាពផ្ទាល់ខ្លួនរបស់អ្នកក្នុងការសងប្រាក់កម្ចី។

ចំណូលប្រចាំខែ ៖ ១០០%

សមត្ថភាពទូទាត់សងបុរចាំខែ៖ ..... ៣០% នៃប្រាក់ចំណូលប្រចាំខែ

⚠ **ចំណុចសំខាន់ៈ** ការខ្ចីប្រាក់ដែលគិតគូរពីសមត្ថភាពសងវិញរបស់អ្នក នឹងជួយឲ្យចិត្តរបស់អ្នកស្ងប់ចិត្ត។

ជំនួយការបណ្តុះបណ្តាល ឃ.៣.១

ការគណនាការចំណាយសម្រាប់ការខ្ចីប្រាក់របស់ណារី



ណារី បានគណនាថា នាងនឹងត្រូវការប្រាក់ ១២០០ ដុល្លារដើម្បីទិញម៉ូតូ។ នាងបានរកឃើញជម្រើសហិរញ្ញវត្ថុ (ប្រាក់កម្ចី) ខាងក្រោមដែលត្រូវបានរៀបចំឡើងជាពិសេសសម្រាប់តម្រូវការរបស់នាង។ នាងកំពុងព្យាយាមស្វែងរកការចំណាយទាបបំផុតដែលអាចធ្វើបាន៖

ជម្រើស	ធនាគារជាតិ	សមាគមមីក្រូហិរញ្ញវត្ថុ	ក្រុមហ៊ុនឯកជនមីក្រូហិរញ្ញវត្ថុ
អត្រាកាតរយប្រចាំឆ្នាំ (APR)	១២%ក្នុងមួយឆ្នាំ	១៨%ក្នុងមួយឆ្នាំ	២៤%ក្នុងមួយឆ្នាំ
រយៈពេលនៃការខ្ចីប្រាក់	២ឆ្នាំ (២៤ខែ)	៣ឆ្នាំ (៣៦ខែ)	១ឆ្នាំ (១២ខែ)
ចំនួនដែលត្រូវបង់ប្រចាំខែ (ការបង់ តាមដំណាក់កាលប្រចាំខែ)	៦៦,៤៨ ដុល្លា	៤៣,៣៨ ដុល្លា	១១៣,៤៧ ដុល្លា
ចំនួនសរុបដែលត្រូវបង់ (រយៈពេលនៃការខ្ចីប្រាក់ X ការបង់ តាមដំណាក់កាលប្រចាំខែ)	៥៦.៤៩ X ២៤ =១៣៥៥, ៧០ដុល្លា		
ការចំណាយ ជាក់ស្តែងសម្រាប់ការខ្ចីប្រាក់ (ចំនួនសរុបដែលត្រូវបង់ ដកប្រាក់ដើមទុន ដែលណារីស្នើសុំខ្ចី)	១៣៥៥, ៧០ដុល្លា –១២០០ ដុល្លា =១៥៥, ៧០ដុល្លា		

(១) ដល់វេនអ្នក! តើត្រូវចំណាយចំនួនប៉ុន្មាន ដើម្បីខ្ចីប្រាក់ពីសមាគមមីក្រូហិរញ្ញវត្ថុ?

(២) តើត្រូវចំណាយចំនួនប៉ុន្មាន ដើម្បីខ្ចីប្រាក់ពីក្រុមហ៊ុនឯកជនពីក្រុមហ៊ុនឯកជន?

(៣) ដូច្នេះ តើជម្រើសខ្ចីប្រាក់មួយណាដែលណារី ធ្វើការចំណាយទាបបំផុត?



⚠ **សូមផ្តោតការយកចិត្តទុកដាក់**! ឥណទានដែលចំណាយតិចបំផុត អាចមិនមានភាពសមស្របបំផុតចំពោះតម្រូវការរបស់ណារីទេ។ ឧទាហរណ៍ វាអាចមានការពិបាក និងប្រថុយប្រថានជាងក្នុងការសងប្រាក់វិញជារៀងរាល់ខែ។ វាអាស្រ័យលើថាតើ ណារី រំពឹងថានឹងរកបានប្រាក់ចំណូលបានប៉ុន្មានក្នុងមួយខែ។

(៣). ចម្លើយនេះ

(១). ចំនួនសរុបនៃការត្រឡប់ = ១.៨៦១.៧ ដុល្លារ (៤៣.៣៤ x ៣៤) ។ ការចំណាយសរុប
ក្នុងរយៈពេល ៦ ខែ = ១.៨៦១.៧ ដុល្លារ (១.៨៦២.៧ ដុល្លារ – ១.៥០០) ។

(១). ចំនួនសរុបនៃការត្រឡប់ = ១.៣៦១.៦ ដុល្លារ (១១៣.៨ x ១៦)។ ការចំណាយ
ក្នុងរយៈពេល ៦ ខែ = ១៦២.៦ ដុល្លារ (១.៣៦១.៦ – ១.៥០០) ។

ដំឡូយការបណ្តុះបណ្តាល ឃ.៣.២

គំរូខិត្តប័ណ្ណផ្សព្វផ្សាយ ប្រាក់កម្ចី



កម្ចីសមាគម
មីក្រូហិរញ្ញវត្ថុ



- **អត្រាការប្រាក់ឆ្នាំ៖** ១៨%
- **រយៈពេលកម្ចី៖** ៣ ឆ្នាំ។
- **ការទូទាត់សងប្រចាំខែ៖**
  ៤៣,៣៨ ដុល្លារ
  (សម្រាប់ប្រាក់កម្ចី ១.២០០ ដុល្លារ)
- **ចំនួនប្រាក់កម្ចីអតិបរមា៖**
  ៥.០០០ ដុល្លារ

អ្នកត្រូវតែជាអតិថិជនរបស់សមាគមមីក្រូហិរញ្ញវត្ថុ។ការចុះឈ្មោះងាយស្រួលនិងរហ័សបំផុត!

អាចពិនិត្យមើលការសងបំណុលដោយខ្លួនឯងបានគ្រប់ពេល។

ផ្តល់ការបណ្តុះបណ្តាលអំពីការចាប់ផ្តើមអាជីវកម្ម និងការអប់រំផ្នែកហិរញ្ញវត្ថុ។

ជាប្រាក់កម្ចីដែលមានរយៈពេលវែងបំផុតនៃទីផ្សារ។បង់តាមដំណាក់កាលចំនួនទាបបំផុត។

សូមអញ្ជើញមកសាកសួរព័ត៌មានបន្ថែមពីយើងខ្ញុំ

ប្រាក់កម្ចីមហ្គ្រូហិរញ្ញវត្ថុ ល្អបផុតរបស់អ្នក

ដៃគូហិរញ្ញវត្ថុរបស់អ្នកសម្រាប់ការរីកចម្រើន និងគម្រោងថ្មី
ប្រាក់កម្ចីពិសេសសម្រាប់ម៉ូតូ៖ ទិញម៉ូតូតាមសុបិន្តរបស់អ្នក



អត្រាតាមរយៈប្រចាំឆ្នាំ៖	២៤%
រយៈពេលកម្ចី៖	១ ឆ្នាំ។
ការទូទាត់សងប្រចាំខែ៖	១១៣,៤៧ ដុល្លារ (សម្រាប់ប្រាក់កម្ចី ១.២០០ ដុល្លារ)
រយៈពេលអនុគ្រោះ៖	មិនមាន
ចំនួនប្រាក់កម្ចីអតិបរមា៖	១០.០០០ ដុល្លារ

- អាចត្រូវបានស្នើសុំប្រាក់រួមចំណែកផ្ទាល់ខ្លួនអប្បបរមាចំនួន១០%
អ្នកត្រូវតែជាអតិថិជនរបស់យើងយ៉ាងហោចណាស់រយៈពេល១២ខែ។

ជំនួយការបណ្តុះបណ្តាល យ.៣.៣

តារាងសង្ខេបអំពីកត្តាដែលមានឥទ្ធិពលទៅលើការជ្រើសរើសអ្នកឲ្យខ្ចី និងកម្ចី

កត្តាផ្សេងៗ	ធនាគារជាតិ	សហគមន៍ក្រុមហិរញ្ញវត្ថុ	ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុ
អត្រាបង់ប្រាក់ប្រចាំឆ្នាំ / ការប្រចំណាយសម្រាប់ការបង់ប្រាក់			
ភាពងាយស្រួលក្នុងការទទួលបានប្រាក់កម្ចី/លក្ខខណ្ឌ			
ចំនួនប្រាក់ដែលអាចខ្ចី			
ការសងប្រាក់ជាប្រចាំ			
ការគាំទ្រ និងការផ្តល់សេវាមិនពាក់ព័ន្ធហិរញ្ញវត្ថុ			

F I N A N C I A L E D U C A T I O N

ចេះអ្នកម្តង!

បន្ទាប់ពីពិនិត្យមើលគោលដៅ ថវិកា និងសមត្ថភាពសងប្រាក់វិញរបស់ខ្ញុំ តើខ្ញុំត្រូវការជម្រើស ឥណទានដែរឬទេ?

☐ ត្រូវការ ☐ មិនត្រូវការ

បើត្រូវការ តើសម្រាប់គោលដៅអ្វី? .....

ចំនួនប៉ុន្មាន? .....

ឥឡូវនេះ ពិនិត្យមើលព័ត៌មាននៅគ្រឹះស្ថានហិរញ្ញវត្ថុជុំវិញអ្នក ហើយបំពេញតារាងរបស់ណារី សម្រាប់គោលដៅដែលអ្នកបានសម្រេចចិត្ត ហើយអ្នកត្រូវការឥណទានសម្រាប់គោលដៅនោះ ។

⚠**សូមប្រុងប្រយ័ត្ន**! ដើម្បីធ្វើការប្រៀបធៀបជម្រើសឥណទានផ្សេងៗ អ្នកត្រូវសួរខ្លួនឯងថាតើអ្នកត្រូវចំណាយប្រាក់ប៉ុន្មាន សម្រាប់ប្រាក់កម្ចីរបស់អ្នក (មានន័យគឺថាតើអ្នកនឹងសងវិញប៉ុន្មានបន្ថែមពីលើចំនួនប្រាក់ដែលអ្នកបានខ្ចី)។ ការចំណាយនោះ រួមបញ្ចូលទាំងអត្រាការប្រាក់សម្រាប់ដើមទុនដែលបានខ្ចី ព្រមទាំងចំណាយរដ្ឋបាល ការធានារ៉ាប់រង សេវាផ្សេងទៀតដែលផ្តល់ជូន។ ដូចគ្នានឹង ណារី ដែរ សូមប្រយ័ត្ន ចំពោះអត្រាការប្រាក់ទាប ដែលតាមការពិត នឹងត្រូវចំណាយច្រើនណាស់ សម្រាប់រយៈពេលវែង!

ជម្រើស			
អត្រាភាគរយប្រចាំឆ្នាំ (APR)			
រយៈពេលនៃការខ្ចីប្រាក់			
ចំនួនដែលត្រូវបង់ប្រចាំខែ (ការបង់ តាមដំណាក់កាលប្រចាំខែ)			
ចំនួនសរុបដែលត្រូវបង់ (រយៈពេលនៃការខ្ចីប្រាក់ X ការបង់ តាមដំណាក់កាលប្រចាំខែ)			
ការចំណាយ ជាក់ស្តែងសម្រាប់ការខ្ចីប្រាក់ (ចំនួនសរុបដែលត្រូវបង់ ដកប្រាក់ដើមទុន ដែលណារីស្នើសុំខ្ចី)			

ជម្រើសល្អបំផុតសម្រាប់តម្រូវការរបស់ខ្ញុំគឺ៖.....



ជំនួយការបណ្តុះបណ្តាល ឃ.៣.៤

សេណារីយ៉ូទិញផ្ទះដោយប្រើហិរញ្ញវត្ថុតាមចម្ងាយ និង ហិរញ្ញវត្ថុតាមបែបឥស្លាម



ហិរញ្ញវត្ថុតាមចម្ងាយ

ស្ត្រីម្នាក់នៅក្នុងសហគមន៍ ចង់ទិញអចលនទ្រព្យតម្លៃ ១០០ ដុល្លារ។

នាងបានខ្ចីប្រាក់ពីធនាគារ ហើយទិញអចលនទ្រព្យនោះ។ នាងទទួលបានទ្រព្យសម្បត្តិភ្លាមៗ។ នាងត្រូវសង ១២០ ដុល្លារ ក្នុងរយៈពេល ២០ ឆ្នាំ។ តម្លៃនៃប្រាក់កម្ចីគឺ ២០ ដុល្លារ គណនាដូចខាងក្រោម:
(១២០ – ១០០ = ២០)

ហិរញ្ញវត្ថុតាមបែបឥស្លាម

ស្ត្រីឥស្លាមម្នាក់នៅក្នុងសហគមន៍ ចង់ទិញអចលនទ្រព្យតម្លៃ ១០០ ដុល្លារ។

ធនាគាររបស់នាងទិញអចលនទ្រព្យក្នុងតម្លៃ ១០០ ដុល្លារ ដោយទទួលយកហានិភ័យដែលពាក់ព័ន្ធ (ឧ. លទ្ធភាពដែលអចលនទ្រព្យអាចនឹងឆេះ)។ ផ្ទះល្វែងឥឡូវនេះជាកម្មសិទ្ធិរបស់ធនាគារ។ ធនាគារលក់ផ្ទះល្វែងឲ្យនាងក្នុងតម្លៃ ១២០ ដុល្លារ ហើយផ្ទេរកម្មសិទ្ធិអចលនទ្រព្យបន្ទាប់ពីរយៈពេល ៩០ ថ្ងៃ។ នាងបានយល់ព្រមសងប្រាក់ទៅធនាគារវិញក្នុងរយៈពេល ២០ ឆ្នាំ។ ការចំណាយសម្រាប់ប្រាក់កម្ចីគឺ ២០ដុល្លារ។
(១២០ – ១០០ = ២០)

សារសំខាន់

- ដើម្បីប្រើប្រាស់ជម្រើសឥណទានបានល្អ អ្នកគួរតែយល់ឲ្យបានច្បាស់នូវលក្ខខណ្ឌឥណទានទាំងអស់។
- ការខ្ចីប្រាក់ភ្ជាប់ជាមួយការទទួលខុសត្រូវក្នុងការទូទាត់សង និងសងទាន់ពេលវេលា។
- ការខ្ចីប្រាក់គឺជាអាជីវកម្មដែលត្រូវយកចិត្តទុកដាក់ខ្ពស់។ កុំគិតងាយៗពេក!
- ដើម្បីជ្រើសរើសជម្រើសឥណទានរបស់អ្នក អ្នកត្រូវដឹងពីជម្រើសផ្សេងៗគ្នា ដោយប្រមូលព័ត៌មានអំពីលក្ខណៈរបស់វានីមួយៗ។ ជាមួយនឹងព័ត៌មានដែលអ្នកទទួលបាន អ្នកនឹងអាចជ្រើសរើសជម្រើស ឥណទានដែលសមស្របបំផុតទៅនឹងតម្រូវការរបស់អ្នក។

៤. សូមប្រុងប្រយ័ត្ន! កុំជំពាក់បំណុលច្រើនពេក!

ជំនួយការបណ្តុះបណ្តាល ឃ.៤.១

រឿងភាពងាក់ឯងនឹងការជំពាក់បំណុលច្រើនពេក

ផ្លែកទី ១៖ រក្សាកំពុងជជែកគ្នានៅបន្ទប់ស្នាក់នៅជាមួយមិត្តរួមការងារ វ៉ានី

វ៉ានី៖ រក្សា សូមកុំភ្លេចខ្ចីប្រាក់ពីក្រុមសន្សំ និងផ្តល់ប្រាក់កម្ចីរបស់អ្នកឲ្យខ្ញុំ។

រក្សា៖ ចាស យើងនឹងជួបគ្នានៅម៉ោង ៦.០០ ល្ងាច បន្ទាប់ពីវេនការងារពេលរសៀល។ ខ្ញុំមិនបារម្ភទេ ព្រោះដូចខ្ញុំបានប្រាប់ហើយ ខ្ញុំអាចខ្ចីបាន ១០០ ដុល្លារ ហើយខ្ញុំនឹងឲ្យអ្នក។

វ៉ានី៖ ប៉ុន្តែ រក្សា ហេតុអ្វីឯងខ្ចីលុយតែ ១០០ ដុល្លារ? តើឯងភ្លេចហើយថាខ្ញុំសុំខ្ចីលុយយ៉ាងតិច ២០០ ដុល្លារ? ខ្ញុំត្រូវសងលុយគេពីរនាក់ដែលខ្ញុំខ្ចីក្រៅផ្លូវការ នៅថ្ងៃស្អែក។

រក្សា៖ វ៉ានី ឯងច្រឡំហើយ។ ខ្ញុំប្រាប់អ្នកថាខ្ញុំអាចខ្ចីបានតែ១០០ដុល្លារទេ ហើយឯងបានឆ្លើយតបថាអ្នកនឹងរកលុយបន្ថែមទៀតដើម្បីយកទៅសងគេ!

វ៉ានី៖ ដឹង ប៉ុន្តែខ្ញុំរកមិនអាចទេ។ ឯងត្រូវតែខ្ចីយ៉ាងហោចណាស់ ២០០ ដុល្លារពីក្រុមរបស់អ្នក ដើម្បី សង្គ្រោះខ្ញុំនៅពេលនេះ។ ខ្ញុំដឹងថា ពេលខ្លះ តុងទីន ផ្តល់ប្រាក់បន្ថែមដល់សមាជិក។ បើទោះជាការប្រាក់ខ្ពស់ក៏ដោយ ខ្ញុំនឹងសងអ្នកវិញ។ ខ្ញុំសូមសន្យា។

រក្សា៖ ប៉ុន្តែខ្ញុំនឹងមិនអាចសងប្រាក់កម្ចីដ៏ច្រើនដល់ក្រុមបានទេ!
ខ្ញុំមិនចង់ធ្វើឲ្យខូចឈ្មោះរបស់ខ្ញុំនៅក្នុងក្រុមសន្សំប្រាក់នោះទេ។

វ៉ានី៖ កុំបារម្ភអី។ ខ្ញុំនឹងសងប្រាក់ដែលឯងត្រូវការនៅពេលក្រោយ។ ឥឡូវ ខ្ញុំត្រូវតែទៅហើយ។ ជួបគ្នាពេលក្រោយ។

ផ្លែកទី ២៖ វ៉ានីកំពុងជជែកគ្នាជាមួយវិសាល ជាអ្នកឲ្យខ្ចីប្រាក់ក្រៅផ្លូវការដែលតែងតែឲ្យលុយកម្មករខ្ចី ហើយនាងជាមិត្តភក្តិរបស់គាត់។

វ៉ានី៖ សួស្តីវិសាល! អ្នកសុខសប្បាយទេ? ខានជួបគ្នាយូរហើយ។

វិសាល៖ បាទ មិនអីទេ អរគុណវ៉ានី។ ចុះអ្នកវិញ?

វ៉ានី៖ ខ្ញុំមិនអីទេ។ ខ្ញុំត្រូវសូមឲ្យជួយ។ តើអ្នកអាចឲ្យខ្ញុំខ្ចី ១០០ ដុល្លារបានទេ? ខ្ញុំមានបំណុលបន្ទាន់ខ្លះ ជាមួយអ្នកផ្តល់ប្រាក់កម្ចីផ្សេងទៀត ដែលខ្ញុំត្រូវសងនៅថ្ងៃនេះ។

វិសាល៖ (ព្យាយាមងាកចេញ..) ប៉ុន្តែ វ៉ានី នេះជាលើកទី២ហើយ ដែលអ្នកសុំខ្ចីលុយពីខ្ញុំទៅសងអ្នក ផ្សេង។ ហើយលើកចុងក្រោយដែលអ្នកបានខ្ចីលុយពីខ្ញុំ អ្នកក្រសងលុយឲ្យខ្ញុំវិញណាស់។

វ៉ានី៖ វិសាល កុំបារម្ភ! ខ្ញុំនឹងសងអ្នកវិញ។ ថ្ងៃនេះខ្ញុំទទួលបានប្រាក់ខ្លះពីអ្នកធ្វើការជាមួយខ្ញុំ ឈ្មោះរក្សា។ ហើយ ខ្ញុំនឹងមិនខ្ចីទៀតទេ ហើយខ្ញុំនឹងខំសងអ្នកវិញ។

វិសាល៖ អ្នកខ្ចីលុយពីអ្នកធ្វើការជាមួយដៃរមែនទេ?

វ៉ានី៖ ចាស ខ្ញុំក៏ត្រូវខ្ចីពីនាងដែរ ព្រោះខ្ញុំមិនអាចធ្វើការបន្ថែមច្រើនម៉ោងបានទេ កាលពីខែមុន។ ខ្ញុំជំពាក់បំណុលគេច្រើន ប៉ុន្តែខ្ញុំជឿជាក់ថាអ្វីៗនឹងប្រសើរឡើងក្នុងពេលឆាប់ៗនេះ។

សំណួរ

- តើវ៉ានីកំពុងធ្វើអ្វី?
- ហេតុអ្វីបានជានាងខ្ចីពីអ្នកឲ្យខ្ចីប្រាក់ ច្រើននាក់?
- តើវ៉ានីគិតយ៉ាងណាចំពោះអ្នកផ្តល់ប្រាក់កម្ចីផ្សេងទៀត?
- តើរក្សា អាចជួយ វ៉ានី បានដោយវិធីណា?
- តើអ្នកគិតថានឹងមានអ្វីកើតឡើងចំពោះវ៉ានី?

ចំណុចសំខាន់ៈ

ការជំពាក់បំណុលច្រើនពេក គឺជាពេលដែលមនុស្សម្នាក់មិនអាចដោះស្រាយបំណុលផ្ទាល់ខ្លួនរបស់ពួកគេ រួមទាំងកម្ចីធនាគារ (ដើម្បីរក្សាបាននូវលក្ខខណ្ឌរស់នៅសមរម្យសម្រាប់ខ្លួន និងគ្រួសារ)

⚠ **ចំណុចសំខាន់ៈ** អ្នកអាចមានអារម្មណ៍ខ្មាស់អៀនចំពោះការជំពាក់បំណុលគេច្រើនពេក ហើយនេះអាចប៉ះពាល់ដល់ទំនាក់ទំនងរបស់អ្នកជាមួយគ្រួសារ និងមិត្តភក្តិ។ កុំនៅឯកោ ហើយចូរនិយាយអំពីបញ្ហារបស់អ្នកជាមួយមនុស្សដែលអ្នកទុកចិត្ត។

គន្លឹះដើម្បីឲ្យរួចផុតពីការជំពាក់បំណុលច្រើនជ្រុល

- ខ្ចីតែចំនួនលុយដែលអ្នកអាចសងគេវិញ។
- គណនាសមាមាត្របំណុលទៅចំណូលរបស់អ្នក។ គណនាប្រាក់ចំណូលប្រចាំខែសរុបរបស់អ្នក និងការទូទាត់ប្រចាំខែ ដើម្បីសងប្រាក់កម្ចីរបស់អ្នក (កាតព្វកិច្ចបំណុលប្រចាំខែ)។ ប្រៀបធៀបតួលេខទាំងពីរ ហើយគណនាសមាមាត្រ។ ជាធម្មតា ប្រសិនបើការទូទាត់សងរបស់អ្នកឈានដល់ ៣០ ភាគរយនៃប្រាក់ចំណូលប្រចាំខែរបស់អ្នក អ្នកមិនគួរខ្ចីប្រាក់បន្ថែមឡើយ។
- ប្រសិនបើអ្នកមិនអាចសងប្រាក់កម្ចីទាន់ពេលទេ ចូរស្មោះត្រង់ជាមួយអ្នកផ្តល់ប្រាក់ឲ្យខ្ចី ហើយពន្យល់ពីមូលហេតុនៃបញ្ហាប្រឈមនេះ។
- ស្តាប់ដំបូន្មានរបស់អ្នកឲ្យប្រាក់ខ្ចី មិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកអំពីរបៀបសងប្រាក់កម្ចីរបស់អ្នក។
- កាត់បន្ថយការចំណាយខ្លះក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ដើម្បីសងបំណុល។
- រក្សាទុកប្រាក់សន្សំមួយចំនួន សម្រាប់ពេលមានអាសន្ន ជានិច្ច ដើម្បីឲ្យអ្នកអាចដោះស្រាយស្ថានភាពអាសន្នដោយមិនប៉ះពាល់ដល់ការសងប្រាក់កម្ចីរបស់អ្នក។
- **ចាត់ឱកាសការ**!ចូរជួបអ្នកគ្រប់គ្រងគណនីរបស់អ្នកនៅគ្រឹះស្ថានហិរញ្ញវត្ថុ។ កុំរង់ចាំរហូតដល់វាយឺតពេក ក្នុងការសុំជំនួយ។



ជំនួយការបណ្តុះបណ្តាល ឃ.៤.២
ភាគសម្រាប់ការដើរតួ

ROLE-PLAY CARDS

តួនាទីទី ១

ពួកអ្នកជាអ្នកធ្វើការជាមួយវ៉ានី។ នាងជំពាក់លុយពួកអ្នក។ នាងមិនបានសងប្រាក់ដែលនាងបានខ្ចី ឡើយ។ ចូររៀបចំការសម្តែងខ្លីមួយ ដែលអ្នកពិភាក្សាអំពីស្ថានភាព និងសម្រេចថាត្រូវធ្វើយ៉ាងណាចំពោះ វ៉ានី។

ការអប់រំផ្នែកហិរញ្ញវត្ថុ

ROLE-PLAY CARDS

តួនាទីទី ២

អ្នកគឺជាសមាជិកនៃគ្រួសារ និងមិត្តភ័ក្តិរបស់វ៉ានី។ អ្នកមិនបានទទួលលុយពីវ៉ានីក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ហើយអ្នកបារម្ភអំពីនាងបន្តិច។ ចូររៀបចំការសម្តែងខ្លីមួយ ដែលអ្នកពិភាក្សាអំពីស្ថានភាព និងសម្រេចថាត្រូវធ្វើយ៉ាងណាចំពោះវ៉ានី។

ការអប់រំផ្នែកហិរញ្ញវត្ថុ

ROLE-PLAY CARDS

តួនាទីទី ៣

អ្នកគឺជាអ្នកឲ្យខ្ចីប្រាក់ក្រៅផ្លូវការម្នាក់ដែលឲ្យលុយទៅវ៉ានីខ្ចីជាញឹកញាប់។ ចូររៀបចំការសម្តែងខ្លីមួយ ដែលអ្នកប្រាប់អំពីស្ថានភាពរបស់វ៉ានីដល់អ្នកផ្តល់ប្រាក់កម្ចីផ្សេងទៀត។

ការអប់រំផ្នែកហិរញ្ញវត្ថុ



ដូចរបស់អ្នកម្តេច!

តើអ្នកជំពាក់បំណុលគេច្រើនជ្រុលមែនទេ?

តើការតបកិច្ចសងបំណុលប្រចាំខែរបស់អ្នកលើសពី ៣០ ភាគរយនៃប្រាក់ចំណូលប្រចាំខែរបស់អ្នកមែនទេ? ☐ ប្រាន/ចាស ☐ អត់ទេ

តើអ្នកទទួលយកឥណទានបសម្រាប់ទុនបង្វិល (ឥណទានដែលអាចបន្តពេលបាន) ញឹកញាប់ដែរឬទេ? ☐ ប្រាន/ចាស ☐ អត់ទេ

តើអ្នកស្នើសុំពន្យារពេលក្នុងការបង់ថ្លៃចំណាយជាប្រចាំ (ថ្លៃជួល ថ្លៃភ្លើង...) ញឹកញាប់ជាងមុនដែរឬទេ? ☐ ប្រាន/ចាស ☐ អត់ទេ

តើអ្នកប្រើប្រាស់ប្រាក់កម្ចីរបស់អ្នកកាន់តែច្រើនឡើង ដើម្បីរ៉ាប់រងការចំណាយក្នុងការរស់នៅប្រចាំថ្ងៃរបស់អ្នកទេ? ☐ ប្រាន/ចាស ☐ អត់ទេ

ប្រសិនបើអ្នកឆ្លើយថា ប្រាន/ចាស ចំពោះសំណួរទាំងនេះ យ៉ាងហោចណាស់មួយ អ្នកត្រូវប្រុងប្រយ័ត្ន! អ្នកអាចនឹងជំពាក់បំណុលច្រើនជ្រុល ឬប្រឈមនឹងការជំពាក់បំណុលច្រើនជ្រុល។
ចាត់វិធានការភ្លាមៗតាមរយៈការរៀបចំបង្កើតថវិកា ហើយនិយាយជាមួយម្ចាស់បំណុលរបស់អ្នកដើម្បីសងបំណុលរបស់អ្នកឲ្យប្រានឆាប់តាមដែលអាចធ្វើទៅប្រាន និងជៀសវាងការធ្លាក់ចូលទៅក្នុងវដ្តដ៏ អាក្រក់នៃបំណុល។

ដំណោះស្រាយមួយចំនួន

ប្រសិនបើអ្នកជំពាក់បំណុលគេច្រើនពេក ខាងក្រោមនេះជាដំណោះស្រាយដែលអាចផ្តល់ដោយស្តាប័នឥណទានរបស់អ្នក ៖

- កំណត់ពេលឡើងវិញសម្រាប់ការសងបំណុល ពោលគឺកាត់បន្ថយចំនួនទឹកប្រាក់ដែលបានសងរាល់ខែ និងពន្យារយៈពេលនៃប្រាក់កម្ចី។
- ផ្អាកការសងសម្រាប់រយៈពេលមួយដែលបានកំណត់។
- លក់ទ្រព្យសកម្ម ដើម្បីសងបំណុលច្រើនរបស់អ្នក (ឧ. បំណុលដែលមានការប្រាក់ខ្ពស់បំផុត)។

សូមកុំស្ទាក់ស្ទើរក្នុងការសាកសួរអំពីសេវាកម្មសម្របសម្រួលរបស់ស្តាប័នឥណទានរបស់អ្នក!

សារសំខាន់


- ការសងប្រាក់វិញ គឺជាការសម្រេចចិត្តមួយដែលត្រូវធ្វើនៅពេលអ្នកសម្រេចចិត្តខ្ចីប្រាក់។
- ជៀសវាងការខ្ចីប្រាក់ដើម្បីសងប្រាក់កម្ចី!
- ប្រាក់ទទួលបានពីឥណទាន មិនមែនជាប្រាក់របស់អ្នកទេ!

ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ

សំណួរដើម្បីសួរទៅកាន់អ្នកដែលអាចឲ្យប្រាក់អ្នកខ្ចី

- តើអ្នកផ្តល់ប្រាក់កម្ចីប្រភេទណាខ្លះ? តើអ្នកអាចឲ្យប្រាក់ខ្ចីដើម្បីទិញអ្វីខ្លះ (ទិញផ្ទះ ចាប់ផ្តើមអាជីវកម្ម ទិញរថយន្ត។ល។)?
- តើមានការប្រាក់ប៉ុន្មាន?
- តើត្រូវគិតថ្លៃសេវាអ្វីខ្លះ?
- តើអត្រាការប្រាក់ប៉ុន្មានភាគរយ (ឧ. ការចំណាយជាក់ស្តែងសម្រាប់ខ្ចីប្រាក់ រួមទាំងថ្លៃសេវា)?
- តើខ្ញុំត្រូវផ្តល់ការធានាដើម្បីទទួលបានប្រាក់កម្ចីដែរឬទេ? បើដូច្នេះ តើផ្តល់ការធានាអ្វីខ្លះ?
- តើខ្ញុំត្រូវចូលរួមចំណែកប៉ុន្មានភាគរយ បើត្រូវចូលរួមចំណែក?
- តើត្រូវបង់ការប្រាក់នៅពេលណាខ្លះ?
- តើត្រូវទូទាត់សងប្រាក់នៅពេលណាខ្លះ? (ឧ. ដើមខែ ឬចុងខែ)?
- តើមានការពិន័យអ្វីខ្លះ ក្នុងករណីនៃការបង់ប្រាក់យឺត?
- តើត្រូវសងប្រាក់នៅកន្លែងណា?
- តើត្រូវចំណាយពេលប៉ុន្មានក្នុងការទទួលបានប្រាក់កម្ចី?
- តើខ្ញុំត្រូវមកទីនេះប៉ុន្មានដងដើម្បីបញ្ចប់ការស្នើសុំប្រាក់កម្ចី?
- តើឯកសារអ្វីខ្លះដែលខ្ញុំត្រូវបង្ហាញជូនអ្នកឲ្យខ្ចី ដើម្បីទទួលបានប្រាក់កម្ចី?
- តើខ្ញុំត្រូវបង់ការប្រាក់ដែលនៅសល់ដែរឬទេ ប្រសិនបើខ្ញុំសងប្រាក់កម្ចីមុនពេលកំណត់?
- តើតម្រូវឲ្យមានការធានារ៉ាប់រងជាកំហិត ឬជាជម្រើសដែរឬទេ ប្រសិនបើខ្ញុំទទួលយកប្រាក់កម្ចីនេះ? ប្រសិនបើតម្រូវឲ្យមាន តើត្រូវចំណាយអស់ប៉ុន្មាន ហើយសម្រាប់អ្វីខ្លះ?
- តើការិយាល័យដែលខ្ញុំត្រូវទូទាត់បង់ប្រាក់ មានចម្ងាយប៉ុន្មានពីផ្ទះ/កន្លែងអាជីវកម្មរបស់ខ្ញុំ?
- តើខ្ញុំត្រូវចូលរួមការប្រជុំនានា ដើម្បីទទួលបានឥណទានដែរឬទេ?
- តើកិច្ចប្រជុំទាំងនេះមានរយៈពេលប៉ុន្មាន?
- តើអ្នកពិនិត្យមើលថាតើខ្ញុំមានខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតដែរឬទេ?

ចម្លើយចំពោះលំហាត់



ជំនួយការបណ្តុះបណ្តាល ឃ.១.៣ៈ គុណសម្បត្តិ និងគុណវិបត្តិនៃវិធីផ្សេងៗនៃការទទួលបានប្រាក់

គុណសម្បត្តិ និងគុណវិបត្តិនៃវិធីផ្សេងៗនៃការទទួលបានប្រាក់

	គុណសម្បត្តិ	គុណវិប្បត្តិ
ការលក់ទ្រព្យ/អចលនទ្រព្យ	• អ្នកអាចប្រើធនធានផ្ទាល់ខ្លួនរបស់អ្នក។	• ទ្រព្យសម្បត្តិ អាចធ្លាក់ថ្លៃ • ប្រសិនបើវាជាទ្រព្យសម្រាប់ផលិតកម្ម គ្រួសារអាចនឹងត្រូវចំណាយបន្ថែម ឬត្រូវចំណាយកាន់តែច្រើនពីមួយថ្ងៃទៅមួយថ្ងៃ
ប្រាក់សន្សំ	• អាចប្រើប្រាស់ភ្លាមៗ • ប្រាក់ផ្ទាល់ខ្លួន • មិនត្រូវបង់ការប្រាក់ • អ្នកអាចធ្វើអ្វីដែលអ្នកពេញចិត្តជាមួយនឹងប្រាក់របស់អ្នក (មិនមានការជ្រៀតជ្រែកពីខាងក្រៅ)	• ប្រាក់សន្សំរបស់អ្នកអាច រិចរិល។ • ប្រាក់ត្រូវសន្សំទុកក្នុងរយៈពេលយូរ ហើយប្រហែលជាមិនអាចបំពេញតម្រូវការទាំងអស់របស់អ្នកបានទេ។ • អ្នកអាចខ្វះធនធាន ហិរញ្ញវត្ថុក្នុងពេលមានអាសន្ន
ការខ្ចីប្រាក់ពីអ្នកផ្តល់ប្រាក់កម្ចីក្រៅផ្លូវការ (គ្រួសារ ម្ចាស់ហាង និយោជក)	• លឿន • អាចខ្ចីបាននៅហ្នឹងកន្លែង • មិនត្រូវអនុវត្តតាមនីតិវិធី	• ការប្រាក់ខ្ពស់ • ហានិភ័យៈ ប្រសិនបើអ្នកខកខានក្នុងការសងប្រាក់វិញ អ្នកផ្តល់ប្រាក់កម្ចីអាចប្រើវិធី "កាច" រួមទាំងការគំរាមកំហែងផងដែរ។ • គ្មានការការពារផ្លូវច្បាប់ក្នុងករណីមានការរំលោភបំពានដោយម្ចាស់បំណុល • ងាយជំពាក់បំណុលគេ
កម្ចីពីស្ថាប័នហិរញ្ញវត្ថុផ្លូវការ (ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សមាគមសន្សំ និងកម្ចីភូមិ អង្គការសហករណ៍សន្សំ និងឥណទាន)	• លឿន • ងាយទទួលបានប្រាក់កម្ចី • នៅជិតខ្លួន • បានចុះឈ្មោះស្របតាមតម្រូវការច្បាប់ • ផ្នែកនៃក្រុមដែលអាចផ្តល់ដំបូន្មាន (ទិដ្ឋភាពសង្គម/ការគាំទ្រពីសហគមន៍)	• ប្រហែលជាមិនមានជម្រើសដែលសមស្របនឹងតម្រូវការរបស់អ្នកឡើយ។ • ជួនកាលអត្រាការប្រាក់ ខ្ពស់។ • អ្នកផ្តល់សេវាខ្លះអាចផ្តល់ហិរញ្ញប្បទានដល់ខ្ញុំប្រសិនបើខ្ញុំមានអាជីវកម្មដែលបានចុះ បញ្ជី។ • ងាយជំពាក់បំណុលគេ

ជំនួយការបណ្តុះបណ្តាល ឃ.២.១

លក្ខខណ្ឌ និងនិយមន័យដែលពាក់ព័ន្ធជាមួយឥណទាន/ប្រាក់កម្ចី

ការប្រាក់	ចំនួនប្រាក់ដែលអ្នកខ្ចីប្រាក់បង់ទៅអ្នកឲ្យប្រាក់ខ្ចី បន្ថែមពីលើការសងប្រាក់កម្ចី ដើម្បីអាចប្រើប្រាស់ប្រាក់របស់អ្នកឲ្យប្រាក់ខ្ចី។
ការពិន័យ	ចំនួនប្រាក់ដែលអ្នកខ្ចីនឹងត្រូវបង់ទៅឲ្យអ្នកខ្ចី ប្រសិនបើគាត់ខកខានក្នុងការសងប្រាក់កម្ចី (ឧ. ការរឹបអូសទ្រព្យសម្បត្តិ យានយន្ត ការសន្យំ...)
ឈ្មួញកណ្តាលឥណទាន	អ្នកជំនាញដែលជួយអតិថិជនរបស់គាត់ក្នុងការទទួលបានប្រាក់កម្ចី សមស្របបំផុត និង/ឬមានការប្រាក់ទាបបំផុត (ជាទូទៅ ប្រាក់កម្ចីបញ្ចាំ) ពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត
ប្រាក់ដើម	ចំនួនប្រាក់កម្ចីដែលផ្តល់ឲ្យដោយអ្នកផ្តល់ប្រាក់កម្ចី មិនគិតបញ្ចូលការប្រាក់
អ្នកធានា	បុគ្គលដែលនឹងសងប្រាក់កម្ចីរបស់អ្នកក្នុងករណីដែលអ្នកខកខានមិនបានសង។ បុគ្គលនេះអាចត្រូវបានស្នើសុំឲ្យចុះហត្ថលេខារបស់គាត់បញ្ជាក់ពីការព្រមព្រៀងជាមួយអ្នកផ្តល់ប្រាក់កម្ចី។ ការធានាក៏អាចធ្វើឡើងក្នុងទម្រង់ជាទ្រព្យសម្បត្តិផងដែរ។
ការចូលរួមចំណែកផ្ទាល់ខ្លួន	សមាមាត្រនៃចំនួនប្រាក់ដែលអ្នកត្រូវផ្តល់សម្រាប់គម្រោងខ្ចីប្រាក់របស់អ្នក មុនពេលខ្ចីប្រាក់បន្ថែមពីស្ថាប័នឥណទាន ដែលផ្តល់ឲ្យតាមរយៈទ្រព្យសកម្ម និងប្រាក់សន្សំរបស់អ្នក។
ការដាក់ទ្រព្យបញ្ចាំ	ការដាក់ទ្រព្យសម្បត្តិរបស់អ្នកជាសន្តិសុខដើម្បីទទួលបានឥណទានពីស្ថាប័នហិរញ្ញវត្ថុ។ ក្នុងករណីដែលមិនបានសងវិញ ម្ចាស់បំណុលអាចរឹបអូសយកទ្រព្យសម្បត្តិដែលពាក់ព័ន្ធ ទៅលក់ដើម្បីទទួលបានមកវិញនូវចំនួនប្រាក់ដែលអ្នកបានខ្ចី បូកនឹងការចំណាយផ្សេងៗ។ កម្មសិទ្ធិកមិនបាត់បង់កម្មសិទ្ធិលើអចលនទ្រព្យដែលដាក់បញ្ចាំទេ ដរាបណាគាត់គោរពតាមកាតព្វកិច្ចសងបំណុលរបស់គាត់។
ការសងប្រាក់មុនពេលកំណត់	ការសងប្រាក់វិញទាំងអស់ ឬមួយផ្នែកនៃប្រាក់កម្ចីរបស់អ្នកមុនរយៈពេលសងប្រាក់ដែលបានព្រមព្រៀង។
ការគិតសារជាថ្មី	ការលុបចោលកិច្ចព្រមព្រៀងឥណទានដោយគ្មានការពិន័យ។ "រយៈពេលសម្រាប់ធ្វើការពិចារណា" សម្រាប់ការទិញដោយគ្មានគ្រោងទុក។
រយៈពេលអនុគ្រោះ	រយៈពេលអនុញ្ញាតចាប់ពីការទទួលប្រាក់កម្ចី និងការសងដំបូង (ទិញឥឡូវនេះ បង់ពេលក្រោយ)

ជំនួយការបណ្តុះបណ្តាល ឃ.៣.១

ការគណនាការចំណាយសម្រាប់ការខ្ចីប្រាក់របស់ណារី

(បំពេញហើយ)

ជម្រើស	ធនាគារជាតិ	សមាគមមីក្រូហិរញ្ញវត្ថុ	ក្រុមហ៊ុនឯកជនមីក្រូហិរញ្ញវត្ថុ
អត្រាការប្រចាំឆ្នាំ (APR)	១២%ក្នុងមួយឆ្នាំ	១៨%ក្នុងមួយឆ្នាំ	២៤%ក្នុងមួយឆ្នាំ
រយៈពេលនៃការខ្ចីប្រាក់	២ឆ្នាំ (២៤ខែ)	៣ឆ្នាំ (៣៦ខែ)	១ឆ្នាំ (១២ខែ)
ចំនួនដែលត្រូវបង់ប្រចាំខែ (ការបង់ តាមដំណាក់កាលប្រចាំខែ)	៦៦,៤៨ ដុល្លា	៤៣,៣៨ ដុល្លា	១១៣,៤៧ ដុល្លា
ចំនួនសរុបដែលត្រូវបង់ (រយៈពេលនៃការខ្ចីប្រាក់ X ការបង់ តាមដំណាក់កាលប្រចាំខែ)	៦៦,៤៨ ដុល្លា	៤៣,៣៨ ដុល្លា	១១៣,៤៧ ដុល្លា
ការចុំណាយ ជាក់ស្តែងសម្រាប់ការខ្ចីប្រាក់ (ចំនួនសរុបដែលត្រូវបង់ ដកប្រាក់ដើមទុន ដែលណារីស្នើសុំខ្ចី)	១៣៥៥, ៧០ដុល្លា –១២០០ ដុល្លា =១៥៥, ៧០ដុល្លា	១.៥៦១ដុល្លា – ១២០០ ដុល្លា = ៣៦១, ៧៨ដុល្លា	១.៣៦១.៦៧ ដុល្លា – ១២០០ ដុល្លា = ១៦១,៦៧ដុល្លា

កន្លែងកត់ត្រា

ជំនួយការបណ្តុះបណ្តាល ឃ.៣.៣

តារាងសង្ខេបអំពីកត្តាដែលមានឥទ្ធិពលទៅលើការជ្រើសរើសអ្នកឲ្យខ្ចី និងកម្ចី (បញ្ចប់)

លក្ខណៈវិនិច្ឆ័យរបស់ណារីក្នុងការជ្រើសរើសអ្នកឲ្យខ្ចី និងកម្ចី

កត្តាផ្សេងៗ	ធនាគារជាតិ	សមាគមមីក្រូហិរញ្ញវត្ថុ	ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុ
អត្រាបង់ប្រាក់ប្រចាំឆ្នាំ /ការចំណាយសម្រាប់ការបង់ប្រាក់	• អត្រាបង់ប្រាក់ប្រចាំឆ្នាំទាបជាងគេ ហើយចំណាយតិចជាងគេសម្រាប់ការខ្ចីប្រាក់	• អត្រាបង់ប្រាក់ប្រចាំឆ្នាំក្នុងកម្រិតមធ្យម ហើយចំណាយច្រើនជាងសម្រាប់ការខ្ចីប្រាក់	• អត្រាបង់ប្រាក់ប្រចាំឆ្នាំខ្ពស់ជាងគេ ហើយចំណាយមធ្យមសម្រាប់ការខ្ចីប្រាក់
ភាពងាយស្រួលក្នុងការទទួលបានប្រាក់កម្ចី/លក្ខខណ្ឌ	• មិនប្រាកដថាណារីជាអតិថិជនរបស់ធនាគារនេះអស់រយៈពេលជាង៦ខែ • ការរួមចំណែកផ្ទាល់ខ្លួនអាចទទួលយកបានសម្រាប់ណារី • ការបង់រំលស់ប្រចាំខែសមស្របទៅនឹងសមត្ថភាពសងរបស់ណារី	• តម្រូវឲ្យក្លាយជា អតិថិជនរបស់សមាគមមីក្រូហិរញ្ញវត្ថុប៉ុន្តែវា ងាយស្រួលសម្រាប់ណារី ដើម្បីក្លាយជាអតិថិជន • ការបង់រំលស់ប្រចាំខែសមស្របទៅនឹងសមត្ថភាពសងរបស់ណារី	• ការរួមចំណែកផ្ទាល់ខ្លួនអាចទទួលយកបានសម្រាប់ណារី • ការបង់រំលោះប្រចាំខែគឺខ្ពស់ពេកសម្រាប់ណារី
ចំនួនប្រាក់ដែលអាចខ្ចី	• ចំនួនគ្រប់គ្រាន់	• ចំនួនគ្រប់គ្រាន់	• ចំនួនគ្រប់គ្រាន់
ការសងប្រាក់ជាប្រចាំ	• ប្រចាំខែ	• ប្រចាំខែ	• ប្រចាំខែ
ការគាំទ្រ និងការផ្តល់សេវាមិនពាក់ព័ន្ធ ហិរញ្ញវត្ថុ	• មិនមាន	• មាន (ប្រហែលជាសំខាន់ណាស់ចំពោះណារីក្នុងការទទួលបានការគាំទ្រ/ការជួយគ្រប់គ្រង)	• មិនមាន
សេចក្តីសន្និដ្ឋាន	• ប្រាក់កម្ចីដែលត្រូវចំណាយតិចបំផុត។ • មិនទទួលបានការគាំទ្រទេ។ • ណារី ត្រូវតែជាអតិថិជន ឬបើមិនដូច្នេះទេ ត្រូវរង់ចាំ ៦ ខែ ទើបមានសិទ្ធិខ្ចី	• ប្រាក់កម្ចីត្រូវចំណាយខ្ពស់បំផុត ប៉ុន្តែមានការគាំទ្រសម្រាប់សហគ្រិន ហើយមិនចាំបាច់ដាក់ប្រាក់រួមចំណែកផ្ទាល់ខ្លួនទេ។ ផ្តល់ឲ្យការបណ្តុះបណ្តាលសំខាន់ដល់ណារី និងការសងប្រាក់មានរយៈពេលវែងជាងគេ។	• ប្រាក់បង់រំលោះមានចំនួនច្រើនពេកសម្រាប់នាង។ • ការចំណាយជាមធ្យម ប៉ុន្តែរយៈពេលខ្លីពេកសម្រាប់លទ្ធភាពនៃការសងបំណុលរបស់នាង។



ជ្រើសរើសមធ្យោបាយនៃការបង់ប្រាក់ និងជម្រើសផ្ទេរប្រាក់

FINANCIAL EDUCATION QUIZ

ជ.១. ការដកប្រាក់គឺជាការដែលខ្ញុំអាច

- ☐ **ក.** ធ្វើការដកប្រាក់ និងទូទាត់ប្រាក់។
- ☐ **ខ.** ធ្វើការដកប្រាក់តែប៉ុណ្ណោះ។
- ☐ **គ.** ធ្វើការដកប្រាក់ ទោះបីជាខ្ញុំគ្មានលុយនៅក្នុងគណនីរបស់ខ្ញុំក៏ដោយ។

ជ ២. មានឧណាម្នាក់លួចកាតធនាគាររបស់ខ្ញុំ តើខ្ញុំគួរធ្វើដូចម្តេច?

- ☐ **ក.** ចោរមិនមានលេខសម្ងាត់របស់ខ្ញុំ ដូច្នេះខ្ញុំមិនបារម្ភទេ។ ខ្ញុំនឹងមិនធ្វើអ្វីទេ។
- ☐ **ខ.** ខ្ញុំបានទាក់ទងធនាគាររបស់ខ្ញុំភ្លាមៗដើម្បីបិទកាត។
- ☐ **គ.** ខ្ញុំបានទាក់ទងធនាគាររបស់ខ្ញុំភ្លាមៗដើម្បីចេញកាតថ្មី។

ជ ៣. ការផ្ទេរប្រាក់អនុញ្ញាត

- ☐ **ក.** ដើម្បីបើកគណនីធនាគារ។
- ☐ **ខ.** ដើម្បីផ្ទេរប្រាក់ពីកន្លែងមួយទៅកន្លែងមួយទៀត។
- ☐ **គ.** ដើម្បីចូលប្រើប័ណ្ណឥណពន្ធ ដើម្បីទូទាត់ការទិញរបស់អ្នក។

ជ៤. តើវិធីណាដែលមានសុវត្ថិភាពបំផុតក្នុងការផ្ញើប្រាក់ទៅផ្ទះ?

- ☐ **ក.** សុំឲ្យមិត្តរួមការងារយកលុយមកផ្ទះវិញ។
- ☐ **ខ.** តាមរយៈប្រតិបត្តិករផ្ទេរប្រាក់ផ្លូវការ។
- ☐ **គ.** តាមរយៈសាច់ញាតិ។

ជ:១ក ជ:២ក ជ:៣ក ជ:៤ក ៖ភាគ្លើរ

១. ប្រើមធ្យោបាយទូទាត់ដោយសុវត្ថិភាព

នៅក្នុងមរៀនមុនៗ យើងបានស្វែងយល់ពីរបៀបជ្រើសរើសជម្រើសកម្ចី និងប្រាក់សន្សំសមស្របនឹងតម្រូវការរបស់អ្នក។ ឥឡូវនេះ យើងនឹងស្វែងយល់ពីវិធីល្អបំផុតក្នុងការប្រើមធ្យោបាយទូទាត់ផ្សេងៗ ឧទាហរណ៍ ការទូទាត់សម្រាប់ទិញទំនិញ។

ប្រសិនបើអ្នកចង់បង់ប្រាក់សម្រាប់ការទិញ តើមធ្យោបាយទូទាត់អ្វីខ្លះ?

មធ្យោបាយផ្សេងគ្នានៃការទូទាត់ និងប្រតិបត្តិការទូទាត់

- សាច់ប្រាក់
- កាតធនាគារ
- ការទូទាត់តាមអ៊ីនធឺណិត
- ការផ្ទេរប្រាក់តាមធនាគារ និងឥណពន្ធផ្ទាល់
- កាបូបឌីជីថល
- មូលប្បទានប័ត្រ
- តាមប្រព័ន្ធអេឡិចត្រូនិក
- ការទូទាត់តាមទូរស័ព្ទដៃ (ប្រសិនបើមានសេវានេះនៅក្នុងប្រទេស)
- ការផ្លាស់ប្តូរទំនិញ និងសេវា...

នៅចុងបញ្ចប់នៃមេរៀននេះ នៅក្នុងចម្លើយសម្រាប់លំហាត់ អ្នកនឹងរកឃើញតារាងបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃមធ្យោបាយទូទាត់នីមួយៗ។



ករណីសិក្សាទី១

រក្សាទទួលបានកាតសម្រាប់សមាជិកម្នាក់ក្នុងគ្រួសាររបស់នាង

រក្សានឹងធ្វើដំណើរទៅរាជធានីជាមួយបងប្អូនជីដូនមួយរបស់នាង។ ពួកគេចង់ទិញរបស់របរជាច្រើនសម្រាប់ប្រើប្រាស់នៅផ្ទះ។ រស្មី បារម្ភពីការយកកាតដែលភ្ជាប់ទៅគណនីធនាគាររបស់នាង ព្រោះនាង ខ្លាចបាត់កាត។ នាងបានទូរស័ព្ទទៅធនាគាររបស់នាង ហើយបានដឹងថាពួកគេមានកាតប្រភេទមួយដែលនាងអាចបញ្ចូលទឹកប្រាក់តាមចំនួនទឹកប្រាក់ដែលនាងចង់បាន ដោយផ្ទេរដោយផ្ទាល់ពីគណនីធនាគាររបស់នាង។ នាងសម្រេចចិត្តទៅធ្វើកាតនេះ។ ក្នុងអំឡុងពេលដែលនាងធ្វើដំណើរទៅទីក្រុង រស្មីអាចដកប្រាក់ បង់ថ្លៃទំនិញ និងថែមទាំងពិនិត្យសមតុល្យរបស់នាងនៅម៉ាស៊ីនដកប្រាក់បានទៀតផង។

ករណីសិក្សាទី ២

ការប្រើប្រាស់កាតរបស់ប៊ូវ៉ាន

វាជាសប្តាហ៍ដំបូងនៃខែ ហើយប៊ូវ៉ានទើបតែទទួលបានការទូទាត់ប្រចាំខែរបស់គាត់ នៅក្នុងគណនីធនាគាររបស់គាត់ជាលើកដំបូង។ តាមអ្វីដែលនិយោជករបស់គាត់បានប្រាប់គាត់ កាតដែលពួកគេផ្តល់ឲ្យគាត់នឹងអនុញ្ញាតឲ្យគាត់ធ្វើប្រតិបត្តិការផ្សេងៗគ្នាបានជាច្រើន។ ប៉ុន្មានថ្ងៃក្រោយមក គាត់បានឈប់នៅទូអេធីអឹមមួយដែលនៅជិតរោងចក្រ ហើយគាត់នឹកឃើញថា គាត់មានកាតនៅក្នុងកាបូបរបស់គាត់ ហើយគាត់ចង់សាកល្បងប្រើវា។ គាត់អនុវត្តតាមអ្វីដែលបង្ហាញនៅលើអេក្រង់ ហើយគាត់អាចពិនិត្យមើលសមតុល្យសាច់ប្រាក់របស់គាត់។ ក្រោយមក គាត់ក៏សម្រេចចិត្តដកប្រាក់ ២០ដុល្លារអាមេរិក ដោយសារគាត់ត្រូវយកប្រាក់នេះទៅសងមិត្តរួមការងារចំនួន ១០ដុល្លារ ដែលគាត់បានខ្ចី ហើយគាត់ក៏ចង់ទុកសាច់ប្រាក់បន្តិចបន្តួចសម្រាប់ការចំណាយរបស់គាត់ផងដែរ។ នៅតាមផ្លូវត្រឡប់ទៅបន្ទប់របស់គាត់វិញ គាត់ឈប់នៅផ្សារទំនើបតូចមួយ។ គាត់ទិញអង្ករខ្លះ និងទឹកមួយដប។ គាត់សម្រេចចិត្តទូទាត់ប្រាក់ដោយប្រើកាតរបស់គាត់ដោយសារគាត់ឃើញសញ្ញាដែលប្រាប់ថា ពួកគេទទួលយកការទូទាត់តាមកាត។ វាជំណើរការយ៉ាងរលូន ហើយគាត់សប្បាយចិត្តខ្លាំងណាស់។ គាត់មិនអាចរង់ចាំបានទេដោយបានប្រាប់ចិន្តាតាមទូរស័ព្ទថា គាត់មានកាតធនាគារហើយ។





ករណីសិក្សាទី៣

បុប្ផាជាមិត្តភក្តិរបស់ណារី ប្រើប្រាស់កាតរបស់គាត់

បុប្ផា ជាអ្នកជិតខាងរបស់ ណារី ទើបទទួលបានការហៅទូរស័ព្ទពីធនាគារ។ ដោយសារតែជាអតិថិជនដ៏ល្អម្នាក់ធនាគារទើបតែផ្តល់ជូននាងនូវកាតថ្មីមួយដែលអាចឲ្យគាត់ធ្វើការទូទាត់បាន ទោះបីជាគាត់មិនមានប្រាក់នៅក្នុងគណនីរបស់ខ្លួនក៏ដោយ។ គាត់មិនធ្លាប់ឮពីកាតប្រភេទនេះទេពីមុនមក។ គាត់សប្បាយចិត្តខ្លាំងណាស់ព្រោះគាត់ដឹងថា វាមានប្រយោជន៍ខ្លាំងណាស់ក្នុងការទូទាត់ប្រាក់ដោយប្រើប្រាស់កាតរបស់ខ្លួនបាន ជាពិសេសដោយសារថា អាជីវកម្មរបស់គាត់កំពុងរីកចម្រើន ហើយពេលខ្លះត្រូវការទំនិញជាបន្ទាន់។ ជាធម្មតាគាត់ទិញទំនិញទាំងនេះតាមអនឡាញ សូម្បីទំនិញខ្លះទិញពីក្រៅប្រទេសក៏មាន។ ច្រើនថ្ងៃកន្លងផុតទៅ ហើយបុប្ផាប្រើប្រាស់កាតរបស់ខ្លួនដោយមិនយកចិត្តទុកដាក់ខ្លាំងចំពោះរាល់ការចំណាយដែលគាត់កំពុងធ្វើនោះឡើយ។ គាត់តែងតែគិតថា គាត់នឹងពិនិត្យមើលការចំណាយរបស់ខ្លួននៅចុងសប្តាហ៍ ប៉ុន្តែគាត់មិនដែលលៃពេលវេលាដើម្បីពិនិត្យមើលវានោះឡើយ។ នៅចុងខែនេះ គាត់ដឹងថា គាត់មិនមានប្រាក់គ្រប់គ្រាន់ដើម្បីរ៉ាប់រងរាល់ការចំណាយដែលគាត់បានធ្វើទាក់ទងនឹងកាតធនាគាររបស់គាត់ឡើយ។ គាត់ត្រូវបង់ការប្រាក់ខ្ពស់បំផុត។ បុប្ផាបន្ទោសខ្លួនឯងចំពោះការធ្វេសប្រហែសនេះ។

និយមន័យ

កាតបង់ប្រាក់ជាមុន ឬកាតមានសាច់ប្រាក់

កាតបង់ប្រាក់ជាមុនអនុញ្ញាតឲ្យលោកអ្នកដកប្រាក់ពីគណនីរបស់ខ្លួនដោយស៊កបញ្ចូលវាទៅក្នុងឧបករណ៍ដែលគេហៅថា ម៉ាស៊ីនដកដាក់ប្រាក់ដោយស្វ័យប្រវត្តិ (ជារឿយៗហៅកាត់ថា អេធីអឹម (ATM)) ។ បន្ថែមពីលើលទ្ធភាពនៃការដកប្រាក់ លោកអ្នកអាចពិនិត្យមើលសមតុល្យនៃគណនីរបស់លោកអ្នកបាន។ លោកអ្នកអាចទិញអាហារ ប្រេងឥន្ធនៈ សម្លៀកបំពាក់ និងបង់ថ្លៃឈ្នួលរបស់លោកអ្នកជាមួយនឹងកាតនេះបានដល់មនុស្សដែលលោកអ្នកកំពុងបង់ប្រាក់ដែលទទួលយកកាតនេះ។ ប្រាក់ដែលលោកអ្នកប្រើប្រាស់ត្រូវបានកាត់ភ្លាមៗពីសមតុល្យរបស់លោកអ្នក។ កាតមួយចំនួនអនុញ្ញាតឲ្យលោកអ្នកបង់វិក្កយបត្រ និងបញ្ចូលលុយទៅក្នុងទូរស័ព្ទដៃរបស់លោកអ្នកបាន។ ធនាគារនីមួយៗមានបណ្តាញអេធីអឹមផ្ទាល់ខ្លួន ប៉ុន្តែជារឿយៗ លោកអ្នកអាចប្រើកាតធនាគាររបស់លោកអ្នកដើម្បីដកប្រាក់ពីម៉ាស៊ីនអេធីអឹមណាមួយក៏បាន មិនថា អេធីអឹមនោះជារបស់ធនាគាររបស់លោកអ្នក ឬក៏មិនមែននោះឡើយ។

ប៉ុន្តែ ធនាគាររបស់លោកអ្នកអាចគិតថ្លៃសេវារាល់ពេលដែលលោកអ្នកប្រើម៉ាស៊ីន អេធីអឹម ដែលជាផ្នែកមួយនៃបណ្តាញរបស់ធនាគារផ្សេងទៀត។ លោកអ្នកអាចប្រើប្រាស់ប្រាក់ដែលលោកអ្នកបានដាក់បញ្ចូលក្នុងសមតុល្យរបស់លោកអ្នក។ លោកអ្នកអាចបញ្ចូលទឹកប្រាក់បានច្រើនដងតាមដែលលោកអ្នកចង់បញ្ចូលតាមរយៈម៉ាស៊ីនអេធីអឹម ការផ្ទេរប្រាក់តាមធនាគារ ឬសូម្បីតែតាមរយៈការប្រើប្រាស់ភ្នាក់ងារបណ្តាញ អាស្រ័យលើប្រទេសនោះ។ ប្រសិនបើលោកអ្នកទទួលបានកាតនេះតាមរយៈស្ថាប័នណាមួយ ពួកគេអាចនឹងបញ្ចូលវាតាមកាលកំណត់ (ឧទាហរណ៍ ជារៀងរាល់ខែជាដើម) ដូច្នេះ លោកអ្នកអាចពិនិត្យមើលសាច់ប្រាក់ដែលដាក់បញ្ចូលក្នុងគណនីរបស់លោកអ្នកជាប្រចាំបាន។

ប័ណ្ណឥណពន្ធ

ប័ណ្ណទូទាត់នេះអនុញ្ញាតឲ្យធ្វើប្រតិបត្តិការធនាគារអេឡិចត្រូនិកបាន។ បន្ថែមពីលើការប្រើប្រាស់ប័ណ្ណនេះដើម្បីដកប្រាក់ពីម៉ាស៊ីនអេធីអឹម លោកអ្នកអាចប្រើប្រាស់ប័ណ្ណឥណពន្ធដើម្បីទូទាត់ទំនិញដែលលោកអ្នកទិញនៅតាមហាងជាច្រើន។ លោកអ្នកត្រូវតែមានសាច់ប្រាក់នៅក្នុងគណនីរបស់លោកអ្នកនៅពេលទិញទំនិញ។ ចំនួនទឹកប្រាក់នៃការទិញរបស់លោកអ្នកត្រូវបានកាត់ចេញពីគណនីរបស់លោកអ្នកភ្លាមៗ។ លោកអ្នកអាចពិនិត្យសមតុល្យរបស់លោកអ្នកជាប្រចាំតាមរយៈធនាគារផ្ទាល់ ឬតាមទូរស័ព្ទដៃ។ ក្នុងករណីខ្លះ លោកអ្នកអាចទទួលបានរបាយការណ៍ពីធនាគារ ដែលបង្ហាញពីចំនួនទឹកប្រាក់សរុបដែលត្រូវបានកាត់ចេញពីគណនីរបស់លោកអ្នក ក៏ដូចជាសមតុល្យរបស់លោកអ្នក។ វាគឺជាមធ្យោបាយងាយស្រួលបំផុតក្នុងការប្រើប្រាស់សាច់ប្រាក់នៅក្នុងគណនីធនាគាររបស់លោកអ្នកដោយមិនចាំបាច់ដកសាច់ប្រាក់ចេញ។

ប័ណ្ណឥណទាន

ជាទូទៅ ប័ណ្ណឥណទានអនុញ្ញាតឲ្យលោកអ្នកធ្វើប្រតិបត្តិការដូចគ្នានឹងប័ណ្ណឥណពន្ធដែរ។ ភាពខុសគ្នាសំខាន់នោះគឺថា វាក៏អនុញ្ញាតឲ្យមានសិទ្ធិចូលប្រើប្រាស់ឥណទានភ្លាមៗផងដែរ។ នោះគឺថា ប្រសិនបើលោកអ្នកមិនមានសាច់ប្រាក់នៅក្នុងគណនីរបស់លោកអ្នកទេនោះ លោកអ្នកនៅតែអាចធ្វើការទិញទំនិញនៅតាមហាងបានដោយទទួលយកប្រាក់កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុដែលបានលក់ប័ណ្ណឥណទានដល់លោកអ្នក (គ្រឹះស្ថានហិរញ្ញវត្ថុ ហាងលក់ទំនិញធំៗលៗ)។
នៅក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទិញប័ណ្ណឥណទាន ចំនួនទឹកប្រាក់នៃការទិញ/ប្រាក់កម្ចីរបស់លោកអ្នកនឹងត្រូវបានកាត់ចេញពីគណនីរបស់លោកអ្នក (ក្នុងមួយដង ឬច្រើនដងក្នុងអត្រាការប្រាក់ដែលជារឿយៗខ្ពស់ជាងផលិតផលឥណទានធម្មតា)។ លោកអ្នកនឹងទទួលបានរបាយការណ៍ជាប្រចាំពីគ្រឹះស្ថានហិរញ្ញវត្ថុដែលបានលក់ប័ណ្ណឥណទានដល់លោកអ្នក ដោយបង្ហាញពីចំនួនទឹកប្រាក់សរុបដែលត្រូវបានកាត់ចេញពីឥណទានរបស់លោកអ្នក ចំនួនទឹកប្រាក់ដែលត្រូវសង និងអត្រាការប្រាក់។ ឥឡូវនេះ អ្នកក៏អាចពិនិត្យមើលព័ត៌មានទាំងអស់នេះតាមអនឡាញបានផងដែរ។

ការបូមឌីជីថល





ករណីសិក្សាទី ៤

ណារី ទូទាត់ប្រាក់ដោយប្រើ QR CODE

ណារី ត្រូវការទិញស្បែកជើងថ្មីមួយគូ ព្រោះស្បែកជើងដែលនាងកំពុងពាក់នេះគឺចាស់ណាស់ទៅហើយ។ នាងកំពុងដើរនៅតាមវិថីពាណិជ្ជកម្ម ក្នុងទីប្រជុំជន ហើយគាត់បានឃើញហាងមួយដែលមានលក់ស្បែកជើងក្នុងតម្លៃធូរថ្លៃ។ គាត់បានដើរចូលទៅក្នុងក្នុងហាងនោះ បានលស្បែកជើងកវែងសម្រាប់ធ្វើការ ហើយសម្រេចចិត្តទិញស្បែកជើងនេះ។ នៅឯបញ្ជរគិតលុយនោះ បុរសម្នាក់នៅហាងនោះប្រាប់គាត់ថា គាត់អាចទូទាត់ជាសាច់ប្រាក់ក៏បាន ហើយថែមទាំងអាចប្រើកាបូបឌីជីថលដែលគ្រប់គ្នាកំពុងនិយាយពីវាបានផងដែរ។ ណារី សួរថា "តើខ្ញុំមានអត្ថប្រយោជន៍អ្វីខ្លះក្នុងការប្រើប្រាស់កាបូបឌីជីថលនេះ?" ម្ចាស់ហាងពន្យល់ថា តម្លៃគឺដូចគ្នា ប៉ុន្តែតាមរយៈការបង់ប្រាក់ជាមួយកាបូបឌីជីថល មិនចាំបាច់ប្រើសាច់ប្រាក់ទេ ហើយវាមានសុវត្ថិភាពជាងសម្រាប់មនុស្សគ្រប់គ្នា។ ណារី ដែលបានទាញយកកាបូបឌីជីថលនេះ ហើយបានដាក់ប្រាក់ចំនួន៣០ដុល្លារអាមេរិកនោះ សម្រេចចិត្តសាកល្បងវាជាលើកដំបូង។ គាត់បានស្កែនកូដ QR Code តាមការណែនាំរបស់ម្ចាស់ហាង ហើយសារដែលមានខ្លឹមសារថា "ការបង់ប្រាក់ដែលបានទទួលយក" លេចឡើងនៅលើទូរសព្ទរបស់គាត់។ គាត់រើសយកកាបូបនេះ ហើយចាកចេញពីហាងដោយក្តីរីករាយដែលបានសាកល្បងវិធីទូទាត់ប្រាក់ថ្មីនេះ។



ករណីសិក្សាទី ៥

សុភាព សងប្រាក់ទៅមិត្តភក្តិដោយប្រើប្រាស់កាបូបឌីជីថលរបស់នាង

កាលពីសប្តាហ៍មុន សុភាព បានខ្ចីប្រាក់ ១០ ដុល្លារអាមេរិកពីមិត្តរួមការងាររបស់នាងឈ្មោះ បុប្ផា ដោយសារគាត់ត្រូវការទិញឆ្នាំងសាកថ្មីសម្រាប់ទូរស័ព្ទរបស់គាត់ ហើយគ្មានសាច់ប្រាក់ក្នុងដៃ។ ថ្ងៃនេះគាត់ចង់សងប្រាក់វិញដោយប្រើប្រាស់កាបូបឌីជីថលរបស់ខ្លួន។ អ្នកទាំងពីរមានប្រព័ន្ធផ្តល់សេវាដូចគ្នា ហើយបន្ទាប់ពីទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លីនៅក្នុងរោងចក្រ ពួកគេពិតជារីករាយក្នុងការប្រើប្រាស់វិធីសាស្ត្របង់ប្រាក់ថ្មីនេះ។ សុភាពចូលទៅក្នុងម៉ឺនុយកាបូបឌីជីថលរបស់ខ្លួន ហើយចុចលើស្លាកទូទាត់ប្រាក់។ បន្ទាប់មក គាត់ជ្រើសរើសជម្រើសស្កេនកូដ។ ក្នុងពេលជាមួយគ្នានោះ បុប្ផា បើកកាបូបរបស់នាង ហើយចូលទៅកាន់ជម្រើសនៃការបង្ហាញ QR Code របស់អ្នក។ ក្នុងជំហានដ៏សាមញ្ញមួយ សុភាព ស្កេនលេខកូដរបស់ បុប្ផា វាយបញ្ចូលទឹកប្រាក់សរុបចំនួន១០ដុល្លារអាមេរិក ហើយចុច OK ។ ភ្លាមនោះ សាច់ប្រាក់ត្រូវផ្ទេរចូលទៅក្នុងគណនីរបស់ បុប្ផា។ ពួកគេទាំងពីរសប្បាយរីករាយខ្លាំងណាស់ក្នុងការប្រើប្រាស់កាបូបឌីជីថលនេះ។

និយមន័យ

តាមរយៈកាបូបឌីជីថល យើងសំដៅទៅលើកម្មវិធី ឬសេវាកម្មអនឡាញដែលប្រើប្រាស់ដើម្បីធ្វើការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ដែលដំណើរការពី ឬតាមរយៈឧបករណ៍ចល័តៗ វាក៏ត្រូវបានគេហៅផងដែរថា កាបូបអេឡិចត្រូនិកៗ នេះអាចត្រូវបានធ្វើតាមរយៈកាបូបឌីជីថលដែលភ្ជាប់ទៅនឹងគណនីធនាគារ ឬតាមរយៈកាបូបឌីជីថលដែលមិនតម្រូវឲ្យអតិថិជនមានគណនីធនាគារនោះឡើយ។

	គុណសម្បត្តិ	គុណវិបត្តិ
កាបូបអេឡិចត្រូនិក	• លោកអ្នកអាចដកប្រាក់នៅក្នុងហាង៖ មិនចាំបាច់តម្រង់ជួរនៅកន្លែងដកប្រាក់ ឬធនាគារនោះឡើយ • លោកអ្នកមិនចាំបាច់យកលុយទៅជាមួយពេលបង់វិក្កយបត្រ ឬបង់ប្រាក់ដល់នរណាម្នាក់នោះឡើយ • កាបូបអេឡិចត្រូនិករបស់លោកអ្នកត្រូវបានការពារដោយលេខកូដសម្ងាត់។ សាច់ប្រាក់របស់លោកអ្នកមានសុវត្ថិភាព • លោកអ្នកមិនចាំបាច់បំពេញទម្រង់បែបបទណាមួយដើម្បីដក ឬដាក់ប្រាក់ ដូចដែលលោកអ្នកធ្វើនៅពេលលោកអ្នកទៅធនាគារនោះឡើយ • វាអាចមានភាពងាយស្រួលក្នុងការដកប្រាក់នៅតាមហាងជាងពីម៉ាស៊ីនអេធីអឹម ឬនៅបញ្ជរបស់ធនាគារ • លោកអ្នកលក់រាយកម្រខ្វះប្រាក់ណាស់ • លោកអ្នកមិនចាំបាច់មានគណនីធនាគារឡើយ • ប្រតិបត្តិការត្រូវបានធ្វើឡើងភ្លាមៗ	• លោកអ្នកអាចភ្លេចលេខសម្ងាត់របស់លោកអ្នក • ទូរស័ព្ទដៃរបស់លោកអ្នកអាចត្រូវបានគេលួច • ពិបាកក្នុងការយកថវិកាតាមខ្លួន • លោកអ្នកប្រហែលជាត្រូវការការប្រើប្រាស់អ៊ីនធឺណិត • បញ្ហាបណ្តាញអាចពន្យារពេលប្រតិបត្តិការ • ភ្នាក់ងារអាចព្យាយាមបន្លំអតិថិជនដែលគ្មានបទពិសោធន៍ទាក់ទងនឹងសមតុល្យរបស់ពួកគេ ឬការគិតថ្លៃ • លក្ខខណ្ឌតម្រូវសម្រាប់ការទទួលបានស៊ីមកាតគឺ តឹងរ៉ឹង

គន្លឹះសុវត្ថិភាពសម្រាប់កាបូបឌីជីថល

- កុំចែករំលែកកូដសម្ងាត់របស់លោកអ្នកជាមួយនរណាម្នាក់
- កុំកត់ត្រាលេខកូដសម្ងាត់របស់លោកអ្នកនៅជាប់ ឬរួមគ្នាជាមួយស៊ីមកាតរបស់លោកអ្នក
- កុំរក្សាទុកលេខកូដសម្ងាត់របស់លោកអ្នកក្នុងបញ្ជីទំនាក់ទំនងនៅក្នុងទូរស័ព្ទរបស់លោកអ្នក
- ទាមទារឲ្យពិនិត្យមើលការគិតថ្លៃសម្រាប់ប្រតិបត្តិការផ្សេងៗ ជាពិសេសនៅពេលប្រើប្រាស់ភ្នាក់ងារ
- នៅពេលលោកអ្នកផ្ញើប្រាក់ទៅនរណាម្នាក់ សូមពិនិត្យមើលឈ្មោះ និងពិនិត្យឈ្មោះនិងចំនួនទឹកប្រាក់ពីរដងមុននឹងវាយបញ្ចូលលេខកូដសម្ងាត់

ករណីសិក្សាទី ៦

ណារី ភ្លេចលេខកូដសម្ងាត់

ណារីត្រូវការ ដកប្រាក់ដើម្បីយកមកចំណាយខ្លះៗ។ គាត់យឺតយ៉ាងរួចទៅហើយសម្រាប់ការណាត់ជួប ជាមួយមិត្តភក្តិ។ គាត់ ឈប់នៅទូម៉ាស៊ីនអេធីអឹម ហើយចាប់ផ្តើមដំណើរការដកប្រាក់។ គាត់វាយលេខកូដសម្ងាត់ដូចដែលបានស្នើសុំ ប៉ុន្តែអេក្រង់ទូអេធីអឹមបង្ហាញថា លេខកូដសម្ងាត់ខុស។ ជាការភ្ញាក់ផ្អើល ណារី វាយលេខកូដសម្ងាត់ម្តងទៀត ប៉ុន្តែ ម៉ាស៊ីនបដិសេធជាថ្មីម្តងទៀត។ គាត់គិតពីរបីវិនាទី ប៉ុន្តែគាត់ពិតជា ច្រឡំ។ គាត់ ព្យាយាមជាលើកទីបីដោយប្តូរលេខកូដសម្ងាត់របស់គាត់។ ម៉ាស៊ីនអេធីអឹមបដិសេធប្រតិបត្តិការនេះ ហើយរក្សាទុកកាតរបស់គាត់។

ណារី អាក់អន់ចិត្តជាខ្លាំង គាត់មិនអាចដកប្រាក់បានទេ ហើយមួយវិញទៀតកាតរបស់នាងត្រូវម៉ាស៊ីនរក្សាទុកទៀត!

គន្លឹះសុវត្ថិភាពសម្រាប់វិធីសាស្ត្រទូទាត់ប្រាក់

- ប្រើមធ្យោបាយទូទាត់ប្រាក់របស់លោកអ្នកដោយប្រុងប្រយ័ត្ន ដោយគិតជានិច្ចអំពីការប្រើប្រាស់ថវិការបស់លោកអ្នក
- រក្សាកាត សៀវភៅមូលប្បទានបត្រ កាបូប និងទូរស័ព្ទដៃរបស់លោកអ្នកនៅកន្លែងដែលមានសុវត្ថិភាព
- កុំឲ្យនរណាម្នាក់ខ្ចីប័ណ្ណឥណទាន ឬសៀវភៅមូលប្បទានបត្ររបស់លោកអ្នកឲ្យសោះ
- កុំចុះហត្ថលេខាលើមូលប្បទានបត្រទទេ (ដោយមិនបានដាក់ចំនួនទឹកប្រាក់)
- កុំសរសេរលេខកូដសម្ងាត់របស់លោកអ្នកនៅលើកាតធនាគាររបស់លោកអ្នក ឬទុកវានៅក្បែរនោះឲ្យសោះ
- កុំផ្ញើព័ត៌មានសម្ងាត់របស់លោកអ្នកតាមអ៊ីមែល សារជាអក្សរ ទូរសារ ។ល។
- ត្រូវយកចិត្តទុកដាក់នៅពេលធ្វើប្រតិបត្តិការនៅលើប្រព័ន្ធអ៊ីនធឺណិត។ ពិនិត្យសុវត្ថិភាពនៃគេហទំព័រដែលលោកអ្នកកំពុងប្រើ (អាសយដ្ឋានគេហទំព័រគួរតែចាប់ផ្តើមដោយពាក្យ "https" គួរតែមាននិមិត្តសញ្ញាសោនៅខាងក្រោមផ្នែកខាងស្តាំនៃអេក្រង់។ល។)
- ពិនិត្យរបាយការណ៍ធនាគាររបស់លោកអ្នកដោយប្រុងប្រយ័ត្ន និងជាប្រចាំ
- រាយការណ៍ភ្លាមៗទៅធនាគារអំពីចំនួនទឹកប្រាក់ដែលបានកាត់ចេញពីគណនីរបស់លោកអ្នក ដែលលោកអ្នកមិនអាចពន្យល់បាន



សំខាន់ៈ ការគ្រប់គ្រងទឹកប្រាក់របស់លោកអ្នក ជាពិសេសនៅពេលដែលលោកអ្នកប្រើមធ្យោបាយទូទាត់ផ្សេងៗ អាចជាការស្មុគស្មាញ។ វាក៏អាចជាសកម្មភាពដែលហត់នឿយខ្លាំងផងដែរ។ សូមអនុវត្តតាមគន្លឹះសុវត្ថិភាពខាងលើដើម្បីឲ្យផ្លូវចិត្តរបស់លោកអ្នកស្ងប់។

សារសំខាន់

- មានមធ្យោបាយទូទាត់ផ្សេងៗ៖ សាច់ប្រាក់ បំណុលទូទាត់ ឬប្រតិបត្តិការទូទាត់៖ ការផ្ទេរប្រាក់តាមធនាគារ ការដកប្រាក់ដោយផ្ទាល់/ការបញ្ជាទិញអចិន្ត្រៃយ៍ ការទូទាត់តាមទូរសព្ទដៃ ឬតាមរយៈអ៊ីនធឺណិត ។ល។
- មធ្យោបាយទូទាត់នីមួយៗគឺខុសគ្នា។ ដូចទៅនឹងផលិតផលហិរញ្ញវត្ថុទាំងអស់ដែរ ការទូទាត់នីមួយៗពាក់ព័ន្ធនឹងការចំណាយ និងវាមានគុណសម្បត្តិ និងគុណវិបត្តិ ដែលជារឿយៗអាស្រ័យលើប្រភេទនៃការចំណាយដែលលោកអ្នកចង់ចំណាយ។
- បំណុលសាច់ប្រាក់អាចឲ្យលោកអ្នកដកប្រាក់បាន។ បំណុលឥណពន្ធក៏អាចប្រើដើម្បីទិញទំនិញពីអ្នកលក់រាយបានផងដែរ (ដោយប្រើទឹកប្រាក់ដែលមាននៅក្នុងគណនីធនាគាររបស់លោកអ្នក)។
- ក៏ដូចជាអាចឲ្យលោកអ្នកដកប្រាក់ និងទូទាត់ប្រាក់សម្រាប់ការទិញជាដើម បំណុលឥណទានផ្តល់ឲ្យអ្នកនូវការចូលប្រើប្រាស់ឥណទានភ្លាមៗ (ប្រសិនបើទឹកប្រាក់ចាំបាច់មិនមាននៅក្នុងគណនីរបស់លោកអ្នកនៅពេលទិញនោះ)។
- ការប្រើប្រាស់មធ្យោបាយទូទាត់ប្រាក់បង្ហាញពីហានិភ័យ! សូមប្រើមធ្យោបាយទូទាត់ប្រាក់របស់លោកអ្នកដោយយកចិត្តទុកដាក់ត្រូវគិតពីការកំណត់នៃថវិការបស់លោកអ្នក។


២. ស្វែងយល់ពីប្រតិបត្តិការផ្ទេរប្រាក់

យើងនឹងស្វែងយល់ពីជម្រើសរបស់លោកអ្នកនៅពេលនិយាយអំពីការផ្ញើ និងការទទួលប្រាក់ក្នុងប្រទេស និងក្រៅប្រទេស។ យើងនឹងពិចារណាពីគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្រនីមួយៗ។

ករណីសិក្សាទី ៧

រក្សា មិនអាចរកប្រាក់បានទេ

រក្សាបានទទួលទូរស័ព្ទបន្ទាន់ពីបងប្អូនជីដូនមួយរបស់នាងដែលរស់នៅក្នុងខេត្តកំពត។ ខ្យល់ព្យុះដ៏ធំមួយបានបណ្តាលឲ្យខូចខាតដល់ដំបូលផ្ទះរបស់ពួកគេ។ ពួកគេត្រូវការប្រាក់ដើម្បីទិញសម្ភារៈមួយចំនួនមកជួសជុលដំបូលនេះ។ រក្សាមានថវិកាតិចតួចក្នុងខែនេះ ប៉ុន្តែបានសម្រេចចិត្តថា គាត់មិនអាចទុកឲ្យបងប្អូនជីដូនមួយរបស់នាងលំបាកបានទេ ហើយគួរតែជួយដល់គាត់។ មិត្តភក្តិរបស់មិត្តភក្តិម្នាក់នឹងទៅកាន់ផ្នែកមួយនៃប្រទេសនេះក្នុងសប្តាហ៍នោះ គាត់ក៏សម្រេចចិត្តប្រគល់ប្រាក់ទៅឲ្យស្ត្រីរូបនេះដែលរស់នៅក្នុងភូមិក្បែរនោះទៅឲ្យបងប្អូនជីដូនមួយរបស់គាត់។ ពីរបីថ្ងៃក្រោយមក គាត់និយាយជាមួយបងប្អូនជីដូនមួយរបស់គាត់ដែលប្រាប់គាត់ថា គាត់នៅតែមិនទាន់បានទទួលប្រាក់នៅឡើយ។ រក្សាគិតថា ស្ត្រីនោះជាមនុស្សស្មោះត្រង់ ប៉ុន្តែគាត់ចាប់ផ្តើមមានការបារម្ភ។ គាត់ក៏ធ្លាប់ឮករណីបែបនេះដែរ ដែលលុយមិនទាន់មកដល់។ គាត់សង្ឃឹមថា វារឿងនេះមិនកើតឡើងទៅចុះ ព្រោះនោះមានន័យថា ប្រាក់នោះអាចមិនដល់បងប្អូនជីដូនមួយរបស់គាត់។





ករណីសិក្សាទី ៨

សុភាព ប្រើប្រាស់គ្រឹះស្ថានផ្តល់សេវាផ្នែរប្រាក់

សុភាពដឹងថា វាជាថ្ងៃនៃខែដែលគាត់ត្រូវផ្ញើរប្រាក់ទៅឲ្យឪពុកម្តាយរបស់ខ្លួន ។ ពេលខ្លះ គាត់ផ្ញើប្រាក់ជាមួយអ្នកដែលធ្វើដំណើរទៅកាន់ភូមិនោះ ប៉ុន្តែ ចុងក្រោយនេះគាត់បានប្រើប្រតិបត្តិករផ្ញើរប្រាក់។ ជាមួយនឹងបុប្ផាដែលជាមិត្តរួមការងាររបស់នាង ពួកគេសម្រេចចិត្តចាកចេញពីព្រឹកព្រលឹមមុនពេលផ្លាស់ប្តូរវេនការងារ។ ពួកគេទៅកាន់ប្រតិបត្តិករផ្ញើរប្រាក់ ABC ព្រោះវាមានតម្លៃសេវាទាប។ ក្រោយពីផ្ញើប្រាក់ភ្លាម សុភាព បានទូរស័ព្ទទៅម្តាយនាង ហើយប្រាប់គាត់ថា នាងទើបផ្ញើប្រាក់ទៅដូចលើកមុនអញ្ចឹង។ ក្រោយមក នៅថ្ងៃនោះ ម្តាយរបស់សុភាពបានទៅកាន់ភ្នាក់ងារនោះ។ គាត់បានបង្ហាញអត្តសញ្ញាណប័ណ្ណរបស់គាត់ ហើយទទួលបានទឹកប្រាក់នោះ។ ជាដំណឹងល្អ! ម្តាយរបស់សុភាពទើបតែបានផ្ញើសារដោយបានប្រាប់ថា គាត់បានទទួលប្រាក់នេះហើយ។

និយមន័យ

ប្រតិបត្តិករផ្ញើរប្រាក់ក្រៅផ្លូវការ

គ្រឹះស្ថាន និងបុគ្គលទាំងនេះមិនត្រូវបានគ្រប់គ្រង ឬត្រួតពិនិត្យដោយរដ្ឋឡើយ។

ប្រតិបត្តិករផ្ញើរប្រាក់ផ្លូវការ

គ្រឹះស្ថានទាំងនេះត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយរដ្ឋ

ប្រតិបត្តិករផ្ញើរប្រាក់ផ្លូវការ	ប្រតិបត្តិករផ្ញើរប្រាក់ក្រៅផ្លូវការ
• ការិយាល័យប្រៃសណីយ៍ (តាមរយៈការិយាល័យក្នុងស្រុក ឬអ៊ីនធឺណិត) • សហគ្រាសដែលមានឯកទេសក្នុងការផ្ញើរប្រាក់ (តាមរយៈភ្នាក់ងារ ឬអ៊ីនធឺណិត) • ធនាគារ (តាមសាខាធនាគារ ឬអ៊ីនធឺណិត) • សេវាផ្ញើរប្រាក់តាមទូរស័ព្ទ	• ម្ចាស់ហាង និងអ្នកលក់ដូរ • អ្នកបើកបរតាក់ស៊ី និងឡានដឹកទំនិញ • មិត្តភក្តិ និងក្រុមគ្រួសារ

មិនថាគ្រឹះស្ថានផ្តល់សេវាណាដែលលោកអ្នកជ្រើសរើសដើម្បីធ្វើការផ្ទេរប្រាក់នោះឡើយ ទោះជាផ្លូវការ ឬក្រៅផ្លូវការក៏ដោយ លោកអ្នកត្រូវពិនិត្យមើលលក្ខណៈនិច្ច័យមួយចំនួនមុននឹងធ្វើការជ្រើសរើស៖

- ការចំណាយក្នុងការផ្ញើប្រាក់ (បង់ដោយអ្នកផ្ញើ)
- ការចំណាយក្នុងការទទួលប្រាក់ (បង់ដោយអ្នកទទួល)
- ភាពនៅជិតនឹងទីតាំងភូមិសាស្ត្រ (សម្រាប់អ្នកផ្ញើ និងអ្នកទទួល)
- សុវត្ថិភាព
- ល្បឿនឆាប់រហ័ស
- កម្រៃជើងសារក្នុងការប្តូរប្រាក់ (ប្រសិនបើពាក់ព័ន្ធ)

សំណួរ

- ចុះអ្នកវិញ? តើលោកអ្នកផ្ញើប្រាក់ទៅមនុស្ស ឬទៅក្រៅបរទេស?

  ☐ បាទ/ចាស ☐ ទេ

- បើ បាទ/ចាស តើមកពីមូលហេតុអ្វី?

- តើលោកអ្នកប្រើវិធីសាស្ត្រអ្វី?

ស្ថានភាពផ្ទាល់ខ្លួន

សូមក្រឡេកមើលស្ថានភាពផ្ទាល់ខ្លួនរបស់ខ្ញុំ វិធីសាស្ត្រដ៏ល្អបំផុតក្នុងការផ្ទេរប្រាក់សម្រាប់ខ្ញុំគឺ

នេះក៏ព្រោះតែ៖

សារសំខាន់

- វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងអំពីនីតិវិធីសម្រាប់ការផ្ទេរប្រាក់ (ឯកសារដែលត្រូវផ្តល់ ការចំណាយ បណ្តាញរបស់ប្រតិបត្តិករ។ល។)

- មានវិធីជាច្រើនក្នុងការផ្ទេរប្រាក់៖ សាច់ប្រាក់ទៅកាន់សាច់ប្រាក់ គណនីធនាគារទៅជាសាច់ប្រាក់ សាច់ប្រាក់ទៅក្នុងគណនីធនាគារ គណនីធនាគារទៅគណនីធនាគារ ទូរសព្ទដៃ ទៅទូរសព្ទដៃ ។ល។

- សូមជ្រើសរើសវិធីផ្ទេរប្រាក់របស់លោកអ្នក និងប្រតិបត្តិកររបស់លោកអ្នកតាមស្ថានភាពរបស់លោកអ្នក និងបុគ្គលដែលលោកអ្នកកំពុងផ្ញើប្រាក់ទៅកាន់។ សូមក្រឡេកមើលលក្ខណៈនានា ដូចជាតម្លៃនៃការផ្ញើ កម្រៃជើងសារក្នុងការប្តូរប្រាក់ ការចំណាយក្នុងការទទួលប្រាក់ ភាពនៅជិតនឹងទីតាំងភូមិសាស្ត្រជាដើម ។ល។) អាចឲ្យលោកអ្នកធ្វើការសម្រេចចិត្តដែលសមស្របបំផុតទៅនឹងតម្រូវការរបស់លោកអ្នក។

- សូមផ្ញើប្រាក់តាមវិធីដែលមានសុវត្ថិភាព ចូលទៅកាន់បណ្តាញផ្លូវការ និងសម្រួលការដកប្រាក់សម្រាប់សាច់ញាតិរបស់លោកអ្នក!

ជំនួយក្នុងការបណ្តុះបណ្តាល ៩.២.១

ប្រតិបត្តិការផ្ទេរប្រាក់ក្រៅផ្លូវការ





ជំនួយក្នុងការបណ្តុះបណ្តាល ១.២.២

ប្រតិបត្តិការផ្ទេរប្រាក់ផ្ទួនការ







ជំនួយក្នុងការបណ្តុះបណ្តាល ៦.២.៣

វិធីសាស្ត្រផ្ទេរប្រាក់ដែលជ្រើសរើសដោយបុគ្គល

វិធីសាស្ត្ររបស់សុភាព

សុភាពផ្ញើប្រាក់ទៅឪពុកម្តាយរបស់ខ្លួនដោយប្រើប្រាស់ប្រតិបត្តិករផ្ទេរប្រាក់

វិធីសាស្ត្របូរ៉ាន

បូរ៉ាន ផ្ញើប្រាក់ទៅប្រពន្ធរបស់គាត់ដោយប្រើប្រាស់ប្រតិបត្តិករផ្ទេរប្រាក់។ គាត់យកសាច់ប្រាក់ទៅកាន់ប្រតិបត្តិករផ្ទេរប្រាក់ ហើយដាក់បញ្ចូលសាច់ប្រាក់នោះដោយផ្ទាល់ទៅក្នុងគណនីធនាគារដែលប្រពន្ធគាត់ទើបនឹងបើកថ្មីៗនេះ។ នៅខែក្រោយ គាត់ចង់ព្យាយាមផ្ទេរប្រាក់ពីគណនីធនាគាររបស់គាត់ដោយផ្ទាល់ទៅកាន់គណនីធនាគាររបស់ប្រពន្ធគាត់។

វិធីសាស្ត្ររបស់ណារី

ណារី ផ្ញើប្រាក់ឲ្យប្អូនប្រុសរបស់ខ្លួន ដោយប្រើប្រាស់គណនីធនាគាររបស់ខ្លួនផ្ទាល់។

វិធីសាស្ត្ររបស់រក្សា

រក្សាសាកល្បងជាលើកដំបូងនូវកាបូបឌីជីថលដែលផ្តល់ការផ្ទេរប្រាក់តាមប្រព័ន្ធឌីជីថល។ ដាក់បញ្ចូលសាច់ប្រាក់ទៅក្នុងកាបូបឌីជីថលរបស់បងប្អូនជីដូនមួយរបស់នាងដោយផ្ទាល់នៅក្នុងខេត្តកំពត។

៣. របៀបផ្ញើ និងទទួលប្រាក់

ជំនួយក្នុងការបណ្តុះបណ្តាល ជ.៣.១

ជំណាក់កាលនៃការផ្ញើ និងការទទួលការផ្ទេរប្រាក់

វិធីសាស្ត្រទី ១៖ តាមរយៈប្រតិបត្តិការផ្ទេរប្រាក់

- សូមទំនាក់ទំនង ឬទៅកាន់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ (ដោយផ្ទាល់ ឬតាមអនឡាញ)
- បំពេញទម្រង់បែបបទផ្ទេរប្រាក់សាមញ្ញ និងរហ័ស
- ទៅកាន់បុគ្គលិក ហើយផ្តល់ព័ត៌មានខាងក្រោមដល់គាត់៖

  ១. ឈ្មោះ និងលេខគណនីរបស់អ្នកទទួលប្រាក់ (ប្រសិនបើអ្នកទទួលប្រាក់ ពោលគឺអ្នកដែលលោកអ្នកកំពុងផ្ញើប្រាក់ទៅកាន់នោះ មានគណនីធនាគារ)

  ២. ឈ្មោះ និងលេខអត្តសញ្ញាណប័ណ្ណ ឬលេខឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់អ្នកទទួលប្រាក់(ប្រសិនបើអ្នកទទួលប្រាក់មិនមានគណនីធនាគារ)

- ជូនដំណឹងដល់អ្នកទទួលប្រាក់អំពីចំនួនទឹកប្រាក់ដែលលោកអ្នកបានផ្ញើរ ហើយអាស្រ័យលើរយៈពេលដែលបានបញ្ជាក់ដោយធនាគារ/ភ្នាក់ងារ (ដែលអាចមានចាប់ពីពីរបីនាទីទៅច្រើនថ្ងៃ) អ្នកទទួលប្រាក់នឹងអាចមកទទួលប្រាក់ពីធនាគារ ឬភ្នាក់ងារ ជាសាច់ប្រាក់ ឬដាក់បញ្ចូលទៅក្នុងគណនីរបស់ពួកគេ (ដូចដែលលោកអ្នកបានបញ្ជាក់)

- ទៅកាន់ធនាគារ ឬទីភ្នាក់ងារ ហើយប្រាប់ព័ត៌មានចាំបាច់ដល់បុគ្គលិកទាក់ទងនឹងចំនួនប្រាក់ដែលត្រូវបានផ្ញើទៅលោកអ្នក និងឈ្មោះរបស់អ្នកផ្ញើ
- បង្ហា អត្តសញ្ញាណប័ណ្ណរបស់លោកអ្នក ឬឯកសារផ្សេងទៀតដែលបញ្ជាក់ពីអត្តសញ្ញាណរបស់លោកអ្នកដល់បុគ្គលិកធនាគារ
- បន្ទាប់ពីពិនិត្យលើប្រព័ន្ធកុំព្យូទ័ររួច បុគ្គលិក ឬភ្នាក់ងារនោះនឹងផ្តល់ប្រាក់ដល់លោកអ្នក

វិធីសាស្ត្រទី ២ ៖ តាមរយៈធនាគាររបស់ខ្ញុំដោយប្រើធនាគារផ្ទាល់

- ចូលទៅកាន់គេហទំព័ររបស់គ្រឹះស្ថានធនាគាររបស់លោកអ្នក។ បំពេញឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់លោកអ្នក។
- នៅពេលដែលចូលទៅក្នុងប្រព័ន្ធហើយនោះ សូមជ្រើសរើសគណនីដែលលោកអ្នកចង់ផ្ញើប្រាក់ទៅកាន់
- ចុចលើការផ្ទេរប្រាក់/ផ្ញើប្រាក់។ ពេលខ្លះមុខងារនេះអាចត្រូវបានរកឃើញនៅលើផ្ទាំងមួយដែលហៅថាការទូទាត់ប្រាក់
- នៅពេលដែលស្ថិតនៅក្នុងផ្នែកផ្ទេរប្រាក់ហើយ លោកអ្នកត្រូវបំពេញព័ត៌មានដូចខាងក្រោម៖
  - កាលបរិច្ឆេទនៃការសម្រេច
  - ទិសដៅ៖ នៅទីនេះលោកអ្នកត្រូវបំពេញឈ្មោះហៅក្រៅ និង/ឬ លេខគណនីធនាគាររបស់អ្នកទទួលប្រាក់
  - រូបិយប័ណ្ណ៖ ជាធម្មតា រូបិយប័ណ្ណក្នុងស្រុក ប៉ុន្តែក៏អាចជារូបិយប័ណ្ណអន្តរជាតិផ្សេងទៀតផងដែរ
  - ចំនួនទឹកប្រាក់៖ បំពេញតម្លៃនៃការផ្ទេរប្រាក់
  - ទស្សនទាន៖ ជ្រើសរើសទស្សនទាននៃការទូទាត់ប្រាក់ (ទ្រព្យសកម្ម ផ្សេងៗ ថ្លៃឈ្នួល ឬផ្សេងទៀតដែលបង្ហាញក្នុងផ្ទាំងក្រោមចំណងជើង)
  - ការពិពណ៌នា៖ នេះគឺជាការផ្ញើសារទៅកាន់អ្នកទទួលប្រាក់
  - អ៊ីមែលរបស់អ្នកទទួល៖ ដើម្បីឲ្យការជូនដំណឹងទៅដល់អ្នកទទួលប្រាក់

- ចុចបន្ត ឬធ្វើការផ្ទេរប្រាក់ ហើយទឹកប្រាក់នេះនឹងត្រូវបានផ្ញើតាមថ្ងៃដែលបានជ្រើសរើស។ ធនាគារមួយចំនួនអាចត្រូវការជំហានសុវត្ថិភាពបន្ថែមនៅទីនេះ (អាចជាសារ SMS ដែលផ្ញើទៅកាន់ទូរស័ព្ទរបស់លោកអ្នកដែលលោកអ្នកត្រូវវាយបញ្ចូលសម្រាប់ការបញ្ជាក់អំពីប្រតិបត្តិការ ក៏អាចជាលេខកូដសម្ងាត់បន្ថែមដែលបង្កើតឡើងសម្រាប់ប្រតិបត្តិការទាំងនេះផងដែរ)។ ជាទូទៅ លោកអ្នកទទួលបានការបញ្ជាក់នៅលើគេហទំព័រដូចគ្នា ឬតាមរយៈអ៊ីមែលបញ្ជាក់ថា ការផ្ទេរត្រូវបានធ្វើឡើងដោយជោគជ័យ។

- ចូលទៅក្នុងគេហទំព័ររបស់គ្រឹះស្ថានធនាគាររបស់លោកអ្នក។ បំពេញឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់លោកអ្នក
- នៅពេលដែលចូលទៅក្នុងប្រព័ន្ធហើយ សូមជ្រើសរើសគណនីដែលលោកអ្នកត្រូវបានផ្ញើប្រាក់។ នៅពេលលោកអ្នកចូលនិងមើលព័ត៌មានលម្អិតអំពីគណនីហើយ លោកអ្នកគួរតែមានចំណូលថ្មីសម្រាប់ចំនួនទឹកប្រាក់ដែលបានផ្ញើ និងព័ត៌មានលម្អិតដែលបង្ហាញថា អ្នកណា និងពេលណាបានផ្ញើប្រាក់មកឲ្យលោកអ្នក។

វិធីសាស្ត្រទី ៣ ៖ តាមរយៈកាបូបឌីជីថលរបស់ខ្ញុំ

- ចូលប្រើកម្មវិធីនេះពីទូរសព្ទរបស់លោកអ្នក។ វាត្រូវតែជាកម្មវិធីដូចគ្នាដែលអ្នកទទួលប្រាក់ប្រើប្រាស់
- ចុចលើម៉ឺនុយហើយជ្រើសរើសយកជម្រើស "ផ្ញើប្រាក់"
- នៅក្នុងប្រអប់ "To" លោកអ្នកអាចជ្រើសរើសទំនាក់ទំនងពីសៀវភៅទូរសព្ទ លេខទូរសព្ទ ឬអាសយដ្ឋានអ៊ីមែលរបស់លោកអ្នក
- វាយបញ្ចូលតម្លៃដែលត្រូវផ្ញើ ជ្រើសរើសហេតុផលសម្រាប់ការផ្ញើប្រាក់ (ឧទាហរណ៍ ការសងប្រាក់ដែលបានខ្ចី ឬប្រាក់សម្រាប់អាហារពេលល្ងាចកាលពីម្សិលមិញ) ហើយចុចបិទុង បន្ត។
- ជ្រើសរើសវិធីទូទាត់ប្រាក់។ វាអាចជាសមតុល្យនៃកាបូបឌីជីថលរបស់លោកអ្នក ឬក៏វិធីសាស្ត្រទូទាត់ណាមួយដែលអ្នកបានភ្ជាប់ជាមួយកាបូបឌីជីថលរបស់លោកអ្នករួចហើយនោះ (បណ្ណឥណពន្ធ បណ្ណឥណទាន ឬគណនីធនាគារជាដើម)។ ក្នុងករណីដែលលោកអ្នកចង់ផ្ញើវាតាមរយៈកាតថ្មី កម្មវិធីនឹងសួរលោកអ្នកសម្រាប់ព័ត៌មានលម្អិតអំពីកាត។ ដោយចុចបិទុងបន្ត កម្មវិធីនេះនឹងបញ្ជាក់ពីការផ្ញើប្រាក់។

- លោកអ្នកអាចទទួលបានការជូនដំណឹងដោយកម្មវិធីរបស់លោកអ្នកដោយផ្ទាល់នៅលើទូរសព្ទរបស់លោកអ្នកដែលលោកអ្នកបានទទួលប្រាក់
- នៅពេលលោកអ្នកបើកកម្មវិធីនេះ លោកអ្នកនឹងកត់សម្គាល់ឃើញការទូទាត់ប្រាក់ភ្លាមៗនៅក្នុងសមតុល្យ និងសកម្មភាពចុងក្រោយរបស់លោកអ្នក។ ប្រាក់ចំណូលគឺអាចរកបានភ្លាមៗ នោះគឺនៅពេលតែមួយដែលអ្នកផ្ញើប្រាក់ឲ្យលោកអ្នកបំពេញប្រតិបត្តិការនេះ។



ជំនួយក្នុងការបណ្តុះបណ្តាល ១.៣.២

ទម្រង់បែបបទសម្រាប់ការផ្ទេរប្រាក់ (ទម្រង់បែបបទរបស់ប្រតិបត្តិការផ្ទេរប្រាក់)

ទម្រង់បែបបទនៃការផ្ទេរប្រាក់

កាលបរិច្ឆេទ

ចំនួនទឹកប្រាក់

រូបិយប័ណ្ណ

ព័ត៌មានរបស់អ្នកផ្ញើប្រាក់

នាមត្រកូល៖
នាមខ្លួន៖
អាសយដ្ឋាន៖

លេខទូរស័ព្ទ៖
ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើត៖
លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន៖

ព័ត៌មានរបស់អ្នកទទួលប្រាក់

នាមត្រកូល៖
នាមខ្លួន៖

សំណួរសាកល្បងក្នុងករណីដែលអ្នកទទួលប្រាក់មិនមានអត្តសញ្ញាណប័ណ្ណមានសុពលភាព៖

សេវាកម្មជាជម្រើសអាចរកបានដោយការចំណាយបន្ថែម។ ពិនិត្យសេវាកម្មដែលចង់បាន៖

- ☐ ខ្ញុំចង់ផ្ញើមូលប្បទានបត្រទៅអាសយដ្ឋានខាងក្រោម
- ☐ ខ្ញុំចង់ឲ្យអ្នកទូរស័ព្ទទៅអ្នកទទួលប្រាក់
- ☐ សារដែលត្រូវផ្ញើ

ហត្ថលេខារបស់អតិថិជន

ជំនួយក្នុងការបណ្តុះបណ្តាល ខ.៣.៣

ទម្រង់បែបបទសម្រាប់ការផ្ទេរប្រាក់

(ទម្រង់បែបបទផ្ទេរប្រាក់របស់ធនាគារ)

ទម្រង់បែបបទផ្ទេរប្រាក់

កាលបរិច្ឆេទ

ចំនួនទឹកប្រាក់

ព័ត៌មានរបស់អ្នកផ្ញើប្រាក់

នាមត្រកូល៖

នាមខ្លួន៖

អាសយដ្ឋាន៖

លេខគណនី៖

ព័ត៌មានរបស់អ្នកទទួលប្រាក់

នាមត្រកូល៖

នាមខ្លួន៖

អាសយដ្ឋាន៖

លេខ IBAN (លេខគណនីធនាគារអន្តរជាតិ អតិបរមា ៣៤ តួអក្សរ)៖

លេខ BIC (លេខអត្តសញ្ញាណធនាគារ ចាប់ពី ៨ ទៅ ១១ តួអក្សរ) ឬលេខកូដ SWIFT៖

ហត្ថលេខារបស់អតិថិជន

សារសំខាន់

• វាមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់អំពីនីតិវិធីសម្រាប់ការផ្ទេរប្រាក់ (ឯកសារដែលត្រូវការ ការចំណាយ បណ្តាញរបស់ប្រតិបត្តិករ។ល។)

• មានវិធីផ្សេងៗជាច្រើនក្នុងការផ្ទេរប្រាក់ៈ សាច់ប្រាក់ទៅសាច់ប្រាក់ គណនីធនាគារទៅជាសាច់ប្រាក់ សាច់ប្រាក់ទៅគណនីធនាគារ គណនីធនាគារទៅគណនីធនាគារ បណ្ណទូទាត់ទៅជាសាច់ប្រាក់ កាតធនាគារទៅគណនីធនាគារ កាតធនាគារទៅកាតធនាគារ កាតធនាគារទៅទូរសព្ទដៃ ទូរសព្ទដៃទៅទូរស័ព្ទដៃជាដើម។ល។ បច្ចេកវិទ្យាកំពុងវិវត្តគ្រប់ពេលវេលា។ លោកអ្នកត្រូវស្វែងយល់ឲ្យបានច្បាស់អំពីវិធីសាស្ត្រថ្មីដូចជាលោកអ្នកអាចនឹងយល់ឃើញថា វាងាយស្រួលជាងវិធីសាស្ត្រចាស់ៗជាដើម។

• ពិចារណាពីកាល:ទេសៈផ្ទាល់ខ្លួនរបស់លោកអ្នក និងបុគ្គលដែលលោកអ្នកកំពុងផ្ញើប្រាក់ទៅឲ្យ នៅពេលលោកអ្នកជ្រើសរើសវិធីផ្ទេរប្រាក់ និងប្រតិបត្តិករ (ការចំណាយក្នុងការផ្ទេរប្រាក់ កម្រៃជើងសារប្តូរប្រាក់បរទេស ការចំណាយក្នុងការទទួលប្រាក់ ភាពនៅជិតទីតាំងភូមិសាស្ត្រជាដើម ។ល។ នឹងជួយដល់លោកអ្នកក្នុងការសម្រេចចិត្តបានល្អបំផុត។


ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ

សំណួរដែលត្រូវសួរដល់ប្រតិបត្តិការផ្ទេរប្រាក់ផ្លូវការ

- *តើខ្ញុំអាចផ្ញើប្រាក់ទៅកាន់សាច់ញាតិដោយរបៀបណា?*
- *តើទម្រង់បែបបទអ្វីខ្លះដែលខ្ញុំត្រូវបំពេញក្នុងការផ្ញើប្រាក់?*
- *តើអ្នកទទួលប្រាក់នឹងត្រូវបំពេញទម្រង់បែបបទអ្វីខ្លះ?*
- *តើឯកសារបញ្ជាក់អត្តសញ្ញាណអ្វីខ្លះដែលត្រូវការសម្រាប់ការផ្ញើប្រាក់?*
- *តើឯកសារបញ្ជាក់អត្តសញ្ញាណអ្វីខ្លះដែលត្រូវការសម្រាប់ការទទួលប្រាក់?*
- *តើខ្ញុំត្រូវតែមានគណនីធនាគារជាមួយធនាគាររបស់លោកអ្នកដើម្បីផ្ញើប្រាក់ដែរឬទេ?*
- *តើអ្នកទទួលប្រាក់ត្រូវចំណាយពេលប៉ុន្មានដើម្បីទទួលប្រាក់?*
- *ប្រសិនបើខ្ញុំផ្ទេរប្រាក់តាមរយៈកម្មវិធីនៅលើទូរសព្ទរបស់ខ្ញុំ តើអ្នកទទួលប្រាក់ត្រូវមានកម្មវិធីដូចគ្នានេះដែរឬទេ?*
- *តើការផ្ទេរប្រាក់មានការចំណាយប៉ុន្មាន?*
- *តើអ្នកទទួលនឹងទទួលបានប្រាក់ទាំងអស់ដែលខ្ញុំផ្ញើ ឬពួកគេនឹងត្រូវបង់ថ្លៃបន្ថែមនៅពេលទទួលប្រាក់?*
- *តើខ្ញុំអាចពិនិត្យមើលថា តើអ្នកទទួលប្រាក់ពិតជាបានទទួលប្រាក់មែនដោយរបៀបណា?*
- *តើអ្នកទទួលប្រាក់នឹងត្រូវបានជូនដំណឹងដោយរបៀបណាថាប្រាក់នោះបានមកដល់?*
- *តើខ្ញុំអាចលុបចោល ឬកែប្រែការផ្ទេរប្រាក់របស់ខ្ញុំបានដែរឬទេ?*
- *តើអត្រាប្តូរប្រាក់អ្វីត្រូវបានប្រើប្រាស់ក្នុងការប្តូរប្រាក់របស់ខ្ញុំទៅជារូបិយប័ណ្ណរបស់ប្រទេសទទួល (ប្រសិនបើខ្ញុំផ្ញើប្រាក់ទៅក្រៅប្រទេស)? តើការចំណាយក្នុងការប្តូរប្រាក់ប៉ុន្មានដែរ?*
- *ប្រសិនបើខ្ញុំផ្ញើប្រាក់ជាដុល្លារអាមេរិក តើអ្នកទទួលនឹងទទួលបានប្រាក់ជារូបិយប័ណ្ណអ្វីដែរ?*
- *តើខ្ញុំត្រូវមកកាន់ធនាគារដោយផ្ទាល់ ឬមានសេវាពីចម្ងាយសម្រាប់ការផ្ទេរប្រាក់ (អ៊ីនធឺណិត សំបុត្រ។ល។)?*
- *តើលោកអ្នកមានសាខា ឬភ្នាក់ងាររបស់ធនាគាររបស់លោកអ្នកនៅក្នុង _____ (កន្លែងលំនៅដ្ឋានរបស់សាច់ញាតិដែលលោកអ្នកកំពុងផ្ញើប្រាក់ទៅដែរឬទេ)?*
- *តើខ្ញុំអាចផ្ញើប្រាក់តាមទូរសព្ទរបស់ខ្ញុំបានទេ បើបុគ្គលម្ខាងទៀតមិនមានកាបូបឌីជីថល? បើដូច្នេះមែន តើគេអាចដកប្រាក់ដែលខ្ញុំផ្ញើទៅនោះនៅកន្លែងណា?*

ចម្លើយចំពោះលំហាត់

គុណសម្បត្តិ គុណវិបត្តិ និងការប្រើប្រាស់វិធីសាស្ត្រក្នុងការទូទាត់ប្រាក់



វិធីសាស្ត្រទូទាត់	គុណសម្បត្តិ	គុណវិបត្តិ	ការប្រើប្រាស់
សាច់ប្រាក់	• សាមញ្ញក្នុងការប្រើប្រាស់ • ទទួលយកយ៉ាងទូលំទូលាយ (ការដេញថ្លៃស្របច្បាប់) • គ្មានការគិតថ្លៃទេ • អាចទិញបានភ្លាមៗ	• ហានិភ័យនៃការលួច ឬការបាត់បង់ • គ្មានដំណោះស្រាយក្នុងករណីមានចោរលួច ឬការបាត់បង់ • ដែនកំណត់លើចំនួនទឹកប្រាក់ក្នុងប្រតិបត្តិការដែលបានអនុញ្ញាត (មិនមែនអ្វីៗទាំងអស់អាចត្រូវបានបង់ជាសាច់ប្រាក់នោះទេ ឡើយ ជាពិសេសនៅពេលមានចំនួនទឹកប្រាក់ច្រើន) • វាមិនបន្សល់កស្តង់លើប្រតិបត្តិការទេ (អាចមានបញ្ហាសម្រាប់ការគ្រប់គ្រងថវិកា)	• សម្រាប់ការទិញប្រចាំថ្ងៃនៅពេលដែលទឹកប្រាក់តិចតួចត្រូវបានពាក់ព័ន្ធ • ដើម្បីកំណត់នូវអ្វីដែលលោកអ្នកអាចចំណាយក្នុងអំឡុងពេលជាក់លាក់ណាមួយឬក្នុងឱកាសជាក់លាក់ណាមួយ • ដើម្បីអាចទិញអ្វីមួយបានភ្លាមៗ
កាតធនាគារ	• សុវត្ថិភាព (និយាយជាទូទៅ) • មិនមានកស្តង់ពីទឹកប្លែងនិងចំនួនទឹកប្រាក់នៃប្រតិបត្តិការនិងទំនិញដែលបានទិញ • ការការពារទប់ទល់នឹងការលួច (លេខកូដសម្ងាត់ កាតអាចត្រូវបានធ្វើមោឃភាពប្រសិនបើត្រូវបានគេលួច) • អាចធ្វើទៅបានក្នុងការទិញដែលពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ច្រើន •វាអាចភ្ជាប់ទៅគណនីធនាគារនៅក្នុងប្រទេសផ្សេងទៀត (មិនចាំបាច់សម្រាប់កន្លែងដែលខ្ញុំរស់នៅនោះទេ) • អាចផ្តល់សិទ្ធិចូលប្រើផលិតផលបន្ទាប់បន្សំ៖ ឧ. ជំនួយផ្នែកច្បាប់ ការធានារ៉ាប់រងនៅពេលទិញសំបុត្រយន្តហោះ • ការទទួលបានសេវាហិរញ្ញវត្ថុផ្សេងទៀត (ការធានារ៉ាប់រង ជំនួយផ្នែកច្បាប់ជាដើម) • វាអាចភ្ជាប់ទៅកម្មវិធីសួយសារដែលអាចនាំទៅរកអត្ថប្រយោជន៍/ការបញ្ចុះតម្លៃ	• ជួនកាលការគិតថ្លៃសំខាន់ៗដូចជា៖ ថ្លៃសេវាប្រចាំឆ្នាំ ការគិតថ្លៃសម្រាប់ការដកប្រាក់ធ្វើការទូទាត់ក្រៅប្រទេស។ល។ • ហានិភ័យនៃការមិនតាមដានការចំណាយរបស់លោកអ្នក • ហានិភ័យនៃការភ្លេចនៅពេលគ្រប់គ្រងថវិការបស់ខ្លួន • មិនអាចប្រើបានគ្រប់ទីកន្លែង៖ អាស្រ័យលើអ្នកលក់រាយដែលមានកន្លែងដំណើរការ	• សម្រាប់ការទូទាត់ប្រចាំថ្ងៃដែលពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ច្រើន • សម្រាប់ការទិញធំៗម្តងម្កាល • សម្រាប់ការទិញទំនិញ និងសេវាកម្មរួមបញ្ចូលផលិតផលដែលពាក់ព័ន្ធ (ឧ. ការបង់ប្រាក់សម្រាប់សំបុត្រយន្តហោះ ប្រសិនបើកាតនេះផ្តល់ការធានារ៉ាប់រង)

វិធីសាស្ត្រទូទាត់	គុណសម្បត្តិ	គុណវិបត្តិ	ការប្រើប្រាស់
ការផ្ទេរប្រាក់តាមធនាគារនិងឥណពន្ធផ្ទាល់	• ទៅណាឬមកណាមិនចាំបាច់យកសាច់ប្រាក់ទៅជាមួយឡើយ • អាចធ្វើការទិញបាន ២៤/៧ • ជាញឹកញាប់អាចឲ្យលោកអ្នកប្រើប្រាស់ការផ្តល់ជូនដ៏ល្អ	• គ្មាននរណាម្នាក់ត្រូវយោងដោយផ្ទាល់ទេ (ប្រសិនបើមានបញ្ហាកើតឡើង) • ហានិភ័យនៃការឆបោកប្រសិនបើលោកអ្នកទិញទំនិញពីគេហទំព័រដែលមិនមានសុវត្ថិភាព • បញ្ហាជីកជញ្ជួនដែលអាចកើតមានជាមួយទំនិញដែលបានទិញតាមអនឡាញ • ហានិភ័យនៃការភ្លេចការចំណាយក្នុងការគ្រប់គ្រងថវិកា • ហានិភ័យនៃការមិនបានតាមដានការចំណាយ	• ដើម្បីទទួលបានការផ្តល់ជូនដ៏ល្អ • សម្រាប់ការទិញហ៊ុសដែលផ្តល់នូវអត្ថប្រយោជន៍ប្រៀបធ្យប (សម្លៀកបំពាក់ សៀវភៅ ឧបករណ៍សំបុត្រសម្រាប់ចូលរួមកម្មវិធីសំបុត្រយន្តហោះ។ល។) • សម្រាប់ទំនិញកម្រដែលមានតែតាមអនឡាញប៉ុណ្ណោះ • សម្រាប់ការទូទាត់ក្តៅបត្រ (ទូរស័ព្ទដៃ) ប្រសិនបើលោកអ្នកមិនមានគណនីធនាគារ • ការទូទាត់ប្រាក់ដោយមិនចាំបាច់មានការប៉ះពាល់ជាក់ស្តែង (កូវីដ-១៩)
កាបូបឌីជីថល	• ជាមួយគ្រឹះស្ថានផ្តល់សេវាកម្មមួយចំនួនមិនចាំបាច់មានគណនីធនាគារដើម្បីបើកគណនីកាបូបឌីជីថលនោះឡើយ • វិធីងាយស្រួលក្នុងការផ្ញើប្រាក់ទៅនរណាម្នាក់ និងធ្វើការទូទាត់ប្រាក់	• ហានិភ័យនៃការត្រូវគេលួចទូរស័ព្ទដៃ • ហានិភ័យនៃការភ្លេចលេខសម្ងាត់/ពាក្យសម្ងាត់ • អាចបង្កើតបញ្ហាបន្ទាប់ពីថវិការបស់លោកអ្នក	• ផ្ទេរប្រាក់ទៅមនុស្សផ្សេងទៀត • ការទូទាត់ដោយមិនចាំបាច់ប៉ះពាល់ដោយផ្ទាល់ • ការទូទាត់ក្តៅបត្រ

តារាងប្រៀបធៀបរវាងកាតធនាគារផ្សេងគ្នា

កាត	បង់ប្រាក់មុន/សាចប្រាក់	ឥណពន្ធ	ឥណទាន
តើលោកអ្នកអាចប្រើកាតនេះនៅកន្លែងណា?	• ម៉ាស៊ីនអេធីអឹមពីធនាគាររបស់លោកអ្នក និងបណ្តាញផ្សេងទៀត • នៅតាមហាងដែលទទួលយកការទូទាត់ដោយប្រើកាត	• ម៉ាស៊ីនអេធីអឹមពីធនាគាររបស់លោកអ្នក និងបណ្តាញផ្សេងទៀត • នៅតាមហាងដែលទទួលយកការទូទាត់ដោយប្រើកាត	• ម៉ាស៊ីនអេធីអឹមពីធនាគាររបស់លោកអ្នក និងបណ្តាញផ្សេងទៀត • នៅតាមហាងដែលទទួលយកការទូទាត់ដោយប្រើកាត
តើលោកអ្នកអាចធ្វើអ្វីបានខ្លះជាមួយកាតនេះ?	• ពិនិត្យសមតុល្យរបស់លោកអ្នក • ដកប្រាក់ • ទូទាត់ទំនិញឲ្យតែលោកអ្នកមាន • ទឹកប្រាក់នៅក្នុងសមតុល្យរបស់លោកអ្នក	• ពិនិត្យសមតុល្យរបស់លោកអ្នក • ដកប្រាក់និងដាក់ប្រាក់ • ទូទាត់ទំនិញឲ្យតែលោកអ្នកមានទឹកប្រាក់ក្នុងគណនីរបស់លោកអ្នក •ផ្ទេរប្រាក់ទៅគណនីផ្សេងទៀត •បញ្ជូលកាតទូរសព្ទរបស់លោកអ្នក	• ពិនិត្យសមតុល្យរបស់លោកអ្នក • ដកប្រាក់ និងដាក់ប្រាក់។ • ទូទាត់ទំនិញឲ្យតែលោកអ្នកមានទឹកប្រាក់ក្នុងគណនីរបស់លោកអ្នក • ទូទាត់ទំនិញ ទោះបីជាលោកអ្នកមិនមានទឹកប្រាក់នៅក្នុងគណនីរបស់លោកអ្នកនៅពេលនោះក៏ដោយ •ទូទាត់ទំនិញដោយការបង់រំលោះជាដើម • ផ្ទេរប្រាក់ទៅគណនីផ្សេងទៀត • បញ្ជូលកាតទូរសព្ទរបស់លោកអ្នក
តើគិតថ្លៃភ្លាមៗឬពន្យារពេល?	• ភ្លាមៗ	• ភ្លាមៗ	• ពន្យារពេល លោកអ្នកនឹងបង់ប្រាក់នៅចុងខែក្នុងចំនួនសរុបនៃការទិញរបស់លោកអ្នក។ លោកអ្នកនឹងមិនប្រឈមការគិតថ្លៃការប្រាក់ឡើយ ដរាបណាលោកអ្នកបង់ប្រាក់ទាន់ពេល ហើយមិនប៉ះពាល់ដល់សមតុល្យ
តើការចំណាយ/ការគិតថ្លៃអ្វីខ្លះសម្រាប់ការប្រើប្រាស់កាតនេះ?	• អាស្រ័យលើការផ្តល់ជូនរបស់គ្រឹះស្ថានផ្តល់សេវាកម្មនីមួយៗ។ លោកអ្នកគួរតែទទួលបានព័ត៌មានទាំងអស់ហើយធ្វើការប្រៀបធៀបគ្នា។		



គុណសម្បត្តិ និង គុណវិបត្តិនៃ ប្រតិបត្តិការផ្ទេរ ប្រាក់

ប្រតិបត្តិការផ្ទេរប្រាក់	គុណសម្បត្តិ	គុណវិបត្តិ
ផ្លូវការ	• សុវត្ថិភាព (ទឹកប្រាក់មានសុវត្ថិភាព ហើយការផ្ទេរប្រាក់មានសុវត្ថិភាព) • កម្ចីរយៈពេលវែងនូវចំនួនទឹកប្រាក់ដ៏ច្រើន • ភាពជឿជាក់ • រក្សាការសម្ងាត់ • ជម្រើសផលិតផល •ដំណើរការក្នុងក្របខ័ណ្ឌបទបញ្ញត្តិធនាគារ ប្រសិនបើត្រូវប្រកាសជាផ្លូវការ •អនុញ្ញាតឲ្យលោកអ្នកបង្កើតកំណត់ត្រាឥណទាន និងបង្កើតសាធនភាពរបស់លោកអ្នក •លទ្ធភាពទទួលបានជំបូន្មានហិរញ្ញវត្ថុ និងផលិតផលហិរញ្ញវត្ថុផ្សេងទៀត។ •ល្បឿន (អាស្រ័យលើវិធីសាស្ត្រ) • ធន្មានុសិទ្ធិ (ពេលខ្លះលេខទូរសព្ទគឺជាអ្វីដែលលោកអ្នក	• ភាពនៅទីឆ្ងាយសម្រាប់អ្នកដែលរស់នៅឆ្ងាយពីទីប្រជុំជន និងក្រុង •ហានិភ័យនៃការប្លន់នៅពេលលោកអ្នកចាកចេញពីសាខា/ភ្នាក់ងារ • ម៉ោងបើកមានកំណត់ •លក្ខខណ្ឌតម្រូវទាក់ទងចំនួនទឹកប្រាក់អប្បបរមា ជួនកាលខ្ពស់ពេក • ការចំណាយអាចខ្ពស់ • ត្រូវរង់ចាំនៅបញ្ជរ •កាន់តែពិបាកប្រើប្រាស់សម្រាប់អ្នកមិនចេះអក្សរ • ជួនកាល កង្វះសាច់ប្រាក់ងាយស្រួលសម្រាប់ការផ្ទេរប្រាក់ក្នុងចំនួនច្រើន• ធន្មានុសិទ្ធិ (ពេលខ្លះលេខទូរសព្ទគឺជាអ្វីដែលលោកអ្នកត្រូវការដើម្បីទទួលបានប្រាក់)
ក្រៅផ្លូវការ	• ការចំណាយ (អាស្រ័យលើវិធីសាស្ត្រ) • ការចូលប្រើប្រាស់ • ភាពអាចរកបានក្នុងតំបន់ •ល្បឿន (អាស្រ័យលើវិធីសាស្ត្រ) • ទំនុកចិត្ត (លោកអ្នកប្រហែលជាអាចធ្វើការផ្ទេរប្រាក់តាមរយៈម្ចាស់ហាងក្នុងស្រុកដែលលោកអ្នកធ្លាប់ស្គាល់ជាយូរមកហើយ) •មិនមាននីតិវិធីឬទម្រង់បែបបទរដ្ឋបាលដែលត្រូវបំពេញឡើយ	• គ្មានសេវាកម្មហិរញ្ញវត្ថុផ្សេងទៀតដែលការផ្ទេរប្រាក់របស់លោកអ្នកអាចផ្តល់សិទ្ធិឲ្យអ្នកបាននោះឡើយ • គ្រោះថ្នាក់របស់អ្នកទទួលប្រាក់ដែលត្រូវមកបើកប្រាក់នៅកន្លែងដែលមិនមានសុវត្ថិភាព (ហាង កន្លែងសាធារណៈជាដើម ។ល។)៖ហានិភ័យនៃការប្លន់ឬការបង្ករបួសស្នាម • ភាពខុសច្បាប់នៃការយកសាច់ប្រាក់ដ៏ច្រើនចូលក្នុង ឬចេញក្រៅប្រទេស (ហានិភ័យដល់អ្នកដែលកាន់សាច់ប្រាក់ត្រូវបានចាប់ខ្លួន) • ហានិភ័យនៃការប្លន់ • លុយក្លែងក្លាយ



៦

ស្វែងយល់ពីគ្រឹះស្ថានហិរញ្ញវត្ថុ ហើយប្រើប្រាស់ប្រកបដោយ ចំណុកចិត្ត

FINANCIAL QUIZ EDUCATION

ច ១. គ្រឹះស្ថានហិរញ្ញវត្ថុគឺជាសេវាសាធារណៈ ឬឯកជន ដែលទាក់ទងនឹងប្រតិបត្តិការ ហិរញ្ញវត្ថុ ដូចជាការសន្សំប្រាក់ ឥណទាន និងការទូទាត់ប្រាក់

- ☐ **ក**. ពិត
- ☐ **ខ**. មិនពិត

ច ២. ខ្ញុំកត់សម្គាល់ឃើញថា មានធនាគារកាន់តែច្រើនឡើងនៅក្នុងតំបន់នេះ

- ☐ **ក**. ខ្ញុំគួរតែទៅសួរព័ត៌មាន។ ធនាគារទាំងនេះអាចមានសេវាសន្សំប្រាក់ ឬឥណទានដ៏ទាក់ទាញសម្រាប់ខ្ញុំ
- ☐ **ខ**. តើការប្រើប្រាស់ដើម្បីអ្វី? ធនាគារទាំងនេះចាប់អារម្មណ៍តែទៅលើអ្នកមាន និងក្រុមហ៊ុនធំៗប៉ុណ្ណោះ
- ☐ **គ**. ខ្ញុំចង់ទៅពិនិត្យមើល ប៉ុន្តែខ្ញុំខ្លាចគេស្តីបន្ទោសខ្ញុំ ព្រោះខ្ញុំអត់មានលុយច្រើនឡើយ

ច៣.តើអ្វីជាប្រយោគដែលមិនមែនជាគោលការណ៍នៃការការពារអតិថិជនដែលគ្រឹះស្ថាន ហិរញ្ញវត្ថុតម្រូវឲ្យគោរព?

- ☐ **ក**. ការទប់ស្កាត់ការជំពាក់បំណុលលើសលប់
- ☐ **ខ**. ការប្រព្រឹត្តិដោយយុត្តិធម៌ និងប្រកបដោយការគោរពចំពោះអតិថិជន
- ☐ **គ**. តម្លាភាព
- ☐ **ឃ**. ផ្តល់អំណោយដល់អតិថិជន
- ☐ **ង**. ការកំណត់តម្លៃដែលមានការទទួលខុសត្រូវ
- ☐ **ច**. យន្តការនៃការដោះស្រាយបណ្តឹង

ច .ឃង ‘ឃ ៖ ២ង ៖ ១ង ៖ ភាគ្លើរ

១. ស្វែងយល់ពីគ្រឹះស្ថានហិរញ្ញវត្ថុ

និយមន័យ

គ្រឹះស្ថានហិរញ្ញវត្ថុ ជាស្ថាប័នសាធារណៈ ឬ ឯកជនដែលផ្តល់សេវាហិរញ្ញវត្ថុដូចជា សេវាប្រាក់សន្សំ សេវាឥណទាន និង សេវាទូទាត់ប្រាក់នានា។

និយមន័យ

ធនាគារគឺជាស្ថាប័នដែលត្រូវបានអនុម័តដោយរដ្ឋជាគ្រឹះស្ថានឥណទានដើម្បីអនុវត្តប្រតិបត្តិការធនាគារ៖ ភាគច្រើនទទួលបានមូលនិធិពីសមាជិកសាធារណជន អនុវត្តប្រតិបត្តិការសន្សំប្រាក់ និងផ្តល់ប្រាក់កម្ចី និងការផ្តល់សេវាទូទាត់ប្រាក់។ ធនាគារអាចជាកម្មសិទ្ធិសាធារណៈ ឬ ឯកជន មានឯកទេសផ្នែកប្រាក់បញ្ញើ ឬការវិនិយោគ បង្កើតផលិតផល ឬដើរតួជាសហគមន៍ ឬសង្គមទៅវិញទៅមក។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានឯកទេសខាងសេវាកម្មធនាគារសម្រាប់ក្រុមមនុស្ស ឬបុគ្គលដែលមានប្រាក់ចំណូលទាប។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់សេវាគណនីដល់គណនីសមតុល្យតិច ដែលធម្មតាមិនត្រូវបានទទួលយកដោយធនាគារប្រពៃណី និងផ្តល់សេវាកម្មប្រតិបត្តិការសម្រាប់ចំនួនទឹកប្រាក់ដែលអាចតូចជាងថ្លៃសេវាប្រតិបត្តិការមធ្យមដែលគិតថ្លៃដោយគ្រឹះស្ថានហិរញ្ញវត្ថុធំៗ។


ក្រុមហ៊ុនហិរញ្ញវត្ថុគឺជាស្ថាប័នដែលរកប្រាក់ចំណេញដែលអនុម័តដោយរដ្ឋជាគ្រឹះស្ថានឥណទាន។ គ្រឹះស្ថានទាំងនេះមិនអាចយកប្រាក់បញ្ញើពីសមាជិកសាធារណជន ឬផ្តល់ជូនផលិតផលជាប្រាក់សន្សំបានទេ។

ភន្លឺ

ដើម្បីជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុរបស់លោកអ្នកឲ្យបានល្អ លោកអ្នកត្រូវពិចារណា៖
- លក្ខណៈរបស់គ្រឹះស្ថានហិរញ្ញវត្ថុ
- លក្ខណៈផលិតផលដែលលោកអ្នកត្រូវការទៅតាមគោលដៅរបស់លោកអ្នកដែល

គ្រឹះស្ថាននេះអាចផ្តល់ជូន៖ ប្រភេទគណនី វិធីសាស្ត្រទូទាត់ ផលិតផលជាប្រាក់សន្សំ និងឥណទាន ផលិតផលផ្នែរប្រាក់ជាដើម ។ល។

គ្រឹះស្ថានហិរញ្ញវត្ថុ៖ សេវាសាធារណៈ ឬឯកជនដែលទាក់ទងនឹងប្រតិបត្តិការហិរញ្ញវត្ថុ ដូចជាការសន្សំប្រាក់ ឥណទាន និងការទូទាត់ជាដើម។



ជំនួយក្នុងការបណ្តុះបណ្តាល ច.១.១

សំណួរដើម្បីសួរដល់គ្រឹះស្ថានហិរញ្ញវត្ថុ

លក្ខណៈដែលត្រូវពិចារណាក្នុងការជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុ	សំណួរដែលត្រូវសួរ
លក្ខណៈនៃគ្រឹះស្ថានហិរញ្ញវត្ថុ • ភាពនៅជិតទីតាំងភូមិសាស្ត្រ • កេរ្តិ៍ឈ្មោះ និងភាពជឿជាក់លើគ្រឹះស្ថានហិរញ្ញវត្ថុ • ការផ្តល់ និងគុណភាពនៃសេវាកម្មមិនមែនហិរញ្ញវត្ថុ (ការបណ្តុះបណ្តាលអាជីវកម្ម ការអប់រំផ្នែកហិរញ្ញវត្ថុ។ល។) • សេវាកម្មពីចម្ងាយ (ការស្នើអំពីសមតុល្យទឹកប្រាក់តាមរយៈអ៊ីនធឺណិត ការជូនដំណឹងអំពីការចំណាយតាមរយៈសារ SMS សេវាធនាគារតាមទូរស័ព្ទ។ល។) និងការចំណាយផ្សេងៗ • គុណភាពសេវាកម្ម និងបុគ្គលិក (ពេលវេលារង់ចាំ ការគោរពអតិថិជន ភាសានិយាយ ល្បឿននៃសេវាកម្មជាដើម ។ល។) • ប្រសិនបើចាំបាច់ លក្ខខណ្ឌនៃការចូលរួមជាមួយគ្រឹះស្ថាន (ការជាវ ភាពញឹកញាប់នៃកិច្ចប្រជុំ អំណាចក្នុងការសម្រេចចិត្តរបស់សមាជិក...) •តម្លាភាពទាក់ទងនឹងការគិតថ្លៃនិងលក្ខខណ្ឌ គុណភាពព័ត៌មានដែលផ្តល់ដល់អតិថិជន •ផលិតផលដែលរៀបចំឡើងសម្រាប់ក្រុមអតិថិជនជាក់លាក់ (សិស្ស បុគ្គលិកដែលមានប្រាក់ខែ សោធននិវត្តន៍ជន...) •ការងារសប្បុរសធម៌ដែលបានអនុវត្ត (មូលនិធិសាមគ្គី ការឧបត្ថម្ភ មូលនិធិ...) •(សម្រាប់អ្នកដែលធ្វើ ឬទទួលការផ្ទេរប្រាក់ទៅ/ពីសាច់ញាតិ) វត្តមានរបស់គ្រឹះស្ថាននៅក្នុងតំបន់ដែលសាច់ញាតិរស់នៅ និងភាពនៅជិតទីតាំងភូមិសាស្ត្រទៅនឹងលំនៅដ្ឋានរបស់ពួកគាត់។	
លក្ខណៈនៃផលិតផលរបស់គ្រឹះស្ថានហិរញ្ញវត្ថុ (ក្នុងករណីនេះ គឺការសន្សំប្រាក់) • ការទទួលបានប្រាក់សន្សំ/ភាពបត់បែននៃការដកប្រាក់ • ភាពរួសរាយរាក់ទាក់ជាមួយអ្នកប្រើប្រាស់ • លក្ខខណ្ឌសម្រាប់ការបើកគណនីសន្សំ • សុវត្ថិភាព • អត្រាការប្រាក់ • លទ្ធភាពនៃការចូលប្រើប្រាស់ផលិតផល និងសេវាកម្មផ្សេងទៀតដែលផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុ • ការចំណាយលើការសន្សំប្រាក់ (ការគិតថ្លៃ ការពិន័យ) • សាច់ប្រាក់ងាយស្រួល •តម្លៃក្រមសីលធម៌នៃផលិតផល (ហិរញ្ញវត្ថុមាននិរន្តរភាព បរិស្ថាន ឥស្លាម...)	

ជំនួយក្នុងការបណ្តុះបណ្តាល ច.១.២

សំណួរដែលត្រូវសួរដល់គ្រឹះស្ថានហិរញ្ញវត្ថុ (ជាមួយនឹងចម្លើយដែលបានស្នើឡើង)

លក្ខណៈដែលត្រូវពិចារណាក្នុងការជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុ	សំណួរដែលត្រូវសួរ
លក្ខណៈនៃគ្រឹះស្ថានហិរញ្ញវត្ថុ	
ភាពនៅជិតទីតាំងភូមិសាស្ត្រ	•តើមានសាខារបស់គ្រឹះស្ថានហិរញ្ញវត្ថុនៅជិតខ្ញុំ (នៅជិតផ្ទះខ្ញុំ កន្លែងធ្វើការរបស់ខ្ញុំ ឬទីតាំងដែលងាយស្រួលផ្សេងទៀត ដូចជាកន្លែងមើលថែទាំកូនរបស់ខ្ញុំដែរឬទេ)? • ប្រសិនបើខ្ញុំមានកាតទូទាត់ប្រាក់ តើមានម៉ាស៊ីន អេធីអឹមនៅក្បែរ (នៅជិតផ្ទះខ្ញុំ កន្លែងធ្វើការ ឬទីតាំងងាយស្រួលផ្សេងទៀត ដូចជាកន្លែងហាត់ប្រាណជាដើមដែរឬទេ...)?
កេរ្តិ៍ឈ្មោះ និងភាពជឿជាក់របស់គ្រឹះស្ថាន (សំណួរដែលត្រូវសួរខ្លួនឯង ឬមិត្តភក្តិ/គ្រួសាររបស់លោកអ្នក)	• តើគ្រឹះស្ថានហិរញ្ញវត្ថុនេះមានកេរ្តិ៍ឈ្មោះល្អដែរឬទេ? • តើគ្រួសារខ្ញុំគិតយ៉ាងណាដែរចំពោះគ្រឹះស្ថាននេះ? • តើគ្រឹះស្ថានហិរញ្ញវត្ថុនេះជំរុញទឹកចិត្តខ្ញុំដោយទំនុកចិត្តដែរឬទេ? • តើខ្ញុំបានឮអំពីបញ្ហាទាក់ទងនឹងគ្រឹះស្ថាននេះនៅក្នុងសារព័ត៌មាន ឬតាមរយៈមិត្តភក្តិ និងក្រុមគ្រួសារដែរឬទេ? • តើខ្ញុំស្គាល់នរណាម្នាក់ដែលធ្លាប់មានបញ្ហាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនេះដែរឬទេ? តើបញ្ហាបែបណាដែរ? តើបញ្ហានេះត្រូវបានដោះស្រាយដោយរបៀបណា?
ការផ្តល់និងគុណភាពនៃសេវាកម្មមិនមែនហិរញ្ញវត្ថុ (ការបណ្តុះបណ្តាលអាជីវកម្ម ការអប់រំផ្នែកហិរញ្ញវត្ថុ...)	• តើអ្នកផ្តល់សេវាកម្មបណ្តុះបណ្តាលសម្រាប់អតិថិជន/សមាជិកដែរឬទេ? បើដូច្នេះមែន តើលើប្រធានបទអ្វីដែរ? តើអ្នកណាអាចទាញយកប្រយោជន៍ពីសេវាកម្មនេះ? តើសេវាកម្មគិតបង់ថ្លៃមែនទេ? • តើលោកអ្នកចូលរួមក្នុងសកម្មភាពសាមគ្គីភាព ឬការឧបត្ថម្ភដែរឬទេ? • តើលោកអ្នកចូលរួមក្នុងសកម្មភាពមនុស្សធម៌ដែរឬទេ? • តើលោកអ្នកមានទីប្រឹក្សាដើម្បីជួយដល់អតិថិជនក្នុងការគ្រប់គ្រងការវិនិយោគ និងគណនីរបស់ពួកគេដែរឬទេ?
សេវាកម្មពីចម្ងាយ (ការស្នើអំពីសមតុល្យតាមរយៈអ៊ីនធឺណិត ការជូនដំណឹងអំពីការចំណាយតាមរយៈសារ SMS សេវាធនាគារតាមទូរស័ព្ទ...) និងការចំណាយផ្សេងៗ	• តើលោកអ្នកផ្តល់សេវាកម្មពីចម្ងាយដែរឬទេ? • តើអតិថិជនអាចស្វែងរកសមតុល្យរបស់ពួកគេតាមអ៊ីនធឺណិតបានដែរឬទេ? • បើបាន តើសេវាកម្មនេះរួមបញ្ចូលដោយមិនគិតថ្លៃដែរទេ នៅពេលនរណាម្នាក់បើកគណនី? បើមិនរួមបញ្ចូល តើថ្លៃសេវាប៉ុន្មានដែរ? •តើខ្ញុំអាចទទួលបានការជូនដំណឹងអំពីការបង់ប្រាក់ដែលខ្ញុំបានធ្វើតាមរយៈសារ SMS បានដែរឬទេ?

លក្ខណៈដែលត្រូវពិចារណាក្នុងការជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុ	សំណួរដែលត្រូវសួរ
លក្ខណៈនៃគ្រឹះស្ថានហិរញ្ញវត្ថុ	
គុណភាពនៃសេវាកម្ម និងបុគ្គលិក (ពេលវេលារង់ចាំ ការគោរពអតិថិជន ភាសានិយាយ ល្បឿននៃសេវាកម្ម...)	• តើធនាគារបើកនៅម៉ោងប៉ុន្មាន? • តើរយៈពេលរង់ចាំជាមធ្យមយូរប៉ុណ្ណាដៃមុនពេលអតិថិជនត្រូវបានដោះស្រាយដោយបុគ្គលិក? • តើលោកអ្នកមានបណ្តាញអេធីអឹមទូទាំងប្រទេសដៃឬទេ? • តើខ្ញុំនឹងត្រូវបានគិតថ្លៃដៃឬទេ ប្រសិនបើខ្ញុំដកប្រាក់ពីម៉ាស៊ីនអេធីអឹមផ្សេងទៀត (នៅក្នុងតំបន់ផ្សេងទៀត ក្រៅប្រទេស ឬដាកម្មសិទ្ធិរបស់ធនាគារផ្សេងនោះ)?
ត្រូវបានសម្រេចចិត្តនៅពេលចុះទៅ	
ប្រសិនបើសមស្រប (សង្គមទៅវិញទៅមក) លក្ខខណ្ឌនៃសមាជិកភាព	• តើមានលក្ខខណ្ឌក្នុងការក្លាយជាសមាជិកគ្រឹះស្ថានហិរញ្ញវត្ថុរបស់លោកអ្នកដៃឬទេ? តើលក្ខខណ្ឌទាំងនោះជាអ្វី? • តើការជាវមានតម្លៃប៉ុន្មានដៃរ? តើត្រូវបង់ប្រចាំខែ ប្រចាំសប្តាហ៍ ប្រចាំឆ្នាំ? •តើការប្រជុំរបស់សមាជិកធ្វើឡើងញឹកញាប់ប៉ុណ្ណាដៃរ? • តើសមាជិកគ្រប់រូបមានកាតព្វកិច្ចចូលរួមកិច្ចប្រជុំទាំងនេះឬ? បើដូច្នេះ តើមានការពិន័យអ្វីខ្លះ បើអ្នកណាម្នាក់មិនចូលរួម? •តើសិទ្ធិធ្វើការសម្រេចចិត្តរបស់សមាជិកមានអ្វីខ្លះ?
តម្លាភាពទាក់ទងនឹងការគិតថ្លៃ និងលក្ខខណ្ឌ គុណភាពនៃព័ត៌មានដែលផ្តល់ដល់អតិថិជន (សំណួរដែលត្រូវសួរខ្លួនឯង)	•តើការគិតថ្លៃនិងលក្ខខណ្ឌត្រូវបានដាក់តាំងបង្ហាញនៅក្នុងបរិវេណគ្រឹះស្ថានហិរញ្ញវត្ថុដៃឬទេ? • តើគ្រឹះស្ថានផ្តល់ខិត្តប័ណ្ណពន្យល់ ឬមធ្យោបាយផ្តល់ព័ត៌មានផ្សេងទៀត (គេហទំព័រ។ល។)? បើដូច្នេះ តើខ្ញុំទទួលបានព័ត៌មានទាំងអស់ដែលខ្ញុំត្រូវការដោយការអានខិត្តប័ណ្ណ/ការប្រឹក្សាយោបល់អំពីព័ត៌មានដៃឬទេ? • តើឯកសារដែលផ្តល់ឲ្យងាយស្រួលយល់ដៃឬទេ? •តើនរណាម្នាក់បើកឬបិទគណនីដោយរបៀបណាដៃរ? តើចំណាយប្រាក់ប៉ុន្មានដៃរ?
ផលិតផលដែលរៀបចំឡើងសម្រាប់ក្រុមអតិថិជនជាក់លាក់ (សិស្ស បុគ្គលិកដែលមានប្រាក់ខែ សោធននិវត្តន៍ជន...)	•តើលោកអ្នកមានផលិតផល ឬសេវាកម្មហិរញ្ញវត្ថុណាមួយដែលត្រូវបានរៀបចំឡើងជាពិសេសសម្រាប់មនុស្សដូចជារូបខ្ញុំដៃឬទេ? (មនុស្សវ័យក្មេង ម្ចាស់ហាង បុគ្គលិក ស្ត្រី ពាណិជ្ជករជាដើម។ល។)
ការងារសប្បុរសធម៌ដែលត្រូវបានអនុវត្ត (មូលនិធិ សាមគ្គី ការឧបត្ថម្ភ...)	• តើគ្រឹះស្ថានរបស់លោកអ្នកចូលរួមក្នុងកិច្ចការសប្បុរសធម៌ដៃឬទេ? បើដូច្នេះ តើការងារទាំងនោះជាអ្វីដៃរ? តើអ្នកណាជាអ្នកទទួលផល (កុមារមានពិការភាព អ្នកជំងឺ ។ល។)?
វត្តមានរបស់គ្រឹះស្ថាននៅក្រៅប្រទេស ឬក្នុងតំបន់ និងភាពនៅជិតទីតាំងកូមិសាស្ត្រទៅនឹងកន្លែងស្នាក់នៅរបស់សាច់ញាតិដែលធ្វើ ឬទទួលប្រាក់	• តើមានសាខានៃគ្រឹះស្ថានហិរញ្ញវត្ថុនៅជិតកន្លែងដែលគ្រួសារខ្ញុំរស់នៅ (ផ្ទះ កន្លែងធ្វើការ ឬទីតាំងងាយស្រួលផ្សេងទៀត) ដូចដែលខ្ញុំនឹងធ្វើ និងទទួលប្រាក់ទៅ/ពីពួកគាត់ដៃឬទេ?

លក្ខណៈដែលត្រូវពិចារណាក្នុងការជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុ	សំណួរដែលត្រូវសួរ
លក្ខណៈនៃផលិតផលរបស់គ្រឹះស្ថានហិរញ្ញវត្ថុ (ក្នុងករណីនេះ ការសន្សំប្រាក់)	
ការទទួលបានប្រាក់សន្សំ/ភាពបត់បែននៃការដកប្រាក់	• តើខ្ញុំអាចដកប្រាក់បានញឹកញាប់ប៉ុណ្ណាដែរ? • តើមានចំនួនទឹកប្រាក់អប្បបរមាក្នុងការដកប្រាក់ម្តងដែរឬទេ? • តើខ្ញុំត្រូវបង់ប្រាក់ពិន័យដែរឬទេ ប្រសិនបើខ្ញុំដកប្រាក់ពីគណនីសន្សំនេះ?
ភាពរួសរាយរាក់ទាក់ជាមួយអ្នកប្រើប្រាស់	• តើអតិថិជនទទួលបានព័ត៌មានទាក់ទងនឹងគណនីសន្សំរបស់ពួកគាត់ដែរឬទេ? ញឹកញាប់ប៉ុណ្ណាដែរ? • តើលោកអ្នកផ្តល់សេវាធនាគារតាមទូរស័ព្ទ និង/ឬតាមអ៊ីនធឺណិតដែរឬទេ?
លក្ខខណ្ឌក្នុងការបើកគណនីសន្សំ	• តើប្រាក់បញ្ញើអប្បបរមាប៉ុន្មានដែរ ប្រសិនបើខ្ញុំបើកគណនីសន្សំ? • តើឯកសារអ្វីខ្លះដែលខ្ញុំត្រូវបង្ហាញលោកអ្នក?
សន្តិសុខ	• តើមានការធានារ៉ាប់រង ឬការធានាអ្វីខ្លះសម្រាប់ការការពារមូលនិធិរបស់អតិថិជន?
អត្រាការប្រាក់	• តើមានអត្រាការប្រាក់ប៉ុន្មានដែរជាមួយគណនីសន្សំនេះ? • តើអត្រាការប្រាក់ប៉ុន្មានដែរធៀបនឹងអត្រាការប្រាក់របស់គ្រឹះស្ថានផ្សេងទៀត? • តើត្រូវបង់ការប្រាក់ញឹកញាប់ប៉ុណ្ណាដែរ? • តើការប្រាក់ត្រូវបានគណនាយ៉ាងដូចម្តេច? តើអត្រាថេរ ឬអថេរ?
លទ្ធភាពនៃការទទួលបានផលិតផលនិងសេវាកម្មផ្សេងទៀតដែលផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុ	• តាមរយៈការទទួលបានផលិតផលហិរញ្ញវត្ថុ តើខ្ញុំអាចចូលប្រើប្រាស់ផលិតផលនិងសេវាកម្មផ្សេងទៀតបានដែរឬទេ? បើបាន តើផលិតផលនិងសេវាកម្មនោះជាអ្វី? ក្នុងអត្រាដែលអំណោយផលច្រើន?
ការចំណាយលើការសន្សំប្រាក់ (ការគិតថ្លៃ ការពិន័យ)	• តើមានតម្លៃប៉ុន្មានដែរ? (តើត្រូវគិតថ្លៃប៉ុន្មានដែរសម្រាប់ការផ្ទេរប្រាក់ សម្រាប់ការដកប្រាក់ពីម៉ាស៊ីន អេធីអឹម) • តើថ្លៃគ្រប់គ្រងប៉ុន្មានដែរសម្រាប់គណនីសន្សំ?
សាច់ប្រាក់ងាយស្រួល	• តើវាងាយស្រួលទេក្នុងការដកប្រាក់? តើមាននីតិវិធីអ្វីខ្លះ? • តើខ្ញុំអាចដកចំនួនទឹកប្រាក់សរុបបានដែរឬទេ ប្រសិនបើខ្ញុំចង់? • តើគិតថ្លៃសេវាទេ ប្រសិនបើទឹកប្រាក់នោះត្រូវបានដកមុនកាលបរិច្ឆេទកំណត់?
តម្លៃសីលធម៌នៃផលិតផល (ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព បរិស្ថាន ឥស្លាម...)	• តើផលិតផលហិរញ្ញវត្ថុត្រូវនឹងស្តង់ដារក្រមសីលធម៌ដែរឬទេ? តើស្តង់ដារមួយណាដែរ? • តើផលិតផលមានស្លាកសញ្ញាបញ្ជាក់ពីការអនុលោមតាមស្តង់ដារទាំងនេះដែរឬទេ?

ភារៈរបស់លោកអ្នក

យោងតាមគោលដៅរបស់ខ្ញុំ ស្ថានភាពផ្ទាល់ខ្លួនរបស់ខ្ញុំ និងតម្រូវការហិរញ្ញវត្ថុរបស់ខ្ញុំ ខ្ញុំជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុដែលមានលក្ខណៈដូចខាងក្រោម៖

ឧទាហរណ៍៖ នៅជិតផ្ទះរបស់ខ្ញុំ


១. .....

២. .....

៣. .....

សារសំខាន់

- ដើម្បីជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុ លោកអ្នកត្រូវពិនិត្យមើលលក្ខណៈ និងផលិតផល ហើយជ្រើសរើសគ្រឹះស្ថានណាដែលសក្តិសមនឹងតម្រូវការរបស់លោកអ្នក។
- លោកអ្នកអាចស្វែងរកព័ត៌មាននៅលើខិត្តប័ណ្ណរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ហើយលោកអ្នកក៏អាចសួរសំណួរទៅកាន់បុគ្គលិករបស់គ្រឹះស្ថានបានផងដែរ។
- នៅពេលលោកអ្នកជ្រើសរើសផលិតផលសន្សំ ឬឥណទាន សូមចាំថា អត្រាការប្រាក់គឺជាចំណុចតែមួយគត់ដែលត្រូវយកមកពិចារណាក្នុងចំណោមផលិតផលច្រើនទៀត។



២. ការប្រើប្រាស់គ្រឹះស្ថានហិរញ្ញវត្ថុដោយចំណុកចិត្ត!



ករណីសិក្សាទី ១

ណារី និងប្អូនប្រុសរបស់នាងនិយាយអំពីគ្រឹះស្ថានហិរញ្ញវត្ថុ

ណារី ធឹកតែជាមួយប្អូនប្រុសរបស់នាងឈ្មោះ ជា។ លោក ជា មានបទពិសោធន៍មិនល្អជាមួយធនាគារមួយ៖ គាត់បានចូលទៅសាកសួរព័ត៌មាន ហើយត្រូវបានបុគ្គលិកម្នាក់បញ្ចុះបញ្ចូលឲ្យបើកគណនី ហើយក្រោយមកគាត់បានដឹងថា គណនីនោះមានថ្លៃសេវាខ្ពស់។ គាត់ក៏បានរកឃើញផងដែរថា គាត់បានបង់ថ្លៃសេវាដែលគាត់ពិតជាមិនបានប្រើ។ គាត់សោកស្តាយដែលបានធ្វើការសម្រេចចិត្តប្រញាប់ប្រញាល់ពេក។ ណារី ពន្យល់ថា មុននឹងបើកគណនីធនាគារដំបូង នាងបានទៅកាន់ធនាគារជាច្រើនលើក ហើយគ្រាន់តែសួរព័ត៌មានប៉ុណ្ណោះ ដូចការលើកឡើងរបស់មិត្តរួមការងារខ្លះមកពីរោងចក្រអញ្ចឹងដែរ។ វាពិបាកក្នុងការនិយាយថាទេណាស់ទៅកាន់បុគ្គលិកធនាគារ ប៉ុន្តែនាងអាចទទួលបានព័ត៌មានជាច្រើន។ នៅទីបំផុត នាងបានសម្រេចចិត្តបើកគណនីមួយជាមួយធនាគារមួយដែលនាងបានទៅកាន់នោះ ដែលផ្តល់ឲ្យនាងនូវគណនីមូលដ្ឋានជាមួយនឹងថ្លៃសេវាទាប ហើយដែលមិនត្រូវការសមតុល្យអប្បបរមាឡើយ។ នាងបានស្នើឲ្យ ជា ធ្វើដូចគ្នានេះដែរ។ ជា និយាយថា គាត់គិតថាគ្មានគ្រឹះស្ថានណាដែលផ្តល់គណនីប្រភេទនេះទេ ហើយក៏សម្រេចចិត្តធ្វើការស្រាវជ្រាវបន្តិចសិន។

សំណួរ

- ហេតុអ្វីបានជាលោក ជា មិនទុកចិត្តគ្រឹះស្ថានហិរញ្ញវត្ថុ?

លោកអ្នកត្រូវដឹងថា ក្នុងនាមជាអតិថិជនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ លោកអ្នកមានទំនួលខុសត្រូវ ប៉ុន្តែលោកអ្នកក៏មានសិទ្ធិដែរ!

តោះស្វែងយល់ពីសិទ្ធិទាំងនេះ!

⚠ **សំខាន់៖** ប្រសិនបើលោកអ្នកធ្លាប់មានបទពិសោធន៍មិនល្អជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ វាអាចទៅរួចដែលថា ការផ្តល់ទំនុកចិត្តជាមួយនឹងការប្រគល់ប្រាក់ឲ្យពួកគេ អាចបណ្តាលឲ្យលោកអ្នកមានការថប់បារម្ភ ឬភាពតានតឹង។ ចូរប្រាប់ខ្លួនអ្នកមុនពេលធ្វើការសម្រេចចិត្ត។ ត្រូវចងចាំ៖ លោកអ្នកមានសិទ្ធិ។

ជំនួយក្នុងការបណ្តុះបណ្តាល ច.២.១

ភាគពិពណ៌នា

ភាគពិពណ៌នាទី ១

ខ្ញុំត្រូវបំពេញព័ត៌មាន ប្រសិនបើអ្នកចង់បើកគណនីធនាគារ។ បន្ទាប់ពីលោកអ្នកបានបំពេញហើយ លោកអ្នកត្រូវបង្ហាញឯកសារអត្តសញ្ញាណរបស់លោកអ្នកដល់បុគ្គលិកដើម្បីបញ្ចប់ដំណើរការនេះ។ នៅពេលដែលលោកអ្នកបានបំពេញព័ត៌មានហើយ និងបានបង្ហាញឯកសារចាំបាច់ លោកអ្នកអាចទៅកាន់បញ្ជរ និងដាក់ប្រាក់នៅក្នុងគណនីរបស់លោកអ្នកបានហើយ។

ភាគពិពណ៌នាទី ២

ខ្ញុំអង្គុយនៅតុមួយនៅច្រកចូលរបស់ទីភ្នាក់ងារ។ ការងាររបស់ខ្ញុំគឺជួយដល់អតិថិជនក្នុងការបើកគណនីធនាគារ។ ខ្ញុំអាចផ្តល់ឲ្យលោកអ្នកនូវទម្រង់បែបបទពាក្យសុំបើកគណនីធនាគារ។ ខ្ញុំក៏អាចជួយលោកអ្នកក្នុងការសម្រេចចិត្តថា តើគណនីធនាគារមួយណាដែលសមស្របបំផុតនឹងតម្រូវការរបស់លោកអ្នក។ សូមសួរសំណួរមកខ្ញុំអំពីផលិតផលដែលយើងខ្ញុំផ្តល់ជូន និងទម្រង់បែបបទដែលលោកអ្នកត្រូវបំពេញ។ សូមសួរខ្ញុំថាតើ លោកអ្នកត្រូវការឯកសារអ្វីខ្លះដើម្បីបើកគណនី។ កុំសុំឲ្យខ្ញុំយកប្រាក់បញ្ញើ ឬផ្តល់ប្រាក់ឲ្យលោកអ្នកឲ្យសោះ។

ភាគពិពណ៌នាទី ៣

ខ្ញុំមើលការខុសត្រូវលើបុគ្គលិកទាំងអស់ ហើយត្រូវប្រាកដថា ពួកគេធ្វើការបានត្រឹមត្រូវ។ ក៏ដូចជាបុគ្គលិកដែលលោកអ្នកអាចមើលឃើញអញ្ចឹង ខ្ញុំគ្រប់គ្រងអ្នកដែលធ្វើការនៅពីក្រោយឆាកនៅក្នុងការិយាល័យរបស់ពួកគេ គ្រប់គ្រងគណនីរបស់មនុស្ស និងធ្វើកិច្ចការផ្សេងៗទៀតជាដើម។ សូមមកជួបខ្ញុំ ប្រសិនបើលោកអ្នកមានបញ្ហាដែលបុគ្គលិកផ្សេងទៀតមិនអាចដោះស្រាយបាន។ កុំមកជួបខ្ញុំដើម្បីបើកគណនីអី។

ភាគពិពណ៌នាទី ៤

ការងាររបស់ខ្ញុំគឺគ្រប់គ្រងសាច់ប្រាក់ និងកត់ត្រាប្រតិបត្តិការ។ ខ្ញុំទទួលយកប្រាក់បញ្ញើរបស់អតិថិជន ហើយចេញជាសាច់ប្រាក់នៅពេលពួកគាត់ដកប្រាក់។ អតិថិជនត្រូវបង្ហាញភស្តុតាងអំពីអត្តសញ្ញាណរបស់ពួកគាត់ និងបំពេញទម្រង់បែបបទឲ្យបានត្រឹមត្រូវ មុនពេលដែលខ្ញុំអាចដោះស្រាយជូន។ លោកអ្នកអាចសួរខ្ញុំបានថាតើលោកអ្នកមានទឹកប្រាក់ប៉ុន្មានក្នុងគណនីរបស់លោកអ្នក ឬថា តើការទូទាត់បានមកដល់ហើយឬនៅ។ កុំសុំឲ្យខ្ញុំបើកគណនីធនាគារឲ្យលោកអ្នកអី។

ភាគពិពណ៌នាទី ៥

ការងាររបស់ខ្ញុំគឺការពារធនាគារ បុគ្គលិកធនាគារ និងអតិថិជនរបស់យើងខ្ញុំ។ ដើម្បីធ្វើដូច្នេះបាន ខ្ញុំត្រូវតាមដានគ្រប់បញ្ហាទាំងអស់ដែលកើតមាននៅក្នុងធនាគារ។ កុំសួរខ្ញុំនូវព័ត៌មានអំពីរបៀបបើកគណនីនៃការបំពេញទម្រង់បែបបទអី។

ភាគពិពណ៌នាទី ៦

ដាក់បង្ហាញព័ត៌មានអំពីប្រភេទផលិតផលដែលធនាគារផ្តល់ជូន និងតម្លៃផលិតផលទាំងនោះ។

ភាគពិពណ៌នាទី ៧

ខ្ញុំមានទម្រង់ទាំងអស់ដែលត្រូវការសម្រាប់ការធ្វើប្រតិបត្តិការ។ លោកអ្នកនឹងត្រូវការទម្រង់បែបបទរបស់ខ្ញុំ ប្រសិនបើលោកអ្នកចង់ធ្វើអាជីវកម្មធនាគារជាមួយបុគ្គលិកនៅតាមបញ្ជរ។

ភាគពិពណ៌នាទី ៨

លោកអ្នកត្រូវបំពេញឲ្យខ្ញុំនៅគ្រប់ព័ត៌មានលម្អិត ហើយចុះហត្ថលេខាលើខ្ញុំ ប្រសិនបើលោកអ្នកចង់ដកប្រាក់ពីគណនីរបស់លោកអ្នក។

ភាគពិពណ៌នាទី ៩

លោកអ្នកអាចប្រើខ្ញុំក្នុងការទូទាត់ប្រាក់ដល់នរណាម្នាក់ដោយមិនចាំបាច់មានសាច់ប្រាក់ (ឧ. ក្រដាសប្រាក់ ឬកាក់ជាដើម)។ នៅពេលលោកអ្នកបំពេញ និងចុះហត្ថលេខាលើខ្ញុំហើយ លោកអ្នកកំពុងតែផ្តល់ការអនុញ្ញាតឲ្យធនាគារទូទាត់ប្រាក់ឲ្យអ្នកដែលមានឈ្មោះនៅលើខ្ញុំហើយ។ ធនាគារនឹងទូទាត់ប្រាក់ឲ្យបុគ្គលនោះជាមួយនឹងប្រាក់ដែលដកចេញពីគណនីរបស់លោកអ្នក។

ភាគពិពណ៌នាទី ១០

លោកអ្នកត្រូវបំពេញឲ្យខ្ញុំនូវរាល់ព័ត៌មានលម្អិតទាំងអស់ រួមទាំងលេខគណនីរបស់លោកអ្នក ប្រសិនបើលោកអ្នកចង់ដាក់ប្រាក់ចូលក្នុងគណនីរបស់លោកអ្នក។

នៅចុងបញ្ចប់នៃម៉ូឌុលនេះ លោកអ្នកនឹងរកឃើញចម្លើយដែលត្រឹមត្រូវទាក់ទងចម្លើយចំពោះលំហាត់ទាំងអស់។

សារសំខាន់

- ដើម្បីជ្រើសរើសគ្រឹះស្ថានហិរញ្ញវត្ថុ លោកអ្នកត្រូវពិនិត្យមើលលក្ខណៈ និងផលិតផលរបស់គ្រឹះស្ថានទាំងនោះ ហើយជ្រើសរើសគ្រឹះស្ថានណាដែលសមស្របបំផុតសម្រាប់តម្រូវការរបស់លោកអ្នក។
- ដើម្បីពិនិត្យមើលលក្ខណៈ និងផលិតផលរបស់គ្រឹះស្ថានហិរញ្ញវត្ថុ វាជាការសំខាន់ណាស់ដែលត្រូវពិនិត្យមើលសៀវភៅផ្សព្វផ្សាយ ខិត្តប័ណ្ណ ក៏ដូចជាការសួរសំណួរត្រឹមត្រូវទៅកាន់បុគ្គលិក៖ សួរបានដោយសេរី វាជាការងាររបស់ពួកគេក្នុងការឆ្លើយសំណួររបស់លោកអ្នក!
- ការចូលទៅក្នុងធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតមិនមានន័យថា លោកអ្នកត្រូវតែប្តេជ្ញាចិត្តក្នុងការបើកគណនីនោះទេ។ លោកអ្នកអាចចាប់ផ្តើមដោយការប្រមូលព័ត៌មានជាដើម។
- តាមទ្រឹស្តី មនុស្សគ្រប់គ្នាអាចទទួលបានសេវាពីគ្រឹះស្ថានហិរញ្ញវត្ថុ (ប្រសិនបើលោកអ្នកអាចផ្តល់ឯកសារដែលត្រូវការ!) គឺ៖ លោកអ្នកត្រូវស្វែងរកគ្រឹះស្ថានដែលបំពេញតម្រូវការរបស់លោកអ្នកច្រើនបំផុត។
- ក្នុងនាមជាអតិថិជនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ លោកអ្នកមានសិទ្ធិ!

ឥឡូវនេះយើងនឹងអនុវត្តស្តីពីការបំពេញទម្រង់បែបបទជាក់ស្តែងក្នុងការបើកគណនីធនាគារ។ យើងនឹងប្រើទម្រង់បែបបទទូទៅ។

ជំនួយក្នុងការបណ្តុះបណ្តាល ច.២.២

ទម្រង់បែបបទសម្រាប់បើកគណនី

YOURBANK

BOX RESERVED TO

ទម្រង់បែបបទសម្រាប់បើកគណនី

ម្ចាស់គណនី ១	**ម្ចាស់គណនី ២**
ស្ថានភាពបុគ្គល	**ស្ថានភាពបុគ្គល**
អត្តានុកូលដ្ឋាន៖ ☐ លោក ☐ លោកស្រី ☐ កញ្ញា	អត្តានុកូលដ្ឋាន៖ ☐ លោក ☐ លោកស្រី ☐ កញ្ញា
គោត្តនាម៖	គោត្តនាម៖
នាម៖	នាម៖
អាសយដ្ឋានស្នាក់នៅ៖ លេខកូដតំបន់៖	អាសយដ្ឋានស្នាក់នៅ៖ លេខកូដតំបន់៖
ទីប្រជុំជន៖	ទីប្រជុំជន៖
ប្រទេស៖	ប្រទេស៖
ស្ថានភាពគ្រួសារ៖ ☐ រៀបការ ☐ រស់នៅបែកគ្នា ☐ លែងលះ ☐ ពោះម៉ាយ ម៉ែម៉ាយ ☐ នៅលីវ	ស្ថានភាពគ្រួសារ៖ ☐ រៀបការ ☐ រស់នៅបែកគ្នា ☐ លែងលះ ☐ ពោះម៉ាយ ម៉ែម៉ាយ ☐ នៅលីវ
ឈ្មោះដើម៖	ឈ្មោះដើម៖
ថ្ងៃខែនិងទីកន្លែងកំណើត៖	ថ្ងៃខែនិងទីកន្លែងកំណើត៖
សញ្ជាតិ៖	សញ្ជាតិ៖
ទូរសព្ទ (នៅផ្ទះ)៖	ទូរសព្ទ (នៅផ្ទះ)៖
ទូរសព្ទ (ចល័ត)៖	ទូរសព្ទ (ចល័ត)៖
អ៊ីមែល៖	អ៊ីមែល៖
ស្ថានភាពវិជ្ជាជីវៈ	**ស្ថានភាពវិជ្ជាជីវៈ**
ចំណូលសុទ្ធប្រចាំខែ៖ ☐☐☐☐☐☐☐☐	ចំណូលសុទ្ធប្រចាំខែ៖ ☐☐☐☐☐☐☐☐
☐ សកម្ម ☐ អ្នកស្វែងរកការងារធ្វើ ☐ សិស្ស ☐ និវត្តន៍ជន	☐ សកម្ម ☐ អ្នកស្វែងរកការងារធ្វើ ☐ សិស្ស ☐ និវត្តន៍ជន
គណនី	
☐ គណនីចរន្តបុគ្គល ☐ គណនីចរន្តរួម ☐ គណនីសន្សំ	
ភាតនិងសហធនាគារ	
☐ អេជីអឹម ☐ ធនាគារអ៊ីនធឺណិត ☐ ប័ណ្ណឥណពន្ធ ☐ ការធានាវ៉ាប់រងសម្រាប់វិធីសាស្ត្រទូទាត់ប្រាក់ ☐ ប័ណ្ណឥណទាន	
ហត្ថលេខា	
ម្ចាស់គណនី ១ / ម្ចាស់គណនី ២ / ប្រធានសាខា	
កាលបរិច្ឆេទ	

ជំនួយក្នុងការបណ្តុះបណ្តាល ច.២.៣

ការប្រើម៉ាស៊ីនអេធីអឹមសម្រាប់ដកប្រាក់

ឥឡូវនេះ យើងនឹងអនុវត្តការប្រើប្រាស់ម៉ាស៊ីនអេធីអឹមជាក់ស្តែង ដោយធ្វើជាដកសាច់ប្រាក់ពីគណនីសន្សំ

ជំហានទី១៖ ស៊កបញ្ចូលកាតអេធីអឹម



ស៊កបញ្ចូលកាតអេធីអឹមរបស់លោកអ្នកទៅក្នុងម៉ាស៊ីនអេធីអឹម (លោកអ្នកអាចឃើញរន្ធស៊កពណ៌បៃតង ឬរន្ធស៊ុកប្រភេទណាមួយ)។


ជំហានទី២៖ បញ្ចូលលេខសម្ងាត់អេធីអឹម៤ខ្ទង់



ដោយប្រើក្តារចុច លោកអ្នកត្រូវបញ្ចូលពាក្យសម្ងាត់៤ខ្ទង់របស់លោកអ្នក។ ប៉ុន្តែ ត្រូវចាំជានិច្ចថា គ្មាននរណាម្នាក់អាចមើលឃើញពាក្យសម្ងាត់របស់លោកអ្នកបានឡើយ នៅពេលលោកអ្នកបញ្ចូលវា ហើយកុំចែករំលែក


ពាក្យសម្ងាត់នេះជាមួយនរណាម្នាក់ឲ្យសោះ។ វាយពាក្យសម្ងាត់ខុសលើសពី៣ ដង កាតអេធីអឹមរបស់លោកអ្នកអាចត្រូវបានរារាំងបង្ហាំងទុក។

ជំហានទី៣៖ ជ្រើសរើសប្រតិបត្តិការរបស់លោកអ្នក




នៅក្នុងផ្នែកនេះ លោកអ្នកអាចឃើញជម្រើសជាច្រើននៅលើការបង្ហាញតាមអេក្រង់ ដូចជា ការដកប្រាក់ ការផ្ទេរប្រាក់ ការសាកសួរអំពីសមតុល្យជាដើម។ ក្នុងករណីនេះ លោកអ្នកត្រូវជ្រើសរើសការដកប្រាក់។

ជំហានទី ៤៖ ជ្រើសរើសគណនីរបស់លោកអ្នក



ក្នុងករណីដែលកាតអេធីអឹមរបស់លោកអ្នកត្រូវបានភ្ជាប់ទៅគណនីធនាគារផ្សេងៗគ្នា លោកអ្នកត្រូវជ្រើសរើសគណនីធនាគារណាមួយដែលលោកអ្នកចង់ដកប្រាក់ចេញពីគណនីនោះ។

ជំហានទី ៥៖ នាយបញ្ជូលចំនួនទឹកប្រាក់



នៅក្នុងផ្នែកនេះ៖ លោកអ្នកត្រូវវាយបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវដក ហើយចុចបញ្ជូន។

ប៉ុន្តែ ត្រូវប្រាកដថា ចំនួនទឹកប្រាក់ដែលត្រូវដកមិនឲ្យលើសពីសមតុល្យ របស់លោកអ្នកនៅក្នុងគណនីឡើយ បើមិនដូច្នេះទេ ប្រតិបត្តិការនឹង បរាជ័យ។

ជំហានទី ៦៖ ទទួលយកសាច់ប្រាក់



នៅក្នុងផ្នែកនេះ៖ លោកអ្នកត្រូវទទួលយកសាច់ប្រាក់របស់លោកអ្នកពីរន្ធ ផ្នែកខាងក្រោមនៃម៉ាស៊ីន។

ជំហានទី ៧៖ ជ្រើសរើសប្រតិបត្តិការផ្សេងទៀត ឬបញ្ចប់ប្រតិបត្តិការ



នៅពេលនេះ៖ លោកអ្នកអាចជ្រើសរើសថា តើលោកអ្នកចង់ធ្វើប្រតិបត្តិ ការផ្សេងទៀត ឬបញ្ចប់ប្រតិបត្តិការរបស់លោកអ្នក។ បន្ទាប់ពីចុចបញ្ចប់ ប្រតិបត្តិការរបស់លោកអ្នកហើយ ត្រូវប្រាកដថា លោកអ្នកយកកាត អេធីអឹមរបស់លោកអ្នកវិញ។



លោកអ្នកត្រូវដឹងថា ក្នុងនាមជាអតិថិជនរបស់ គ្រឹះស្ថានហិរញ្ញវត្ថុ លោកអ្នកមានទំនួលខុសត្រូវ ប៉ុន្តែ លោកអ្នកក៏មានសិទ្ធិផងដែរ! តោះស្វែងយល់

ផ្នែកទាក់ទងអតិថិជន ហើយប្រើប្រាស់ប្រកបដោយទំនុកចិត្ត

ជំនួយក្នុងការបណ្តុះបណ្តាល ច.២.៤

ភាពពិពណ៌នា - គោលការណ៍ការពារអតិថិជន

ភាពពិពណ៌នា

ខ្ញុំជាកម្មករកាត់ដេរ។

កាលពីប៉ុន្មានខែមុន ខ្ញុំបានចុះកិច្ចសន្យាខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្បែរនោះដើម្បីយកប្រាក់មកទិញម៉ាស៊ីនបោកគក់។ រាល់ខែ ខ្ញុំត្រូវបង់រំលោះក្នុងចំនួនទឹកប្រាក់ដ៏ច្រើន។ ការបង់ប្រាក់គឺខ្ពស់ណាស់ ដែលខ្ញុំមិនមានប្រាក់ផ្ញើទៅគ្រួសាររបស់ខ្ញុំនៅដើមខែនីមួយៗ ដូចដែលខ្ញុំធ្លាប់ធ្វើមុនពេលមានប្រាក់កម្ចីនេះ។ ខ្ញុំព្រួយបារម្ភយ៉ាងខ្លាំងអំពីសុខភាព និងសុខុមាលភាពរបស់ពួកគាត់។

តើនេះជារឿងធម្មតាឬ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

ភាពពិពណ៌នា

ខ្ញុំបានចុះកិច្ចសន្យាខ្ចីប្រាក់កម្ចីចំនួនពីរជាមួយធនាគាររួចហើយ៖ ប្រាក់កម្ចីមួយសម្រាប់ទិញផ្ទះ ប្រាក់កម្ចីមួយទៀតសម្រាប់ចំណាយក្នុងពិធីសាសនាកាលពីឆ្នាំមុន។

ពេលនេះខ្ញុំចង់ទិញម៉ូតូមួយគ្រឿងដើម្បីខ្ញុំអាចធ្វើដំណើរទៅណាមកណាបានស្រួលជាងមុន។ ធនាគាររបស់ខ្ញុំបដិសេធមិនផ្តល់ប្រាក់កម្ចីទីបីដល់រូបខ្ញុំឡើយ។

តើនេះជារឿងធម្មតាទេ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

ភាពពិពណ៌នា

ខ្ញុំជាអតិថិជនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ។

ខ្ញុំបានព្យាយាមស្វែងយល់អំពីលក្ខខណ្ឌ និងការគិតថ្លៃសេវាដែលទាក់ទងនឹងផលិតផលសន្សំ ប៉ុន្តែខិត្តប័ណ្ណដែលពួកគេបានផ្តល់ឲ្យខ្ញុំគឺមានការសរសេរអក្សរតូចៗពេក ហើយខ្ញុំមិនយល់ពីលក្ខខណ្ឌទាំងអស់ដែលបានប្រើនោះទេ។

តើខ្ញុំត្រូវធ្វើអ្វី?

ការអប់រំផ្នែកហិរញ្ញវត្ថុ

ភាពពិពណ៌នា

ខ្ញុំមានគណនីចរន្ត និងគណនីសន្សំជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ។

ខ្ញុំមិនសប្បាយចិត្តឡើយ ព្រោះខ្ញុំត្រូវបង់ថ្លៃសេវាគ្រប់គ្រងខ្ពស់សម្រាប់គណនីចរន្តរបស់ខ្ញុំ ចំណែកគណនីបញ្ញើរបស់ខ្ញុំបង់អត្រាការប្រាក់ទាបបំផុត។

នេះហាក់ដូចជាអយុត្តិធម៌។

តើនេះជាការធម្មតាឬ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

ភាពពិណ៌នា

ជំពាក់បំណុលច្រើនខ្លាំងណាស់ ហើយមិនអាចមានលទ្ធភាពសងប្រាក់កម្ចីបានតទៅទៀតទេ ព្រោះខ្ញុំទើបតែបាត់បង់ការងារ។

ខ្ញុំបារម្ភថា ធនាគារអាចនឹងធ្វើអ្វីៗមិនខាន ប្រសិនបើមិនអាចសងប្រាក់នោះ។

តើគេអាចមកកាន់ផ្ទះរបស់ខ្ញុំ ហើយរឹបអូសយករបស់របរបស់ខ្ញុំ ឬរបស់របរបស់គ្រួសារខ្ញុំ ឬអត់ក៏ជាចំនេះទៅទៀតនោះ?

ការអប់រំផ្លែកហិរញ្ញវត្ថុ

ភាពពិណ៌នា

ខ្ញុំមិនយល់ស្របទាល់តែសោះជាមួយធនាគារបស់ខ្ញុំអំពីបញ្ហាដែលបានកើតឡើង។

តើខ្ញុំអាចជាកទៅរកអ្នកណាទិញ? តើមានឧទ្ធរណ៍អ្វីខ្លះនៅធនាគារដែលអាចជួយខ្ញុំបានទេ?

ការអប់រំផ្លែកហិរញ្ញវត្ថុ

ភាពពិណ៌នា

បុគ្គលិកធនាគារដែលមើលតាមដានគណនីចរន្តផ្ទាល់ខ្លួនរបស់ខ្ញុំដឹងថា ខ្ញុំបានទទួលប្រាក់យ៉ាងច្រើនកាលពីខែមុន។

តើគាត់អាចពិភាក្សាអំពីបញ្ហានេះជាមួយសមាជិកគ្រួសាររបស់ខ្ញុំដោយគ្មានការអនុញ្ញាតពីខ្ញុំបានដែរឬទេ?

ការអប់រំផ្លែកហិរញ្ញវត្ថុ



ការរៀបចំផលិតផលសមស្រប និងការផ្តល់ជូន

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធានាថា ផលិតផល និងបណ្តាញចែកចាយរបស់ពួកគេត្រូវបានរៀបចំឡើងតាមរបៀបដែលធ្វើយ៉ាងណាមិនធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍អតិថិជនរបស់ខ្លួន។ ពួកគេគិតគូរពីលក្ខណៈអតិថិជនរបស់ខ្លួននៅពេលរៀបចំផលិតផល និងបណ្តាញចែកចាយ។

ការទប់ស្កាត់ការជំពាក់បំណុលច្រើនហួស

ពិតមែនហើយ វាជារឿងធម្មតាទេ។ គ្មានបញ្ហាដូចនេះឡើយ ព្រោះជាសិទ្ធិក្នុងការខ្ចីប្រាក់។ តាមរយៈការទប់ស្កាត់អតិថិជនរបស់ខ្លួនពីការជំពាក់បំណុលច្រើន ធនាគារកំពុងការពារលោកអ្នក។ គោលការណ៍នេះតម្រូវឲ្យសគ្រឹះស្ថានហិរញ្ញវត្ថុចាត់វិធានការដើម្បីធានាថា ប្រាក់កម្ចីត្រូវបានផ្តល់ជូន លុះត្រាតែអ្នកខ្ចីអាចបញ្ជាក់ថា ពួកគេអាចមានលទ្ធភាពសងវិញបានប៉ុណ្ណោះ ហើយប្រាក់កម្ចីនោះមិនធ្វើឲ្យអ្នកខ្ចីមានហានិភ័យក្នុងការជំពាក់បំណុលច្រើនខ្លាំងនោះឡើយ។

តម្លាភាព

លោកអ្នកត្រូវសួរបុគ្គលិកធនាគារសម្រាប់ព័ត៌មានបន្ថែម។ នេះគឺជាសិទ្ធិរបស់លោកអ្នក ហើយគ្រឹះស្ថានហិរញ្ញវត្ថុត្រូវអនុវត្តតាមគោលការណ៍នៃការផ្តល់នូវប្រព័ន្ធគិតថ្លៃសេវាច្បាស់លាស់ និងមានការទទួលខុសត្រូវ។ ម្យ៉ាងវិញទៀត ការគិតថ្លៃសេវា និងលក្ខខណ្ឌដែលទាក់ទងនឹងផលិតផលហិរញ្ញវត្ថុត្រូវសរសេរឲ្យបានច្បាស់ និងទំនាក់ទំនងក្នុងភាសាដែលងាយស្រួលយល់សម្រាប់អតិថិជនទាំងអស់។

ការកំណត់តម្លៃដែលមានការទទួលខុសត្រូវ

សូមសួរអ្នកប្រឹក្សាយោបល់នៅធនាគារដើម្បីទទួលបានព័ត៌មានបន្ថែម។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធានាថា ការគិតថ្លៃសេវា លក្ខខណ្ឌ និងនីតិវិធីរបស់ពួកគេមានតម្លៃសមរម្យសម្រាប់អតិថិជន ទន្ទឹមនឹងការដែលអនុញ្ញាតឲ្យពួកគេធ្វើជាអាជីវកម្មដើម្បីទទួលបានប្រាក់ចំណេញសមរម្យផង។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវខិតខំប្រឹងប្រែងដើម្បីធានាថា ទឹកប្រាក់ដែលជាក់ជាប្រាក់បញ្ញើជាមួយគ្រឹះស្ថានទាំងនេះផ្តល់អត្រាការប្រាក់សមរម្យ។

ការប្រព្រឹត្តិដោយយុត្តិធម៌ និងប្រកបដោយការគោរពចំពោះអតិថិជន


គ្រឹះស្ថានហិរញ្ញវត្ថុមានកាតព្វកិច្ចប្រព្រឹត្តចំពោះអតិថិជនរបស់ខ្លួនដោយយុត្តិធម៌ និងប្រកបដោយការគោរព។ ពួកគេមិនត្រូវធ្វើការរើសអើងគ្រប់ទម្រង់ទាំងអស់។ ពួកគេត្រូវធានាថា មានវិធានការគ្រប់គ្រាន់ដើម្បីស្វែងរក និងដោះស្រាយករណីនៃអំពើពុករលួយ និងអាកប្បកិរិយាបែបគម្លើន ឬបំពានណាមួយលើផ្នែកនៃភ្នាក់ងារ និងបុគ្គលិករបស់ពួកគេ ជាពិសេសនៅពេលផ្តល់ប្រាក់កម្ចី និងការសងបំណុល។

យន្តការដោះស្រាយបណ្តឹង

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវមានយន្តការសម្រាប់ការអន្តរាគមន៍ឲ្យបានទាន់ពេលវេលាក្នុងករណីមានបញ្ហា និងការតវ៉ាពីអតិថិជនរបស់ខ្លួន។ ពួកគេត្រូវប្រើយន្តការទាំងនេះដើម្បីដោះស្រាយបញ្ហាបុគ្គល និងដើម្បីកែលម្អផលិតផល និងសេវាកម្មរបស់ខ្លួន។

ឯកជនភាពទិន្នន័យអតិថិជន

ការសម្ងាត់ទាក់ទងនឹងទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជនត្រូវតែគោរពអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនៃប្រព័ន្ធច្បាប់របស់ប្រទេសនីមួយៗ។ ទិន្នន័យបែបនេះអាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដែលបានកំណត់នៅពេលដែលត្រូវបានផ្តល់ឲ្យ និងត្រូវបានអនុញ្ញាតស្របច្បាប់លុះត្រាតែមានការយល់ព្រមផ្សេងពីនេះជាមួយអតិថិជន។



ចម្លើយចំពោះលំហាត់

ជំនួយក្នុងការបណ្តុះបណ្តាល ច.២.១

កាតពិពណ៌នា

កាតពិពណ៌នាចម្លើយទី១៖

ទម្រង់បែបបទពាក្យសុំបើកគណនី

កាតពិពណ៌នាចម្លើយទី២៖

ភ្នាក់ងារសេវាកម្មអតិថិជន

កាតពិពណ៌នាចម្លើយទី៣៖

ប្រធានសាខា

កាតពិពណ៌នាចម្លើយទី៤៖

បុគ្គលិកធនាគារ

កាតពិពណ៌នាចម្លើយទី៥៖

សន្តិសុខ

កាតពិពណ៌នាចម្លើយទី៦៖

ក្តារព័ត៌មាន

កាតពិពណ៌នាចម្លើយទី៧៖

ធ្នើដាក់តាំងឯកសារ

កាតពិពណ៌នាចម្លើយទី៨៖

បង្គាន់ដៃដកប្រាក់


កាតពិពណ៌នាចម្លើយទី៩៖

មូលប្បទានបត្រ

កាតពិពណ៌នាចម្លើយទី១០៖

បង្គាន់ដៃប្រាក់បញ្ញើ

ជំនួយក្នុងការបណ្តុះបណ្តាល ច.២.៥
ជាមួយនឹងដំណោះស្រាយ



ភាគពិពណ៌នា

ខ្ញុំជាកម្មករកាត់ដេរ។
កាលពីប៉ុន្មានខែមុន ខ្ញុំបានចុះកិច្ចសន្យាខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្បែរនោះដើម្បីយកប្រាក់មកទិញម៉ាស៊ីនបោកគក់។ រាល់ខែខ្ញុំត្រូវបង់រំលោះក្នុងទឹកប្រាក់ដ៏ច្រើន។ ការបង់ប្រាក់ក្នុងចំនួនដ៏ខ្ពស់ដែលខ្ញុំមិនមានប្រាក់ផ្ញើទៅគ្រួសាររបស់ខ្ញុំនៅដើមខែនីមួយៗ ដូចដែលខ្ញុំធ្លាប់ធ្វើមុនពេលមានប្រាក់កម្ចីនេះ។ ខ្ញុំព្រួយបារម្ភយ៉ាងខ្លាំងអំពីសុខភាព និងសុខុមាលភាពរបស់ពួកគាត់។

តើនេះជាការឆបោកឬ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

គោលការណ៍ការពារអតិថិជនត្រូវបានអនុវត្ត

ការរៀបចំផលិតផលសមស្រប និងការផ្តល់ជូន

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធានាថា ផលិតផល និងបណ្តាញចែកចាយរបស់ពួកគេត្រូវបានរៀបចំឡើងតាមរបៀបដែលធ្វើយ៉ាងណាមិនប៉ះពាល់ដល់ផលប្រយោជន៍អតិថិជនរបស់ខ្លួន។
ពួកគេត្រូវគិតគូរពីលក្ខណៈរបស់អតិថិជនរបស់ខ្លួននៅពេលរៀបចំផលិតផល និងបណ្តាញចែកចាយរបស់ពួកគេ។

ភាគពិពណ៌នា

ខ្ញុំបានចុះកិច្ចសន្យាខ្ចីប្រាក់កម្ចីចំនួនពីរជាមួយធនាគាររួចហើយ៖ ប្រាក់កម្ចីមួយសម្រាប់ទិញផ្ទះ ប្រាក់កម្ចីមួយទៀតសម្រាប់ចំណាយក្នុងពិធីសាសនាកាលពីឆ្នាំមុន។

ពេលនេះខ្ញុំចង់ទិញម៉ូតូមួយគ្រឿងដើម្បីខ្ញុំអាចធ្វើដំណើរទៅណាមកណាបានស្រួលជាងមុន។ ធនាគាររបស់ខ្ញុំបដិសេធមិនផ្តល់ប្រាក់កម្ចីទីបីដល់រូបខ្ញុំឡើយ។

តើនេះជារឿងធម្មតាទេ? តើខ្ញុំអាចធ្វើអ្វីបានអំពីបញ្ហានេះ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

គោលការណ៍ការពារអតិថិជនត្រូវបានអនុវត្ត

ការចៀសវាងការជំពាក់បំណុលច្រើនហួសហេតុ

ពិតមែនហើយ វាជារឿងធម្មតាទេ។ គ្មានបញ្ហាដូចនេះឡើយ ព្រោះជាសិទ្ធិក្នុងការខ្ចីប្រាក់។ តាមរយៈការទប់ស្កាត់អតិថិជនរបស់ខ្លួនពីការជំពាក់បំណុលច្រើន ធនាគារកំពុងការពារលោកអ្នក។ គោលការណ៍នេះតម្រូវឲ្យស្ថាប័នហិរញ្ញវត្ថុចាត់វិធានការដើម្បីធានាថា ប្រាក់កម្ចីត្រូវបានផ្តល់ជូន លុះត្រាតែអ្នកខ្ចីអាចបញ្ជាក់ថា ពួកគេអាចមានលទ្ធភាពសងវិញបានប៉ុណ្ណោះ ហើយប្រាក់កម្ចីនោះមិនធ្វើឲ្យអ្នកខ្ចីមានហានិភ័យក្នុងការជំពាក់បំណុលច្រើនខ្លាំងនោះឡើយ។

ភាគពិពណ៌នា

ខ្ញុំខ្ញុំជាអតិថិជនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ។

ខ្ញុំបានព្យាយាមស្វែងយល់អំពីលក្ខខណ្ឌ និងការគិតថ្លៃសេវាដែលទាក់ទងនឹងផលិតផលសន្សំ ប៉ុន្តែខិត្តប័ណ្ណដែលពួកគេបានផ្តល់ឲ្យខ្ញុំគឺមានការសរសេរអក្សរតូចៗពេក ហើយខ្ញុំមិនយល់ពីលក្ខខណ្ឌទាំងអស់ដែលបានប្រើនោះទេ។

តើខ្ញុំត្រូវធ្វើអ្វី?

ការអប់រំផ្នែកហិរញ្ញវត្ថុ

គោលការណ៍ការពារអតិថិជនត្រូវបានអនុវត្ត

តម្លាភាព

លោកអ្នកត្រូវស្នើរបុគ្គលិកធនាគារសម្រាប់ព័ត៌មានបន្ថែម។ នេះគឺជាសិទ្ធិរបស់លោកអ្នក ហើយគ្រឹះស្ថានហិរញ្ញវត្ថុត្រូវអនុវត្តតាមគោលការណ៍នៃការផ្តល់នូវប្រព័ន្ធគិតថ្លៃសេវាច្បាស់លាស់ និងមានការទទួលខុសត្រូវ។ ម្យ៉ាងវិញទៀត ការគិតថ្លៃសេវា និងលក្ខខណ្ឌដែលទាក់ទងនឹងផលិតផលហិរញ្ញវត្ថុត្រូវសរសេរឲ្យបានច្បាស់ និងទំនាក់ទំនងក្នុងភាសាដែលងាយស្រួលយល់សម្រាប់អតិថិជនទាំងអស់

ភាគពិពណ៌នា

ខ្ញុំមានគណនីចរន្ត និងគណនីសន្សំជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ។

ខ្ញុំមិនសប្បាយចិត្តឡើយ ព្រោះខ្ញុំត្រូវបង់ថ្លៃសេវាគ្រប់គ្រងខ្ពស់សម្រាប់គណនីចរន្តរបស់ខ្ញុំ ចំណែកគណនីបញ្ញើរបស់ខ្ញុំបង់អត្រាការប្រាក់ទាបបំផុត។

នេះហាក់ដូចជាអយុត្តិធម៌។ តើនេះជាការធម្មតាឬ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

គោលការណ៍ការពារអតិថិជនត្រូវបានអនុវត្ត

ការកំណត់តម្លៃដែលមានការទទួលខុសត្រូវ

សូមសួរអ្នកប្រឹក្សាយោបល់នៅធនាគារដើម្បីទទួលបានព័ត៌មានបន្ថែម។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធានាថា ការគិតថ្លៃសេវា លក្ខខណ្ឌ និងនីតិវិធីរបស់ពួកគេមានតម្លៃសមរម្យសម្រាប់អតិថិជន ទន្ទឹមនឹងការដែលអនុញ្ញាតឲ្យពួកគេធ្វើជាអាជីវកម្មដើម្បីទទួលបានប្រាក់ចំណេញសមរម្យផង។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវខិតខំប្រឹងប្រែងដើម្បីធានាថា ទឹកប្រាក់ដែលដាក់ជាប្រាក់បញ្ញើជាមួយគ្រឹះស្ថានទាំងនេះផ្តល់អត្រាការប្រាក់សមរម្យ។

ភាគពិពណ៌នា

ខ្ញុំខ្ញុំជំពាក់បំណុលច្រើនខ្លាំងណាស់ ហើយមិនអាចមានលទ្ធភាពសងប្រាក់កម្ចីបានតទៅទៀតទេ ព្រោះខ្ញុំទើបតែបាត់បង់ការងារ។

ខ្ញុំបារម្ភថា ធនាគារអាចនឹងធ្វើអ្វីៗមិនខាន ប្រសិនបើមិនអាចសងប្រាក់នោះ។

តើគេអាចមកកាន់ផ្ទះរបស់ខ្ញុំ ហើយរឹបអូសយករបស់របរបស់ខ្ញុំ ឬរបស់របរបស់ក្រួសារខ្ញុំ ឬអ្វីក្រក់ជាងនេះទៅទៀតឬទេ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

គោលការណ៍ការពារអតិថិជនត្រូវបានអនុវត្ត

ការប្រព្រឹត្តដោយយុត្តិធម៌ និងប្រកបដោយការគោរពចំពោះអតិថិជន

គ្រឹះស្ថានហិរញ្ញវត្ថុមានកាតព្វកិច្ចប្រព្រឹត្តចំពោះអតិថិជនរបស់ខ្លួនដោយយុត្តិធម៌ និងប្រកបដោយការគោរព។ ពួកគេមិនត្រូវធ្វើការរើសអើងគ្រប់ទម្រង់ទាំងអស់។ ពួកគេត្រូវធានាថា មានវិធានការគ្រប់គ្រាន់ដើម្បីស្វែងរក និងដោះស្រាយករណីនៃអំពើពុករលួយ និងអាកប្បកិរិយាបែបគម្លើន ឬបំពានណាមួយលើផ្នែកនៃភ្នាក់ងារ និងបុគ្គលិករបស់ពួកគេ ជាពិសេសនៅពេលផ្តល់ប្រាក់កម្ចី និងការសងបំណុល។ខ្លាំងនោះឡើយ។

ស្វែងយល់ពីអ្នកផ្តល់សេវាហិរញ្ញវត្ថុ ដើម្បីជ្រើសរើសអ្នកសម្រាប់តំណាងអតិថិជន

ភាពពិពណ៌នា

ខ្ញុំមិនយល់ស្របទាល់តែសោះជាមួយធនាគាររបស់ខ្ញុំអំពីបញ្ហាដែលបានកើតឡើង។ តើខ្ញុំអាចងាកទៅរកអ្នកណាវិញ?

តើមានឧទ្ធរណ៍ណាម្ខាក់នៅធនាគារដែលអាចជួយខ្ញុំបានទេ?

ការអប់រំផ្នែកហិរញ្ញវត្ថុ

គោលការណ៍ការពារអតិថិជនត្រូវបានអនុវត្ត

យន្តការដោះស្រាយបណ្តឹង

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវមានយន្តការសម្រាប់ការអន្តរាគមន៍ឲ្យបានទាន់ពេលវេលាក្នុងករណីមានបញ្ហា និងការតវ៉ាពីអតិថិជនរបស់ខ្លួន។ ពួកគេត្រូវប្រើយន្តការទាំងនេះដើម្បីដោះស្រាយបញ្ហាបុគ្គលនិងដើម្បីកែលម្អផលិតផល និងសេវាកម្មរបស់ខ្លួន។

ភាពពិពណ៌នា

កាតពិពណ៌នា
បុគ្គលិកធនាគារដែលមើលតាមដានគណនីចរន្តផ្ទាល់ខ្លួនរបស់ខ្ញុំដឹងថា ខ្ញុំបានទទួលប្រាក់យ៉ាងច្រើនកាលពីខែមុន។

តើគាត់អាចពិភាក្សាអំពីបញ្ហានេះជាមួយសមាជិកគ្រួសាររបស់ខ្ញុំដោយគ្មានការអនុញ្ញាតពីខ្ញុំបានដែរឬទេ?


ការអប់រំផ្នែកហិរញ្ញវត្ថុ

គោលការណ៍ការពារអតិថិជនត្រូវបានអនុវត្ត

ឯកជនភាពទិន្នន័យអតិថិជន

ការសម្ងាត់ទាក់ទងនឹងទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជនត្រូវតែគោរពអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនៃប្រព័ន្ធច្បាប់របស់ប្រទេសនីមួយៗ។ ទិន្នន័យបែបនេះអាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដែលបានកំណត់នៅពេលដែលត្រូវបានផ្តល់ឲ្យ និងត្រូវបានអនុញ្ញាតស្របច្បាប់ លុះត្រាតែមានការយល់ព្រមផ្សេងពីនេះជាមួយអតិថិជន។





ក្រ

ការគ្រប់គ្រងហ្គានិភ័យ និងការធានារ៉ាប់រង

FINANCIAL QUIZ EDUCATION

ឆ១. តើប្រយោគខាងក្រោមមួយណាដែលមិនទាក់ទងនឹងហានិភ័យ?

- ☐ **ក.** ធ្លាក់ចូលទៅក្នុងការក្សេីយធន
- ☐ **ខ.** សោកស្តាយខ្លាំង
- ☐ **គ.** មានគ្រោះថ្នាក់ការងារ
- ☐ **ឃ.** ក្លាយជាជនរងគ្រោះដោយសារអគ្គិភ័យ

ឆ២. បញ្ជីខាងក្រោមបង្ហាញពីវិធានការការពារប្រឆាំងនឹងហានិភ័យ លើកលែងតែមួយ តើមួយណា?

- ☐ **ក.** មានប្រាក់សន្សំ
- ☐ **ខ.** ការទិញធានារ៉ាប់រង
- ☐ **គ.** ផ្ញើប្រាក់
- ☐ **ឃ.** ប្រើមុង

ឆ៣. ការធានារ៉ាប់រងផ្តល់នូវការការពារប្រឆាំងនឹងលទ្ធភាពនៃការបាត់បង់

- ☐ **ក.** ពិត
- ☐ **ខ.** មិនពិត

ឆ៤. តើការលើកលែងគឺជាអ្វី?

- ☐ **ក.** ឯកសារដែលផ្តល់ឲ្យអ្នកកាន់ប័ណ្ណធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងដែលបញ្ជាក់ពីលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រង
- ☐ **ខ.** លក្ខខណ្ឌជាក់លាក់ កាលៈទេសៈ ឬស្ថានភាពដែលធម្មតាត្រូវបានលើកឡើងនៅក្នុងកិច្ចសន្យាថាមិនត្រូវបានគ្របដណ្តប់
- ☐ **គ.** សំណើសម្រាប់ការទូទាត់ចំពោះការខាតបង់ដែលត្រូវបានគ្របដណ្តប់ដោយគោលនយោបាយធានារ៉ាប់រង

ខ ៖ ១ឆ ‘ ង ៖ ២ឆ ‘ ង ៖ ៣ឆ ‘ ខ ៖ ៤ឆ ៖ ការឆ្លើយ

១. គ្រប់គ្រងហានិភ័យ

ហានិភ័យគឺជាគ្រោះថ្នាក់ដែលអាចមើលឃើញទុកជាមុនច្រើនឬតិចដែលអាចមានផលប៉ះពាល់ដល់ខ្លួនយើង ឬដល់ក្រុមគ្រួសាររបស់យើង។

ហានិភ័យមានភាពដែលអាចកើតមានខុសៗគ្នាដែលអាចកើតឡើង ហើយផលវិបាករបស់វាខុសគ្នាពីស្រាលទៅកម្រិតធ្ងន់ធ្ងរខ្លាំង អាស្រ័យលើលក្ខណៈនៃហានិភ័យ និងលក្ខណៈរបស់មនុស្ស ឬទីកន្លែងដែលរងផលប៉ះ ពាល់។

និយមន័យ

គ្រោះថ្នាក់គឺជាស្ថានភាពដែលអាចមានភាពកើតឡើង ឬការគំរាមកំហែងដែលរឿងរ៉ាវអ្វីមួយដែលមិនជាទីពេញចិត្ត ឬមិនជាទីសប្បាយចិត្តកើតឡើង។


ជំនួយក្នុងការបណ្តុះបណ្តាលឆ.១.១

ភាគហានិភ័យ





ជំងឺ



មរណៈភាព



អគ្គភ័យ



ដោយការគិតគូរពីហានិភ័យដែលលោកអ្នក និងគ្រួសាររបស់លោកអ្នកអាចប្រឈម សូមសរសេរអំពីហានិភ័យខ្លះៗនៅក្នុងប្រអប់ដោយយោងទៅតាមភាពញឹកញាប់ (ប្រូបាប៊ីលីតេដែលកើតឡើង) និងការចំណាយ។ ឧទាហរណ៍ ការស្លាប់គឺជារឿងដែលកើតឡើងកម្រណាស់ (តែមួយម្តង!) ប៉ុន្តែ វាមានការចំណាយខ្ពស់ណាស់សម្រាប់ក្រុមគ្រួសារ។

		ការចំណាយ		
		មិនសូវសំខាន់	សំខាន់ល្មម	សំខាន់ខ្លាំង
ភាពញឹកញាប់	កម្រ			ឧទាហរណ៍៖ មរណភាព
	មធ្យម			
	ញឹកញាប់			

ដូចដែលលោកអ្នកអាចឃើញហើយ ហានិភ័យផ្សេងៗទំនងជាមានច្រើន ឬតិច ហើយអាចមានផលវិបាកផ្សេងៗគ្នា ពីតិចតួចទៅធ្ងន់ធ្ងរខ្លាំង អាស្រ័យលើលក្ខណៈនៃហានិភ័យ និងលក្ខណៈរបស់មនុស្ស ឬទីកន្លែងដែលរងផលប៉ះពាល់។

សូមចងចាំ

មានវិធានការការពារផ្សេងៗគ្នាដែលលោកអ្នកអាចអនុវត្តដើម្បីការពារខ្លួនលោកអ្នក៖

- ការលុបបំបាត់/ជៀសវាងហានិភ័យ (ឧ. ដោយការជ្រុសធ្មេញរបស់លោកអ្នក)
- ការផ្ទេរហានិភ័យទៅឲ្យភាគីទីបី (សមាគមដែលមានផលប្រយោជន៍ទៅវិញទៅមក ឬក្រុមហ៊ុនធានារ៉ាប់រង)
- ព្យាករពីផលប៉ះពាល់ដោយសារហានិភ័យ និងត្រៀមខ្លួនទប់ទល់ (ឧទាហរណ៍ ដោយការសន្សំសំចៃ)



មានវិធានការផ្សេងៗគ្នាដែលលោកអ្នកអាចអនុវត្តដើម្បីការពារខ្លួនលោកអ្នក និងក្រុមគ្រួសាររបស់លោកអ្នក ពីហានិភ័យនេះ។ សូមសរសេរវិធានការទាំងនេះនៅក្រោមឆត្រ!

ជំនួយក្នុងការបណ្តុះបណ្តាល ឆ.១.២

ឆត្ររបស់ខ្ញុំ



សារសំខាន់

- ហានិភ័យកើតមាននៅក្នុងជីវិត
- ហានិភ័យមួយចំនួនអាចត្រូវបានគេមើលឃើញទុកជាមុន ហើយលោកអ្នកត្រូវចាត់វិធានការដើម្បីធ្វើយ៉ាងណាឲ្យផលប៉ះពាល់របស់វាកាន់តែទាប
- វាចាំបាច់ណាស់ក្នុងការមានមូលនិធិគ្រាបន្ទាន់ ដូច្នេះ ការសង្គ្រោះបន្ទាន់តិចតួចមិនប៉ះពាល់ដល់លោកអ្នកខ្លាំងពេកនោះទេ។ ការសន្សំប្រាក់គឺជាការសំខាន់ណាស់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់លោកអ្នក
- សម្រាប់ការសង្គ្រោះបន្ទាន់ផ្សេងទៀត ការសន្សំប្រាក់ផ្ទាល់ខ្លួនប្រហែលជាមិនគ្រប់គ្រាន់ទេ៖ លោកអ្នកត្រូវប្រើប្រាស់ការធានារ៉ាប់រង
- លោកអ្នកត្រូវចាត់វិធានការដើម្បីការពារខ្លួនលោកអ្នក និងក្រុមគ្រួសាររបស់លោកអ្នក

២. គន្លឹះក្នុងការបង្កើតមូលនិធិគ្រោះអាសន្នរបស់លោកអ្នក

- ចាប់ផ្តើមលៃទុកសាច់ប្រាក់មួយឡែកសម្រាប់ភាពអាសន្នផ្ទាល់ខ្លួនជារៀងរាល់ថ្ងៃ ឬប្រចាំសប្តាហ៍ បើទោះបីជាក្នុងចំនួនតិចតួចក៏ដោយ។ បន្តិចម្តងៗ សាច់ប្រាក់របស់លោកអ្នកនឹងកើនឡើង
- រក្សាទុកសាច់ប្រាក់របស់លោកអ្នកនៅកន្លែងដែលមានសុវត្ថិភាព យកល្អនៅខាងក្រៅផ្ទះ ដូច្នេះគ្មាននរណាម្នាក់អាចចូលទៅយកបាននោះទេ។ ប្រសិនបើអាចធ្វើទៅបាន ត្រូវបើកគណនីសន្សំ អាចជាគំនិតដ៏ល្អផងដែរ
- រក្សាទុកចំនួនសាច់ប្រាក់ផ្សេងគ្នា អាស្រ័យលើចំនួនសាច់ប្រាកក់ដែលលោកអ្នកត្រូវបានបង់ក្នុងកាលៈទេសៈជាក់លាក់ណាមួយ។ វាមិនចាំបាច់ទេដែលលោកអ្នកតែងតែសន្សំប្រាក់ក្នុងចំនួនដដែលនោះ
- ធ្វើអ្វីគ្រប់យ៉ាងដែលលោកអ្នកអាចធ្វើបានដើម្បីកាត់បន្ថយការចំណាយដែលមិនចាំបាច់។ មនុស្សគ្រប់រូបអាចសន្សំប្រាក់បាន ទោះបីជាពួកគេរកចំណូលបានតិចតួចក៏ដោយ ប្រសិនបើចំនួនតិចតួចក្តី។



ករណីសិក្សាទី ១

មូលនិធិគ្រោះអាសន្នរបស់សុភាព

សុភាពបានសម្រេចចិត្តរៀបចំសាច់ប្រាក់គ្រោះអាសន្នរបស់នាង។ ដើម្បីធ្វើដូច្នេះបាន នាងបានសម្រេចចិត្តបង្កើតតារាងមួយដែលបង្ហាញពីប្រាក់ចំណូលរបស់នាងទាំងអស់ក្នុងកំឡុងឆ្នាំកន្លង។

តារាងមានរាងដូចនេះ៖

ប្រាក់ចំណូលរបស់គ្រួសារសុភាពក្នុងមួយឆ្នាំ

ខែ	ដុល្លារ
មករា	២៧០
កុម្ភៈ	២៧០
មីនា	២៩០
មេសា	២៩០
ឧសភា	៣០០
មិថុនា	២៧០
កក្កដា	២៧០
សីហា	២៧០
កញ្ញា	៣០០
តុលា	៣១០
វិច្ឆិកា	២៧០
ធ្នូ	៣១០
	៣៤២០


សំណួរអំពី សុភាព និងក្រុមគ្រួសាររបស់នាង៖

- តើចំនួនទឹកប្រាក់សរុបដែលគ្រួសាររបស់ សុភាព រកបានចំនួនប៉ុន្មានក្នុងរយៈពេល១២ ខែ (គឺតថា អាចមានប្រាក់ចំណូលថេរ និងអថេរ)?
- តើប្រាក់ចំណូលប្រចាំខែជាមធ្យមរបស់គ្រួសារនេប៉ុន្មាន?
- តើចំនួនទឹកប្រាក់សរុបប៉ុន្មានដែលពួកគេត្រូវការដើម្បីលៃទុកដោយឡែកនៅក្នុងមូលនិធិគ្រោះអាសន្ន?

សូមចងចាំ

មូលនិធិគ្រាអាសន្នរបស់លោកអ្នកមានគោលបំណងរ៉ាប់រងលើការចំណាយសម្រាប់ការសង្គ្រោះបន្ទាន់តិចតួច។មនុស្សភាគច្រើននឹងមិនអាចទុកប្រាក់មួយឡែកសម្រាប់គ្រាអាសន្នធំៗ ដូចជា ការព្យាបាលជំងឺរយៈពេលវែង ឬការស្លាប់នៅក្នុងគ្រួសារនោះទេ។

ប្រសិនបើលោកអ្នកមានគម្រោងសម្រាប់គ្រាអាសន្ន លោកអ្នកទំនងជានឹងសម្រេចឲ្យបាននូវគោលដៅរបស់លោកអ្នក។ ប្រសិនបើលោកអ្នកមានមូលនិធិគ្រាអាសន្ន នោះលោកអ្នកនឹងជៀសវាងការដកប្រាក់សន្សំដែលលោកអ្នកបានសន្សំសម្រាប់ការចាប់ផ្តើមអាជីវកម្ម ការកែលម្អគេហដ្ឋាន ការវិនិយោគលើការអប់រំ (របស់លោកអ្នក ឬកូនៗរបស់លោកអ្នក)។ ហើយលោកអ្នកនឹងជៀសវាងបាននូវការខ្វី និងការបង់អត្រាការប្រាក់ខ្ពស់ជាដើម។



៣. ស្វែងយល់ពីគោលការណ៍ធានារ៉ាប់រងរបស់លោកអ្នក

ការធានារ៉ាប់រង៖ តើគំនិតនេះល្អទេ?

គោលការណ៍នៃការធានារ៉ាប់រងគឺដើម្បីការពារខ្លួនយើងពីហានិភ័យដែលយើងអាចប្រឈម (គ្រោះថ្នាក់ ជំងឺ ចោរកម្មជាដើម)។ល។ ហើយលៃសាច់ប្រាក់មួយចំនួនដោយឡែកដើម្បីទទួលបានសំណងនៅថ្ងៃដែលហេតុការណ៍នេះនឹងកើតឡើង។

និយមន័យ

*ការធានារ៉ាប់រង*គឺជាទម្រង់នៃការការពារសម្រាប់អ្នកដែលបានទិញកិច្ចសន្យាធានារ៉ាប់រងក្នុងទម្រង់ជាសំណងរូបិយវត្ថុដោយសារការកើតមានឧប្បត្តិហេតុ ឬព្រឹត្តិការណ៍ណាមួយដែលធានារ៉ាប់រងដោយការធានារ៉ាប់រង។

សមាគមផ្តល់ផលប្រយោជន៍ទៅវិញទៅមក៖ សមាគមដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកគឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ ដែលជាកម្មសិទ្ធិសមូហភាពដោយសមាជិករបស់ខ្លួន។ អង្គការនេះផ្តល់ការធានារ៉ាប់រងដល់សមាជិករបស់ខ្លួន និងធ្វើសកម្មភាពដើម្បីផលប្រយោជន៍ល្អបំផុតរបស់សមាជិក។

ក្រុមហ៊ុនធានារ៉ាប់រង៖ ក្រុមហ៊ុនធានារ៉ាប់រងគឺជាអាជីវកម្មដែលផ្តល់សេវាកម្មធានារ៉ាប់រង។ គោលដៅរបស់ក្រុមហ៊ុនគឺដើម្បីរកប្រាក់ចំណេញ។

ករណីសិក្សាទី២

ប៉ូវ៉ានរបួសដៃរបស់គាត់



ប៉ូវ៉ាន បានធ្វើការនៅក្នុងឃ្លាំងនេះជិតពីរឆ្នាំមកហើយមកទល់នឹងពេលនេះ។ ខណៈពេលកំពុងបើកប្រអប់មួយជាមួយឧបករណ៍កាត់ គាត់បានរងរបួសម្រាមដៃដោយចៃដន្យ។ គាត់បានប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីឃាត់ការហូរឈាម និងចង់រុំមុខរបួស។ គាត់ព្យាយាមមិនអើពើនឹងការឈឺចាប់នេះឡើយ ប៉ុន្តែ នៅល្ងាចនោះនៅបន្ទប់តូចរបស់គាត់កន្លែងដែលគាត់ដេក គាត់ដឹងច្បាស់ថា ម្រាមដៃរបស់គាត់មានសភាពហើមយ៉ាងខ្លាំង។ នៅថ្ងៃបន្ទាប់ ម្រាមដៃរបស់គាត់ឈឺចាប់ខ្លាំង ប៉ុន្តែ គាត់បានទៅធ្វើការតាមវេនរបស់គាត់ជាធម្មតា។ នេះជាលើកទីមួយហើយដែលមានរឿងបែបនេះកើតឡើងចំពោះគាត់។

នៅពេលសម្រាកទទួលទានអាហារថ្ងៃត្រង់ ប៉ូវ៉ាន មានការឈឺចាប់ជាខ្លាំង ហើយបានប្រាប់មិត្តរួមការងារថ្មីរបស់គាត់ ឈ្មោះ វិបុល ថា គាត់នឹងទៅគ្លីនិកនៅរោងចក្រ។ លោក វិបុល មានការភ្ញាក់ផ្អើលដោយមិនដឹងថាកម្មកររោងចក្រមានជម្រើសនេះទេ។ គាត់ធ្វើឲ្យមានការចាប់អារម្មណ៍ដល់កម្មករជាច្រើនប្រសិនបើចៀសវាងទៅគ្លីនិករោងចក្រ ឬនិយាយអ្វីជាមួយថៅកែព្រោះខ្លាចពួកគេខឹងសម្បារ។ ប៉ូវ៉ាន បានពន្យល់ប្រាប់វិបុលថា កម្មករនៅរោងចក្រនេះមានលទ្ធភាពទទួលបានសេវាថែទាំសុខភាពបឋមនៅក្នុងរោងចក្រដែលបើកដំណើរការក្នុងពេលម៉ោងធ្វើការ។ គាត់បានពន្យល់ប្រាប់ វិបុល ថា គាត់មានសិទ្ធិទៅកាន់គ្លីនិក និងពិនិត្យ ប្រសិនបើចាំបាច់។ ក្នុងករណីគាត់មានបញ្ហាធ្ងន់ធ្ងរជាងនេះ បុគ្គលិកពេទ្យអាចបញ្ជូនគាត់ទៅកាន់វេជ្ជបណ្ឌិតឯកទេស ឬមន្ទីរពេទ្យដោយមិនគិតថ្លៃសម្រាប់គាត់ ព្រោះថា ពួកគេនឹងត្រូវបានធានារ៉ាប់រងដោយរដ្ឋ។ បើក្នុងករណីចាំបាច់ គាត់ក៏នឹងមានសិទ្ធិឈប់ទទួលបានការឈប់សម្រាកពេលមានជំងឺផងដែរ។ ទាំងអស់នេះត្រូវបានសរសេរនៅក្នុងកិច្ចសន្យារបស់គាត់។

ករណីសិក្សាទី ៣

ជា ម្ចាស់ប្រុសរបស់ ណារី រងរបួសជើង



ជួនកាល ជា ធ្វើការនៅហាងជួសជុលរថយន្តជិតផ្ទះរបស់គេ។ ថ្ងៃមួយ នៅកន្លែងធ្វើការ ជា បានជ្រុះឧបករណ៍ដ៏ធ្ងន់មួយមកលើជើង ហើយបែកម្រាមជើង។ គាត់បានប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីឃាត់ការហូរឈាម និងចង់រុំមុខរបួស។ គាត់ព្យាយាមមិនអើពើនឹងការឈឺចាប់នេះទេ ប៉ុន្តែ នៅល្ងាចនោះ ម្រាមជើងរបស់គាត់បានហើមយ៉ាងខ្លាំង។ នៅថ្ងៃបន្ទាប់ គាត់បានទៅធ្វើការជាធម្មតា ប៉ុន្តែ មានការឈឺចាប់យ៉ាងខ្លាំង។ គាត់មិនបាននិយាយអ្វីទៅកាន់ម្ចាស់ហាងទេ ព្រោះគាត់ខ្លាចបាត់បង់ឱកាសការងារនេះ ពេលខ្លះពេលមានការងារច្រើននៅហាង។ គាត់ក៏បារម្ភដែរថា បើគាត់ទៅមន្ទីរពេទ្យ គាត់មិនអាចមានលទ្ធភាពបង់ថ្លៃថតកាំរស្មីអ៊ិចបង់រុំរបួស និងថ្នាំពេទ្យបានទេ។ គាត់មានការព្រួយបារម្ភ។ តើនឹងមានអ្វីកើតឡើងប្រសិនបើគាត់ត្រូវការថ្នាំពេទ្យដែលមានតម្លៃថ្លៃ ឬត្រូវចំណាយក្នុងការទៅជួបគ្រូពេទ្យទៀតនោះ? តើគាត់គួរធ្វើអ្វី? មិត្តរួមការងារម្នាក់មកពីហាងជួសជុលបានប្រាប់គាត់ថា ហាងជួសជុលនេះមិនបានចុះបញ្ជីជាមួយបេឡាជាតិរបបសន្តិសុខសង្គមទេ ហើយ ជា មិនដែលបានទទួលប័ណ្ណ ប.ស.ស.ទេ ដោយសារគាត់ទើបតែចាប់ផ្តើមធ្វើការ។ ដោយសារគាត់មិនបានដឹងពីគោលនយោបាយធានារ៉ាប់រង គាត់បានសុំខ្ចីប្រាក់ណាខ្លះ ហើយគាត់អាចមានលទ្ធភាពទៅរកការព្យាបាល។ គាត់ចង់ជៀសវាងការខ្ចីប្រាក់ប្រសិនបើមានរឿងហេតុស្រដៀងគ្នានេះកើតឡើងម្តងទៀត។

⚠ **សំខាន់ៈ** ពេលខ្លះភាពតានតឹងរបស់យើងអាចមានឥទ្ធិពលលើរាងកាយរបស់យើង។ ប្រសិនបើការគ្រប់គ្រងលុយកាក់ធ្វើឲ្យលោកអ្នកព្រួយបារម្ភ វាអាចបណ្តាលឲ្យមានបញ្ហាសុខភាពរាងកាយបន្ថែមទៀត។


ជំនួយក្នុងការបណ្តុះបណ្តាល ឆ.២.១

ល្បែងប្រៀប Treasure Pot Game

TREASURE POT GAME

៣ មុខ







ថ្នាំពេទ្យ

ការអប់រំផ្នែកហិរញ្ញវត្ថុ

TREASURE POT GAME

៧ មុខ







មន្ទីរពេទ្យ

ការអប់រំផ្នែកហិរញ្ញវត្ថុ

TREASURE POT GAME







សុខភាពល្អ

ការអប់រំផ្នែកហិរញ្ញវត្ថុ

TREASURE POT GAME

៤ មុខ







វេជ្ជបណ្ឌិត

ការអប់រំផ្នែកហិរញ្ញវត្ថុ

ការលេងល្បែង
THE TREASURE POT

លោកអ្នកមិនដឹងថា នៅពេលណា ឬប្រាក់ប៉ុន្មានដែលលោកអ្នកត្រូវចំណាយសម្រាប់សុខភាពរបស់លោកអ្នកនោះឡើយ។ ពេលខ្លះការចំណាយលើសុខភាពមានទំហំទឹកប្រាក់ច្រើនណាស់ ដែលវាហួសពីសមត្ថភាពហិរញ្ញវត្ថុរបស់យើង។ នេះជាហេតុផលដែលវាមានសារៈសំខាន់ក្នុងការប្រមូលផ្តុំនូវហានិភ័យតាមរយៈការទិញធានារ៉ាប់រង។

អាថ៌កំបាំងនៃការប្រមូលផ្តុំហានិភ័យគឺស្ថិតនៅលើការពិតដែលថាយើងទាំងអស់គ្នានឹងរួមចំណែកជាមួយធនធានរបស់យើងមួយផ្នែកចំពោះក្អមរួម។ យើងមិនចាំបាច់ដកប្រាក់ពីក្អមនេះអស់ក្នុងពេលតែមួយទេ។ ប៉ុន្តែ ការធានារ៉ាប់រងអាចដំណើរការបានលុះត្រាតែក្អមទាំងអស់រួមចំណែកទាំងអស់គ្នា។

លោកអ្នកត្រូវបង់ប្រាក់ជាមុនដើម្បីប្រាកដថា អាចទទួលបានសេវាថែទាំសុខភាព ដែលគ្របដណ្តប់ដោយការធានារ៉ាប់រង។ វិសាលភាពនៃសេវាថែទាំសុខភាពដែលលោកអ្នកអាចទទួលបានគឺអាស្រ័យលើកម្រិតនៃការរួមចំណែករបស់អ្នក។ លោកអ្នករួមចំណែកកាន់តែច្រើន លោកអ្នកទទួលបានសេវាកម្មកាន់តែច្រើន។

សារសំខាន់



- ការធានារ៉ាប់រង៖ ជាឧបករណ៍សម្រាប់រក្សាទុកប្រាក់ចំណូល និងការគាំពារសង្គម
- ការធានារ៉ាប់រងគឺដើម្បីទប់ស្កាត់ហានិភ័យ
- ការធានារ៉ាប់រង៖ ការប្រមូលផ្តុំហានិភ័យ

ការយកចិត្តទុកដាក់៖ កម្មករដែលធ្វើការឲ្យសហគ្រាសផ្លូវការ (សហគ្រាសដែលបានចុះបញ្ជីជាមួយរដ្ឋ ហើយដែលបង់ពន្ធ) និងទទួលបានប្រាក់ខែពីនិយោជករបស់ពួកគេ ដែលជារឿយៗត្រូវបានធានារ៉ាប់រងដោយការធានារ៉ាប់រង។ ប៉ុន្តែពួកគេច្រើនតែមិនដឹងថាវាការធានារ៉ាប់រងដោយរបៀបណា និងរបៀបប្រើប្រាស់វាយ៉ាងដូចម្តេចនោះ។ យន្តការនិងលក្ខខណ្ឌនៃការធានារ៉ាប់រងដែលត្រូវបានប្រើប្រាស់អាចមានភាពស្មុគស្មាញ ដូច្នេះវាជាការសំខាន់ក្នុងការមានទំនុកចិត្តដោយធ្វើការសួរសំណួរ។

សូមចងចាំ

ចំណេះដឹងគឺជាសិទ្ធិអំណាច។ លោកអ្នកត្រូវដឹងថា ការធានារ៉ាប់រងគឺជាអ្វី (ហេតុការណ៍ដែលគ្របដណ្តប់ ការបង់ប្រាក់បុព្វលាភ របៀបធ្វើការទាមទារសំណង)។ សូមក្សាបណ្ណធានារ៉ាប់រងរបស់លោកអ្នកជាប់ជាមួយលោកអ្នកជានិច្ច ប្រសិនបើលោកអ្នកមានបណ្ណនេះ។




៤. ប្រើប្រាស់គោលនយោបាយធានារ៉ាប់រងរបស់លោកអ្នក

មនុស្សប្រឈមនឹងហានិភ័យផ្សេងៗគ្នាជាច្រើនក្នុងដំណើរជីវិតរបស់ខ្លួន ហើយរយៈពេលនីមួយៗនៃជីវិតរបស់ពួកគេកើតមានហានិភ័យផ្សេងៗគ្នា។ ហានិភ័យខ្លះមានលក្ខណៈទូទៅ ហើយអាចកើតឡើងចំពោះមនុស្សគ្រប់រូប។ ហានិភ័យផ្សេងទៀតអាចជាក់លាក់ចំពោះប្រភេទមនុស្ស។

ជំនួយក្នុងការបណ្តុះបណ្តាល ឆ.៣.១ ភាគហានិភ័យ













សំណួរ

- តើលោកអ្នកមានគោលនយោបាយធានារ៉ាប់រងទេ? បើមិនមិនមាន តើលោកអ្នកចង់មានដែរឬទេ?

☐ បាទ/ចាស ☐ ទេ

- តើលោកអ្នកដឹងពីលក្ខខណ្ឌធានារ៉ាប់រងសំខាន់ៗឬទេ?

☐ បាទ/ចាស ☐ ទេ

ចូរពិនិត្យមើលពាក្យគន្លឹះ និងនិយមន័យ

លក្ខខណ្ឌធានារ៉ាប់រងជាមូលដ្ឋាន	
សំណង ឬការទូទាត់	ចំនួនទឹកប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងបង់ទៅឲ្យអ្នកដែលត្រូវបានធានា នៅពេលដែលហេតុការណ៍កើតឡើងចំពោះអ្នកដែលត្រូវបានធានារ៉ាប់រង (ជារឿយៗសំដៅដល់ហានិភ័យ៖ គ្រោះថ្នាក់ អគ្គិភ័យ ជំងឺតម្កាត់ជាដើម។ល។ បានកើតឡើងដោយធ្វើការដាក់ជូននូវការទាមទារសំណងដែលមានសុពលភាព
គោលនយោបាយធានារ៉ាប់រង	កិច្ចព្រមព្រៀងរវាងអ្នកដែលត្រូវបានធានារ៉ាប់រង (អតិថិជន) និងក្រុមហ៊ុនធានារ៉ាប់រង។ គោលនយោបាយធានារ៉ាប់រងនេះកំណត់នូវលក្ខខណ្ឌ រយៈពេល ហានិភ័យដែលត្រូវបានធានា និងការមិនរាប់បញ្ចូល។
បុព្វលាភ	តម្លៃ ឬការចំណាយលើគោលនយោបាយធានារ៉ាប់រង ជារឿយៗបែងចែកទៅជាការបង់ប្រចាំខែ ឬប្រចាំត្រីមាស
អ្នកត្រូវធានារ៉ាប់រង (បុគ្គល) / សមាជិក / អ្នកទទួលផល	បុគ្គលដែលទទួលការទូទាត់ប្រាក់ធានារ៉ាប់រងនៅពេលដែលហានិភ័យត្រូវបានគ្របដណ្តប់ដោយគោលនយោបាយធានារ៉ាប់រង
ការទាមទារសំណង	ស្នើសុំសំណងបន្ទាប់ពីការខាតបង់ដែលគ្របដណ្តប់ដោយគោលនយោបាយធានារ៉ាប់រង
ប័ណ្ណធានារ៉ាប់រង	ប័ណ្ណ ដែលចេញដោយក្រុមហ៊ុនផ្តល់សេវាធានារ៉ាប់រងជាភស្តុតាងដែលបញ្ជាក់ថា អ្នកកាន់ប័ណ្ណធានារ៉ាប់រងបានបង់ប្រាក់សម្រាប់បុព្វលាភ។

ដើម្បីធ្វើការទាមទារសំណងប្រកបដោយជោគជ័យ លោកអ្នកត្រូវអនុវត្តតាមជំហានមួយចំនួន។ សូមចងចាំថា លោកអ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង ហើយធ្វើឯកសារចាំបាច់ទាំងអស់នេះ។



ជំនួយក្នុងការបណ្តុះបណ្តាល ឆ.៣.២

ជំណាក់កាលនៃការទាមទារសំណងធានារ៉ាប់រង

ជំណាក់កាលនៃការទាមទារសំណង ធានារ៉ាប់រង

សូមបំពេញបែបបទទាមទារសំណងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការខូចខាត/ការបាត់បង់បានកើតឡើង (ក្នុងរយៈពេល ១២ខែ អាស្រ័យលើលក្ខខណ្ឌនៃគោលនយោបាយធានារ៉ាប់រង)។

ការអប់រំផ្នែកហិរញ្ញវត្ថុ

ជំណាក់កាលនៃការទាមទារសំណង ធានារ៉ាប់រង

សូមបំពេញបែបបទទាមទារសំណងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការខូចខាត/ការបាត់បង់បានកើតឡើង (ក្នុងរយៈពេល ១២ខែ អាស្រ័យលើលក្ខខណ្ឌនៃគោលនយោបាយធានារ៉ាប់រង)។

ការអប់រំផ្នែកហិរញ្ញវត្ថុ

ជំណាក់កាលនៃការទាមទារសំណង ធានារ៉ាប់រង

ដាក់ជូនឯកសារដែលតម្រូវ៖ លិខិតទាមទារសំណងដែលចុះហត្ថលេខាដោយម្ចាស់បណ្ណធានារ៉ាប់រង កាតសមាជិក ច្បាប់ថតចម្លងឯកសារអត្តសញ្ញាណរបស់លោកអ្នកជាដើម។ល។

ការអប់រំផ្នែកហិរញ្ញវត្ថុ

ជំណាក់កាលនៃការទាមទារសំណង ធានារ៉ាប់រង

ប្រសិនបើលោកអ្នកមិនទទួលបានការផ្តល់ប្រាក់ក្នុងរយៈពេលប្រាំពីរថ្ងៃ (ឬពេលវេលាដែលបានកំណត់ក្នុងគោលនយោបាយធានារ៉ាប់រង) សូមទាក់ទងក្រុមហ៊ុនធានារ៉ាប់រងម្តងទៀតដើម្បីពិនិត្យវឌ្ឍនភាពនេះ។

ការអប់រំផ្នែកហិរញ្ញវត្ថុ

ជំណាក់កាលនៃការទាមទារសំណង ធានារ៉ាប់រង

ប្រសិនបើលោកអ្នកទទួលបានប្រាក់សំណងតិចជាងការរំពឹងទុក សូមដាក់ពាក្យបណ្តឹង ស្វែងរកមូលហេតុ ហើយព្យាយាមដោះស្រាយបញ្ហានេះ។

ការអប់រំផ្នែកហិរញ្ញវត្ថុ



សារសំខាន់ៗ

- ដើម្បីស្វែងរកផ្តល់តផលធានារ៉ាប់រងដែលបំពេញតម្រូវការរបស់អ្នកបានល្អបំផុត ជាដំបូងលោកអ្នកត្រូវកំណត់ពីហានិភ័យដែលលោកអ្នកនិងបុគ្គលដែលលោកអ្នកចង់ធានារ៉ាប់រងដែលត្រូវប្រឈម។

- ការធានារ៉ាប់រងប្រើលក្ខខណ្ឌជាក់លាក់ - លោកអ្នកត្រូវសិក្សាឲ្យបានច្បាស់ល្អាស់ដើម្បីស្វែងយល់អំពីផ្តល់តផលធានារ៉ាប់រងដែលមាន និងធ្វើការជ្រើសរើសដែលបានផ្តល់ព័ត៌មាន។

- ហានិភ័យធានារ៉ាប់រងនីមួយៗអាចទាមទារឯកសារផ្សេងៗគ្នានៅពេលធ្វើការទាមទារសំណង

៥. ជ្រើសរើសជម្រើសធានារ៉ាប់រងត្រឹមត្រូវ

ឥឡូវនេះ យើងនឹងជួយបុគ្គលិករបស់យើងក្នុងការដោះស្រាយមន្ទិលសង្ស័យមួយចំនួនដែលពួកគាត់អាចមានអំពីគោលនយោបាយធានារ៉ាប់រងសុខភាព។

ជំនួយក្នុងការបណ្តុះបណ្តាល ឆ.៥.១
ករណីសិក្សាអំពីការធានារ៉ាប់រងសុខភាព

ករណីសិក្សាទី១៖ ឱពុករបស់សុភាព

សុភាពគឺជាផ្នែកមួយនៃគម្រោងធានារ៉ាប់រងសុខភាពដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ព្រោះនោះជាអត្ថប្រយោជន៍ដែលកម្មករោងចក្រទាំងអស់ទទួលបាន។ កាលពីចុងសប្តាហ៍នេះ ពេលនាងដើរនៅផ្សារនាងគ្រេចកជើង។ ទោះបីជារបួសនេះនៅក្រៅម៉ោងការងារក៏ដោយ ក៏ សុភាព ប្រាកដណាស់ថានាងនៅតែអាចប្រើប្រាស់គម្រោងថែទាំសុខភាពរបស់នាងបានដែរ។

- **តើសុភាពអាចទទួលបានការព្យាបាលដោយមិនគិតថ្លៃដែរឬទេ បើទោះជាគ្រោះថ្នាក់នេះមិនទាក់ទងនឹងការងារក៏ដោយ? ហេតុអ្វី?**

ករណីសិក្សាទី២៖ ណារី

អតីតមិត្តរួមការងាររបស់ ណារី ទើបតែបានទូរស័ព្ទទៅប្រាប់នាងថា នាងនឹងថា នឹងមានកូន។ ណារី សប្បាយចិត្តខ្លាំងណាស់។ មិត្តរួមការងាររបស់នាងសួរនាងថា តើនាងដឹងថា នាងមានសិទ្ធិទទួលបានការឈប់សម្រាកលំហែមាតុភាពដែលមានប្រាក់ឈ្នួលដែរឬទេ បើទោះបីជានាងមិនបានធ្វើការនៅរោងចក្រនេះតទៅទៀតក្តី។ មិត្តរួមការងាររបស់នាងប្រាប់នាងថា នាងមានផ្ទៃពោះអំឡុងរយៈពេលប៉ុន្មានខែដែលនាងធ្វើការនៅទីនោះឯង។

- **តើមិត្តរួមការងាររបស់ ណារី មានសិទ្ធិឈប់សម្រាកលំហែមាតុភាពមានប្រាក់ឈ្នួលដែរឬទេ? ហេតុអ្វី?**

ករណីសិក្សាទី ៣៖ រក្សា

រក្សាបានជួបឧបទ្វវហេតុបន្តិចបន្តួចពេលកំពុងធ្វើការ។ គ្រូពេទ្យនៅគ្លីនិករោងចក្រប្រាប់នាងឲ្យទៅថតកាំរស្មីអ៊ុចដើម្បីឲ្យប្រាកដថា ម្រាមដៃនាងមិនបានបាក់។ រក្សា បារម្ភថា នាងមិនអាចមានលទ្ធផលបង់ថ្លៃថតកាំរស្មីអ៊ុចបានទេ ព្រោះនាងបានឮពីបងប្អូនជីដូនមួយរបស់នាងថា វាមានតម្លៃថ្លៃណាស់។ នាងមានការងឿងឆ្ងល់ថាតើ ការធានារ៉ាប់រងសុខភាពដែលផ្តល់ជូនតាមរយៈនិយោជករបស់នាងនឹងរ៉ាប់រងការចំណាយនេះដែរឬទេ។

- **តើការធានារ៉ាប់រងរបស់ រក្សា រ៉ាប់រងថ្លៃចំណាយលើការថតកាំរស្មីអ៊ុចដែរឬទេ? ហេតុអ្វី?**

សារសំខាន់

• ការធានារ៉ាប់រងអាចមើលទៅស្មុគស្មាញណាស់។ ប៉ុន្តែ ដោយសារលោកអ្នកយល់ដឹងអំពីមូលដ្ឋានគ្រឹះ លោកអ្នកអាចវាយតម្លៃបានថា តើការការពារដែលផ្តល់ជូនដោយការធានារ៉ាប់រងគឺសក្តិសមនឹងការចំណាយដែរឬទេ។

• ប្រសិនបើលោកអ្នកចង់ទិញគោលនយោបាយធានារ៉ាប់រងសុខភាព លោកអ្នកត្រូវសម្រេចចិត្តថា តើសមាជិកគ្រួសារណាខ្លះដែលត្រូវបញ្ចូលក្នុងគោលនយោបាយនេះ។ គោលនយោបាយធានារ៉ាប់រងមួយចំនួនគិតថ្លៃបុព្វលាភបន្ថែមសម្រាប់សមាជិកគ្រួសារនីមួយៗដែលលោកអ្នកបញ្ចូលទៅក្នុងគោលនយោបាយនេះ។ គោនយោបាយខ្លះផ្តល់កញ្ចប់មូលដ្ឋានសម្រាប់គ្រួសារដែលមានគ្នាបួននាក់ ហើយគិតថ្លៃបន្ថែមសម្រាប់សមាជិកគ្រួសារលើសពីនេះ។

• វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងស្វែងយល់ពីវិថានដែលគោលនយោបាយនីមួយៗប្រើដើម្បីគណនាបុព្វលាភសម្រាប់ការធានារ៉ាប់រងគ្រួសាររបស់លោកអ្នក។

• គោលនយោបាយធានារ៉ាប់រងមិនដូចគ្នាទាំងអស់នោះទេ។ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងអំពីគោលនយោបាយធានារ៉ាប់រង និងលក្ខខណ្ឌរបស់វាមុនពេលទិញធានារ៉ាប់រង។ ត្រូវមានទំនុកចិត្តក្នុងការនិយាយជាមួយភ្នាក់ងារធានារ៉ាប់រង និយោជក ឬតំណាងសហជីពរបស់លោកអ្នក ប្រសិនបើលោកអ្នកមានមន្ទិលសង្ស័យ។

• ប្រសិនបើលោកអ្នកចាប់អារម្មណ៍ក្នុងការទិញគោលនយោបាយធានារ៉ាប់រង ឬប្រសិនបើលោកអ្នកមានចម្ងល់ណាមួយ សូមពិភាក្សាភ្លាមៗអំពីបញ្ហានេះទៅកាន់ភ្នាក់ងារធានារ៉ាប់រង និយោជក ឬតំណាងសហជីពរបស់លោកអ្នក។

កន្លែងកត់ត្រា

ឧបសម្ព័ន្ធ និងឯកសារសំខាន់ៗ

បញ្ហាប្រឈមក្នុងការលៃទុកប្រាក់ដោយឡែក សម្រាប់មូលនិធិគ្រាអាសន្ន	ដំបូន្មាន
ខ្ញុំពេញចិត្តផ្តល់ប្រាក់ចំណូលទាំងអស់របស់ខ្ញុំដល់ឪពុកម្តាយ និងគ្រួសាររបស់ខ្ញុំ (កាតព្វកិច្ចគ្រួសារជាពិសេសខ្លាំងក្លា ក្នុងករណីយុវជននិងជនចំណាកស្រុក)	• សន្សំប្រាក់ទុកសម្រាប់ពេលមានអាសន្នផ្ទាល់ខ្លួន ដូច្នេះលោកអ្នកអាចមើលថែខ្លួនលោកអ្នកនៅពេលដែលគ្រួសាររបស់លោកអ្នកមិនអាចជួយលោកអ្នកបាន (ជាពិសេសសម្រាប់លោកអ្នកដែលរស់នៅឆ្ងាយពីផ្ទះ)។ • ចាប់ផ្តើមលៃទុកប្រាក់ដោយឡែកសម្រាប់ភាពអាសន្នផ្ទាល់ខ្លួនជាប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ បើទោះបីជាក្នុងចំនួនតិចតួចក៏ដោយ។ បន្តិចម្តងៗសាច់ប្រាក់របស់លោកអ្នកនឹងកើនឡើងមិនខាន។.
នៅពេលខ្ញុំទុកលុយក្នុងបន្ទប់ ខ្ញុំបារម្ភថា វាអាចត្រូវគេលួច ឬបាត់ជាដើម។	• សូមទុកប្រាក់របស់លោកអ្នកនៅកន្លែងដែលមានសុវត្ថិភាព យកល្អទុកខាងក្រៅផ្ទះ ដូច្នេះគ្មាននរណាម្នាក់អាចចូលយកបានទេ។ • បើកគណនីសន្សំ (សម្រាប់មូលនិធិគ្រាអាសន្ន ជាដំណោះស្រាយដ៏ល្អបំផុតគឺកម្មវិធីប្រាក់សន្សំដែលអាចបត់បែនបាន ដែលមានន័យថា លោកអ្នកអាចដកប្រាក់របស់លោកអ្នកបានគ្រប់ពេល)។
ប្រាក់ចំណូលរបស់ខ្ញុំមិនទៀងទាត់ (ឧ. តាមរដូវ)។	• សូមសន្សំប្រាក់ក្នុងចំនួនផ្សេងគ្នា អាស្រ័យលើចំនួនទឹកប្រាក់ដែលលោកអ្នកមានក្នុងឱកាសជាក់លាក់ណាមួយ។
ខ្ញុំត្រូវប្រើប្រាក់ចំណូលដែលខ្ញុំរកបានទាំងអស់ដើម្បីសងបំណុល	• សូមគូរតារាងពេលវេលាសម្រាប់ការសងបំណុលរបស់លោកអ្នក ដោយចាប់ផ្តើមពីចំនួនទឹកប្រាក់ដែលលោកអ្នកបង់ការប្រាក់ខ្ពស់បំផុត។ • ក្នុងពេលជាមួយគ្នានេះ ចាប់ផ្តើមលៃទុកប្រាក់មួយឡែកសម្រាប់ភាពអាសន្នផ្ទាល់ខ្លួនជាប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ បើទោះបីជាក្នុងចំនួនតិចតួចក៏ដោយ។ ការសន្សំប្រាក់របស់លោកអ្នកនឹងកើនឡើង។
ខ្ញុំស្ទើរតែមិនអាចរ៉ាប់រងតម្រូវការមូលដ្ឋានរបស់ខ្ញុំ	• ធ្វើអ្វីគ្រប់យ៉ាងដែលលោកអ្នកអាចធ្វើបាន ដើម្បីកាត់បន្ថយការចំណាយដែលមិនចាំបាច់។ • មនុស្សគ្រប់គ្នាអាចសន្សំប្រាក់បាន ទោះបីជាពួកគេរកចំណូលបានតិចតួចក៏ដោយ ប្រសិនបើក្នុងចំនួនតិចតួច (ចូរលើកឡើងពីចំនួនទឹកប្រាក់តិចតួចជារូបិយប័ណ្ណក្នុងស្រុក ដែលអាចលៃទុកមួយឡែកជារៀងរាល់ថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ)។


ចម្លើយចំពោះលំហាត់ដំឆ្នូយក្នុងការបណ្តុះបណ្តាល ឆ.៤.១



ដំណោះស្រាយករណីសិក្សាទី១

តើសុភាពអាចទទួលបានការព្យាបាលដោយមិនគិតថ្លៃដែរឬទេ បើទោះជាគ្រោះថ្នាក់នេះមិនទាក់ទងនឹងការងារក្តី? ហេតុអ្វី?

បាទ/ចាស សុភាពអាចទទួលបានព្យាបាល បើទោះជាគ្រោះថ្នាក់នេះមិនទាក់ទងនឹងការងារក៏ដោយ។ កំណែទម្រង់គម្រោងថៃទាំសុខភាពនៅឆ្នាំ ២០១៦ ការពារកម្មករផងដែរ សម្រាប់ការរងរបួសក្រៅម៉ោងធ្វើការ។



ដំណោះស្រាយករណីសិក្សាទី២

តើមិត្តរួមការងាររបស់ ណារី មានសិទ្ធិឈប់សម្រាកលំហែមាតុភាពមានប្រាក់ឈ្នួលដែរឬទេ? ហេតុអ្វី?


ទេ អត្ថប្រយោជន៍នៃការឈប់សម្រាកលំហែមាតុភាពមានប្រាក់ឈ្នួលគឺអាចអនុវត្តបាននៅពេលដែលលោកអ្នកនៅតែជាកម្មករនិយោជិតរបស់រោងចក្រតែប៉ុណ្ណោះ។ ប្រសិនបើលោកអ្នកលែងបម្រើការងារទៅហើយនោះ អត្ថប្រយោជន៍នេះមិនអាចអនុវត្តបានក្រោមគម្រោងធានារ៉ាប់រងសុខភាពដែលផ្តល់ដោយប.ស.ស បានឡើយ។




ដំណោះស្រាយករណីសិក្សាទី៣

តើការឆានារ៉ាប់រងរបស់ រក្សា រ៉ាប់រងការចំណាយលើការថតកាំរស្មីអ៊ុចដែរឬទេ? ហេតុអ្វី?

រក្សាមិនគួរមានការបារម្ភទេ។ គម្រោងថៃទាំសុខភាពសម្រាប់កម្មករគ្របដណ្តប់លើការចំណាយនេះ។ សេវាថៃទាំវេជ្ជសាស្ត្រគ្របដណ្តប់លើការចំណាយទាំងអស់ដែលទាក់ទងនឹងការធ្វើរោគវិនិច្ឆ័យ មន្ទីរពិសោធន៍ ការថតកាំរស្មីអ៊ុច និងសេវាពិនិត្យសុខភាពផ្សេងទៀត។



បន្ថែម



ប្រាក់សោធននិវត្តន៍ និងការធ្វើផែនការរយៈពេលវែង



ខ.១. ចំណុចខាងក្រោមបញ្ហាញពីវិធីរៀបចំផែនការសម្រាប់ការចូលនិវត្តន៍ លើកលែងតែមួយតើមួយណា?

- ☐ **ក.** ការសន្សំប្រាក់
- ☐ **ខ.** គម្រោងប្រាក់សោធននិវត្តន៍
- ☐ **គ.** ការវិនិយោគ
- ☐ **ឃ.** ចំណាយប្រាក់ភាគច្រើនរបស់ខ្ញុំលើអ្វីដែលខ្ញុំចង់បាន ប៉ុន្តែខ្ញុំមិនត្រូវការទេ

ខ.២. បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) គឺជាស្ថាប័នសាធារណៈដែលចាត់ចែង និងគ្រប់គ្រងប្រាក់សោធននិវត្តន៍នៅក្នុងប្រទេស

- ☐ **ក.** ពិត
- ☐ **ខ.** មិនពិត

ខ.៣. ផែនការសម្រាប់មនុស្សចាស់ និងនិវត្តន៍ជនគឺ៖

- ☐ **ក.** ចូលរួមវិភាគទានឲ្យបានច្រើនតាមតែអាចធ្វើទៅបានដល់ប្រព័ន្ធសោធននិវត្តន៍ ហើយសង្ឃឹមថា វានឹងគ្រប់គ្រាន់សម្រាប់ពេលលោកអ្នកចាស់ទៅ។
- ☐ **ខ.** ព្យាយាមសន្សំប្រាក់ឲ្យបានច្រើនក្នុងគណនីធនាគារផ្សេងៗគ្នា ជាមួយនឹងអត្រាការប្រាក់ខ្ពស់
- ☐ **គ.** ការវិនិយោគ
- **ឃ.** វាជាដំណើរការនៃការកំណត់គោលដៅប្រាក់ចំណូលសោធននិវត្តន៍ និងសកម្មភាព និងការសម្រេចចិត្តចាំបាច់ដើម្បីសម្រេចបាននូវគោលដៅទាំងនោះ

ខ ៖ ១ឆ ‘ឃ ៖ ២ឆ ‘ង ៖ ៣ឆ ‘ខ ៖ ៤ឆ ៖ ពាក្យឆ្លើយ

១. រៀបចំផែនការចូលនិវត្តន៍របស់លោកអ្នក

នៅក្នុងសង្គមរបស់យើង មនុស្សចូលនិវត្តន៍ដោយស្ម័គ្រចិត្ត ឬត្រូវបានបង្ខំឲ្យចាកចេញពីការងារ។ មនុស្សមួយចំនួនមិនឈប់ធ្វើការទាំងស្រុងទេ ដោយសារពួកគេមិនមានគម្រោងមុនពេលចូលនិវត្តន៍។ ការផ្លាស់ប្តូរពីជីវិតការងារទៅជាការចូលនិវត្តន៍ត្រូវការការរៀបចំផែនការហិរញ្ញវត្ថុ និងការសម្រេចចិត្តយ៉ាងប្រុងប្រយ័ត្ន ហើយនេះគឺធាប់តាមដែលអាចធ្វើទៅបានក្នុងជីវិតវិជ្ជាជីវៈរបស់មនុស្សម្នាក់ៗ។

និយមន័យ

ផែនការចូលនិវត្តន៍គឺជាដំណើរការកំណត់គោលដៅប្រាក់ចំណូលពេលចូលនិវត្តន៍ និងសកម្មភាព និងការសម្រេចចិត្តចាំបាច់ដើម្បីសម្រេចបាននូវគោលដៅទាំងនោះ។ ការចូលនិវត្តន៍គឺជាដំណាក់កាលដែលមនុស្សម្នាក់ឈប់ធ្វើការងារ។ ការធ្វើផែនការចូលនិវត្តន៍រួមមានការកំណត់អំពីប្រភពប្រាក់ចំណូល ការប៉ាន់ប្រមាណការចំណាយ ការអនុវត្តកម្មវិធីសន្សំប្រាក់ និងការគ្រប់គ្រងទ្រព្យសម្បត្តិជាដើម។

ករណីសិក្សាទី១


វិធីសាស្ត្ររបស់ ណារី ក្នុងការចូលនិវត្តន៍

ណារី មិនដែលមានគម្រោងសម្រាប់ការចូលនិវត្តន៍របស់នាងទេ។ កាលពីមួយរយៈមុន នាងជំពាក់បំណុលគេច្រើន ប៉ុន្តែនាងអាចរើខ្លួនពីវាវិញបាន ដោយសារការណែនាំពីមិត្តរួមការងារនាងឈ្មោះ រក្សា។ ណារី ទទួលបានហិរញ្ញវត្ថុរបស់នាងតាមលំដាប់លំដោយ ហើយចាប់ផ្តើមបន្តិចម្តងៗនូវការគ្រប់គ្រងការចំណាយរបស់នាងបន្ថែមទៀត។ នាងមិនដែលយកកម្ចីទៅសងកម្ចីផ្សេងទៀតនោះឡើយ។ ប៉ុន្តែ ពេលគិតដល់ការចូលនិវត្តន៍របស់នាង ណារី មិនដែលមានគម្រោងសម្រាប់រឿងនេះឡើយ។ នាងតែងតែនិយាយថា៖ "ធ្វើតែអ្វីដែលលោកអ្នកចូលចិត្ត ហើយកុំខ្វល់ខ្វាយច្រើនពីអនាគត គឺជាការប្រសើរ"។ ពេលវេលាកន្លងផុតទៅ ណារី ចាប់ផ្តើមមានប្រាក់ខែល្អនៅរោងចក្រ ប៉ុន្តែក៏ចំណាយប្រាក់ច្រើនដែរ។ ពេលវេលាបានកន្លងផុតទៅ ពេលនេះ ណារី ចាប់ផ្តើមគិតថា នាងចង់ចាប់ផ្តើមធ្វើការឲ្យតិចជាងមុន។ នាងមិនដែលហ៊ានគិតអំពីការលែទុកដាក់លុយកាក់ខ្លះសម្រាប់ពេលនាងចាស់ឡើយ ហើយនាងកាន់តែព្រួយបារម្ភអំពីរឿងនេះ។



ត្រៀមខ្លួនចូលនិវត្តន៍

១) សងបំណុលរបស់លោកអ្នកឲ្យអស់
២) បង្វែរប្រាក់សន្សំរបស់លោកអ្នកទៅជាប្រាក់ចំណូល
៣) គណនាប្រាក់ចំណូលប្រចាំខែរបស់លោកអ្នក
៤) បង្កើតថវិកា
៥) ពិនិត្យមើលតម្រូវការធានារ៉ាប់រងរបស់លោកអ្នក
៦) ដឹងពីសិទ្ធិ និងទំនួលខុសត្រូវរបស់លោកអ្នកទាក់ទងនឹងបេឡាជាតិរបបសន្តិសុខសង្គម



⚠ សូមចងចាំ៖

លោកអ្នកមានវិធីផ្សេងគ្នាដើម្បីបង្កើនប្រាក់ចំណូលរបស់លោកអ្នក ឬកាត់បន្ថយការចំណាយរបស់លោកអ្នកនៅពេលចូលនិវត្តន៍។ ការធ្វើការក្រៅម៉ោង ការផ្លាស់ទៅកាន់តំបន់ដែលមានតម្លៃសមរម្យ ឬកាត់បន្ថយទំហំផ្ទះរបស់លោកអ្នក គឺជាគំនិតមួយចំនួនដែលអាចជួយលោកអ្នកឲ្យមានគុណភាពថវិការបស់ខ្លួន។

សារសំខាន់

- មានវិធីជាច្រើនដើម្បីរៀបចំផែនការសម្រាប់ការចូលនិវត្តន៍៖ ការសន្សំប្រាក់គម្រោងប្រាក់សោធននិវត្តន៍ ផែនការចូលនិវត្តន៍ ទ្រព្យសម្បត្តិ ការធានារ៉ាប់រង និងការវិនិយោគ។
- ត្រូវគិតពីគោលដៅ និងចំណង់ចំណូលចិត្តរបស់លោកអ្នក នៅពេលអ្នកគិតអំពីការវិនិយោគរបស់ខ្លួននៅពេលខ្លួនចាស់ទៅ
- នៅពេលដែលលោកអ្នកចូលនិវត្តន៍ ការមានប្រភពចំណូលបន្ថែមអាចជួយលោកអ្នកឲ្យមានជីវិតដែលប្រកបដោយផាសុកភាពថែមទៀត
- ផែនការចូលនិវត្តន៍ដំបូង និងចម្រុះ គឺជាគន្លឹះសម្រាប់ឯករាជភាពផ្នែកហិរញ្ញវត្ថុរបស់លោកអ្នកនៅពេលលោកអ្នកចូលនិវត្តន៍
- ការសន្សំប្រាក់សម្រាប់ការចូលនិវត្តន៍គឺជាការវិនិយោគរយៈពេលវែង។

គន្លឹះ៖

ការទទួលបានប្រាក់តាមប្រព័ន្ធឌីជីថលចាប់ពីថ្ងៃនេះ អាចជួយលោកអ្នកឲ្យមានកំណត់ត្រានៃការទូទាត់ប្រាក់ឈ្នួល និងការរួមចំណែករបស់លោកអ្នកចំពោះប្រព័ន្ធសោធននិវត្តន៍នៃបេឡាជាតិរបបសន្តិសុខសង្គម។ នៅពេលលោកអ្នកចូលនិវត្តន៍ ប្រសិនបើលោកអ្នកប្រឈមនឹងបញ្ហាក្នុងការប្រើប្រាស់អត្ថប្រយោជន៍ចូលនិវត្តន៍របស់លោកអ្នកនោះ លោកអ្នកអាចបង្ហាញកំណត់ត្រាទាំងនេះជាភស្តុតាងនៃការរួមចំណែក។

ប្រាក់សោធននិវត្តន៍គឺជាផ្នែកមួយនៃគម្រោងគាំពារសង្គមរបស់ប្រទេសនីមួយៗ។ ជាធម្មតា វាមានភាពស្មុគស្មាញក្នុងការស្វែងយល់ ហើយព័ត៌មានដែលត្រូវផ្តល់ឲ្យនៅទីនេះ សម្រាប់តែគោលបំណងនៃការណែនាំរហ័សអំពីប្រាក់សោធននិវត្តន៍តែប៉ុណ្ណោះ។

នៅឆ្នាំ ២០២១ រដ្ឋាភិបាលកម្ពុជាបានចេញក្រឹត្យថ្មីមួយដែលបានផ្លាស់ប្តូររបៀបដែលប្រព័ន្ធប្រាក់សោធននិវត្តន៍ដំណើរការសម្រាប់កម្មករភាគច្រើនក្នុងប្រទេស។ គំនិតនេះគឺដើម្បីឆ្ពោះទៅរកប្រព័ន្ធគាំពារសង្គមដែលរួមបញ្ចូលមនុស្សកាន់តែច្រើន។

ជាដំបូង ត្រូវស្វែងយល់ថា បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) គឺជាស្ថាប័នសាធារណៈដែលចាត់ចែង និងគ្រប់គ្រងប្រាក់សោធននិវត្តន៍នៅក្នុងប្រទេស។ របបសន្តិសុខសង្គមស្តីពីសោធននិវត្តន៍ (SSSP) បង្កើតយន្តការ លក្ខខណ្ឌ និងបែបបទនៃអត្រាការចូលរួមចំណែករបស់ប្រព័ន្ធសោធននិវត្តន៍សម្រាប់កម្មករនិយោជិតនៅក្នុងប្រទេស។

របបសន្តិសុខសង្គមស្តីពីសោធននិវត្តន៍ផ្តល់អត្ថប្រយោជន៍ចំនួនបួនគឺ៖ (i) ប្រាក់សោធននិវត្តន៍ពេលចាស់ទៅ (ii) សោធននិវត្តន៍មិនមានសុពលភាព (iii) ប្រាក់សោធននិវត្តន៍សម្រាប់ការរស់រានមានជីវិត និង (iv) ប្រាក់ឧបត្ថម្ភពិធីបុណ្យសព។

ការផ្លាស់ប្តូរសំខាន់ៗដែលបានដាក់ចេញនៅក្នុងបទប្បញ្ញត្តិថ្មីនេះគឺថា កម្មករនិយោជិតដែលនៅក្រៅវិស័យសាធារណៈអាចចូលប្រើប្រាស់គម្រោងសោធននិវត្តន៍តាមរយៈវិធីសំខាន់ចំនួនពីរគឺ៖

១. គម្រោងការរួមចំណែកជាកាតព្វកិច្ច៖ គម្រោងនេះគឺត្រូវប្រើដោយក្រុមហ៊ុនទាំងអស់ដែលជួលបុគ្គលិកម្នាក់ ឬច្រើនាក់។ ពួកគេមានកាតព្វកិច្ចប្រមូល និងបង់វិភាគទានប្រចាំខែរបស់និយោជិតខ្លួន។ វិភាគទានត្រូវបង់ស្មើៗគ្នាដោយនិយោជក ឬម្ចាស់ក្រុមហ៊ុន និងនិយោជិត។

២. គម្រោងបង់វិភាគទានដោយស្ម័គ្រចិត្ត៖ គម្រោងនេះគឺជាការបង់វិភាគទានដែលធ្វើឡើងដោយសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួម។ មានអត្ថប្រយោជន៍ និងការរួមចំណែកផ្សេងៗគ្នា។

ប្រសិនបើលោកអ្នកបម្រើការងារក្នុងវិស័យឯកជន ទាំងនិយោជករបស់លោកអ្នក និងលោកអ្នកត្រូវបង់វិភាគទានដល់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។ គឺជាការបង់វិភាគទានជាកាតព្វកិច្ចដោយច្បាប់របស់ប្រទេសកម្ពុជា។ វាមានសារៈសំខាន់ណាស់ក្នុងការទទួលបានព័ត៌មានរបស់លោកអ្នកពីបេឡាជាតិរបបសន្តិសុខសង្គមដើម្បីជានាថា ប្រាក់របស់លោកអ្នកត្រូវបានសន្សំជារៀងរាល់ខែ។ លោកអ្នកនឹងទទួលបានប្រាក់វិភាគទាននេះ នៅពេលដែលលោកអ្នក៖

- ត្រូវបានចុះឈ្មោះត្រឹមត្រូវក្រោមគម្រោងប្រាក់សោធននិវត្តន៍
- មានអាយុយ៉ាងតិច ៦០ ឆ្នាំ
- បានបង់វិភាគទានយ៉ាងតិច១២ខែ

បើទោះជាចំណុចនេះប្រហែលជាមិនទាន់ត្រូវបានពន្យល់យ៉ាងពេញលេញដល់លោកអ្នកនៅឡើយក្តី សូមប្រាកដថា ត្រូវនិយាយជាមួយអ្នកតំណាងកម្មករ សហជីព និង/ឬផ្នែកធនធានមនុស្សដើម្បីឲ្យពួកគេអាចធ្វើការពន្យល់ដល់លោកអ្នកអំពីការបង់វិភាគទានរបស់លោកអ្នក។

វិធីសាស្ត្រ

ផ្នែកទូទៅ

គោលដៅ

- គោលដៅគឺជាអ្វីដែលអ្នកចង់ធ្វើនៅពេលអនាគត។

ផ្លូវការ/ក្រៅផ្លូវការ

- ផ្លូវការសំដៅលើទម្រង់បែបបទ សមស្របទៅនឹងក្របខ័ណ្ឌ រចនាសម្ព័ន្ធឬច្បាប់។ ជាទិដ្ឋភាពស្រប ច្បាប់ ទទួលស្គាល់ដោយអាជ្ញាធរ។
- ផ្ទុយទៅវិញ ច្បាប់ឬក្របខ័ណ្ឌផ្លូវការ មិនរឹតបន្តឹងលើភាពមិនផ្លូវការនោះទេ។ ឧទាហរណ៍ សេដ្ឋកិច្ចក្រៅ ផ្លូវការ ជាបណ្តុំអាជីវកម្មដែលមិនបានចុះបញ្ជីត្រឹមត្រូវ និងមិនបង់ពន្ធជាដើម។

ថវិកា

- ថវិកាគឺជាឧបករណ៍ធ្វើការសម្រេចចិត្ត រៀបចំផែនការនិងប្រើប្រាក់ដើម្បីសម្រេចបានគោលដៅ។

កិច្ចសន្យាការងារ

- កិច្ចព្រមព្រៀងស្របច្បាប់រវាងនិយោជកនិងកម្មករដែលបញ្ជាក់ពីភារកិច្ចនិងការទទួលខុសត្រូវនិងអត្ថប្រយោជន៍សម្រាប់ភាគីទាំងពីរ។
- កិច្ចសន្យាត្រូវពិពណ៌នាអំពីភារកិច្ចការ ការទទួលខុសត្រូវនិងសិទ្ធិ។ បញ្ជាក់ពីការងារ និងលក្ខខណ្ឌ ដូចជាប្រាក់ឈ្នួលម៉ោងធ្វើការងារ ។ល។
- កិច្ចសន្យាគឺជាកិច្ចព្រមព្រៀងដែលគូភាគីបានចុះហត្ថលេខាបង្ហាញពីឆន្ទៈខ្លួន។ កិច្ចសន្យាការងារ ត្រូវធ្វើឡើង ជាលាយលក្ខអក្សរ ប្រើប្រាស់ភាសាដែលគូភាគីយល់ ចុះហត្ថលេខាដោយភាគីទាំងពីរ និងផ្តល់ ច្បាប់ ចម្លងដល់ភាគីនីមួយៗ។

គ្រឹះស្ថានហិរញ្ញវត្ថុ

- គ្រឹះស្ថានហិរញ្ញវត្ថុ សំដៅលើទាំងសេវាសាធារណៈឬឯកជនពាក់ព័ន្ធនឹងប្រតិបត្តិការហិរញ្ញវត្ថុ ដូចជាការដាក់ ប្រាក់សន្សំ ឥណទាននិងការបង់ប្រាក់។

ប្រាក់សន្សំនិងឥណទានសមាគម

- ប្រាក់សន្សំនិងឥណទានសមាគម គឺជាយន្តការតាមបែបប្រជាធិបតេយ្យ ចូលរួមដោយសមាជិក ក្នុង គោល ដៅជួយគ្នាទៅវិញទៅមក ក្នុងកិច្ចខិតខំបំពេញឲ្យបានតម្រូវការហិរញ្ញវត្ថុរបស់សមាជិក ខ្លួន។ សមាជិក ជាអ្នកគ្រប់គ្រង ចាត់ចែងនិងជាម្ចាស់។

គណនីបញ្ជើសំចៃ

គណនីសន្សំជាប្រចាំ

- គណនីសន្សំជាប្រចាំឬសៀវភៅគណនីសន្សំ (ឬគណនីឬញ្ជើតាមតម្រូវការ) នៅតាមស្ថាប័ន ហិរញ្ញវត្ថុ ផ្តល់លទ្ធភាពឲ្យម្ចាស់គណនីធ្វើការដាក់ប្រាក់ឬដកប្រាក់នៅពេលណាមួយក៏បាន។ មិន មាន ការកំណត់អំពី ចំនួនទឹកប្រាក់និងពេលវេលាជាមុននោះទេ។ ការប្រាក់ត្រូវបានផ្តល់សម្រាប់ ប្រាក់សន្សំ (អត្រាប្រចាំឆ្នាំ)។ គណនី បញ្ជើសំចៃនេះជាធម្មតាមិនអាចត្រូវបានប្រើដើម្បីធ្វើឲ្យការ ទូទាត់ដោយផ្ទាល់។

គណនីសន្សំតាមកិច្ចសន្យា

- គណនីសន្សំតាមកិច្ចសន្យា ភ្ជាប់ទៅនឹងសមិទ្ធិផលគម្រោងជាក់លាក់។ គណនីប្រភេទនេះ
ម្ចាស់គណនីប្តេជ្ញាចិត្តទូទាត់ជាទៀងទាត់ បើមិនដូច្នោះទេមូលនិធិនេះអាចត្រូវបង្កកក្នុងរយៈពេល ណាមួយ។ អត្រាការប្រាក់ថេរ ត្រូវបានផ្តល់ជូន។ ឧទាហរណ៍ គណនីសន្សំតាមកិច្ចសន្យារួមមាន គណនី សន្សំទិញ លំនៅដ្ឋាន សម្រាប់ផ្តល់ហិរញ្ញប្បទានវិនិយោគលើអចលនទ្រព្យ។ ធនាគារ ហៅផលិតផល នេះថាជា គណនី បង់រំលោះ ដោយមិនទាមទារការបញ្ជាក់ពីគោលដៅជាមុនឡើយ។

គណនីបញ្ញើមានកាលកំណត់

• គណនីប្រាក់បញ្ញើមានកាលកំណត់នៅតាមគ្រឹះស្ថានហិរញ្ញវត្ថុអនុញ្ញាតឲ្យម្ចាស់គណនីដាក់ប្រាក់តម្កល់ ដែល ខ្លួននឹងមិនដកយកមកប្រើប្រាស់ក្នុងពេលវេលាជាក់លាក់មួយ។ លក្ខខណ្ឌមានច្រើន ដែល អតិថិ ជន អាចជ្រើសរើសបាន។ គណនីនេះអាចមានការលំបាកមួយចំនួន (រយៈពេលនិងចំនួន ទឹកប្រាក់ ដែលត្រូវបង្ខាំងទុក) សម្រាប់អតិថិជន ជាធម្មតា ប្រាក់សំណងខ្ពស់ជាងផលិតផល សន្សំផ្សេងទៀត។

ឥណទាន

អត្រាការប្រាក់

• ចំនួនប្រាក់ដែលអ្នកខ្ចីបង់ទៅឲ្យអ្នកផ្តល់ប្រាក់កម្ចី បន្ថែមលើប្រាក់កម្ចី ដែលយកទៅប្រើប្រាស់។

ប្រាក់ដើម

• ចំនួនប្រាក់ដើម ដោយគ្មានការប្រាក់។

រយៈពេលកម្ចី

• រយៈពេលដែលអ្នកខ្ចីប្រើប្រាក់កម្ចីនិងសងត្រលប់មកវិញ។

ទ្រព្យបញ្ចាំ

• វត្ថុមានតម្លៃដែលកូនបំណុលផ្តល់ទៅឲ្យម្ចាស់ប្រាក់កម្ចី ក្នុងករណីដែលមិនអាចសងត្រលប់ (អាចជាដីរថយន្ត,ប្រាក់សន្សំ,។ល។)។

រយៈពេលអនុគ្រោះ

• រយៈពេលបន្ទាប់ពីទទួលបានប្រាក់កម្ចីនិងមុនពេលផុតកំណត់សងលើកដំបូង។

ការពិចារណាឡើងវិញ

• ការលុបបំបាត់កិច្ចសន្យាឥណទាន។ នៅក្នុងប្រទេសមួយចំនួនកិច្ចព្រមព្រៀងប្រាក់កម្ចីនេះមិនត្រូវ បាន ចង ដោយស្របច្បាប់រហូតដល់ជាច្រើនថ្ងៃឬសប្តាហ៍បន្ទាប់ពីការចុះហត្ថលេខា។ ក្នុងអំឡុងពេល នេះការទូទាត់ នោះទេអាចត្រូវបានធ្វើឡើងពីការផ្តល់ប្រាក់កម្ចីទៅឲ្យអ្នកខ្ចី។ ជាការធានាដែលមាន ប្រសិទ្ធិភាពប្រឆាំង នឹង ការជម្រុញឲ្យទទួលយក។

ការទូទាត់សងដើម

• អ្នកខ្ចីគឺតែងតែមានសេរីភាពក្នុងការសងទាំងអស់ឬជាផ្នែកមួយនៃបំណុលរបស់គាត់ មុនពេលផុតកំណត់ នៃ កិច្ច ព្រមព្រៀងប្រាក់កម្ចី ដោយមិនមានពិន័យ។

អ្នកធានា

• បុគ្គលដែលនឹងសងប្រាក់កម្ចីជំនួស ក្នុងករណីដែលមិនអាចសងត្រលប់ គាត់ត្រូវចូលរួមចុះ ហត្ថលេខា លើ កិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយអ្នកខ្ចីលុយ។

បំណុលលើសលប់

• អសមត្ថភាពក្នុងការសងត្រលប់បំណុលផ្ទាល់ខ្លួន។

វិធីសាស្ត្រទូទាត់

កាតសាច់ប្រាក់

- កាតសាច់ប្រាក់ត្រូវបានផ្តល់ជូនលោកអ្នកដោយធនាគារ ដើម្បីទទួលបានសាច់ប្រាក់ពីគណនីដោយប្រើប្រាស់ម៉ាស៊ីនពិសេសមួយដែលមានឈ្មោះថាម៉ាស៊ីនបញ្ចេញសាច់ប្រាក់ Automated Teller Machine (ATM)ឬ cash dispenser។ បន្ថែមពីលើការដកសាច់ប្រាក់ពីគណនី អ្នកអាចប្រើម៉ាស៊ីន ATM ដើម្បីមើលសមតុល្យគណនី ផ្ទេរប្រាក់ពីគណនីមួយទៅគណនីមួយទៀត និងដាក់ ប្រាក់ចូលក្នុងគណនីរបស់អ្នក។ ម៉ាស៊ីន ATM មួយចំនួនមានលក់ ឬកាតទូរស័ព្ទ ឬទូទាត់វិក្កយបត្រ មួយចំនួន(...ភ្លើងអគ្គីសនី)។ ធនាគារនីមួយៗ មានបណ្តាញម៉ាស៊ីនអេធីអឹមរបស់ខ្លួន ប៉ុន្តែ ភាគ ច្រើនអ្នក អាចប្រើប័ណ្ណធនាគារ ដកប្រាក់ពីម៉ាស៊ីន អេធីអឹម ដែលមិនមែន ជា កម្មសិទ្ធិរបស់ធនាគារអ្នកបានផងដែរ។ ក្នុងករណីនេះ ធនាគារអាចគិត ប្រាក់ថ្លៃសេវា រាល់ពេលដែលអ្នកប្រើកាតអេធីអឹម របស់ធនា គារ មួយផ្សេងទៀត។

ប័ណ្ណឥណពន្ធ

- ប័ណ្ណឥណពន្ធគឺជាវិធីមួយផ្សេងទៀតដើម្បីធ្វើប្រតិបត្តិការធនាគារអេឡិចត្រូនិច។ ក្រៅតែពី ដកប្រាក់ពីម៉ាស៊ីន ATM អ្នកអាចប្រើកាតឥណពន្ធមួយដើម្បីបង់ប្រាក់ថ្លៃទំនិញតាមហាងជាច្រើន។ អ្នកត្រូវតែមាន ប្រាក់នៅ ក្នុង គណនី ទើប អាចទិញបាន។ ចំនួនទឹកប្រាក់ នឹងកាត់ចេញភ្លាមពីគណនី របស់អ្នក។ លោកអ្នកនឹង ទទួល បានរបាយការណ៍ជាប្រចាំពី ធនាគារ បង្ហាញពីចំនួនទឹកប្រាក់សរុប ដែលបានកាត់ចេញពីគណនី និង សមតុល្យ។

កាតឥណទាន

- ជាទូទៅ អ្នកអាចប្រើប្រាស់កាតឥណទានធ្វើប្រតិបត្តិការដូចចាយសាច់ប្រាក់និងកាតឥណពន្ធផងដែរ។ ចំណុច សំខាន់គឺអ្នកអាចទទួលបានឥណទានប្រើប្រាស់ភ្លាមៗ។ ឬនិយាយម្យ៉ាងទៀតថា ទោះជាអ្នក គ្មាន ប្រាក់ នៅក្នុងគណនី ក៏អ្នក នៅតែអាចទិញទំនិញដោយប្រើប្រាស់ប្រាក់កម្ចីពីស្ថាប័ន ចេញកាតឥណទាន (ស្ថាប័ន ហិរញ្ញវត្ថុ ផ្សារទំនើប ហាងទំនិញ ផ្សេងៗ)។
- ចំនួនទឹកប្រាក់ដែលអ្នកទិញ នឹងត្រូវកាត់ចេញពីគណនី ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា (សងមួយ ដង ឬច្រើនដង ក្នុងអត្រាការប្រាក់ដែលខ្ពស់ជាងអត្រាស្តង់ដារ)។ អ្នកនឹងទទួលបាន របាយការណ៍ ពីស្ថាប័ន ដែល ចេញកាតឥណទាន ជាទៀងទាត់ បង្ហាញពីចំនួនសរុបដែលត្រូវសង ចំនួនទឹកប្រាក់ដែលបានបង់រួចនិង អត្រាការប្រាក់។

សេវាផ្ទេរប្រាក់

សេវាផ្ទេរប្រាក់ក្រៅប្រទេស

- អង្គភាពទាំងនេះ មិនស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់រដ្ឋឡើយ។ អ្នកផ្តល់សេវាទាំងនេះ រួម មាន ហាង លក់រាយ មិត្តភក្តិនិងផ្នែកដឹកជញ្ជូន។

អ្នកផ្តល់សេវាផ្ទេរប្រាក់ផ្លូវការ

- អង្គភាពទាំងនេះ ស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់រដ្ឋ។ អ្នកផ្តល់សេវាបែបនេះ រួមមាន ប្រតិបត្តិករផ្ទេរប្រាក់(MTOs) ធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ សមាគមប្រាក់សន្សំនិង ឥណទាន និង អ្នក ផ្តល់សេវាទូរស័ព្ទចល័ត។

ហានិភ័យនិងការធានារ៉ាប់រង

ហានិភ័យ

- ហានិភ័យសំដៅលើលទ្ធភាពនៃការបាត់បង់ឬរងរបួស។

ការធានារ៉ាប់រង

- ការធានារ៉ាប់រងគឺជាទម្រង់នៃការការពារបុគ្គលជាវកិច្ចសន្យាធានារ៉ាប់រង តាមរយៈការផ្តល់សំណង រូបិយវត្ថុ បណ្តាលមកពីគ្រោះថ្នាក់ឬព្រឹត្តិការណ៍ណាមួយគ្របដណ្តប់ដោយការធានារ៉ាប់រង។

ក្រុមហ៊ុនធានារ៉ាប់រង

- ក្រុមហ៊ុនធានារ៉ាប់រង គឺជាអាជីវកម្មដែលផ្តល់សេវាធានារ៉ាប់រង (ផ្តោតលើប្រាក់ចំណេញ)។

សមាគមផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក (សហករណ៍)

- សមាគមផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក (សហករណ៍) គឺជាអង្គភាពមិនរកប្រាក់ចំណេញ និងផ្តល់ការធានារ៉ាប់រងដល់សមាជិកខ្លួន។

គោលនយោបាយ

- ឯកសារចេញដោយក្រុមហ៊ុនធានារ៉ាប់រងឲ្យអ្នកជាវប័ណ្ណធានារ៉ាប់រង ដែលចែងពីលក្ខខណ្ឌនៃ កិច្ចសន្យា ធានា រ៉ាប់រង។

បុព្វលាភ

- ប្រាក់បង់ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងដើម្បីអនុវត្តគោលនយោបាយធានារ៉ាប់រងនិងរក្សាសុពលភាពកិច្ចសន្យានោះ។

អត្ថប្រយោជន៍

- ប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងបង់ទៅឲ្យអ្នកជាក់ស្តែសុំទូទាត់ ឬទៅឲ្យអ្នកទទួលផលដែល គាត់កំណត់។

អ្នកទទួលផល

- បុគ្គលដែលទទួលបានប្រាក់ធានារ៉ាប់រងនៅពេលព្រឹត្តិការណ៍ធានារ៉ាប់រងមួយបានកើតឡើង។

ពាក្យបណ្តឹងឬការស្នើសុំទូទាត់

- សំណើសុំបង់ប្រាក់សម្រាប់ការខាតបង់ដែលគ្របដណ្តប់ដោយគោលនយោបាយ។

ប័ណ្ណធានារ៉ាប់រង

- កាតដែលចេញដោយអ្នកផ្តល់សេវាធានារ៉ាប់រងជាភស្តុតាងដែលថាប័ណ្ណធានារ៉ាប់រងបានបង់ បុព្វលាភ។

ការបដិសេធ

- លក្ខខណ្ឌជាក់លាក់ កាលៈទេសៈ ឬស្ថានភាពដែលបានមិនទទួលបានការធានារ៉ាប់រង ដូចមានចែង ក្នុង កិច្ចសន្យា។

សៀវភៅសម្រាប់សិក្ខាកាម

ការអប់រំផ្នែកហិរញ្ញវត្ថុរបស់ ILO សម្រាប់កម្មករកាត់ដេរនៅកម្ពុជា

ក្នុងភាពជាដៃគូជាមួយមជ្ឈមណ្ឌលសកលរបស់អង្គការ ILO ស្តីពីប្រាក់ឈ្នួលឥជីវធនសម្រាប់ ការងារសមរម្យ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា បានអនុវត្តគម្រោងមួយក្នុងគោលបំណងលើកកម្ពស់ការផ្លាស់ប្តូរពីការទូទាត់ប្រាក់ឈ្នួលជាសាច់ប្រាក់ ទៅជាការទូទាត់ប្រាក់ឈ្នួលឥជីវធនក្នុងវិស័យកាត់ដេរ។ គម្រោងនេះ ផ្តោតលើ ការអភិវឌ្ឍសមត្ថភាពរបស់រោងចក្រនិងកម្មករ ជួយសម្រួលដល់ ការផ្លាស់ប្តូរ និងជំរុញការអនុម័ត លើការ ទូទាត់ប្រាក់ឈ្នួលឥជីវធននិងសេវាកម្មហិរញ្ញវត្ថុឥជីវធនផ្សេងៗទៀត។

សៀវភៅនេះផ្តោតលើការអប់រំផ្នែកហិរញ្ញវត្ថុដល់កម្មករស្ត្រីនិងបុរស ដែលមានបំណងចាត់ចែងថវិកាខ្លួនបានកាន់តែប្រសើរ។

សៀវភៅនេះគ្របដណ្តប់លើប្រធានបទដូចខាងក្រោម៖កំណត់គោលដៅហិរញ្ញវត្ថុ ការប្រាស្រ័យ ទាក់ទងប្រកបដោយទំនុកចិត្ត ការគ្រប់គ្រងប្រាក់ចំណូលដោយឆ្លាតវៃ ការយល់ដឹងអំពីផលិតផល ហិរញ្ញវត្ថុសំខាន់ៗ (ប្រាក់សន្សំ ប្រាក់កម្ចី ការទូទាត់ ការធានារ៉ាប់រង) ការចរចាជាមួយស្ថាប័ន ហិរញ្ញវត្ថុ ការផ្ទេរប្រាក់ និងការគ្រប់គ្រងហានិភ័យ។

ព័ត៌មានក្នុងសៀវភៅនេះ ជាគួអង្គប្រឌិត ករណីសិក្សា លំហាត់ និងចំណុចយោងសម្រាប់ក្រុម ជាក់លាក់។ កូន សៀវភៅនេះ ក៏រៀបរាប់ពីសារសំខាន់ៗពីការបណ្តុះបណ្តាល និងឧបករណ៍ ប្រើប្រាស់ និងគ្រប់គ្រង ថវិកាដោយឈ្លាសវៃ។ សៀវភៅនេះ សមស្របសម្រាប់សិក្ខាកាមទាំងប្រុសនិងស្រី។ យើងអាចប្រើជា សៀវភៅលំហាត់អំឡុងពេលបង្រៀន និងជាឯកសារយោងនៅពេល ក្រោយបានដែរ។ យើងបានដាក់បញ្ចូល លំហាត់ជាច្រើននិងសន្លឹកកិច្ចការដែលសិក្ខាកាម អាច បំពេញដោយខ្លួនឯង។

ISBN: 9789220388105 (print)
ISBN: 9789220388112 (web PDF)

International Labour Organization

BetterFactories Cambodia